**ឯកទេស**

# រូបវិទ្យា



សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)

២០២៦

# បុព្វកថា

ទស្សនៈវិស័យអប់រំនាសតវត្សរ៍ទី២១ បានផ្តោតលើការរីកចម្រើនខ្លាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឌីជីថល (Digital) ដែលជាមូលដ្ឋានគ្រឹះរឹងមាំមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសគឺការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្ពោះទៅរកគំនិតនវានុវត្តន៍ថ្មីៗ សម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់សង្គមជាតិទាំងមូល។ ដោយសារនិន្នាការពិភពលោក ដែលមានការអភិវឌ្ឍឥតឈប់ឈរ ទើបរាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព។

ឈរលើស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ បានដាក់ចេញនូវគោលដៅជាអាទិភាពសម្រាប់ការធ្វើកំណែទម្រង់វិស័យអប់រំដោយផ្អែកលើ សសរស្តម្ភទាំងប្រាំរួមមាន៖ ១. ការអនុវត្តគោលនយោបាយគ្រូបង្រៀន ២.ការវាយតម្លៃ ៣.ការងារអធិការកិច្ច ៤. កម្មវិធីសិក្សា និងបរិស្ថាន ៥.ឧត្តមសិក្សា។ ដោយឡែក កំណែទម្រង់គ្រូបង្រៀន និងកម្មវិធីសិក្សាជានាឱ្យកម្ពុជាមានធនធានមនុស្ស ដែលមានសមត្ថភាពសម្រាប់ដំណើរការអភិវឌ្ឍលើគ្រប់វិស័យ។ ក្រសួងអប់រំ យុវជន និងកីឡាបានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជា នៅគ្រប់កម្រិតគ្រប់ភូមិសិក្សារហូតដល់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា និងកាន់តែធ្វើឱ្យប្រសើរឡើង នូវគុណភាពអប់រំ ក្នុងគោលបំណងឆ្លើយតបទៅនឹងការវិវឌ្ឍរបស់ពិភពលោក និងគោលដៅយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

សៀវភៅសិក្សាគោលនេះ ត្រូវបានកសាងឡើងដោយគ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ ដើម្បីកសាងឧត្តមភាពគុណវុឌ្ឍគ្រូបង្រៀន ទៅតាមទស្សនៈ និងចក្ខុវិស័យថ្មី ជាមួយនឹងខ្លឹមសារបែបវិទ្យាសាស្ត្រ បែបបញ្ញត្តិសិក្សា និងបញ្ចូលគុណសម្បទាសតវត្សរ៍ទី២១ បន្ថែមទៅលើគុណសម្បទាពលរដ្ឋសកល។

វិទ្យាស្ថានជាតិអប់រំសង្ឃឹមថា គ្រប់ស្ថាប័នអប់រំ ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណាប់អារម្មណ៍ទាំងអស់ចូលរួមគាំទ្រសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តលើ កម្មវិធីបណ្តុះបណ្តាលនេះ ដើម្បីពង្រឹងសក្តានុពលរបស់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សាទាំងអស់ ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

វិទ្យាស្ថានជាតិអប់រំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះ គណៈ កម្មការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបរិញ្ញាបត្រ+១ ផ្នែកឯកទេស អ្នកបច្ចេកទេស លោកគ្រូ អ្នកគ្រូ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាធ្វើឱ្យស្នាដៃដ៏មានសារៈសំខាន់នេះ សម្រេចបានដើម្បីជាប្រយោជន៍ដល់សង្គមជាតិយើង។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**នាយកវិទ្យាស្ថានជាតិអប់រំ**

# អារម្ភកថា

ធនធានមនុស្សជាកម្លាំងយ៉ាងសំខាន់ សម្រាប់ការអភិវឌ្ឍសង្គមជាតិ ឱ្យទទួលបានជោគជ័យ។ គោលដៅចម្បងរបស់ផែនការអភិវឌ្ឍសង្គមសេដ្ឋកិច្ច គឺការរៀបចំប្រជាជនយើងឱ្យក្លាយទៅជាពលរដ្ឋពេញលេញដែលប្រកបទៅដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលការអប់រំជាយុទ្ធសាស្ត្រយ៉ាងសំខាន់ ដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រជាជាតិប្រកបដោយជោគជ័យ។

ដូចនេះ ការកែលម្អវិស័យអប់រំជាការធានានូវការលើកកម្ពស់គុណភាពអប់រំដែលជានិន្នាការរួមរបស់បណ្តាប្រទេសក្នុងពិភពលោក។ ចំណែកឯការអភិវឌ្ឍសមត្ថភាពលើមុខវិជ្ជាឯកទេសរូបវិទ្យាសម្រាប់ការបង្រៀន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពអប់រំ។ ឈរលើស្មារតីនេះ ក្រុមគ្រូឧទ្ទេសរូបវិទ្យាបានកសាងសៀវភៅសិក្សាគោលរូបវិទ្យាសម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលគរុនិស្សិតបរិញ្ញាបត្រ+2

សៀវភៅសិក្សាគោលត្រូវបានរៀបចំជាពីរផ្នែកគឺ ពិសោធន៍ និងទ្រឹស្តី ព្រមទាំងកិច្ចការស្រាវជ្រាវរបស់គរុនិស្សិត។ នៅក្នុងឯកសារនេះមានខ្លឹមសារមេរៀន ដូចជាពិសោធន៍មេកានិច អគ្គិសនី ម៉ាញេទិច អេឡិចត្រូនិច អុបទិក ទែម៉ូឌីណាមិក រូបវិទ្យាទំនើប ។

គណៈកម្មការរៀបចំសៀវភៅសិក្សាគោលនេះ នឹងផ្តល់មូលដ្ឋានគ្រឹះដ៏មានប្រយោជន៍ សម្រាប់អ្នកអនុវត្តការបណ្តុះបណ្តាល ឬបំប៉នក្នុងវិទ្យាស្ថានជាតិអប់រំ ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងជំរុញឱ្យការអប់រំនៅកម្ពុជាមានការអភិវឌ្ឍដូចបណ្តាប្រទេសនានាក្នុងតំបន់ និងលើសកលលោក។

គណៈកម្មការរៀបចំសៀវភៅ

ចងក្រង និងបោះពុម្ពដោយ៖ វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២៦
គាំទ្រថវិការដោយវិទ្យាស្ថានជាតិអប់រំ
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៦

## គណៈកម្មការនិពន្ធ

— លោក ទូច ចន្ទទុំ — លោក បូ ចាន់ថា
— លោក ស្រ៊ន់ តៃស្រ៊ីម — លោក ហាម ចិន្តា

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

— លោក មាស ចាន់ — លោក ផែន សារឹត — លោក ឃី មឿយ

## គណៈកម្មការរចនា

— លោក ស្រ៊ន់ តៃស្រ៊ីម — លោក ទូច ចន្ទទុំ
— លោក បូ ចាន់ថា

## គណៈកម្មការគ្រប់គ្រង

— ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា — លោក ម៉ៅ សារឿន
— បណ្ឌិត ឡឹយ សុគា

# សេចក្តីផ្តើម

ការបណ្តុះបណ្តាល គរុនិស្សិតផ្នែករូបវិទ្យានៅវិទ្យាស្ថានជាតិអប់រំ ហូតមកដល់បច្ចុប្បន្ននេះមានរយៈពេលម្ភៃប្រាំឆ្នាំមកហើយ។

វិទ្យាស្ថានជាតិអប់រំបានបើកដំណើរការបណ្តុះបណ្តាល បរិញ្ញាបត្រ+២ (ឆ្នាំ២០២១ ~ ២០២២) ហើយតម្រូវឱ្យគរុនិស្សិតរូបវិទ្យាមួយចំនួន ត្រូវសិក្សារយៈពេលពីរឆ្នាំនៅវិទ្យាស្ថានជាតិអប់រំ។ ដូចនេះវាចាំបាច់ណាស់ត្រូវធ្វើការកែសម្រួលកម្មវិធីសិក្សា ដើម្បីជានាឱ្យត្រូវនឹងបរិបទថ្មីនៃប្រទេសកម្ពុជា នៅក្នុងតំបន់ និងក្នុងពិភពលោក ដែលផ្តោតការយកចិត្តទុកដាក់លើ STEM, បញ្ញាសិប្បនិម្មិត (AI), ឧស្សាហម្ម4.0 និងជំនាញសតវត្សរ៍ទី២១។ល។

កម្មវិធីសិក្សានេះរួមមាន ៦ក្រេឌីតស្មើនឹង ១២០ម៉ោង (ក្នុងនោះទ្រឹស្តី 60 ម៉ោង និងអនុវត្តន៍ 60 ម៉ោង ដែលគរុនិស្សិតតម្រូវឱ្យសិក្សាដោយខ្លួនឯងចំនួន 10ម៉ោងក្នុងមួយសប្តាហ៍) ចែកចេញជាបីផ្នែក៖ ផ្នែកទី១ ទ្រឹស្តីសំខាន់ៗ និងពិសោធន៍(ពិសោធដោយប្រើសម្ភារៈជាក់ស្តែង និង E-Lab)(២ក្រេឌីត) ផ្នែកទី២ អេឡិចត្រូនិក (ការបញ្ចូល និងប្រើប្រាស់ Software Engineering និង Micro-Controller និង coding)(២ក្រេឌីត) និងផ្នែកទី៣ រូបវិទ្យាទំនើប (២ក្រេឌីត)។
គណៈកម្មការនិពន្ធយើងខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា គរុនិស្សិតនឹងទទួលបាននូវ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ពិតប្រាកដ ដើម្បីក្លាយជាពលរដ្ឋ ដែលមានសក្តានុពល ចូលរួមចំណែកក្នុង៖ (១) ការបង្ហាត់បង្រៀនសិស្សនៅសាលាមធ្យមសិក្សាទុតិយភូមិ (២) ការកសាងធនធានមនុស្សសម្រាប់ប្រទេសកម្ពុជា ដែលចូលរួមចំណែកក្នុងការអភិវឌ្ឍ និងការពារពិភពលោក ចៀសផុតពីការកើនកម្តៅនៃភពផែនដី ការបំផ្លាញបរិស្ថាន (ពិភពលោកគ្មានផ្សែង)... ក្រោយពេលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀននៅវិទ្យាស្ថានជាតិអប់រំ។

# មាតិកា


**ពិសោធន៍ ការប្រើប្រាស់កាលីព័រ** ........ 1

**ពិសោធន៍ ការវាស់ម៉ាសមាឌ** ........ 6

**ពិសោធន៍ការប្រើប្រាស់ម៉ុលទីម៉ែត្រ** ........ 9

**ពិសោធន៍ទន្លាក់សេរី** ........ 14

**ពិសោធន៍ រង្វាស់មេគុណកកិត** ........ 18

**កកិតនឹងថ្កល់** ........ 18

**កកិតដោយរអិល** ........ 22

**ពិសោធន៍ប៉ោលទោល** ........ 25

( **ប៉ោល - លំយោលអាកម៉ូនិកខាយ** ) ........ 25

**រង្វាស់កម្ដៅម៉ាសរបស់អង្គធាតុ**( **ទង់ដែង** ) ........ 34

**ដែនអគ្គិសនី និងប៉ូតង់ស្យែលអគ្គិសនី** ........ 37

**ពិសោធន៍ទី រង្វាស់រេស៊ីស្តង់ និងច្បាប់អូម** ........ 54

**សៀគ្វីស្ពានវីស្តុន** ........ 62

**ច្បាប់គៀរឆុប** ........ 67

**រង្វាស់កម្លាំងអគ្គិសនីចលករនៃថ្មពិលដោយប្រើប៉ូតង់ស្យូម៉ែត្រ និងវ៉ុលម៉ែត្រ** ........ 73

**រង្វាស់ស្ពានកាប៉ាស៊ីតេ និងបង្គុំកុងដង់** ........ 79

**សៀគ្វី**RC ( **ថេរពេល** ) ........ 83

**កម្លាំងម៉ាញេទិច**( **បម្លាស់ទីរបស់កំណាត់របារលោហ:** ) ........ 93

**សៀគ្វីចរន្តឆ្លាស់** RL ........ 97

**សៀគ្វីចរន្តឆ្លាស់**RC **និង** RLC ........ 106

**ដំណើរការសមាសធាតុអេឡិចត្រូនិក** ........ 114

**ពិសោធន៍ទ្វារតក្ក** ..... 141
**ពិសោធន៍ចំណាំងផ្លាត និងចំណាំងបែរនៃពន្លឺ** ..... 156
**ពិសោធន៍ចម្ងាយគំលាំរបស់ឡង់ទី** ..... 159
**កិច្ចការស្រាវជ្រាវរបស់គរុនិស្សិត** ..... 169
**មេរៀនទី១៖ រូបវិទ្យាធៀប** ..... 171
1.1 **គោលការណ៍ធៀបហ្គាលីលេ** ..... 171
1.2 ពិសោធន៍ Michelson-Morley ..... 177
1.3 **គោលការណ៍ធៀបរបស់អាញស្តាញ**(Einstein’s Principle of Relativity) ..... 180
1.4 **វិបាកនៃទ្រឹស្តីធៀប៖** ..... 183
1.4.1 ភាពដំណាលគ្នា និងធៀបភាពនៃរយៈពេល ..... 183
1.4.2 ការរីកនៃពេល៖ ..... 186
1.4.3 ភាពរួញនៃប្រវែង៖ ..... 188
1.5 **បំលែងរបស់ឡូរ៉ង់**( The Lorentz Transformations ) ..... 189
1.5.1 បំលែងកូអរដោនេរបស់ឡូរ៉ង់៖ ..... 189
1.5.2 បំលែងនៃវ៉ិចទ័រល្បឿនរបស់ឡូរ៉ង់៖ ..... 192
1.6 **បរិមាណចលនាធៀប៖** ..... 194
1.6.1 ធៀបភាព ច្បាប់ទី២ញូតុន៖ ..... 196
1.6.2 ថាមពលស៊ីនេទិចធៀប៖ ..... 197
1.6.3 អេឡិចត្រុងវ៉ុល(eV)៖ ..... 200
**មេរៀនទី២៖ សេចក្តីផ្តើមនៃរូបវិទ្យាកង់ទិច** ..... 202
2.1 បន្សាយស្មើនៃអង្គធាតុខ្មៅ និងសម្មតិកម្មប្លង់៖ ..... 202
2.1.1 បន្សាយស្មើនៃអង្គធាតុខ្មៅ៖ ..... 202
2.1.2 សម្មតិកម្មប្លង់៖ ..... 207

2.2 ផលផូតូអគ្គិសនី៖ ........................................ 210

2.3 ផលកំតុង ( Compton Effect )៖ ........................................ 214

2.4 ធម្មជាតិនៃរលកអេឡិចត្រូម៉ាញេទិច៖ ........................................ 221

2.5 លក្ខណៈរលករបស់ភាគល្អិត៖ ........................................ 222

2.6 ភាគល្អិតកង់ទិច៖ ........................................ 223

2.7 ពិនិត្យពិសោធន៍រន្ធះពីរ៖ ........................................ 229

2.8 គោលការណ៍នៃភាពមិនជាក់លាក់៖ ........................................ 230

# ពិសោធន៍ ការប្រើប្រាស់កាលីព័រ




- **របៀបប្រើប្រាស់**

**ក. តួនាទីបំណែកនីមួយៗរបស់ម៉ែត្រកៀបមានដូចខាងក្រោម៖**

- ធ្មេញសម្រាប់វាស់ខាងក្នុង ៖ ប្រើសំរាប់វាស់ប្រវែង និងមុខកាត់ផ្នែកខាងក្នុង
- ធ្មេញសម្រាប់វាស់ខាងក្រៅ ៖ ប្រើសំរាប់វាស់ប្រវែង និងមុខកាត់ផ្នែកខាងក្រៅ
- ដងសម្រាប់វាស់ជម្រៅ ៖ ប្រើសំរាប់វាស់កម្ពស់ជម្រៅចង្អូរ ឬគន្លាក់
- វីសមូលសម្លាប់ ៖ ប្រើសំរាប់មួររឹតលើក្រិតរំកិលកុំឲ្យបំលាស់ទីនៅពេលធ្វើការអានតម្លៃខ្នាត
- ដុំរុញ ឬក្បាលរុយ ៖ ប្រើសំរាប់រុញឬទាញក្រិតរំកិលឲ្យបំលាស់ទីនៅពេលធ្វើការវាស់ខ្នាត
- មាត្រដ្ឋានកៀប ឬក្រិតរំកិល ៖ ប្រើសំរាប់កំណត់តម្លៃលេខដែលនៅខាងក្រោយក្បៀស ឬចំនួនទសភាគ
- មាត្រដ្ឋានចម្បង ឬក្រិតគោល ៖ ប្រើសំរាប់កំណត់តម្លៃលេខគោល ឬចំនួនគត់។

**ខ. របៀបអានគំនូសក្រិត**

- អានតម្លៃនៅលើក្រិតគោល(ជាចំនួនគត់) ដោយរាប់ចំនួនប្រឡោះក្រិតពីគំនូសសូន្យនៅលើក្រិតគោលរហូតដល់គំនូស(នៅលើក្រិតគោល)ដែលចង្អុលដោយគំនូសសូន្យនៅលើក្រិតរំកិល។ មួយប្រឡោះក្រិតស្មើ $1\ mm$ (១ មីលីម៉ែត្រ)។

- អានតម្លៃនៅលើក្រិតរំកិល តម្លៃលេខនៅលើក្រិតរំកិលជាចំនួនទសភាគ(លេខក្រោយក្បៀស) ។ អានតម្លៃនៅលើក្រិតរំកិល ដោយរាប់ពីគំនូសសូន្យរហូតដល់គំនូសក្រិតដែលត្រួតស៊ីគ្នាបំផុតជាមួយគំនូសក្រិតនៅលើក្រិតគោល។ បន្ទាប់មកយកចំនួនប្រឡោះក្រិតដែលអានបាននៅលើក្រិតរំកិលគុណនឹងកម្រិតល្អៀង (អាច 0.02 និង 0.05 )។




រូបទី២៖ ម៉ែត្រកៀបដែលកម្រិតល្អៀង $0.02\ mm$

- ចំពោះរូបទី២ តម្លៃអាននៅលើក្រិតគោលគឺ $1\ mm$ ។ ចំនួនប្រឡោះក្រិតនៅលើក្រិតរំកិលគឺ 30 ប្រឡោះ ដូច្នេះតម្លៃអាននៅលើក្រិតរំកិលគឺ $30 \times 0.02\ mm = 0.6\ mm$ ។
- ដូចនេះតម្លៃដែលវាស់បានគឺ $1\ mm + (30 \times 0.02\ mm) = 1.6\ mm$




រូបទី៣៖ ម៉ែត្រកៀបដែលកម្រិតល្អៀង $0.05\ mm$

ចំពោះរូបទី៣ តម្លៃអាននៅលើក្រិតគោលគឺ $19\ mm$ ។ ហើយចំនួនប្រឡោះក្រិតនៅលើក្រិតរំកិលគឺ 9 ប្រឡោះក្រិត នោះតម្លៃអាននៅលើក្រិតរំកិលគឺ $9 \times 0.05\ mm = 0.45\ mm$ ។

- ដូចនេះតម្លៃដែលវាស់បានគឺ $19\ mm + (9 \times 0.05\ mm) = 19.45\ mm$ ។

**គ.វិធីវាស់៖** ក្នុងការវាស់ដោយប្រើម៉ែតកៀប មានច្រើនចំណុចដែលយើងត្រូវវាស់៖

១. ការវាស់វិមាត្រក្រៅ

- ដាក់ដុំការងារ(វត្ថុដែលត្រូវវាស់)នៅនឹងមួយកន្លែង
- ទាញមាត់របស់ម៉ែតកៀប(ធ្មេញឬថ្គាមសម្រាប់វាស់ខាងក្រៅ)ឲ្យបានធំជាងដុំការងារបន្តិច ហើយយកទៅស៊កចូលដុំការងារ
- ប្រើមេដៃរុញដុំរុញ(មើលរូប១)ឲ្យធ្មេញសម្រាប់ក្រៅ កៀបដុំការងារបំផុតដែលអាចធ្វើបាន
- ត្រូវដាក់ធ្មេញម៉ែត្រកៀបឲ្យកែងនឹងដុំការងារឲ្យបានត្រឹមត្រូវ
- បន្ទាប់មកអានតម្លៃឲ្យបានត្រឹមត្រូវ



រូបទី៤៖ បង្ហាញពីការវាស់វិមាត្រក្រៅ។



ការវាស់មិនត្រឹមត្រូវ



ការវាស់ត្រឹមត្រូវ

រូបទី៥៖ បង្ហាញពីការដាក់ម៉ែត្រកៀបដែលត្រឹមត្រូវ និងមិនត្រឹមត្រូវ

២.ការវាស់វិមាត្រខាងក្នុង

- ស៊កធ្មេញសម្រាប់វាស់ខាងក្នុងរបស់ម៉ែត្រកៀប ចូលក្នុងដុំការងារ(វត្ថុដែលត្រូវវាស់)ដូចរូបទី៦
- ហើយយកមេដៃទាញដុំរុញរបស់ម៉ែត្រកៀបឲ្យអឹបបំផុតដែលអាចធ្វើទៅបាន

រួចអានតម្លៃឲ្យបានត្រឹមត្រូវ



រូបទី៦៖ បង្ហាញពីការវាស់វិមាត្រក្នុង

៣.ការវាស់ជម្រៅ

- ប្រើមេដៃទាញជំរុញដើម្បីឲ្យដងសម្រាប់វាស់ជម្រៅរបស់ម៉ែត្រកៀបលៀនចេញ
- ស៊កដងវាស់ជម្រៅចូលទៅក្នុងប្រហោងដែលត្រូវវាស់
- អានតម្លៃឲ្យបានត្រឹមត្រូវ



រូបទី៧៖ បង្ហាញពីការវាស់ជម្រៅរបស់ម៉ែត្រកៀប។

## បំរុងប្រយ័ត្ន មុននិងក្រោយពេល ប្រើប្រាស់ម៉ែត្រកៀប

- មុនពេលប្រើប្រាស់ម៉ែត្រកៀបត្រូវជូតជាមួយក្រណាត់ទន់ៗហើយស្អាត
- ត្រួតពិនិត្យភាពសុក្រិតរបស់ម៉ែត្រកៀប
- ធូលីដែលជាប់នៅលើមាត់ម៉ែត្រកៀប ដែលអាចឲ្យយើងអានតម្លៃខ្វាតខុសប្រហែល 0,003-0,005 mm។
- ជូតធូលីនិងប្រេងចេញក្រោយពេល ប្រើប្រាស់ម៉ែត្រកៀប បន្ទាប់មកដាក់វាចូលក្នុងប្រអប់ដាក់ឧបករណ៍ឲ្យបានត្រឹមត្រូវ។

- កុំយកម៉ែត្រកៀប ទៅគូសឬដំ និងគាស់ឡើយ
- មិនត្រូវធ្វើឲ្យម៉ែត្រកៀបធ្លាក់ឡើយ
- ដាក់ឧបករណ៍វាស់ឲ្យមានសណ្តាប់ធ្នាប់

# ពិសោធន៍ ការវាស់ម៉ាសមាឌ

## ១. វត្ថុបំណង៖

- ការប្រើប្រាស់កាលីព័រ និងជញ្ជីង
- កត្តាកំណត់ម៉ាសមាឌ
- គណនាមាឌអាតូម

## ២. ទ្រឹស្តី៖

- រង្វាស់ដោយប្រើកាលីបព័រ និងជញ្ជីង
- ម៉ាសមាឌនៃសារធាតុ

## ៣. ពិសោធន៍៖

### ក. សំណួរគន្លឹះ

តើវត្ថុដែលមានម៉ាសខុសគ្នា មានជាតុគីមីដូចគ្នា ម៉ាសមាឌរបស់វាយ៉ាងដូចម្តេច?

### ខ. ការបង្កើតសម្មតិកម្ម៖

- សារធាតុពីរដែលធ្វើឡើងពីដែកដូចគ្នា មានម៉ាសខុសគ្នា តើវាមានម៉ាសមាឌស្មើគ្នាឬទេ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

- សារធាតុពីរដែលធ្វើឡើងពីសំណដូចគ្នា មានម៉ាសខុសគ្នា តើវាមានម៉ាសមាឌស្មើគ្នាឬទេ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

- សារធាតុពីរដែលធ្វើឡើងពីទង់ដែងដូចគ្នា មានម៉ាសខុសគ្នា តើវាមានម៉ាសមាឌស្មើគ្នាឬទេ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

- សារធាតុពីរដែលធ្វើឡើងពីអាលុយមីញ៉ូមដូចគ្នា មានម៉ាសខុសគ្នា តើវាមានម៉ាសមាឌស្មើគ្នាឬទេ?

...........................................................................................................................................

.................................................................................................................................

**គ. ពិសោធន៍៖**

- **សម្ភារៈចាំបាច់៖** កាលីបព័រ សំណ អាលុយមីញ៉ូម ទង់ដែង ដែក និងជញ្ជីង
- **ដំណើរការពិសោធ៖**
  - វាស់កម្ពស់ បណ្ដោយ និងទទឹងដើម្បីគណនាមាឌរបស់សារធាតុ
  - ថ្លឹងម៉ាសនៃសារធាតុ
  - គណនាម៉ាសមាឌនៃសារធាតុ
  - ធ្វើដូចគ្នាចំពោះម៉ាសផ្សេងៗទៀត

ឃ. លទ្ធផល៖

| **វត្ថុ** | **មាឌ** ($cm^3$) | **ម៉ាស** (kg) | **ម៉ាសមាឌ** ($kg/cm^3$) |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

ង. សន្និដ្ឋាន៖

វត្ថុដែលមានមាឌដូចគ្នាគឺ៖

.................................................................................................................................

...........................................................................................................................................

.................................................................................................................................

វត្ថុដែលបង្កើតពីធាតុគីមីតែមួយមានៈ

.........................................................................................................................................

.............................................................................................................................................

.......................................................................................................................................

ប្រៀបធៀបម៉ាសមាឌដែលរកឃើញជាមួយតារាងខាងក្រោម រួចកំណត់អត្តសញ្ញាណធាតុគីមីនោះ

.............................................................................................................................................

.............................................................................................................................................

.....................................................................................................................................

ដូចនេះ កត្តាដែលកំណត់ម៉ាសមាឌគឺ ..................................... ............................................និង

........................................................................................................................................

**តារាងម៉ាសមាឌនៃសារធាតុមួយចំនួន**

| **សារធាតុ** | **ម៉ាសមាឌ** ($kg/m^3$) |
|---|---|
| មាស | $19.3 \times 10^3$ |
| អ៊ីយ៉ាញ៉ូម | $18.7 \times 10^3$ |
| សំណ | $11.3 \times 10^3$ |
| ទង់ដែង | $8.93 \times 10^3$ |
| ដែក | $7.89 \times 10^3$ |
| អាលុយមីញ៉ូម | $2.70 \times 10^3$ |
| ទឹក | $1.00 \times 10^3$ |
| សំលោហៈ( ទង់ដែង៦០ និងសង្ក័សី ៤០ ) | $8.52 \times 10^3$ |
| ស័ង្កសី | $7.14 \times 10^3$ |
| ម៉ាញេស្យូម | $1.75 \times 10^3$ |

# ពិសោធន៍ការប្រើប្រាស់ម៉ុលទីម៉ែត្រ

## ១. វត្ថុបំណង៖

- បង្ហាញពីរបៀបប្រើម៉ុលទីម៉ែត្រ។
- បង្ហាញមុខងារ និងអានតម្លៃលេខតាមកាលីបរបស់មុលទីម៉ែត្រឱ្យបានត្រឹមត្រូវ។

  មុលទីម៉ែត្រមានមុខងារច្រើនយ៉ាង ប៉ុន្តែយើងសិក្សាតែអំពែម៉ែត្រ វ៉ុលម៉ែត្រ និងអូមម៉ែត្រ។ មុលទីម៉ែត្រមានពីរប្រភេទគឺ មុលទីម៉ែត្រលេខ និងមុលទីម៉ែត្រទ្រនិច។

## ២. មុខងាររបស់មុលទីម៉ែត្រទ្រនិច៖

(១) ច (អេក្រង់) បង្ហាញតម្លៃលេខ

(២) ប្រដាប់សម្រាប់ជ្រើសរើសកាលីប (ដើម្បីជ្រើសរើសមុខងាររបស់វាជាអំពែម៉ែត្រ វ៉ុលម៉ែត្រ និងអូមម៉ែត្រ)។

(៣) DCmA មានមុខងារជាអំពែម៉ែត្រសម្រាប់វាស់ចរន្តជាប់។

(៤) DCV មានមុខងារជាវ៉ុលម៉ែត្រសម្រាប់វាស់តង់ស្យុងជាប់។

(៥) ACV មានមុខងារជាវ៉ុលម៉ែត្រសម្រាប់វាស់តង់ស្យុងឆ្លាស់។

(៦) (Ω) មានមុខងារជាអូមម៉ែត្រសម្រាប់វាស់តម្លៃរេស៊ីស្តង់។

(៧) គោលម៉ាស COM (-)

(៨) គោល (+)

(៩) ទ្រនិចចង្អុលលេខ (គំនូសក្រិត)។

(១០) ឧបករណ៍លៃតម្រូវទ្រនិចក្នុងការប្រើប្រាស់ជាអូមម៉ែត្រ 0Ω។

(១១) ប្រដាប់សម្រាប់មួលលៃតម្រូវដើម្បីឱ្យទ្រនិចមកដល់ចំណុចសូន្យ (ករណីជាវ៉ុលម៉ែត្រ និងអំពែម៉ែត្រ)។




## ៣. ការជ្រើសរើសកាលីប៖

- ជ្រើសរើសមុខងារដែលអ្នកចង់វាស់ DCmA DCV ឬ ACV និងΩ ADJ។
- ជ្រើសរើសកាលីបឱ្យធំជាងតម្លៃដែលយើងចង់វាស់ ព្រោះតម្លៃលេខរបស់កាលីបនិមួយៗបង្ហាញតម្លៃលេខ អតិបរមាសម្រាប់វាស់។ ឧទាហរណ៍កាលីប 25V យើងអាចវាស់តង់ស្យុងពី 0V ទៅ 25V។

- ប្រសិនបើយើងមិនដឹងតម្លៃលេខពិតប្រាកដ យើងគួរប្រើកាលីបដែលមានតម្លៃធំជាងគេបំផុត។
- ដើម្បីវាស់តង់ស្យុងរបស់ថ្មពិលមួយ ដែលយើងមិនស្គាល់តម្លៃតង់ស្យុងពិតរបស់វា ជាដំបូងយើងគួរជ្រើសរើសមុខងារជា DCV និងចាប់ផ្តើមពីកាលីបដែលធំបំផុត 1000V។
- ប្រសិនបើទ្រនិចរបស់ម៉ុលទីម៉ែត្រមិនងាក អ្នកគួរបន្ថយកាលីបពីធំមកតូចជាបន្តបន្ទាប់ពី 250V → $50V \rightarrow 10V$។
- អ្នកនឹងឃើញទ្រនិចរបស់វាចង្អុលតម្លៃលេខ 1.5V ឬ 1.55V។ នេះជាតម្លៃពិតប្រាកដរបស់ថ្មពិល។

## ៤.របៀបភ្ជាប់ឧបករណ៍ដែលចង់វាស់ជាមួយនឹងមុលទីម៉ែត្រ

❖ ការវាស់តង់ស្យុងរវាងគោលនៃថ្មពិល ឬគោលនៃរេស៊ីស្តរ

ដើម្បីវាស់តង់ស្យុងរវាងគោលនៃថ្មពិល ឬគោលនៃរេស៊ីស្តរណាមួយយើងត្រូវ៖

- តវ៉ុលម៉ែត្រជាខ្នែងជាមួយនឹងគោលទាំងពីរនៃថ្មពិល ឬរេស៊ីស្តរ។
- ភ្ជាប់វាដោយឱ្យចរន្តចូលតាមប៉ូល (+) និងចេញតាមប៉ូល (-)។

❖ ការវាស់អាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់អង្គធាតុចម្លង

ដើម្បីវាស់អាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់អង្គធាតុចម្លងណាមួយយើងត្រូវ៖

- តអំពែម៉ែត្រជាស៊េរីជាមួយនឹងរេស៊ីស្តង់ R។ ចូរប្រុងប្រយ័ត្នកុំភ្ជាប់វាទៅនឹងប្រភពដូចជាថ្មពិល ឬអាគុយដោផ្ទាល់ វាធ្វើឱ្យអំពែម៉ែត្រឆេះខូច។
- ភ្ជាប់វាដោយឱ្យចរន្តចូលតាមប៉ូល (+) និងចេញតាមប៉ូល(-)នៃឧបករណ៍ បើពុំនោះទេប្រនិចរបស់វានឹងងាកបញ្ច្រាស។

❖ ការវាស់រេស៊ីស្តង់

ដើម្បីវាស់រេស៊ីស្តង់នៃរេស៊ីស្តរណាមួយយើងត្រូវ៖

- ដោតខ្សែចម្លងពណ៌ខ្មៅទៅក្នុងគោល COM ( - ) និងខ្សែចម្លងពណ៌ក្រហមទៅប៉ូល ( + )
- ជ្រើសរើសយកមុខងារជាអូមម៉ែត្រ និងកាលីបដែលត្រូវប្រើ
- ធ្វើតេស្តអូមម៉ែត្ររយៈពេលខ្លី ដោយដាក់ខ្សែក្រហមឱ្យប៉ះនឹងខ្សែខ្មៅដើម្បីឱ្យទ្រនិចរបស់វាចង្អុលត្រង់ចំណុចសូន្យ។ ប្រសិនបើទ្រនិចរបស់វាមិនចង្អុលត្រង់ចំណុចសូន្យទេ អ្នកត្រូវមួលឧបករណ៍លៃតម្រូវ 0Ω ADJ ដើម្បីឱ្យទ្រនិចងាកមកចំណុចសូន្យ។ ប្រសិនបើទ្រនិចមិនចង្អុលចំណុចសូន្យទេអ្នកត្រូមប្តូរថ្ម។
- កុំវាស់រេស៊ីស្តង់ក្នុងសៀគ្វីបិទ
- ភ្ជាប់ខ្សែចម្លងទៅនឹងគោលទាំងពីរនៃរេស៊ីស្តរ និងអានតម្លៃលេខ។

## ៥. ការអានតម្លៃលេខ

❖ **ចំពោះវ៉ុលម៉ែត្រ និងអំពែម៉ែត្រ**

យើងអានតម្លៃលេខដែលយើងវាស់បាននៅលើច ( អេក្រង់ ) ត្រង់ប្រឡោះក្រិត B ( រូបទី២ ) ដោយប្រើរូបមន្ត៖

– **អំពែម៉ែត្រ**

$$I = \frac{Cal}{n_0} \times n$$

- n ចំនួនប្រឡោះក្រិតដែលវាស់បាន
- $n_0$ ចំនួនប្រឡោះក្រិតសរុប
- **Cal** កាលីប

– **វ៉ុលម៉ែត្រ**

$$V = \frac{Cal}{n_0} \times n$$

❖ **ចំពោះអូមម៉ែត្រ**

ក្នុងប្រឡោះក្រិតនិមួយៗរបស់អូមម៉ែត្រមានតម្លៃផ្សេងៗគ្នា។ យើងអានតម្លៃលេខតាមលេខនៅលើច (អេក្រង់) ត្រង់ប្រឡោះក្រិត A (រូបទី២) ដោយគិតមេគុណទៅតាមកាលីបនិមួយៗ។

បើកាច់កាលីបមកកតម្លៃ ×1 មានន័យថា៖

ពីលេខ 0 → 2: មួយប្រឡោះក្រិតតូចត្រូវនឹង 0.2Ω

2 → 10: មួយប្រឡោះក្រិតតូចត្រូវនឹង 0.5Ω

10 → 20: មួយប្រឡោះក្រិតតូចត្រូវនឹង 1Ω

20 → 50: មួយប្រឡោះក្រិតតូចត្រូវនឹង 2Ω

50 → 100: មួយប្រឡោះក្រិតតូចត្រូវនឹង 5Ω

100 → 200: មួយប្រឡោះក្រិតតូចត្រូវនឹង 20Ω

200 → 300: មួយប្រឡោះក្រិតតូចត្រូវនឹង 50Ω

300 → 500: មួយប្រឡោះក្រិតតូចត្រូវនឹង 100Ω

500 → $1k$: មួយប្រឡោះក្រិតតូចត្រូវនឹង 500Ω

1k → $2k$: មួយប្រឡោះក្រិតតូចត្រូវនឹង 1000Ω=1kΩ



**ឧទាហរណ៍៖**

ចូរសង្កេតរូបភាព រួចឆ្លើយសំណួរដូចខាងក្រោម៖




១. យើងចង់វាស់តង់ស្យុងរវាងគោលនៃរេស៊ីស្តង់មួយដោយជ្រើសរើសកាលីប DCV, 50V។ យើងសង្កេតឃើញទ្រនិចងាកបានដូចរូបខាងលើ។ តើតង់ស្យុងរវាងគោលនៃរេស៊ីស្តង់មានតម្លៃប៉ុន្មាន?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..........................................................................................................................................

២. ប្រសិនបើទ្រនិចងាកបានដូចរូបខាងលើ តើតង់ស្យុងរវាងគោលនៃរេស៊ីស្តង់មានតម្លៃប៉ុន្មាន? ក្នុងករណីគេជ្រើសរើសកាលីប៖ ក. 10V ខ. 250V គ. 0.5V

..................................................................................................................................................

..................................................................................................................................................

.............................................................................................................................................

៣.ដូចរូបខាងលើដដែល តើរេស៊ីស្តង់មានតម្លៃប៉ុន្មាន? ក្នុងករណីគេកាច់កាលីប៖ក. ×1Ω ខ. ×10Ω គ. ×1kΩ

..................................................................................................................................................

..................................................................................................................................................

...................................................................................................................................................

.........................................................................................................................................

៤. ប្រសិនបើយើងវាស់អាំងតង់ស៊ីតេចរន្តដោយជ្រើសរើសកាលីប 0.25A ហើយទ្រនិចងាកបានដូចរូបខាងលើ។ តើអាំងតង់ស៊ីតេចរន្តមានតម្លៃប៉ុន្មាន?

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

..........................................................................................................................................

# ពិសោធន៍ទន្លាក់សេរី

## ១. ទស្សនៈចំណាច

កំណត់សំទុះទន្លាក់សេរី(សំទុះទំនាញផែនដី )និង(%)កម្រិតល្អៀងរបស់វាបានត្រឹមត្រូវតាមពិសោធន៍។

## ២. ចំណេះដឹងមូលដ្ឋាន( ទ្រឹស្តី )

- កម្ពស់ធ្លាក់របស់អង្គធាតុ $h = \frac{1}{2}gt^2$
- ល្បឿន $v = gt$
- សំទុះ $g = 9.80\ \mathrm{m/s^2}$
- %កម្រិតល្អៀង $= \left|\frac{\text{តម្លៃទ្រឹស្តី}-\text{តម្លៃពិសោធន៍}}{\text{តម្លៃទ្រឹស្តី}}\right| \times 100\% = \left|\frac{g-a}{g}\right| \times 100\%$

  ឬ %កម្រិតល្អៀង $= \left|\frac{\text{តម្លៃពិត}-\text{តម្លៃពិសោធន៍}}{\text{តម្លៃពិត}}\right| \times 100\% = \left|\frac{g-a}{g}\right| \times 100\%$

## ៣. ពិសោធន៍

### ៣.១ ការកំណត់បញ្ហា

តើអ្នកអាចកំណត់សំទុះទន្លាក់សេរី ( សំទុះទំនាញផែនដី ) និង( % )កម្រិតល្អៀងរបស់វាបានយ៉ាងដូចម្ដេច ?

### ៣.២ សម្មតិកម្ម

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

………………………………………………………………………………………………

### ៣.៣ តេស្តសម្មតិកម្ម

( ក ) តម្រូវការសម្ភារៈ

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

………………………………………………………………………………………………

( ខ ) ដំណើរការដំឡើងសម្ភារៈ និងពិសោធន៍

…………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………………

## ៣.៤ លទ្ធផល

តារាងទិន្នន័យ និងគណនា

| ចំណុច | $y$ (cm) | $\Delta y$ (cm) | $v$ (cm/s) | $\Delta v$ (cm/s) | $a$ (cm/s$^2$) |
|---|---|---|---|---|---|
| ទី0 | $y_0 = 0$ | | | | |
| ទី5 | $y_1 =$ | $\Delta y_1 =$ | $v_1 = \frac{\Delta y_1}{\Delta t_1} =$ | | |
| ទី10 | $y_2 =$ | $\Delta y_2 =$ | $v_2 = \frac{\Delta y_2}{\Delta t_2} =$ | $\Delta v_1 =$ | $a_1 = \frac{\Delta v_1}{\Delta t_1} =$ |
| ទី15 | $y_3 =$ | $\Delta y_3 =$ | $v_3 = \frac{\Delta y_3}{\Delta t_3} =$ | $\Delta v_2 =$ | $a_2 = \frac{\Delta v_2}{\Delta t_2} =$ |
| ទី20 | $y_4 =$ | $\Delta y_4 =$ | $v_4 = \frac{\Delta y_4}{\Delta t_4} =$ | $\Delta v_3 =$ | $a_3 = \frac{\Delta v_3}{\Delta t_3} =$ |
| ទី25 | $y_5 =$ | $\Delta y_5 =$ | $v_5 = \frac{\Delta y_5}{\Delta t_5} =$ | $\Delta v_4 =$ | $a_4 = \frac{\Delta v_4}{\Delta t_4} =$ |
| ……… | | | | | |

| | | | |
|---|---|---|---|
| រយៈពេល $t = \Delta t =$ ថេរ $=$ | $g = \dots\dots\dots \mathrm{m/s^2}$ | $a = \frac{a_1 + a_2 + a_3 + a_4}{4} =$ | %កម្រិតល្អៀង = |

### ការគណនាគំរូ

- $\Delta y_1 = y_1 - y_0 =$
- $\Delta y_2 = y_2 - y_1 =$
- $v_1 = \frac{\Delta y_1}{\Delta t_1} =$
- $v_2 = \frac{\Delta y_2}{\Delta t_2} =$
- $\Delta v_1 = v_2 - v_1$
- $a_1 = \frac{\Delta v_1}{\Delta t_1} =$
- %កម្រិតល្អៀង $= \left|\frac{\text{តម្លៃទ្រឹស្តី}-\text{តម្លៃពិសោធន៍}}{\text{តម្លៃទ្រឹស្តី}}\right| \times 100\% = \left|\frac{g-a}{g}\right| \times 100\% =$

ក្រាប៖




បម្លាស់ទី-ពេល




(វ៉ិចទ័រ)ល្បឿន-ពេល




សំទុះ-ពេល

## ៣.៥ វិភាគ និងសន្និដ្ឋាន

- វិភាគ៖ ផ្អែកតាមការពិសោធខាងលើ

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

……………………………………………………………………………………………………

- សន្និដ្ឋាន៖

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

……………………………………………………………………………………………………………………។

## ៤. ពិភាក្សា៖

(១) ហេតុអ្វីបានជាតម្លៃសំទុះ($a$)ដែលអ្នកបានរកឃើញតូចជាងសំទុះទំនាញផែនដី($g$) ទោះបីជាកូនទម្ងន់ដែលអ្នកបានទន្លាក់នោះស្ថិតក្រោមតែអំពើកម្លាំងទំនាញផែនដី?

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

…………………………………………………………………………………………………………………។

(២) តើអ្នកមានគំនិតច្នៃប្រឌិតដូចម្តេច ដើម្បីឱ្យការពិសោធលើកក្រោយៗទៀតទទួលបានលទ្ធផលល្អប្រសើរជាងនេះ?

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

…………………………………………………………………………………………………………………។

(៣) ក្រោយពីបានប្រើប្រាស់ឧបករណ៍ពិសោធន៍នេះរួចមក តើអ្នកយល់ពីគោលការណ៍ដំណើរការរបស់វា និងដឹងពីវិធីផលិត ឬអភិវឌ្ឍវាដែលឬទេ? បើដឹងចូរបង្ហាញយោបល់អ្នក។

(៤)តើសំទុះនៃអង្គធាតុដែលធ្លាក់ក្នុងដែនទំនាញផែនដីអាស្រ័យនឹងម៉ាសរបស់អង្គធាតុដែលធ្លាក់ដែរឬទេ(មិនគិតកម្លាំងទប់នៃខ្យល់? ចូរបង្ហាញហេតុផល។

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

………………………………………………………………………………………………………………

(៥)  តើសំទុះនៃអង្គធាតុដែលធ្លាក់ក្នុងដែនទំនាញផែនដីអាស្រ័យនឹងរាងរបស់អង្គធាតុដែលធ្លាក់ដែរឬទេ(គិតកម្លាំងទប់នៃខ្យល់ ? ចូរបង្ហាញហេតុផល និងលើកឧទាហរណ៍ក្នុងការរស់នៅឬក្នុងបច្ចេកទេសមកបញ្ជាក់។

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

…………………………………………………………………………………………

(៦)  យានអវកាសមួយត្រូវ បានបាញ់បង្ហោះចេញពីផ្ទៃផែនដីទៅកម្ពស់ 800 km ។  រយៈកម្ពស់នេះគឺជាព្រំដែននៃស្រទាប់បរិយាកាសពីររបស់ផែនដីគឺ Thermosphere និងExosphere ហើយសីតុណ្ហភាពប្រហែលជា 1200 °C។ ចូរប្រៀបធៀបសំទុះទំនាញផែនដីដែលនៅក្បែរផ្ទៃផែនដី និងនៅរយៈកម្ពស់ខាងលើ។

……………………………………………………………………………………………………

……………………………………………………………………………………………………

…………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

…………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………

# ពិសោធន៍ ទំនាស់មេគុណកកិត
# កកិតនឹងថ្កល់

## ១. ទស្សនៈបំណង

- មេគុណកកិតនឹងថ្កល់ និងមេគុណកកិតដោយរអិលមិនអាស្រ័យនឹងម៉ាសទេ វាអាស្រ័យនឹងភាពគ្រើម ឬរលោងនៃផ្ទៃប៉ះ។

- គណនាមេគុណកកិតនឹងថ្កល់ និងមេគុណកកិតដោយរអិល។

- ប្រៀបធៀបមេគុណកកិតនឹងថ្កល់ និងដោយរអិល។

## ២. ចំណេះដឹងមានស្រាប់

-ប្រភេទនៃកកិត។

-ការគូសទិសដៅកម្លាំង។

វត្ថុមួយមានម៉ាស ។ តើគេត្រូវផ្តល់កម្លាំងយ៉ាងតិចបំផុតប៉ុន្មាន ដើម្បីអោយវត្ថុនេះផ្លាស់ទី ?

ក តិចជាង 100N ☐

ខ ស្មើ 100N ☐

គ ធំជាង 100N ☐

## ៣. ពិសោធន៍ទី១៖ កកិតនឹងថ្កល់

ក. ការកំណត់បញ្ហា

-តើយើងអាចរកមេគុណកកិតនឹងថ្កល់បានយ៉ាងដូចម្តេច ?

ខ. ការបង្កើតសម្មតិកម្ម

យើងយកដុំឈើមួយដែលមានម៉ាស $M_o$ ដាក់លើប្លង់ដេក រួចយើងយកដុំឈើនោះ មកភ្ជាប់នឹងវត្ថុដែលមានម៉ាស $m_o$ ដោយខ្សែកាត់តាមរ៉កដែលមានម៉ាសអាចចោលបាន។ យើងឃើញថាម៉ាស ចាប់ផ្តើមរំកិលតិចៗ។ មេគុណកកិតនឹងថ្កល់រវាងវត្ថុ និងប្លង់ដេក(រូបទី១) អាចកំណត់បានតាមទំនាក់ទំនង៖

$\mu_s = \frac{f_r}{N}$ ☐

$\mu_s = \frac{M_o}{m_o}$ ☐

$\mu_s = \frac{m_o}{M_o}$ ☐



រូបទី១

❖ **គំរូឃេះ:**

ត្រង់ម៉ាស $M_o$ ៖ តាមច្បាប់ទី២របស់ញូតុនៈ .........................⇒$f_r$=.............................(1)

ត្រង់ម៉ាស $m_o$ ៖ តាមច្បាប់ទី២របស់ញូតុនៈ ........................⇒ $T$ =...........................(2)

(1) និង (2) ⇒ $f_r = P_1$ (3)

តាមរូបមន្ត កម្លាំងកកិត $f_r$ = ..............(4)

ជំនួស (4) ក្នុង (3) ⇒ $\mu_s$ =........................

គ. ពិសោធន៍

- **សំភារៈចាំបាច់៖** ដុំឈើរាងប្រលេពីប៉ែតកែង ខ្សែអំបោះ កន្ត្រក (សម្រាប់ដាក់កូនទម្ងន់) បន្ទះ ក្តារ កូនទំងន់ (100g, 10g និង1g) បន្ទាត់ ជញ្ជីង និងរ៉ក។
- **ដំណើរការពិសោធន៍៖**

១. ថ្លឹងដុំឈើ ដែលមានម៉ាស $M_o$ (g) និងកន្ត្រកដែលមានម៉ាស $m_o$ (g)។

២. តំឡើងឧបករណ៍ដូចរូបទី២។ កែតម្រូវទីតាំងរបស់រ៉កដើម្បីអោយខ្សែលោតត្រង់ស្មើ។

៣. កំណត់ទីតាំងលំនឹងរបស់វត្ថុ ដោយគូសខ្មៅដៃចំណាំ។

៤. ដាក់កូនទម្ងន់ដែលមានម៉ាស 100g ទៅលើកន្ត្រកម្តងមួយៗ រហូតដល់វត្ថុនោះចាប់ផ្តើមផ្លាស់ទី។ នៅពេលវាចាប់ផ្តើមផ្លាស់ទី ដកកូនទំងន់ដែលមានម៉ាស 100g ចេញ។ បន្ទាប់មកដាក់កូនទំងន់ 10g បន្ថែមលើកូនទំងន់ 100g ម្តងមួយៗ។ បើដុំឈើចាប់ផ្តើមផ្លាស់ទី ដកកូនទំងន់ 10g ចេញរួចបន្ថែម

កូនទំងន់ 1g ម្តងមួយៗរហូតដុំឈើ ចាប់ផ្តើមផ្លាស់ទីបានបន្តិច។ រកម៉ាសសរុបរវាងកូនទំងន់ និងកន្ត្រក ( $m_o + m$ ) g។

៥. កំនត់មេគុណកកិតនឹងថ្កល់រវាងដុំឈើ និងបន្ទះក្តារ។

៦. ដាក់កូនទម្ងន់បន្ថែមទៅលើដុំឈើ។ ធ្វើដូចគ្នានឹងដំណើរការទី១-៤ ជាមួយកូនទំងន់ខុសគ្នាដែលបន្ថែមទៅលើដុំឈើឱ្យបាន៤ ទៅ ៥ដង។ ចូរកំណត់មេគុណកកិតនឹងថ្កល់ ក្នុងករណី នីមួយៗ។



រូបទី២

ឃ. លទ្ធផល

| ម៉ាសកូនទំងន់សរុប( $m + m_o$ ) (g) | ម៉ាសវត្ថុរាងប្រលេពីប៉ែតកែង ( $M_o$+M )( g ) | មេគុណកកិតនឹងថ្កល់អតិបរមា $\mu_o$ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

ង. វិភាគ និងសន្និដ្ឋាន

វិភាគ

១. នៅពេលយើងចង់អោយវត្ថុមួយផ្លាស់ទី តើចាំបាច់ត្រូវផ្តល់កំលាំងដែលធំជាងទំងន់របស់វត្ថុនោះដែរឬទេ ? ហេតុអ្វី ?

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

២. តើមេគុណកកិតអាស្រ័យនឹងម៉ាស ដែររឺទេ ?

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

៣. តើកម្លាំងកកិតអាស្រ័យនឹងម៉ាសដែររឺទេ ?

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

សន្និដ្ឋាន៖

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

- **ពិភាក្សា៖**

ដើម្បីលើកវត្ថុមួយដែលមានម៉ាស តើចាំបាច់ផ្តល់កម្លាំងយ៉ាងតិចបំផុតប៉ុន្មាន ទៅលើវត្ថុនោះ ?

………………………………………………………………………………………………………………………………………

………………………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

# កកិតដោយរអិល

## ក. ការកំណត់បញ្ហា

តើយើងអាចរកមេគុណកកិតដោយរអិលបានដោយរបៀបណា ?

## ខ. សម្មតិកម្ម

យកដុំឈើ $M_o = 320,0g$ អោយរអិលលើប្លង់ទេរ ដែលបង្កើតបានមុំ $\theta = 45°$ ជាមួយប្លង់ដេក(រូបទី៣) (បន្ទះក្តារក្នុងពិសោធន៍ទី១ មកធ្វើជាប្លង់ទេរ)។ តើមេគុណកកិតដោយរអិល រវាងដុំឈើនិងបន្ទះក្តារមានតម្លៃប្រហែលប៉ុន្មាន ?




រូបទី៣

❖ **គំរូយេះ**

ត្រង់ចំនុច តាមច្បាប់ទី២ញូតុន៖ ............................................................

$$P_X - f_r = ma \ (*)$$

តាមរូប $P_X$= ………………..(1) និង N=…………………………

តាមរូបមន្ត $f_r = \mu . N$ (2)




ដោយដុំឈើរអិលលើប្លង់ទេរដោយចលនាស្ទុះ យើងបាន $l = \frac{1}{2}at^2 \Rightarrow \ a = \frac{2l}{t^2}$ (3)

យក (1), (2) និង (3) ជំនួសក្នុង(*)

$\Rightarrow P\ \sin\theta - \mu P\cos\theta = \ m\frac{2l}{t^2}$

$\Rightarrow \mu P\ \cos\theta = P\sin\theta - m\ \frac{2l}{t^2}$

$\Rightarrow \mu = \ \tan\theta - 2m\frac{1}{P\cos\theta\, t^2}$ (P=mg,និង $\cos\theta = \frac{1}{\sqrt{1+\tan\theta}}$ )

$\Rightarrow$ μ = ⋯ … … … … … … … … … … ….

## គ. ពិសោធន៍

- **តម្រូវការសម្ភារះ** ដុំឈើរាងប្រលេពីប៉ែតកែង កូនទំងន់ ជើងទំរ បន្ទះក្ដារ ម៉ែត្រ ក្រូណូម៉ែត្រ (stopwatch។
- **ដំណើការពិសោធន៍៖**

១. តំឡើងឧបករណ៏ដូចបង្ហាញក្នុងរូបទី៣។

២. គូសខ្មៅដៃកំនត់ទីតាំងដើមរបស់ដុំឈើ។

៣. ប្រើបន្ទាត់ ឬ ម៉ែត្រ វាស់កំពស់ និងចំងាយ ដើម្បីកំណត់តង់សង់។

៤. ប្រើក្រូណូម៉ែត្រ វាស់រយៈពេលដែលវត្ថុផ្លាស់ទីពី ទៅ យ៉ាងហោចណាស់ អោយបាន៤ដង។

៥. បន្ថែមកូនទំងន់លើវត្ថុរាងប្រលេពីប៉ែតកែង រួចវាស់រយៈពេល ដូចដំណាក់កាលទី៤។ បន្ថែមកូនទំងន់ឱ្យបាន៤ដង ឬ៥ ដង រួចវាស់រយៈពេលនៅពេលវាផ្លាស់ទី។

៦. គណនាមេគុណកកិតដោយរអិលរវាងដុំឈើ និងបន្ទះក្ដារក្នុងករណីនីមួយៗ។

ឃ. លទ្ធផល

*d= …………………………cm*

$\tan\theta = \cdots$ … … … … … … … …, $\cos\theta = \frac{1}{\sqrt{1+tg^2\theta}} = \cdots$ … … … … … …

មេគុណកកិតដោយរអិល (ប្លង់ទេរ) $\mu = \tan\theta - \frac{2l\sqrt{1+tg^2\theta}}{gt^2}$

| ម៉ាសដុំឈើ M (Kg) | $M_{1=}$………… | $M_2$=……… | $M_3$=…… | $M_4$=…… | $M_5$=… |
|---|---|---|---|---|---|
| រយៈពេលផ្លាស់ទី t (s) | $t_1$ =…… | $t_2$ =………… | $t_3$ =…… | $t_4$ =… | $t_5$=… |
| មេគុណកកិតរវាងដុំឈើ និងបន្ទះក្តារ μ | $\mu_1$=……… | $\mu_2$=……… | $\mu_3$=……. | $\mu_4$=…… | $\mu_5$=… |

ង. វិភាគ និងសន្និដ្ឋាន

វិភាគ

១. ចូរប្រៀបធៀបតំលៃ រវាងមេគុណកកិតនឹងថ្កល់ និងមេគុណកកិតដោយរអិល?

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………

២. មេគុណកកិតដោយរអិលអាស្រ័យនឹងម៉ាសរឺទេ?

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………

សន្និដ្ឋានៈ

- មេគុណកកិតនឹងថ្កល់ និងមេគុណកកិតដោយរអិលមិនអាស្រ័យនឹងម៉ាសទេ វាអាស្រ័យតែនឹងភាពគ្រើមឬរលោងនៃផ្ទៃប៉ះ។

- មេគុណកកិតនឹងថ្កល់ មានតម្លៃធំជាមេគុណកកិតដោយរអិល។

- កម្លាំងកកិតកំណត់ដោយរូបមន្ត

$$f_r = \mu_o \cdot N$$

$f_r$ កំលាំងកកិត N កំលាំងប្រតិកម្ម $\mu_o$មេគុណកកិត។

**ពិភាក្សាៈ**

តើ $\mu_k$អាស្រ័យនឹងមុំឬទេ? ចូរពន្យល់បកស្រាយ។

# ពិសោធន៍ប៉ោលទោល
# ( ប៉ោល - លំយោលអាកម៉ូនិកខាយ )

## ១. វត្ថុបំណង

- កំណត់ភាពអាស្រ័យគ្នារវាងខួប( *T*) ប្រវែង( *L*) និងម៉ាស( *m*)របស់ប៉ោល។
- បង្ហាញថាខួបនៃប៉ោល( *T*)អាស្រ័យលើអំព្លីទុតមុំនៃលំយោលចំពោះមុំលំយោលធំ ប៉ុន្តែភាពអាស្រ័យនេះអាចចោលបាន ចំពោះមុំលំយោលតូច( ខួបនៃប៉ោលទោល )។
- កំណត់តម្លៃសំទុះទំនាញផែនដីតាមពិសោធន៍ដែលទាញតាមរង្វាស់ខួបនៃប៉ោល និងប្រៀបធៀបវាជាមួយនឹងតម្លៃតាមទ្រឹស្តី។

## ២. ទ្រឹស្តី

ប៉ោលផ្សំឡើងដោយខ្សែមិនយឺតមួយប្រវែង( *L*) ដែលចុងម្ខាងរបស់វាភ្ជាប់ទៅនឹងម៉ាស( *m*) និងចុងម្ខាងទៀតរបស់ខ្សែភ្ជាប់ទៅនឹងចំណុចនឹងមួយ។ សំណុំនេះត្រូវបានគេហៅថាប៉ោលទោលដែលយើងសិក្សាក្នុងករណីមុំតូច( លំយោលមិនថយ ) (បើមុំធំ លំយោលថយ វាមិនមែនជាប៉ោលទោលទេ )។

ម៉ាស( *m*)ផ្លាស់ទីតាមមួយវិមាត្រ នោះចលនាជាចលនាស៊ីនុយសូអ៊ីត បើបម្លាស់ទី *x* ពីទីតាំងលំនឹងណាមួយជាអនុគមន៍នៃស៊ីនុសឬកូស៊ីនុស។ ចលនានេះកើតឡើង កាលណាចំណុចរូបធាតុមួយរងនូវកម្លាំង *F* ដែលសមាមាត្រដោយផ្ទាល់នឹងអាំងតង់ស៊ីតេនៃបម្លាស់ទី និងមានទិសដៅឆ្ពោះទៅកាន់ទីតាំងលំនឹង។ សមីការឲ្យដោយ៖




$$F = -k\,x \qquad (1)$$

ខួប( *T*)នៃចលនា គឺជារយៈពេលមួយលំយោលពេញ និងត្រូវបានកំណត់ដោយ

$$T = 2\pi\sqrt{\frac{M}{k}} \qquad (2)$$

ប៉ោលទោលមិនគោរពលក្ខខណ្ឌលំយោលអាកម៉ូនិចងាយពេញលេញនោះទេ ប៉ុន្តែវាសឹងតែជាលំយោលអាកម៉ូនិចងាយ។ ប៉ោលទោលបរិសុទ្ធមានម៉ាសជាចំណុច និងខ្សែមិនគិតម៉ាសបង្ហាញដូចរូបខាងលើ។

ចលនារបស់ប្រព័ន្ធកើតឡើងក្នុងប្លង់ឈរ កាលណាម៉ាស $m$ ត្រូវបានលែងពីទីតាំងមួយដែលបង្កើតបានមុំ θ ជាមួយនឹងខ្សែឈរ។ ទម្ងន់នៃប៉ោលមានទិសដៅចុះក្រោមអាចត្រូវបានបំបែកជាកំប៉ូសង់ពីរដូចបង្ហាញក្នុងរូបខាងលើ។

កំប៉ូសង់ $mg\cos\theta = N$ (តំណឹងខ្សែនៃប៉ោល)

កំប៉ូសង់ $mg\sin\theta$ប៉ះទៅនឹងធ្នូវង់តាមបណ្តោយម៉ាស $m$ ផ្លាស់ទី។ កំប៉ូសង់នេះផ្តល់កម្លាំងដើម្បីទាញប្រព័ន្ធ។ សមីការនៃកម្លាំងតាមបណ្តោយទិសដៅចលនាឲ្យដោយៈ

$F = -mg\sin\theta$ (3)

កាលណាមុំ θ តូច នោះ sinθ ≈ tanθ ≈ θ ≈ mg/L

$F = -mgx/L$ (4)

ពីសមីការ (4)និង(1) យើងបាន $k = mg/L$

ដូចនេះខួបនៃប៉ោលទោលគឺ

$$T = 2\pi\sqrt{\frac{m}{mg/L}} = 2\pi\sqrt{\frac{L}{g}} \qquad (5)$$

សមីការ (5) បង្ហាញថាខួបនៃប៉ោលទោល $T$ មិនអាស្រ័យនឹងម៉ាស $m$ និងអំព្លីទុតមុំ θ ទេ និងវាអាស្រ័យតែប្រវែង(ខ្សែ)ប៉ោលប៉ុណ្ណោះ។

កាលណាមុំធំ នោះតម្លៃនៃខួបពិតគឺ

$$T = 2\pi\sqrt{\frac{L}{g}}\ \left(1 + \frac{1}{4}\sin^2\theta/2 + \frac{9}{64}\sin^4\theta/2 + \cdots\right) \qquad (6)$$

ចំពោះប៉ោលបរិសុទ្ធ(គ្មានកកកិត) ចលនាយោលសាចុះសាឡើងមានអំព្លីទុតមិនថយទោះបីជារយៈពេលបន្តទៅមុខទៀតក៏ដោយ។ ចំពោះប៉ោលពិត វាតែងតែមានកកិតខ្លះៗ និងអំព្លីទុតនៃលំយោលថយចុះយឺតៗតាមពេល។ **ចំពោះអំព្លីទុតដើមតូច បម្រែបម្រួលខួបតាមអំព្លីទុតថយចុះអាចចោលបាន។** នេះជាមូលដ្ឋានគ្រឹះនៃនាឡិកាប៉ោល។

## ៣. តេស្តមុនចូលទីពិសោធន៍

១. តើអ្វីទៅជាប៉ោលទោល?

២. សរសេររូបមន្តខួបនៃប៉ោលទោល។

៣. តើខួបនៃប៉ោលទោលអាស្រ័យនឹងអ្វីខ្លះ?

៤. ក្នុងករណីអំព្លីទុតនៃលំយោធំ ឬមុំធំ តើលំយោលជាលំយោលអ្វី?

៥. ចូរបង្ហាញថាខួបនៃប៉ោលទោលឲ្យតាមរូបមន្ត $T = 2\pi\sqrt{\frac{L}{g}}$ ។

៦. ចូរបង្ហាញថាកាលណាមុំធំ ខួបនៃប៉ោលឲ្យតាមរូបមន្ត

$$T = 2\pi\sqrt{\frac{L}{g}}\ \left(1 + \frac{1}{4}\sin^2\theta/2 + \frac{9}{64}\sin^4\theta/2 + \cdots\right)$$

៧. ប៉ោលទោលមួយមានប្រវែងខ្សែស្មើនឹង 0.700 m និងគេទាញវាចេញពីទីតាំងលំនឹងក្រោមមុំតូចប្រហែល $5.0°$ បន្ទាប់មកគេលែងវាឲ្យយោល។ កំណត់ខួបនៃប៉ោលទោល។ យក $g = 9.80\, m/s^2$ ។

៨. ប៉ោលទោលមួយមានប្រវែងខ្សែ $L$ ។ គេទាញវាចេញពីទីតាំងលំនឹងក្រោមមុំលំយោលតូច រួចលែងវាឲ្យយោល។ គេវាស់ឃើញខួបលំយោលរបស់វាស្មើ 1.81 s ។ គណនាប្រវែងខ្សែ $L$ នេះ។ $g = 9.80\, m/s^2$ ។

៩. ប៉ោលទោលមួយមានប្រវែងខ្សែ 1.00 m ។ គេទាញវាចេញពីទីតាំងលំនឹងក្រោមមុំតូចប្រហែល $5.0°$ បន្ទាប់មកគេលែងវាឲ្យយោល។

ក. កំណត់ខួបនៃប៉ោលទោល។ យក $g = 9.80\, m/s^2$ ។

ខ. ដោយប្រើក្រូណូម៉ែត្រកត់ត្រារយៈពេល 10 លំយោលពេញចំនួន 5 ដងផ្សេងៗគ្នា គេបានតម្លៃក្នុងតារាងខាងក្រោម៖

| ពិសោធន៍ | លើកទី1 | លើកទី2 | លើកទី3 | លើកទី4 | លើកទី5 |
|---|---|---|---|---|---|
| រយៈពេល10 លំយោលពេញ (s) | 20.05 | 20.08 | 20.08 | 20.04 | 20.08 |
| ខួប(T) | | | | | |

| | | | | | |
|---|---|---|---|---|---|
| $\overline{T}$ | | | | | |
| %កម្រិតល្អៀង | | | | | |
| ល្អៀងគំរូ($\alpha$) | | | | | |

(a) គណនាខួប(រយៈពេលមួយលំយោលពេញ) ($T$)

(b) គណនាតម្លៃមធ្យមនៃខួប $\overline{T}$

(c) គណនាកម្រិតល្អៀង(ភាគរយ)

(d) កម្រិតល្អៀងគំរូ ($\alpha$)

## ៤. ឧបករណ៍សម្ភារ

Software PHET

## ៥. ដំណើរការ

(ក) Install Software PHET (Offline or online) ចូលក្នុងកុំព្យូទ័ររបស់អ្នក។ បើ Online ពេលប្រើត្រូវភ្ជាប់ Internet ។ បើ Offline មិនចាំបាច់ភ្ជាប់ Internet ទេ។ បន្ទាប់ពី Install ចប់ វានឹងបង្ហាញ Icon PHET simulations នៅលើ Screen នៃកុំព្យូទ័ររបស់អ្នក។

(ខ) ដាក់ Mouse pointer លើ Icon PHET simulations រួចចុចពីរដងលើ Mouse ខាងឆ្វេងនោះវានឹងលេចចេញផ្ទាំងបញ្ជីឈ្មោះពិសោធន៍ដែលរៀបតាមអក្ខរក្រម(Alphabet) ពី A ទៅ Z ។ នៅជួរខាងឆ្វេងមានពាក្យថា Simulations និងខាងក្រោមវាមានពាក្យថា Physics, Chemistry, Biology, Earth Science, Math, ... ដែលបញ្ជាក់ថាអ្នកអាចធ្វើពិសោធន៍បានជាមួយ Physics, Chemistry, Biology, Earth Science, Math ។

(គ) ចុចលើពាក្យថា Physics (រូបវិទ្យា) វានឹងបង្ហាញបញ្ជីពិសោធន៍យ៉ាងច្រើនដែលអ្នកអាចធ្វើពិសោធន៍បានក្រោមទម្រង់ជារូបភាព។ សូមចងចាំថា ពិសោធន៍របស់អ្នកគឺប៉ោលទោល(Pendulum Lab)។ ដូចនេះត្រូវយក Pendulum Lab ។

(ឃ) ចុចលើពាក្យ Pendulum Lab ពេលនោះវានឹងលេចចេញជា File VIDEO ។

(ង) ចុចលើ VIDEO នេះ វានឹងចេញរូបប៉ោលដែលនៅស្ងៀម និងប្រអប់ជាច្រើន។

- **ចំពោះប្រវែងប៉ោល**

(ច) ចុចជ្រើសរើសប្រវែងខ្សែ ($L$) ម៉ាសប៉ោល($m$) សំទុះទំនាញដី($g$) (ផែនដី) និងគ្មានកកិត នៅក្នុងប្រអប់ខាងស្តាំនៃប៉ោល។។ តម្លៃទាំងនេះមើលតាមតារាងទិន្នន័យនិងគណនាទី១ខាងក្រោម។

(ឆ) ទាញប៉ោលចេញពីទីតាំងលំនឹងបានមុំប្រហែល 5.0° រួចលែងវា។

(ជ) ចុចលើប្រអប់ខាងក្រោមផ្នែកខាងឆ្វេងដើម្បីជ្រើសយក Stopwatch (ក្រូណូម៉ែត្រ) នោះវានឹងលេចចេញនូវ Stopwatch (ក្រូណូម៉ែត្រ)ដែលអាចឲ្យយើងវាស់ខួបនៃលំយោលបាន។

(ឈ) វាស់ខួប 10 លំយោលពេញ រួចកត់ត្រាទិន្នន័យដាក់ក្នុងតារាងទិន្នន័យនិងគណនាទី១ខាងក្រោម។ វាស់វាចំនួនបីដងផ្សេងៗគ្នាទៀត។ **ធ្វើដូចគ្នាចំពោះប្រវែងខ្សែផ្សេងៗទៀត**។

- **ចំពោះម៉ាសប៉ោល**

(ញ) ពិនិត្យតារាងទិន្នន័យ និងគណនាទី២ រួចយកម៉ាសតាមក្នុងតារាង និងធ្វើតាមចំណុច(ឈ)។ **ធ្វើដូចគ្នាចំពោះម៉ាសប៉ោលផ្សេងៗទៀត**។ពិសោធន៍នេះត្រូវរក្សាប្រវែងប៉ោល និងមុំ(អំព្លីទុត)ថេរ។

- **ចំពោះមុំប៉ោល(អំព្លីទុតមុំ)**

(ដ) ពិនិត្យតារាងទិន្នន័យ និងគណនាទី៣ រួចយកមុំតាមក្នុងតារាង និងធ្វើតាមចំណុច(ឈ)។**ធ្វើដូចគ្នាចំពោះមុំប៉ោល(អំព្លីទុតមុំ)ផ្សេងៗទៀត**។ ពិសោធន៍នេះត្រូវរក្សាប្រវែងប៉ោល និងម៉ាសថេរ។

- **ដំបូន្មានក្នុងការគណនា**
  **ប្រវែងប៉ោល**

១. គណនាតម្លៃមធ្យម $\bar{t}$ កម្រិតល្អៀងស្តង់ដា $\alpha_t$ សម្រាប់ប្រវែងនីមួយៗនិងកត់ត្រាតម្លៃរបស់វាក្នុងតារាងទិន្នន័យនិងគណនាទី១។

២. គណនាខួប $T$ ដែល $T=\bar{t}/10$ និងកត់ត្រាវាក្នុងតារាងទិន្នន័យនិងគណនាទី១។

៣. គណនា $\sqrt{L}$ និងកត់ត្រាវាក្នុងតារាងទិន្នន័យនិងគណនាទី១។ សង់ក្រាបរវាង $T$ និង$\sqrt{L}$ ដែល $T$ ស្ថិតលើអ័ក្សឈរនិង $\sqrt{L}$ លើអ័ក្សដេក។ តាមរូបមន្ត $T=\frac{2\pi}{\sqrt{g}}\sqrt{L}$ នោះមេគុណប្រាប់ទិសនៃបន្ទាត់ $\tan\theta=\frac{2\pi}{\sqrt{g}}$ ដែល $g$ ជាអញ្ញត្តិ

និងកត់ត្រាវាជា$g_{exp}$ ក្នុងតារាងទិន្នន័យនិងគណនាទី១។ កត់ត្រាមេគុណទំនាក់ទំនង $r$ (Correlation coefficient)។

**ម៉ាសប៉ោល**

១. គណនាតម្លៃមធ្យម $\bar{t}$ និងកម្រិតល្អៀងស្តង់ដា $\alpha_t$ សម្រាប់ម៉ាសនីមួយៗ និងកត់ត្រាតម្លៃរបស់វាក្នុងតារាងទិន្នន័យនិងគណនាទី២។

២. គណនាខួប $T$ ដែល $T = \bar{t}/10$ និងកត់ត្រាវាក្នុងតារាងទិន្នន័យនិងគណនាទី២។

**មុំប៉ោល(អំព្លីទុតមុំ)**

១. គណនាតម្លៃមធ្យម $\bar{t}$ និងកម្រិតល្អៀងស្តង់ដា $\alpha_t$ សម្រាប់មុំនីមួយៗ និងកត់ត្រាតម្លៃរបស់វាក្នុងតារាង

ទិន្នន័យនិងគណនាទី៣។

២. គណនាខួប $T$ ដែល $T = \bar{t}/10$ និងកត់ត្រាវាក្នុងតារាងទិន្នន័យនិងគណនាទី៣ជា $T_{exp}$ ។

៣. ប្រើសមីការ (6) គឺ $T = 2\pi\sqrt{\frac{L}{g}}\left(1 + \frac{1}{4}\sin^2\theta/2 + \frac{9}{64}\sin^4\theta/2 + \cdots\right)$ដើម្បីគណនា $T$ដោយយក $L$ = 1.00 m, និង m = 0.200 kg និង $\theta$ ក្នុងតារាង។ កត់ត្រាវាក្នុងតារាងទិន្នន័យនិងគណនាទី៣ជា $T_{theo}$ ។

៤. សម្រាប់តម្លៃខួបតាមពិសោធន៍ $T_{exp}$ គណនាផលធៀបនៃខួបត្រង់មុំផ្សេងៗទៅនឹងខួបត្រង់មុំ 5.0°។ ហៅផលធៀបនេះជា $\frac{T_{\text{exp}}(\theta)}{T_{\text{exp}}(5°)}$ ។ កត់ត្រាតម្លៃនេះក្នុងតារាងទិន្នន័យនិងគណនាទី៣។

៥. សម្រាប់តម្លៃខួបតាមទ្រឹស្តី $T_{theo}$ គណនាផលធៀបនៃខួបត្រង់មុំផ្សេងៗទៅនឹងខួបត្រង់មុំ 5.0°។ ហៅផលធៀបនេះជា $\frac{T_{\text{theo}}(\theta)}{T_{\text{theo}}(5°)}$ ។ កត់ត្រាតម្លៃនេះក្នុងតារាងទិន្នន័យនិងគណនាទី៣។

## ៦. លទ្ធផល

តារាងទិន្នន័យ និងគណនាទី១

- **យក m = 0. 200 kg, និង $\theta = 5.0°$** (ថេរ)

| $L$ (m) | $t_1$ (s) | $t_2$ (s) | $t_3$ (s) | $\bar{t}$(s) | $T$(s)= $\bar{t}$/10 | $\sqrt{L}(\sqrt{m})$ | $\alpha_t$ (s) |
|---|---|---|---|---|---|---|---|
| 1.00 | 19.91 | 19.94 | 19.86 | 19.90 | 1.990 | 1.00 | |
| 0.800 | 17.74 | 17.73 | 17.83 | 17.77 | 1.777 | 0.8944 | |
| 0.600 | 15.61 | 15.44 | 15.46 | 15.50 | 1.550 | 0.7746 | |
| 0.500 | 14.05 | 14.09 | 14.08 | 14.07 | 1.407 | 0.7071 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 0.400 | 12.59 | 12.59 | 12.58 | 12.59 | 1.259 | 0.6325 | |
| 0.300 | 10.91 | 10.99 | 10.96 | 10.95 | 1.095 | 0.5477 | |
| 0.200 | 8.85 | 8.90 | 8.83 | 8.86 | 0.886 | 0.4472 | |
| 0.100 | | | | | | | |
| មេគុណប្រាប់ទិស tanθ = 2 | | $g_{exp}$= 9.86 m/s$^2$ | | %កម្រិតល្អៀង = | | $r$ = 1 | |

តារាងទិន្នន័យ និងគណនាទី២

❖ **យក $L$ = 1. 00 m, និង $\theta = 5.0°$ (ថេរ)**

| $m$ (kg) | $t_1$ (s) | $t_2$ (s) | $t_3$ (s) | $\bar{t}(s)$ | T(s) = $\bar{t}/10$ | $\alpha_t$ (s) |
|---|---|---|---|---|---|---|
| 0.100 | 19.91 | 19.93 | 19.96 | 19.93 | 1.993 | |
| 0.200 | 19.94 | 19.92 | 19.93 | 19.93 | 1.993 | |
| 0.300 | 19.87 | 19.88 | 19.98 | 19.91 | 1.991 | |
| 0.500 | 19.95 | 19.90 | 19.92 | 19.92 | 1.992 | |

តារាងទិន្នន័យ និងគណនាទី៣

❖ **យក $L$ = 1.00 m, និង m = 0.200 kg (ថេរ)**

| $\theta$ | $t_1$ (s) | $t_2$ (s) | $t_3$ (s) | $\bar{t}(s)$ | $\alpha_t$ (s) | $T$(s)=$T_{exp}$ | $T_{theo}$ (s) | $\frac{T_{exp}(\theta)}{T_{exp}(5°)}$ | $\frac{T_{theo}(\theta)}{T_{theo}(5°)}$ |
|---|---|---|---|---|---|---|---|---|---|
| 5° | 19.85 | 19.93 | 20.07 | 19.95 | | 1.995 | 2.008 | 1.000 | 1.000 |
| 10° | 20.03 | 20.01 | 20.00 | 20.01 | | 2.001 | 2.011 | 1.003 | 1.001 |
| 20° | 20.07 | 20.25 | 20.15 | 20.16 | | 2.016 | 2.022 | 1.010 | 1.007 |
| 30° | 20.26 | 20.31 | 20.30 | 20.29 | | 2.029 | 2.042 | 1.017 | 1.017 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| $45^{o}$ | 20.78 | 20.85 | 20.76 | 20.80 | | 2.080 | 2.087 | 1.043 | 1.039 |

ការគណនាគំរូ

$$T_{exp} = \frac{\bar{t}}{10} = \sqrt{L} =$$

$$g_{exp} = \frac{4\pi^2}{\tan^2\theta} =$$

$$T_{\text{theo}} = 2\pi\sqrt{\frac{L}{g}}\left(1 + \frac{1}{4}\sin^2\theta/2 + \frac{9}{64}\sin^4\theta/2 + \cdots\right)$$

$$\delta_{n-1} = \sum \frac{1}{n-1}(t-\bar{t})^2$$

$$\alpha_t = \frac{\delta_{n-1}}{\sqrt{n}} =$$

%កម្រិតល្មៀង $= \left|\frac{g_{theo}-g_{exp}}{g_{theo}}\right| \times 100\% =$

- ក្រាប







## ៧. សន្និដ្ឋាន

-ផ្អែកលើសទ្ធផលពិសោធន៍តាមតារាងទិន្នន័យនិងគណនាទី១កាលណាប្រវែង ($L$)ប៉ោល……………..នោះខួប($T$)នៃប៉ោល…………..។ ចំណែកឯតាមតារាងទិន្នន័យនិងគណនាទី២ កាលណាម៉ាស ($m$)ប៉ោល……………….នោះខួប($T$)នៃប៉ោល………………….។ ដូចនេះ

យើងអាចសន្និដ្ឋានបានថា ខួបនៃប៉ោលទោល( $T$)អាស្រ័យលើ***ប្រវែង***នៃប៉ោល និងមិនអាស្រ័យលើ***ម៉ាស***របស់ប៉ោលទេ។

- តាមលទ្ធផលក្នុងតារាងទិន្នន័យនិងគណនាទី៣ កាលណាមុំ(អំព្លីទុតមុំ)ប៉ោល$\theta$ = 5.0$^{o}$ នោះ ខួប( $T$)នៃប៉ោលស្មើ………………..និង$\theta$ = 10$^{o}$ នោះ ខួប( $T$)នៃប៉ោលស្មើ………..។ ប៉ុន្តែកាលណាមុំ(អំព្លីទុតមុំ)ប៉ោលធំ $\theta$> 10$^{o}$ នោះ ខួប( $T$)នៃប៉ោល………..។ ដូចនេះយើងអាចសន្និដ្ឋានបានថា ខួបនៃប៉ោលទោល( $T$)មាន***តម្លៃថេរ*** កាលណាមុំ(អំព្លីទុតមុំ)ប៉ោល( $\theta$) តូចប្រហែល 10$^{o}$ និងមាន***តម្លៃកើនឡើង*** កាលណាមុំ(អំព្លីទុតមុំ)ប៉ោល( $\theta$) ធំ ( > 10$^{o}$) និង ។

- សំទុះទំនាញផែនដីអាចត្រូវបានកំណត់តាមពិសោធន៍ $g_{exp}$ =………….m/s$^{2}$។

## ៨. ពិភាក្សា

១. តើកត្តាអ្វីខ្លះដែលធ្វើលទ្ធផលពិសោធន៍របស់អ្នកមិនបានល្អ?

២. តើអ្នកធ្វើដូចម្តេចបានជាលទ្ធផលពិសោធន៍របស់អ្នកបានល្អ?

៣. ដើម្បីឲ្យការពិសោធន៍លើកក្រោយៗទៀតទទួលបានលទ្ធផលកាន់តែល្អជាងនេះ តើអ្នកត្រូវយកចិត្តទុកដាក់លើចំណុចអ្វីខ្លះ?

# រង្វាស់កម្ដៅម៉ាសរបស់អង្គធាតុ(ទង់ដែង)

## ១. វត្ថុបំណង

កំណត់កម្ដៅម៉ាសទង់ដែងតាមពិសោធន៍ និងគណនាកម្រិតល្អៀងរបស់វាបានត្រឹមត្រូវ។

## ២. ចំណេះដឹងមូលដ្ឋាន(ទ្រឹស្ដី)

- កម្ដៅម៉ាស ($c$)
- រូបមន្តបរិមាណកម្ដៅដែលទឹក និងកាឡូរីម៉ែត្រស្រូប
  $$Q_{\text{ស្រូប}} = (m_1c_1 + m_2c_2)\Delta T = (m_1c_1 + m_2c_2)(T_f - T_c)$$
- រូបមន្តបរិមាណកម្ដៅដែលអង្គធាតុក្ដៅបញ្ចេញ $Q_{\text{បញ្ចេញ}} = (m_3c_3)\Delta T = (m_3c_3)(T_h - T_f)$
- គោលការណ៍បណ្ដូរកម្ដៅ $Q_{\text{ស្រូប}} = Q_{\text{បញ្ចេញ}}$
- %កម្រិតល្អៀង ($c$)= $\left|\frac{c_{\text{ទ្រឹស្ដី}} - c_{\text{ពិ}}}{c_{\text{ទ្រឹស្ដី}}}\right| \times 100\%$

## ៣. ពិសោធន៍

### ៣.១ ការកំណត់បញ្ហា

ដោយប្រើប្រាស់កាឡូរីម៉ែត្រ តើអ្នកអាចកំណត់កម្ដៅម៉ាសរបស់លោហៈបានយ៉ាងដូចម្ដេច?

### ៣.២ សម្មតិកម្ម

ដាក់ដុំទង់ដែងក្ដៅដែលស្គាល់ម៉ាសនិងសីតុណ្ហភាពរបស់វាចូលក្នុងទឹកនៃកាឡូរីម៉ែត្រដែលស្គាល់ម៉ាសទឹក និងម៉ាស់កាឡូរីម៉ែត្រ និងសីតុណ្ហភាពដើមរបស់វា រួចវាស់សីតុណ្ហភាពស្រេចរបស់ប្រព័ន្ធ នោះយើងអាចកំណត់កម្ដៅម៉ាសនៃទង់ដែងបាន។

### ៣.៣ តេស្តសម្មតិកម្ម(ពិសោធន៍)

(ក) តម្រូវការសម្ភារៈ៖ ដុំទង់ដែង កាឡូរីម៉ែត្រទង់ដែង ទឹក ជញ្ជីង ទែម៉ូម៉ែត្រ តង្កៀបចាប់ដុំទង់ដែង ឆ្នាំងដាំទឹក និងចង្ក្រានហ្គាស

(ខ) ដំណើរការដំឡើង និងពិសោធន៍

- ថ្លឹងម៉ាសកាឡូរីម៉ែត្រ និងម៉ាសដុំទង់ដែងដោយប្រើជញ្ជីងរៀងគ្នា។ ម៉ាសកាឡូរីម៉ែត្រ$m_1$ និងម៉ាសដុំទង់ដែង $m_3$ និងកត់ត្រាទិន្នន័យនីមួយៗដាក់ក្នុងតារាងទិន្នន័យខាងក្រោម។

- ចាក់ទឹកចូលជិតពាក់កណ្ដាលកាឡូរីម៉ែត្រ រួចថ្លឹងវាដោយប្រើជញ្ជីង។ ម៉ាសទឹក-កាឡូរីម៉ែត្រគឺ $m$ ម៉ាសទឹកគឺ $m_2$ ដែល $m_2 = m - m_1$ រួចកត់ត្រាទិន្នន័យដាក់ក្នុងតារាងទិន្នន័យខាងក្រោម។
- ដាក់ដុំទង់ដែងក្នុងឆ្នាំងដាំទឹក រួចដាំទឹករហូតដល់ពុះដោយប្រើចង្ក្រានហ្គាស។ ត្រាំតង្កៀប និងទែម៉ូម៉ែត្រក្នុងទឹកពុះ។ វាស់សីតុណ្ហភាពទឹកពុះ $t_h$ រួចកត់ត្រាទិន្នន័យដាក់ក្នុងតារាងទិន្នន័យខាងក្រោម។ សីតុណ្ហភាពនៃទឹកពុះស្មើគ្នានឹងសីតុណ្ហភាពនៃដុំទង់ដែង។
- ដកទែម៉ូម៉ែត្រពីឆ្នាំងដាំទឹកពុះយកទៅដាក់ក្នុងទឹកត្រជាក់ដើម្បីបញ្ចុះសីតុណ្ហភាពវាមកធម្មតាវិញ រួចដាក់បញ្ចូលក្នុងរន្ធនៃគម្របកាឡូរីម៉ែត្រ ដោយលៃយ៉ាងណាឱ្យបាតនៃកណ្ដក់ត្រឹមពាក់កណ្ដាលកាឡូរីម៉ែត្រគិតពីគម្របលើ។
- ដាក់ម៉ាសទឹក-កាឡូរីម៉ែត្រក្នុងផើងធំនៃកាឡូរីម៉ែត្រ។
- ចាប់ដុំទង់ដែងក្ដៅដាក់ចូលក្នុងទឹក-កាឡូរីម៉ែត្រ ដោយប្រើតង្កៀប និងគ្របគម្របដែលមានទែម៉ូម៉ែត្រ។ កូរទឹកដោយប្រើប្រដាប់កូរ(ខ្នូរ) រួចអានសីតុណ្ហភាស្រេចនៃទឹក។ កត់ត្រាទិន្នន័យដាក់ក្នុងតារាងទិន្នន័យ។




## ៣.៤ លទ្ធផល

តារាងទិន្នន័យ

<table>
<tr><th></th><th>តម្លៃម៉ាស (kg)</th><th>សីតុណ្ហភាព(℃)</th><th>កម្ដៅម៉ាស ($c$) (J/kg℃)</th></tr>
<tr><td>ម៉ាសទឹក-កាឡូរីម៉ែត្រ m</td><td></td><td rowspan="3">$t_c$</td><td>កម្ដៅម៉ាសទឹក $c_2 = 4187$ J/kg℃</td></tr>
<tr><td>ម៉ាសកាឡូរីម៉ែត្រទង់ដែង $m_1$</td><td></td><td>កម្ដៅម៉ាសទង់ដែង $c_{\text{ទ្រី}} = 387$ J/kg℃</td></tr>
<tr><td>ម៉ាសទឹក $m_2 = m - m_1$</td><td></td><td>$c_{\text{ពិ}} =$</td></tr>
<tr><td>ម៉ាសដុំទង់ដែង $m_3$</td><td></td><td>$t_h =$</td><td>$t_f =$</td></tr>
</table>

| %កម្រិតល្អៀងនៃកម្ដៅម៉ាស ($c$) | |
|---|---|

ការគណនាគំរូ

……………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

……………………………………………………………………………………………………………………………

……………………………………………………

### ៣.៥ សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ កម្ដៅម៉ាសទង់ដែងតាមទ្រឹស្ដី $c_{ទ្រឹ} =$ ………………………… និងតាមពិសោធន៍ ត្រូវបានរកឃើញ $c_{ពិ} =$ ………………………….។ កម្រិតល្អៀងរបស់វាគឺ …………………………………….។ ដូចនេះសម្មតិកម្មត្រូវបាន……………………ដោយពិសោធន៍។

**ពិភាក្សា៖** ១. តើកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើលទ្ធផលពិសោធន៍របស់អ្នកដែលធ្វើឱ្យវាមិនបានល្អ?

២. តើអ្នកមានគំនិតបែបណាដើម្បីកាត់បន្ថយកត្តាទាំងនោះដើម្បីឱ្យការពិសោធលើក្រោយបានលទ្ធផលល្អជាងនេះ?

# ដែនអគ្គិសនី និងប៉ូតង់ស្យែលអគ្គិសនី

## ដែនអគ្គិសនី

### ១. វត្ថុបំណង៖

- បង្ហាញខ្សែដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកអគ្គិសនី និងស្ប៉ិចអគ្គិសនី។
- កំណត់ទិសដៅ និងអាំងតង់ស៊ីតេដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកត្រង់ចំណុចណាមួយ។គូរក្រាបដែនអគ្គិសនី( *E*) ជាអនុគមន៍នៃចម្ងាយ( *a*) ។
- កំណត់កម្រិតល្អៀងរវាងតម្លៃតាមទ្រឹស្តី និងពិសោធន៍។

### ២. ទ្រឹស្តី

កាលពីពិសោធន៍មុនយើងបានសិក្សាពីអគ្គិសនីកម្ម និងបានបញ្ចូលបញ្ញតិកម្លាំងអគ្គិសនី ដែនអគ្គិនីនិងទំនាក់ទំនងរវាងកម្លាំងនិងដែនអគ្គិសនីខ្លះៗមកហើយ ក្នុងគោលបំណងដើម្បីពន្យល់ពីអន្តកម្មនៃបន្ទុកអគ្គិសនី។ ពិសោធន៍នេះយើងនឹងរៀនពិស្តាពីបន្ទុកបង្កើតដែនអគ្គិសនី។ តើដែនអគ្គិសនីជាអ្វី? ដែលអគ្គិសនីជាលំហមួយដែលកើតមានជុំវិញបន្ទុកអគ្គិសនី ដែលតាមរយៈលំហនេះអាចឲ្យបន្ទុកអគ្គិសនីមួយមានអំពើលើបន្ទុកអគ្គិសនីមួយទៀតដែលនៅក្បែរនោះ។

ដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកមួយឲ្យដោយ៖

$\vec{E} = K\frac{Q}{a^2}\vec{\imath}$ ដែល $\vec{\imath}$ ជាវ៉ិចទ័រឯកតា

ជាម៉ូឌុល $E = K\frac{Q}{a^2}$

ដែល $K = 9.0 \times 10^9$ $Nm^2/C^2$ ហៅថាថេរគូឡុំ, *Q* ជាបន្ទុកបង្កើតដែនត្រង់ចំណុចណាមួយ គិតជា (C)

*a* ជាចម្ងាយពីបន្ទុកបង្កើតដែន( *Q*)ទៅចំណុចបង្កើតដែន គិតជា (m), *E* ជាដែនអគ្គិសនីត្រង់ចំណុចណាមួយ គិតជា (N/C)ឬ (V/m)







$Q > 0$ ដែនអគ្គិសនីចាកផ្ចិត $\vec{E} = K\frac{Q}{a^2}\vec{\imath}$  $Q < 0$ ដែនអគ្គិសនីចូលផ្ចិត $\vec{E} = -K\frac{Q}{a^2}\vec{\imath}$

ដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកច្រើនឲ្យដោយ៖

$$\vec{E} = \vec{E}_1 + \vec{E}_2 + \cdots = \sum_i K \frac{Q_i}{{a_i}^2} \vec{\imath}$$




ខ្សែដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកអគ្គិសនី





ខ្សែដែនអគ្គិសនីនៃបន្ទុកវិជ្ជមាន

ខ្សែដែនអគ្គិសនីនៃបន្ទុកអវិជ្ជមាន



( សំណុំខ្សែដែនអគ្គិសនីហៅថាស្ប៉ិចអគ្គិសនី )

ខ្សែដែនអគ្គិសនីនៃបន្ទុកវិជ្ជមាន និងអវិជ្ជមានដែលដាក់ក្បែរគ្នា

កម្រិតល្អៀងភាគរយ(%Error)

$$\%\text{កម្រិតល្អៀង} = \left|\frac{\text{តម្លៃតាមទ្រឹស្តី} - \text{តម្លៃតាមពិសោធន៍}}{\text{តម្លៃតាមតទ្រឹស្តី}}\right| \times 100\%$$

## ៣. សំណួរមុនចូលទីពិសោធន៍

១. តើដែនអគ្គិសនីជាអ្វី?

២. តើដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកវិជ្ជមានមួយត្រង់ចំណុចផ្សេងៗក្បែរៗចំណុចបន្ទុកមានទិសដៅដូចម្តេច? គូររូបតាងខ្សែដែនអគ្គិសនីជុំវិញចំណុចបន្ទុកអគ្គិសនីនេះ។

៣. តើដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកអវិជ្ជមានមួយត្រង់ចំណុចផ្សេងៗក្បែរៗចំណុចបន្ទុកមានទិសដៅដូចម្តេច? គូររូបតាងខ្សែដែនអគ្គិសនីជុំវិញចំណុចបន្ទុកអគ្គិសនីនេះ។

៤. តើស្ប៉ិចអគ្គិសនីជាអ្វី?

៥. សរសេររូបមន្តនៃដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកមួយ។

៦. សរសេររូបមន្តនៃដែនអគ្គិសនីផ្លូបដែលបង្កើតដោយចំណុចបន្ទុកច្រើន។

៧. ចំណុចបន្ទុកអគ្គិសនីមួយ $q = 25.0\,\mu C$ ស្ថិតក្នុងខ្យល់។ កំណត់ដែនអគ្គិសនីត្រង់ចំណុច $M$ ចម្ងាយ 5.0 cm ពីចំណុចបន្ទុកនេះ។ គេឲ្យ $K = 9.0 \times 10^9$ Nm$^2$/C$^2$ ។

៨. ចំណុចបន្ទុកអគ្គិសនីមួយ $q = -25.0\,\mu C$ ស្ថិតក្នុងខ្យល់។ កំណត់ដែនអគ្គិសនីត្រង់ចំណុច $M$ ចម្ងាយ 1.0 m ពីចំណុចបន្ទុកនេះ។ គេឲ្យ $K = 9.0 \times 10^9$ Nm$^2$/C$^2$ ។

៩. ចំណុចបន្ទុកអគ្គិសនីពីរ $q_1 = 25.0\,\mu C$និង $q_2 = -25.0\,\mu C$ ស្ថិតក្នុងខ្យល់។ កំណត់ដែនអគ្គិសនីផ្ទួបត្រង់ចំណុច $M$ ស្ថិតនៅពាក់កណ្តាលរវាងចំណុចបន្ទុកទាំងពីរ។ ចម្ងាយរវាងចំណុចបន្ទុកទាំងពីរគឺ 2.0 m ។ គេឲ្យ $K = 9.0 \times 10^9$ Nm$^2$/C$^2$ ។

១០. ចំណុចបន្ទុកអគ្គិសនីពីរ $q_1 = q_2 = 1.0\,nC$ ស្ថិតក្នុងខ្យល់ ត្រូវបានដាក់លើកំពូលនៃត្រីកោណសម័ង្ស($ABC$)មួយដែលមានជ្រុង $a$ ។

(ក) កំណត់ដែនអគ្គិសនីផ្ទួបត្រង់ចំណុច $C$ដែលគ្មានបន្ទុកអគ្គិសនី។ គេឲ្យ $K = 9.0 \times 10^9$ Nm$^2$/C$^2$ និង $a = 3.0$ m ។

(ខ) បើតម្លៃដែនអគ្គិសនីផ្ទួបតាមពិសោធន៍ត្រង់ $C$ត្រូវបានវាស់ឃើញស្មើនឹង 1.73 N/C គណនាកម្រិតល្អៀង(ភាគរយ)របស់វា។

១១. ចំណុចបន្ទុកអគ្គិសនីពីរ $q_1 = 1.0\,nC$ និង$q_2 = -1.0\,nC$ ស្ថិតក្នុងខ្យល់ ត្រូវបានដាក់លើកំពូលនៃត្រីកោណសម័ង្ស($ABC$)មួយដែលមានជ្រុង $a$ ។

(ក) កំណត់ដែនអគ្គិសនីផ្ទួបត្រង់ចំណុច $C$ដែលគ្មានបន្ទុកអគ្គិសនី។ គេឲ្យ $K = 9.0 \times 10^9$ Nm$^2$/C$^2$ និង $a = 3.0$ m ។

(ខ) បើតម្លៃដែនអគ្គិសនីផ្ទួបតាមពិសោធន៍ត្រង់ $C$ត្រូវបានវាស់ឃើញស្មើនឹង 1.01 N/C គណនាកម្រិតល្អៀង(ភាគរយ)របស់វា។

## ៤. តម្រូវការសម្ភារ

Software PHET Simulation ដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក

## ៥. ដំណើរការ

(ក) ចុចពីរដងជាប់គ្នាលើ PHET Simulations លើអេក្រង់នៃកំព្យូទ័ររបស់អ្នក ពេលនោះវានឹងលេចចេញផ្ទាំងបញ្ជីឈ្មោះពិសោធន៍ដែលរៀបតាមអក្ខរក្រម(Alphabet) ពី A ទៅ Z ។ នៅជួរខាងឆ្វេងមានពាក្យថា Simulations និងខាងក្រោមវាមានពាក្យថា Physics, Chemistry, Biology, Earth

Science, Math, ... ដែលបញ្ជាក់ថាអ្នកអាចធ្វើពិសោធន៍បានជាមួយ Physics, Chemistry, Biology, Earth Science, Math ។

(ខ) ចុចលើពាក្យថា Physics (រូបវិទ្យា) វានឹងបង្ហាញបញ្ជីពិសោធន៍យ៉ាងច្រើនដែលអ្នកអាចធ្វើពិសោធន៍បានក្រោមទម្រង់ជារូបភាព។ សូមចងចាំថា ពិសោធន៍របស់អ្នកគឺដែនអគ្គិសនី (Charges and Fields)។ ដូចនេះត្រូវយក Charges and Fields ។ ចុចលើពាក្យ Charges and Fields ពេលនោះវានឹងលេចចេញជា File VIDEO ។

(គ) ចុចលើ VIDEO នេះ វានឹងចេញប្រអប់ធំៗបី គឺខាងក្រោមមួយ និងខាងស្តាំពីរ។

- ប្រអប់ធំខាងក្រោមមាន៖
  - + 1 nC មានន័យថាបន្ទុកអគ្គិសនីវិជ្ជមាន 1 nC
  - - 1 nC មានន័យថាបន្ទុកអគ្គិសនីអវិជ្ជមាន -1 nC
  - Sensors មានន័យថាជាឧបករណ៍សម្រាប់វាស់ដែនអគ្គិសនីត្រង់ចំណុចណាមួយដែលចង់វាស់។
- ប្រអប់ធំខាងស្តាំ និងខាងលើមាន៖
  - Electric Field មានន័យថាបង្ហាញទិសដៅខ្សែដែនអគ្គិសនី ឆ្ងាយពីបន្ទុកខ្សែដែនព្រាលៗ
  - Direction Only មានន័យថាបង្ហាញតែទិសដៅខ្សែដែនអគ្គិសនីប៉ុណ្ណោះ
  - Voltage មានន័យថាតង់ស្យុង វាបង្ហាញព៌ណជុំវិញបន្ទុក។ (+) ព៌ណក្រហម និង(-)ព៌ណខៀវ។
  - Values មានន័យថាបង្ហាញតម្លៃដែនអគ្គិសនីដែលវាស់ដោយប្រើ Sensors និងមុំជាដឺក្រេ។
  - Grid មានន័យថាបង្ហាញក្រឡាការ៉ូដែលជាមាត្រដ្ឋាន 2 ការ៉ូធំត្រូវជា 1 m ។
- ប្រអប់ធំខាងស្តាំ និងខាងក្រោមមាន៖
  - 0.0 V មានន័យថាបង្ហាញឧបករណ៍វាស់ប៉ូតង់ស្យែលត្រង់ចំណុចណាមួយ
  - ម៉ែត្ររមូ សម្រាប់វាស់ប្រវែងឬចម្ងាយ។

### ➢ ខ្សែដែន និងស្ប៉ិចអគ្គិសនី

(ឃ) ទាញយកបន្ទុកវិជ្ជមាន (+1 nC) ដាក់ក្នុងកន្លែងធ្វើការ(Work sheet) ខាងលើត្រង់ចំណុចណាមួយ។ពិនិត្យមើលខ្សែដែនអគ្គិសនីជុំវិញបន្ទុកអគ្គិសនី។ កត់ត្រាទម្រង់ខ្សែដែនអគ្គិសនីដាក់ក្នុងតារាង

ទិន្នន័យទី១ខាងក្រោម។

(ង) ទាញបន្ទុកវិជ្ជមាន (+1 nC) មួយទៀតដាក់នៅជ្រុងម្ខាងទៀតឆ្ងាយពីបន្ទុកមុន។ ពិនិត្យមើលខ្សែដែនអគ្គិសនីជុំវិញបន្ទុកអគ្គិសនីទាំងពីរ។ កត់ត្រាទម្រង់ខ្សែដែនអគ្គិសនីដាក់ក្នុងតារាងទិន្នន័យទី១ខាងក្រោម។

(ច) ទាញបន្ទុកទាំងពីរដាក់ក្នុងប្រអប់នៅកន្លែងដើមវិញ។ រួចទាញបន្ទុកអវិជ្ជមាន (-1 nC) មួយដាក់ក្នុងកន្លែងធ្វើការ(Work sheet)ជំនួសបន្ទុកវិជ្ជមាន ពិនិត្យមើលខ្សែដែនអគ្គិសនីរបស់វា បន្ទាប់មកទាញបន្ទុកអវិជ្ជមានមួយទៀតដាក់នៅជ្រុងម្ខាងទៀតឆ្ងាយពីបន្ទុកមុន។ ពិនិត្យមើលខ្សែដែនអគ្គិសនីជុំវិញបន្ទុកអគ្គិសនីទាំងពីរ។ កត់ត្រាទម្រង់ខ្សែដែនអគ្គិសនីដាក់ក្នុងតារាងទិន្នន័យទី១។

(ឆ) ទាញបន្ទុកអវិជ្ជមានមួយដាក់ក្នុងប្រអប់នៅកន្លែងដើមវិញ រួចទាញបន្ទុកវិជ្ជមានដាក់ជំនួសវិញ។ ពិនិត្យមើលខ្សែដែនអគ្គិសនីជុំវិញបន្ទុកទាំងពីរ។ កត់ត្រាទម្រង់ខ្សែដែនអគ្គិសនីដាក់ក្នុងតារាងទិន្នន័យទី១។

- **ការគណនាដែនអគ្គិសនី និងគូរក្រាប**

(ជ) រក្សាទុកតែបន្ទុកវិជ្ជមាន +1.0 nC មួយប៉ុណ្ណោះនិងដាក់វានៅផ្នែកខាងឆ្វេងនិងខាងក្រោមក្បែរបាត។ ប្រើSensors (ដាក់ត្រង់ទីតាំងផ្សេងៗ) និងម៉ែត្រដើម្បីវាស់ដែនអគ្គិសនីនិងប្រវែងរៀងគ្នាដូចបង្ហាញក្នុងតារាងទិន្នន័យនិងគណនាទី២។

(ឈ) ជំឡើងរូបតាមលំហាត់ទី១០ និង១១ ក្នុងសំណួរមុនចូលទីពិសោធន៍ និងធ្វើពិសោធន៍ម្តងមួយៗ រួចគណនាដែនអគ្គិសនីផ្ទប និងគណនាកម្រិតល្បឿងរបស់វា។ កត់ត្រាទិន្នន័យដាក់ក្នុងតារាងទិន្នន័យនិងគណនាទី៣ខាងក្រោម។ ចម្ងាយរវាងបន្ទុក a = 3.0 m




បន្ទុក + 1.0 nC  បន្ទុក + 1.0 nC




បន្ទុក + 1.0 nC     បន្ទុក - 1.0 nC

## ៦. លទ្ធផល

តារាងទិន្នន័យទី១

| ប្រភេទបន្ទុកអគ្គិសនី | ខ្សែដែនអគ្គិសនី |
|---|---|
| (+) | |
| (-) | |
| (+) និង (-) | |
| (+) និង (+) | |
| (-) និង (-) | |
| ស្ប៉ិចអគ្គិសនី | |

តារាងទិន្នន័យនិងគណនាទី២

| ចម្ងាយ *a* (m) | $E_{ពិសោធន៍}$(N/C) | $E_{ទ្រឹស្តី}$(N/C) |
|---|---|---|
| 0.50 m | | |
| 0.60 m | | |
| 0.70 m | | |
| 0.80 m | | |
| 1.0 m | | |
| 1.5 m | | |
| 2.0 m | | |
| 2.5 m | | |
| 3.0 m | | |
| 3.5 m | | |
| 4.0 m | | |
| $Q = 1.0\times10^{-9}$ C | $K = 9.0\times10^{9}$ Nm$^2$/C$^2$ | |

ក្រាប



តារាងទិន្នន័យនិងគណនាទី3

<table>
<tr><td>ចម្ងាយ $a$ (m)</td><td colspan="2">$E_{ពិសោធន៍}$(N/C)</td><td>$E_{ទ្រឹស្ដី}$(N/C)</td></tr>
<tr><td>3.0 m</td><td colspan="2"></td><td></td></tr>
<tr><td colspan="4">% Error =</td></tr>
<tr><td colspan="2">$Q_1 = Q_2 = 1.0\times10^{-9}$ C</td><td colspan="2">$K = 9.0\times10^{9}$ Nm$^2$/C$^2$</td></tr>
<tr><td colspan="4"></td></tr>
<tr><td>ចម្ងាយ $a$ (m)</td><td colspan="2">$E_{ពិសោធន៍}$(N/C)</td><td>$E_{ទ្រឹស្ដី}$(N/C)</td></tr>
<tr><td>3.0 m</td><td colspan="2"></td><td></td></tr>
<tr><td colspan="4">% Error =</td></tr>
<tr><td colspan="4">$Q_1 = 1.0\times10^{-9}$ C និង $Q_2 = -1.0\times10^{-9}$ C</td></tr>
</table>

ការគណនាគំរូ

- $E = K\frac{Q}{a^2} =$

- $\vec{E} = \vec{E}_1 + \vec{E}_2$ យើងបាន $E =$

- $\%\text{កម្រិតល្អៀង}(Error) = \left|\frac{\text{តម្លៃតាមទ្រឹស្តី} - \text{តម្លៃតាមពិសោធន៍}}{\text{តម្លៃតាមតទ្រឹស្តី}}\right| \times 100\%$

## ៧. សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើបង្ហាញខ្សែដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកអគ្គិសនីវិជ្ជមានមានរាងជា………………….និងទិសដៅ………………… ចំណែកឯចំណុចបន្ទុកអគ្គិសនីអវិជ្ជមានមានរាងជា………………….និងទិសដៅ……………..។ សំណុំខ្សែដែនអគ្គិសនីច្រើនត្រូវបានគេហៅថា………………………..។

អាំងតង់ស៊ីតេដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកត្រង់ចំណុចមួយនៅជិតបន្ទុកមានតម្លៃ…………..និងនៅឆ្ងាយពីបន្ទុកមានតម្លៃ……………..ជាអនុគមន៍……………………….បង្ហាញដូចក្រាបខាងលើ។ កម្រិតល្អៀងរវាងតម្លៃតាមទ្រឹស្តី និងពិសោធន៍មានតម្លៃ < 5% ។ ដូចនេះទ្រឹស្តីត្រូវបានគាំទ្រដោយពិសោធន៍។

## ៨. ពិភាក្សា

១. ដោយប្រើតារាងទិន្នន័យ និងគណនាទី២ ចូរគូរក្រាបរវាង $E$ ជាអនុគមន៍នៃ $1/a^2$ និងគណនាកម្រិតល្អៀងនៃបន្ទុក។

# ប៉ូតង់ស្យែលអគ្គិសនី

## ១. វត្ថុបំណង៖

- កំណត់ប៉ូតង់ស្យែលអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកត្រង់ចំណុចណាមួយ។ គូរក្រាបប៉ូតង់ ស្យែលអគ្គិសនី( $V$)ត្រង់ចំណុចណាមួយជាអនុគមន៍នៃចម្ងាយ( $a$) ។
- កំណត់កម្រិតល្អៀងរវាងតម្លៃតាមទ្រឹស្តី និងពិសោធន៍។

## ២. ទ្រឹស្តី

កាលពីពិសោធន៍មុនយើងបានសិក្សាដែនអគ្គិសនីរួចហើយ ឥឡូវនេះយើងនឹងសិក្សាប៉ូតង់ស្យែអគ្គិ សនីវិញម្តង។ ប៉ូតង់ស្យែលអគ្គិសនីស្រដៀងគ្នានឹងដែនអគ្គិសនីដែរ ប៉ុន្តែត្រូវគិតតាមតម្លៃពីជគណិត។ គេថាប៉ូតង់ស្យែលអគ្គិសនីចង្អុលបង្ហាញលក្ខណៈនៃដែនអគ្គិសនី។

ដែនអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកមួយឲ្យដោយ៖

$\vec{E} = K\frac{Q}{a^2}\vec{\imath}$ ដែល $\vec{\imath}$ ជាវ៉ិចទ័រឯកតា

ជាម៉ូឌុល $E = K\frac{Q}{a^2}$

ប៉ូតង់ស្យែលអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកមួយឲ្យដោយ៖

$$V = K\frac{Q}{a}$$

បើ $Q > 0$ នោះ $V > 0$

បើ $Q < 0$ នោះ $V < 0$

ដែល $K = 9.0 \times 10^9\ Nm^2/C^2$ ហៅថាថេរគូឡុំ, $Q$ ជាបន្ទុកបង្កើតដែនត្រង់ចំណុចណាមួយ គិតជា (C)

$a$ ជាចម្ងាយពីបន្ទុកបង្កើតដែន( $Q$)ទៅចំណុចបង្កើតប៉ូតង់ស្យែល គិតជា (m), $V$ ជាប៉ូតង់ស្យែលអគ្គិសនីត្រង់ចំណុចណាមួយ គិតជា (V)






$Q > 0$ ប៉ូតង់ស្យែលត្រង់ $M$, $V_M = +K\frac{Q}{a} > 0$ $-Q < 0$ ប៉ូតង់ស្យែលត្រង់ $M$, $V_M = K\left(\frac{-Q}{a}\right) < 0$

ប៉ូតង់ស្យែលអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកច្រើនឲ្យដោយ៖

$$V = V_1 + V_2 + \cdots = \sum_i K\frac{Q_i}{a_i}$$

កម្រិតល្អៀងភាគរយ( %Error )

$$\%\text{កម្រិតល្អៀង} = \left|\frac{\text{តម្លៃតាមទ្រឹស្តី} - \text{តម្លៃតាមពិសោធន៍}}{\text{តម្លៃតាមតទ្រឹស្តី}}\right| \times 100\%$$

## ៣. សំណួរមុនចូលទីពិសោធន៍

១. តើប៉ូតង់ស្យែលអគ្គិសនីជាអ្វី?

២. សរសេររូបមន្តនៃប៉ូតង់ស្យែលអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកអគ្គិសនីវិជ្ជមាន និងបន្ទុកអគ្គិសនីអវិជ្ជមានមួយ។

៣. កំណត់ប៉ូតង់ស្យែលអគ្គិសនីផ្ចិតត្រង់កំពូលត្រីកោណសម័ង្សមួយជ្រុងង $a$ ដែលបង្កើតដោយចំណុចបន្ទុកអគ្គិសនីវិជ្ជមាន( $q$) និងបន្ទុកអគ្គិសនីអវិជ្ជមាន( $-q$)មួយដែលដាក់ត្រង់បាតនៃត្រីកោណ។

៤. ចំណុចបន្ទុកអគ្គិសនីមួយ $q = 25\,\mu C$ ស្ថិតក្នុងខ្យល់។ កំណត់ប៉ូតង់ស្យែលអគ្គិសនីត្រង់ចំណុច $M$ ចម្ងាយ 5.0 cm ពីចំណុចបន្ទុកនេះ។ គេឲ្យ $K = 9.0 \times 10^9$ Nm$^2$/C$^2$ ។

៥. ចំណុចបន្ទុកអគ្គិសនីមួយ $q = -25\,\mu C$ ស្ថិតក្នុងខ្យល់។ កំណត់ប៉ូតង់ស្យែលអគ្គិសនីត្រង់ចំណុច $M$ ចម្ងាយ 1.0 m ពីចំណុចបន្ទុកនេះ។ គេឲ្យ $K = 9.0 \times 10^9$ Nm$^2$/C$^2$ ។

៦. ចំណុចបន្ទុកអគ្គិសនីពីរ $q_1 = 25.0\,\mu C$និង $q_2 = -30\,\mu C$ ស្ថិតក្នុងខ្យល់។ កំណត់ប៉ូតង់ស្យែលអគ្គិសនីផ្ចិតត្រង់ចំណុច $M$ ស្ថិតនៅពាក់កណ្តាលរវាងចំណុចបន្ទុកទាំងពីរ។ ចម្ងាយរវាងចំណុចបន្ទុកទាំងពីរគឺ 2.0 m ។ គេឲ្យ $K = 9.0 \times 10^9$ Nm$^2$/C$^2$ ។

៧. ចំណុចបន្ទុកអគ្គិសនីពីរ $q_1 = q_2 = 1.0\,nC$ ស្ថិតក្នុងខ្យល់ ត្រូវបានដាក់លើកំពូលនៃត្រីកោណសម័ង្ស (*ABC*)មួយដែលមានជ្រុង *a* ។

(ក) កំណត់ប៉ូតង់ស្យែលអគ្គិសនីផ្ទួបត្រង់ចំណុច *C* ដែលគ្មានបន្ទុកអគ្គិសនី។ គេឲ្យ $K = 9.0 \times 10^9$ $Nm^2/C^2$ និង $a = 3.0$ m ។

(ខ) បើតម្លៃប៉ូតង់ស្យែលអគ្គិសនីផ្ទួបតាមពិសោធន៍ត្រង់ *C* ត្រូវបានវាស់ឃើញស្មើនឹង 6.034 V គណនាកម្រិតល្អៀង(ភាគរយ)របស់វា។

៨. ចំណុចបន្ទុកអគ្គិសនីបី $q_1 = q_2 = 1.0\,nC$ និង$q_3 = -1.0\,nC$ ស្ថិតក្នុងខ្យល់ ត្រូវបានដាក់លើកំពូលនៃការេ(*ABCD*)មួយដែលមានជ្រុង *a* ។

(ក) កំណត់ប៉ូតង់ស្យែលអគ្គិសនីផ្ទួបត្រង់ចំណុច *D* ដែលគ្មានបន្ទុកអគ្គិសនី។ គេឲ្យ $K = 9.0 \times 10^9$ $Nm^2/C^2$ និង $a = 3.0$ m ។

(ខ) បើតម្លៃប៉ូតង់ស្យែលអគ្គិសនីផ្ទួបតាមពិសោធន៍ត្រង់ *D* ត្រូវបានវាស់ឃើញស្មើនឹង 2.110 V គណនាកម្រិតល្អៀង(ភាគរយ)របស់វា។

## ៤. តម្រូវការសម្ភារ

Software PHET Simulation ដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក

## ៥. ដំណើរការ

(ក) ចុចពីរដងជាប់គ្នាលើ PHET Simulations លើអេក្រង់នៃកំព្យូទ័របស់អ្នក ពេលនោះវានឹងលេចចេញផ្ទាំងបញ្ជីឈ្មោះពិសោធន៍ដែលរៀបតាមអក្ខរក្រម(Alphabet) ពី A ទៅ Z ។ នៅជ្រុងខាងឆ្វេងមានពាក្យថា Simulations និងខាងក្រោមវាមានពាក្យថា Physics, Chemistry, Biology, Earth Science, Math, … ដែលបញ្ជាក់ថាអ្នកអាចធ្វើពិសោធន៍បានជាមួយ Physics, Chemistry, Biology, Earth Science, Math ។

(ខ) ចុចលើពាក្យថា Physics (រូបវិទ្យា) វានឹងបង្ហាញបញ្ជីពិសោធន៍យ៉ាងច្រើនដែលអ្នកអាចធ្វើពិសោធន៍បានក្រោមទម្រង់ជារូបភាព។ សូមចងចាំថា ពិសោធន៍របស់អ្នកគឺដែនអគ្គិសនី (Charges and Fields)។ ដូចនេះត្រូវយក Charges and Fields ។ ចុចលើពាក្យ Charges and Fields ពេលនោះវានឹងលេចចេញជា File VIDEO ។

(គ) ចុចលើ VIDEO នេះ វានឹងចេញប្រអប់ធំៗបី គឺខាងក្រោមមួយ និងខាងស្តាំពីរ។

- ប្រអប់ធំខាងក្រោមមានៈ
  - + 1 nC មានន័យថាបន្ទុកអគ្គិសនីវិជ្ជមាន 1 nC
  - - 1 nC មានន័យថាបន្ទុកអគ្គិសនីអវិជ្ជមាន -1 nC
  - Sensors មានន័យថាជាឧបករណ៍សម្រាប់វាស់ដែនអគ្គិសនីត្រង់ចំណុចណាមួយដែលចង់ វាស់។
- ប្រអប់ធំខាងស្តាំ និងខាងលើមានៈ
  - Electric Field មានន័យថាបង្ហាញទិសដៅខ្សែដែនអគ្គិសនី ឆ្ងាយពីបន្ទុកខ្សែដែនព្រាលៗ
  - Direction Only មានន័យថាបង្ហាញតែទិសដៅខ្សែដែនអគ្គិសនីប៉ុណ្ណោះ
  - Voltage មានន័យថាតង់ស្យុង វាបង្ហាញព៌ណជុំវិញបន្ទុក។ (+) ព៌ណក្រហម និង (-) ព៌ណខៀវ។
  - Values មានន័យថាបង្ហាញតម្លៃដែនអគ្គិសនីដែលវាស់ដោយប្រើ Sensors និងមុំជាដឺក្រេ។
  - Grid មានន័យថាបង្ហាញក្រឡាការ៉ូដែលជាមាត្រដ្ឋាន 2 ការ៉ូធំត្រូវជា 1 m ។
- ប្រអប់ធំខាងស្តាំ និងខាងក្រោមមានៈ
  - 0.0 V មានន័យថាបង្ហាញបង្ហាញឧបករណ៍វាស់ប៉ូតង់ស្យែលត្រង់ចំណុចណាមួយ
  - ម៉ែត្ររមូ សម្រាប់វាស់ប្រវែងឬចម្ងាយ។

- **ការគណនាប៉ូតង់ស្យែលអគ្គិសនី និងគូរក្រាប**

(ឃ) ដាក់បន្ទុកវិជ្ជមាន +1.0 nC មួយនៅផ្នែកខាងឆ្វេង ។ ប្រើឧបករណ៍វាស់ប៉ូតង់ស្យែល(ដាក់ត្រង់ទីតាំងផ្សេងៗ) និងម៉ែត្រដើម្បីវាស់ប៉ូតង់ស្យែលអគ្គិសនីនិងប្រវែងរៀងគ្នាដូចបង្ហាញក្នុងតារាងទិន្នន័យនិងគណនាទី១។ គូរក្រាប $V$(V) ជាអនុគមន៍ $a$(m) ។

(ឈ) ដំឡើងរូបតាមលំហាត់ទី៧ និង៨ ក្នុងសំណួរមុនចូលទីពិសោធន៍ និងធ្វើពិសោធន៍ម្តងមួយៗ រួចគណនាដែនអគ្គិសនីផ្គួប និងគណនាកម្រិតល្អៀងរបស់វា។ កត់ត្រាទិន្នន័យដាក់ក្នុងតារាងទិន្នន័យនិងគណនាទី២ខាងក្រោម។

## ៦. លទ្ធផល

តារាងទិន្នន័យនិងគណនាទី១

| ចម្ងាយ $a$ (m) | $V_{\text{ពិសោធន៍}}$(V) | $V_{\text{ទ្រឹស្តី}}$(V) |
|---|---|---|
| 0.50 m | | |
| 0.60 m | | |
| 0.70 m | | |
| 0.80 m | | |
| 1.0 m | | |
| 1.5 m | | |
| 2.0 m | | |
| 2.5 m | | |
| 3.0 m | | |
| 3.5 m | | |
| 4.0 m | | |
| $Q = 1.0\times10^{-9}$ C | $K = 9.0\times10^{9}$ Nm$^2$/C$^2$ | |

ក្រាប



តារាងទិន្នន័យនិងគណនាទី2

| ចម្ងាយ $a$ (m) | $V_{ពិសោធន៍}$(V) | $V_{ទ្រឹស្តី}$(V) |
|---|---|---|
| 3.0 m | | |
| % Error = | | |
| $Q_1 = Q_2 = 1.0\times10^{-9}$ C | $K = 9.0\times10^{9}$ Nm$^2$/C$^2$ | |
| | | |
| ចម្ងាយ $a$ (m) | $V_{ពិសោធន៍}$(V) | $V_{ទ្រឹស្តី}$(V) |
| 3.0 m | | |
| % Error = | | |
| $Q_1 = 1.0\times10^{-9}$ C និង $Q_2 = -1.0\times10^{-9}$ C | | |

ការគណនាគំរូ

- $V_1 = K\frac{Q}{a} =$
- $V = V_1 + V_2 =$

$$\%កម្រិតល្អៀង = \left|\frac{តម្លៃតាមទ្រឹស្តី - តម្លៃតាមពិសោធន៍}{តម្លៃតាមតទ្រឹស្តី}\right| \times 100\%$$

## ៧. សន្និដ្ឋាន

តាមលទ្ធផលពិសោធន៍ខាងលើបង្ហាញថាប៉ូតង់ស្យែលអគ្គិសនីដែលបង្កើតដោយចំណុចបន្ទុកត្រង់ចំណុចណាមួយអាចត្រូវបានកំណត់។ ក្រាបនៃប៉ូតង់ស្យែលអគ្គិសនី( $V$)ជាអនុគមន៍នៃចម្ងាយ($a$) មានរាងជា.........................................។ កម្រិតល្អៀងរបស់វារវាងតម្លៃតាមទ្រឹស្តី និងពិសោធន៍ < 5% ។ ដូចនេះ សម្មតិកម្ម(វត្ថុបំណង)ត្រូវបានគាំទ្រដោយពិសោធន៍។

## ៨. ពិភាក្សា

ដោយប្រើតារាងទិន្នន័យនិងគណនាទី១ ចូរធ្វើពិសោធន៍និងគូរក្រាបឡើងវិញចំពោះបន្ទុកអគ្គិសនី-1.0 nC។

# ពិសោធន៍ទី វាស់រេស៊ីស្តង់ និងច្បាប់អូម

## ១. វត្ថុបំណង

- វាស់តង់ស្យុង និងចរន្តអគ្គិសនី ដូច្នេះយើងអាចកំណត់តម្លៃរេស៊ីស្តង់ (មេគុណប្រាប់ទិសនៃបន្ទាត់)តាមរយៈក្រាប។
- គណនាកម្រិតល្អៀង.
- កំណត់រេស៊ីស្តង់សមមូលក្នុងបង្គុំជាស៊េរី និងជាខ្នែង។
- ធ្វើពិសោធន៍ដោយប្រើ Software Proteus ។

## ២. ទ្រឹស្តី

- រេស៊ីស្តង់ និង និមិត្តសញ្ញារបស់វា





- រេស៊ីស្តង់មានន័យថា ទប់ ឬប្រឆាំង។ រេស៊ីស្តង់អគ្គិសនីមានន័យថាជាការប្រឆាំង ឬទប់លំហូរអេឡិចត្រុងដែលហូរ ឆ្លងកាត់ខ្សែចម្លង ឬអង្គធាតុចម្លង។
- រេស៊ីស្តង់បំព្រួញ៖ 560R មានន័យថា 560 Ω

  2K5 មានន័យថា 2.5 k Ω = 2 500 Ω

  45K មានន័យថា 45 k Ω = 45 000 Ω

  2M0 មានន័យថា 2.0 M Ω = 2 000 k Ω = 2 000 000 Ω
- បង្គុំរេស៊ីស្តង់ជាស៊េរី







រេស៊ីស្តង់សមមូល $R_e$

$$R_e = R_1 + R_2 + R_3$$

- បង្គុំរេស៊ីស្តង់ជាខ្នែង






រេស៊ីស្តង់សមមូល $R_e$

$1/R_e = 1/R_1 + 1/R_2 + 1/R_3$

- ចេះប្រើប្រាស់ Software Proteus

$$\% \text{ កម្រិតល្អៀង(Error)} = \left|\frac{\text{តម្លៃតាមទ្រឹស្តី} - \text{តម្លៃតាមពិសោធន៍}}{\text{តម្លៃតាមទ្រឹស្តី}}\right| \times 100\%$$

$$\% \text{ ផលសងភាគរយ (Difference)} = \left|\frac{\text{តម្លៃវង្វាស់តាមវិធីទី}1 - \text{តម្លៃវង្វាស់តាមវិធីទី}2}{(\text{តម្លៃវង្វាស់តាមវិធីទី}1 + \text{វិធីទី}2)/2}\right| \times 100\%$$

## ៣. សំណួរមុនចូលទីពិសោធន៍

១. ដូចម្តេចដែលហៅថារេស៊ីស្តង់, រេស៊ីស្តង់នៃអង្គធាតុចម្លងអូម?

២. គេមានរេស៊ីស្តរពីរដែលរេស៊ីស្តង់ទី១គឺ $R_1 = 22\ \Omega$ និង $R_2 = 33\ \Omega$ ។ តើរេស៊ីស្តង់សមមូល របស់វាមានតម្លៃប៉ុនាន?

ក. បើគេតវាជាស៊េរី

ខ. បើគេតវាជាខ្នែង

៣. គេមានរេស៊ីស្តរបីដែលរេស៊ីស្តង់ $R_1 = 22\ \Omega$, $R_2 = 33\ \Omega$ និង $R_3 = 11\ \Omega$ ។ តើរេស៊ីស្តង់សមមូលរបស់វាមានតម្លៃប៉ុន្មាន?

ក. បើគេតវាជាស៊េរី

ខ. បើគេតវាជាខ្នែង

៤. គេមានរេស៊ីស្តរពីដែលរេស៊ីស្តង់ $R_1$ = 50 Ω,និង $R_2$ = 25 Ω ។ តើរេស៊ីស្តរណាមួយក្តៅជាង បើគេភ្ជាប់វាទៅ នឹងប្រភព 9.0 V និងតវាក្នុងករណី ៖

ក. $R_1$ និង $R_2$ ជាស៊េរី

ខ. $R_1$, និង $R_2$ជាខ្នែង

៤. តម្រូវការសម្ភារ

Software Proteus ដែលដំឡើងរួច និងទាញយករេស៊ីស្តង់ 50.0 Ω, 80.0 Ω, 100 Ω, ប៉ូតង់ស្យូម៉ែត្រ 1kΩ អំពែម៉ែត្រចរន្តជាប់, តង់ស្យុងចរន្តជាប់, ប្រភពចរន្តជាប់ 12 V

## ៦. ដំណើរការ

### ដំឡើងតាមរូបដោយធ្វើពិសោធន៍ជាមួយ $R_1$ $R_2$ និង $R_3$

ម្តងមួយៗរៀងគ្នា។

ពិសោធន៍នេះត្រូវគ្នានឹងតារាងទិន្នន័យ និងតារាងគណនាទី១ និងគូរក្រាប។



- បង្គុំជាស៊េរី (ធ្វើតាមតារាងទិន្នន័យ និងគណនាទី២)




- បង្គុំជាខ្នែង (ធ្វើតាមតារាងទិន្នន័យ និងគណនាទី២)




## ៦. លទ្ធផល

### តារាងទិន្នន័យ និងគណនាទី១

| $I$ (mA) | $V_{R1}$(V) | $V_{R2}$(V) | $V_{R3}$(V) |
|---|---|---|---|
| 0 | 0 | 0 | 0 |
| 20.0 | | | |
| 40.0 | | | |
| 60.0 | | | |
| 79.9 | | | |
| 99.9 | | | |
| 120 | | | |

| | $R_1$(Ω) | $R_2$(Ω) | $R_3$(Ω) |
|---|---|---|---|
| $R_{Exp}$(Ω) | | | |
| $R_{Theo}$(Ω) | | | |
| $R$(Correlation Coefficient) | | | |
| %Error | | | |

### តារាងទិន្នន័យទី២

| | $I$ (mA) | $V$ (V) | $I$ (mA) | $V$ (V) |
|---|---|---|---|---|
| $R_1$ $R_2$ $R_3$ ស៊េរី | 30.0 | | 50.0 | |
| $R_1$ $R_2$ ស៊េរី | 30.0 | | 50.0 | |
| $R_1$ $R_2$ ខ្នែង | 29.9 | | 49.8 | |
| $R_1$ $R_3$ ខ្នែង | 29.0 | | 49.3 | |
| $R_2$ $R_3$ ខ្នែង | 29.7 | | 49.1 | |

តារាងគណនាទី២

| | $(R_e)_{exp}1(\Omega)$ | $(R_e)_{exp}2\ (\Omega)$ | $(\bar{R}_e)_{exp}\ (\Omega)$ | $(R_e)_{theo}1(\Omega)$ | % Diff |
|---|---|---|---|---|---|
| $R_1$ $R_2$ $R_3$ ស៊េរី | | | | | |
| $R_1$ $R_2$ ស៊េរី | | | | | |
| $R_1$ $R_2$ ខ្នែង | | | | | |
| $R_1$ $R_3$ ខ្នែង | | | | | |
| $R_2$ $R_3$ ខ្នែង | | | | | |

ការគណនាគំរូ

$(R_e)_{exp} = V/I =$

$$\% \text{ កម្រិតល្អៀង(Error)} = \left|\frac{\text{តម្លៃតាមទ្រឹស្តី} - \text{តម្លៃតាមពិសោធន៍}}{\text{តម្លៃតាមទ្រឹស្តី}}\right| \times 100\% =$$

(ស៊េរី) $(R_e)_{theo} = R_1 + R_2 + R_3 =$ ..........................

(ខ្នែង) $(R_e)_{theo} = 1/(1/R_1 + 1/R_2) =$ .........................

$$\% \text{ ផលសងភាគរយ (Difference)} = \left|\frac{\text{តម្លៃវង្វាស់តាមវិធីទី}1 - \text{តម្លៃវង្វាស់តាមវិធីទី}2}{\frac{\text{តម្លៃវង្វាស់តាមវិធីទី}1 + \text{វិធីទី}2}{2}}\right| \times 100\%$$









## ៧. សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ កម្រិតល្បឿង(ភាគរយ) និងផលសងល្បឿង(ភាគរយ)មានតម្លៃ ____ និងមេគុណទំនាក់ទំនង $r$ =________________ ។ ដូចនេះ អ្នកអាចសន្និដ្ឋានថា តម្លៃរេស៊ីស្តង់អគ្គិសនី(មេគុណប្រាប់ទិសនៃបន្ទាត់) និងរេស៊ីស្តង់ ក្នុងបង្គុំជាស៊េរី និងជាខ្នែងអាចត្រូវ____________________ ________ហើយ ចរន្ត និងតង់ស្យុងអគ្គិសនីត្រូវបានវាស់តាម ______________________ ______ដោយប្រើនៃកម្មវិធី Proteus។

## ៨. ពិភាក្សា

១. ក្នុងបាតឺរីខាងលើ រេស៊ីស្តង់ក្នុងរបស់វាស្មើនឹង 0.1 Ω ។ បើយើងឲ្យរេស៊ីស្តង់ក្នុងរបស់វាស្មើនឹង 2Ω វិញ តើកម្រិតល្បឿងរបស់វាទៅជាយ៉ាងណា? □ កើនឡើងធំជាងមុន □ ថយចុះតូចជាងមុន □ នៅតែដដែល។ ហេតុអ្វីបានជាអ្នកគិតដូច្នេះ?

# សៀគ្វីស្ពានវីស្តុន

## ១. វត្ថុបំណង

- កំណត់គោលការណ៍អនុវត្តន៍នៃស្ពានវីស្តុនប្រើប៉ូតង់ស្យូម៉ែត្រ និងរេស៊ីស្តង់នៃរេស៊ីស្ទរ

## ២. ទ្រឹស្តី

សៀគ្វីដែលបង្ហាញដូចរូបខាងក្រោមជាសៀគ្វីស្ពានវីស្តុន (រូបទី១ )និងស្ពានវីស្តុនប្រើប៉ូតង់ស្យូម៉ែត្រ(រូបទី២)។ ស្ពានរងលំនឹង កាលណាចរន្តឆ្លងកាត់វ៉ុលម៉ែត្រស្មើសូន្យ ($I_V = 0$) នេះមានន័យថាប៉ូតង់ស្យែលត្រង់ $A$ ($V_A$) ស្មើនឹងប៉ូតង់ស្យែល ត្រង់ $B$ ($V_B$) គេសរសេរ ៖ $V_A = V_B$

ដោយ $V_A = V_B$ នោះ $V_{MA} = V_{MB}$

យើងបាន $R_1 I_1 = R_3 I_2$ និង $R_1 / R_3 = I_2 / I_1$ (1)

$V_{AN} = V_{BN}$ យើងបាន $R_2 I_1 = R_4 I_2$ និង $R_2 / R_4 = I_2 / I_1$ (2)

ពីសមីការ (1) = (2) យើងបាន $R_1 / R_3 = R_2 / R_4$ (3) ឬ $R_1 / R_2 = R_3 / R_4$ (3)

រូបទី១




រូបទី២




ដោយសន្មតថា $R_1 = R_U$ , $R_2 = R_K$ និង $R_3$ , $R_4$ វាស់ដោយប្រើអូមម៉ែត្រ យើងបាន ៖

$$R_U = (R_K \; R_3) / R_4 \quad (4)$$

## ៣. សំណួរមុនពេលធ្វើពិសោធន៍

១.តាមរូបទី១កាលណាចរន្តឆ្លងកាត់វ៉ុលម៉ែត្រស្មើសូន្យ ($I_V = 0$) ចូរបង្ហាញថា $R_1 = R_2 R_3 / R_4$ ។

២. តាមរូបទី២ ចូរបង្ហាញថា $R_U = (R_K \; R_3) / R_4$

៣. តាមរូបទី១ គេឱ្យ $R_2 = 100\ \Omega$, $R_3 = 500\ \Omega$, និង $R_4 = 1000\ \Omega$ ចូរកំណត់ $R_1$ ?

៤. តាមរូបទី២ គេឱ្យ $R_K = 60\ \Omega$, $R_3 = 54\%$នៃប៉ូតង់ស្យូម៉ែត្រដែលមានរេស៊ីស្តង់សរុប 1kΩ ។ ចូរកំណត់ $R_U$ ?

៥. តើរេស៊ីស្តង់បង្ហាញដូចរូបខាងក្រោមមានតម្លៃប៉ុន្មាន?




## ៤. តម្រូវការសម្ភារ

- ស្ពានវីស្តូនប្រើប៉ូតង់ស្យូម៉ែត្រ, ប្រអប់រេស៊ីស្តង់ពី 10 Ω  ទៅ 1000 Ω និងវ៉ុលម៉ែត្រ។

➢ ប្រភពចរន្តជាប់ 1.50 V ឬ  3.00 V,  ខ្សែតភ្ជាប់ និងអូមម៉ែត្រ ។

➢ រេស៊ីស្ទរចំនួនប្រាំដែលមានរេស៊ីស្តង់ចន្លោះពី 10 Ω ទៅ 100 Ω ។

## ៥. ដំណើរការពិសោធ

១. អានតម្លៃរេស៊ីស្តង់ពីកូដពណ៌លើរេស៊ីស្តង់នីមួយៗនៃរេស៊ីស្តង់ទាំងប្រាំដែលជារេស៊ីស្តង់មិនស្គាល់ ( $R_U$ ) និងកត់ត្រា តម្លៃរបស់វាដាក់ក្នុងតារាងទិន្នន័យទី១។ កត់ត្រាតម្លៃដែលតូចជាងគេជា រេស៊ីស្តង់មិនស្គាល់ទី១ (Unknown-1)  និងបន្តបន្ទាប់។

២. កែ ឬមួលតម្រូវតង់ស្យុងទៅតម្លៃប្រហែល 1.5 V ឬ 3.0 V ។ តម្លៃតង់ស្យុងនៃប្រភពត្រូវរក្សាតម្លៃថេរនេះគ្រប់ រង្វាស់ទាំងអស់។ ដោយសាររង្វាស់តង់ស្យុងដែលជ្រើសរើសមានតម្លៃស្មើៗគ្នា នោះចរន្តឆ្លងកាត់រេស៊ីស្ទទាំងអស់ មានតម្លៃតូចដែលបញ្ជាក់ថារេស៊ីស្ទរមិនឡើងកម្តៅទេ។ បើរេស៊ីស្ទរឡើងក្តៅ នោះនឹងនាំឱ្យមានកម្រិតល្អៀង។

៣. ដាក់រេស៊ីស្ទរមិនស្គាល់ទី១(រេស៊ីស្ទរដែលត្រូវវាស់)ក្នុងសៀគ្វីស្ពានវីស្តូនត្រង់ទីតាំងនៃ $R_U$ រូបទី២។ ដាក់រេស៊ីស្តង់ ប្រអប់ត្រង់ទីតាំង $R_K$ រូបទី២ និងជ្រើសរើសតម្លៃ $R_K$ សឹងតែស្មើ ឬធំជាង $R_U$ ពីរដង។ កត់ត្រាតម្លៃ $R_K$ ដាក់ក្នុង តារាងទិន្នន័យទី១។ តម្លៃ $R_K$ ត្រូវថែមមួយតួលេខទៀតពីក្រោយតួលេខចុងក្រោយរបស់រេស៊ីស្តង់ប្រអប់ ព្រោះ ភាពមិនជាក់លាក់មិនស្ថិតត្រង់តួលេខចុងក្រោយនៃរេស៊ីស្តង់ប្រអប់ទេ។ ឧទាហរណ៍ បើរេស៊ីស្តង់ប្រអប់ត្រូវបាន ជ្រើសរើសត្រង់តម្លៃ 153Ω  នោះត្រូវសរសេរជា 153.0 Ω វិញ ព្រោះតួលេខមិនជាក់លាក់មិនមែនជាតួលេខ 3 នោះទេ។

៤. រំកិលកូនបូត $B$ ហូតដល់ទ្រនិចវ៉ុលម៉ែត្រមានលំនឹង( ចង្អុលលេខតូចជាងគេបំផុត )មានន័យថា គ្មានចរន្តឆ្លងកាត់វ៉ុលម៉ែត្រ។

៥. កត់ត្រាតម្លៃ $R_3$ និង $R_4$ ដាក់ក្នុងតារាងទិន្នន័យទី១។ ឧទាហរណ៍ $R_3$ = 54% នៃ 1kΩ យើងបាន $R_3$ = 540 Ω
និង $R_3$ = 460 Ω ។
៦. ដោយប្រើរេស៊ីស្តរមិនស្គាល់ដដែល (រេស៊ីស្តង់ដែលវាស់អំបាញ់មិញ)ចូរធ្វើពីជំហានទី៣.ដល់ទី៥ឡើងវិញនូវតម្លៃ $R_K$ ដែលធំ និងតូចជាងតម្លៃ $R_K$ ដើមប្រហែល 10% ។
៧. ចូរធ្វើពីជំហានទី៣.ដល់ទី៦ឡើងវិញចំពោះតម្លៃនៃរេស៊ីស្តរដែលមិនស្គាល់ផ្សេងៗទៀត។
៨. (ដោយប្រើអូមម៉ែត្រ) អាន/វាស់តម្លៃរេស៊ីស្តង់នៃរេស៊ីស្តរដែលមិនស្គាល់ទាំងប្រាំ និងកត់ត្រាទិន្នន័យរបស់វាដាក់ក្នុងតារាង ទិន្នន័យទី២។

- ដំបូន្មានក្នុងការគណនា

១. គណនា និងកត់ត្រាតម្លៃរង្វាស់ទាំងបីនៃរេស៊ីស្តរមិនស្គាល់នីមួយៗ និងធ្វើទាំងប្រាំដាក់ក្នុងតារាងគណនា

២. គណនា និងកត់ត្រាតម្លៃមធ្យម និងកម្រិតល្អៀងស្តង់ដា (Standard error) ចំពោះតម្លៃរង្វាស់ទាំងបីនៃតម្លៃរបស់រេស៊ីស្តរមិនស្គាល់នីមួយៗ និងទាំងប្រាំក្នុងតារាង។ ចូរគណនាលំងាកស្តង់ដា (Standard deviation) និងកម្រិតល្អៀងភាគរយ។

## ៦. **លទ្ធផល**

តារាងទិន្នន័យទី១ (រេស៊ីស្តង់ប៉ូតង់ស្យូម៉ែត្រ 1kΩ )

| | $R_K$ (Ω) | $R_3$ (Ω) | $R_4$ (Ω) |
|---|---|---|---|
| រេស៊ីស្តង់មិនស្គាល់ទី១ ( 100 Ω) | 90 | | |
| | 100 | | |
| | 110 | | |
| រេស៊ីស្តង់មិនស្គាល់ទី២ (200 ▯ ) | 190 | | |
| | 200 | | |
| | 210 | | |
| រេស៊ីស្តង់មិនស្គាល់ទី៣ (500▯▯ ) | 480 | | |
| | 500 | | |
| | 520 | | |
| រេស៊ីស្តង់មិនស្គាល់ទី៤ ( ▯ ) | 950 | | |
| | 1000 | | |
| | 1050 | | |
| រេស៊ីស្តង់មិនស្គាល់ទី៥ ( 1500 ▯ ) | 1450 | | |
| | 1500 | | |
| | 1550 | | |

តារាងគណនាទី១

| $R_U$ (Ω) | $\bar{R}_U$ (Ω) | $\alpha(R_U)$ (Ω) |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

➢ **ការគណនាគំរូ**

- $R_3$ = %( 1kΩ ) = Ω, $R_4$ = Ω,
- $R_U = ( R_K R_3 ) / R_4$
- % Error =

$$\delta_{n-1} = \sqrt{\frac{1}{n-1}\sum(x_i - \bar{x}_i)^2}$$

- $\alpha( R_U ) = \frac{\delta_{n-1}}{\sqrt{n}}$

១. គណនាកម្រិតល្អៀង(ភាគរយ)នៃរេស៊ីស្តង់នីមួយៗរបស់រេស៊ីស្តរមិនស្គាល់ទាំងប្រាំដែលវាស់ដោយប្រើស្ពានវីស្តុន ទៅនឹងតម្លៃរបស់វាដែលអានតាមកូដពណ៌ដោយសន្មតថាតម្លៃនៃកូដពណ៌ត្រឹមត្រូវ។ ចូរពោលពីភាពជាក់លាក់ (Precision) នៃរេស៊ីស្តរដោយផ្អែកលើកូដពណ៌របស់វា។

1- %កម្រិតល្អៀង =______ 2- %កម្រិតល្អៀង =______ 3- %កម្រិតល្អៀង =______
4- %កម្រិតល្អៀង =______ 5- %កម្រិតល្អៀង =______

២. គណនាកម្រិតល្អៀង(ភាគរយ)នៃរេស៊ីស្តង់នីមួយៗរបស់រេស៊ីស្តរមិនស្គាល់ទាំងប្រាំដែលវាស់ដោយប្រើស្ពានវីស្តុន ទៅនឹងតម្លៃរបស់វាដែលវាស់ដោយអូមម៉ែត្រក្នុងតារាងទិន្នន័យទី២ដោយសន្មតថាតម្លៃក្នុងតារាងត្រឹមត្រូវ។ ចំពោះ រេស៊ីស្តរនីមួយៗ តើកម្រិតល្អៀងតាមកូដពណ៌ និងតាមការវាស់ណាមួយប្រសើរជាង។

1- %កម្រិតល្អៀង =______ 2- %កម្រិតល្អៀង =______ 3- %កម្រិតល្អៀង =______
4- %កម្រិតល្អៀង =______ 5- %កម្រិតល្អៀង =______ ភាពជាកើលាក់ =______.

៣. គណនាកម្រិតល្អៀងស្តង់ដា (Standard error) នីមួយៗរបស់វា

1- កម្រិតល្អៀងស្តង់ដា = ______. 2- កម្រិតល្អៀងស្តង់ដា =______.
3- កម្រិតល្អៀងស្តង់ដា =______. 4- កម្រិតល្អៀងស្តង់ដា = ______.
5- កម្រិតល្អៀងស្តង់ដា =______.

## ៧. សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ កម្រិតល្អៀង(ភាគរយ)និងល្អៀងស្តង់ដានៃរេស៊ីស្តង់នីមួយៗតូចជាង 5% និងតម្លៃ រវាងទ្រឹស្តី និងពិសោធន៍សឹងតែ ____________________។ ដូចនេះដោយប្រើស្ពានវីស្តុន អ្នកអាចសន្និដ្ឋានបានថា តម្លៃ នៃរេស៊ីស្តងមិនស្គាល់អាចត្រូវបានវាស់ ________________________។

## ៨. សំណួរពិភាក្សា

១. ដើម្បីទទួលបានលទ្ធផលពិសោធន៍ល្អ តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ?

២. តើអ្នកមានគំនិតអ្វីខ្លះ ដើម្បីកែលំអពិសោធន៍នេះឲ្យកាន់តែប្រសើរឡើង?

# ច្បាប់គៀរឆូប

១. វត្ថុបំណង

- កំណត់ថាតើសៀគ្វីបែបណាដែលអាចអនុវត្តន៍ច្បាប់គៀ ឆូបបាន។
- អនុវត្តន៍ច្បាប់គៀ ឆូបដើម្បីទាញរកចរន្តអគ្គិសនី និងកំណត់កម្រិតល្បឿង(ភាគរយ)របស់វា។

២. ទ្រឹស្តី

ច្បាប់គៀ ឆូបអនុវត្តចំពោះសៀគ្វីស្មុគស្មាញ។ សៀគ្វីស្មុគស្មាញជាសៀគ្វីដែលមិនអាចបង្រួមបាន។ ចំណែកសៀគ្វីងាយ យើងមិនប្រើច្បាប់គៀ ឆូបទេ គឺយើងប្រើតែច្បាប់អូម ប៉ុណ្ណោះ។



សៀគ្វីងាយ



សៀគ្វីស្មុគស្មាញ

- ច្បាប់គៀ ឆូបចំពោះចរន្ត(KCL)

  ផលបូកចរន្តចូលថ្នាំង = ផលបូកចរន្តចេញពីថ្នាំង

  ចំពោះថ្នាំង A $\quad I_1 = I_2 + I_3 \quad (1)$

- ច្បាប់គៀ ឆូបចំពោះតង់ស្យុង(KVL)

ផលបូកពីជគណិតនៃតង់ស្យុងជុំវិញវង់ឬខ្សែបិទ = 0

ចំពោះវង់ (1) $\quad -R_2 I_1 + \varepsilon_1 - R_1 I_1 + \varepsilon_2 - R_3 I_2 = 0$ or $-30 I_1 + 6 - 20 I_1 + 12 - 50 I_2 = 0$

(2)

ចំពោះវង់ (2)   $R_3 I_2 - \varepsilon_2 - R_4 I_3 = 0$ or $-50 I_2 - 12 - 100 I_3 = 0$ (3)

ពីសមីការ(1), (2) និង (3) យើងទាញរក $I_1, I_2$ និង $I_3$ ។

ដូចនេះយើងបាន $I_1 = 168\text{mA}$, $I_2 = 192\text{mA}$, $I_3 = 24.0\text{mA}$ .

៣. សំណួរមុនពេលធ្វើពិសោធន៍

១. ពិនិត្យសៀគ្វីបង្ហាញដូចខាងក្រោម ។ ចូរជ្រើសរើសពំនោលខាងក្រោមដែលត្រឹមត្រូវ។ ពំនោលដែលត្រឹមត្រូវអាចមាន ច្រើនជាងមួយ។ ក. វាជាសៀគ្វីងាយមួយ   ខ. វាជាសៀគ្វីស្មុគស្មាញ
គ. ស្គាល់រេស៊ីស្តរ និងតង់ស្យុងទាំង អស់, ចរន្តអាចត្រូវបានគណនាដោយប្រើតែច្បាប់គៀធុប។
ឃ. ស្គាល់រេស៊ីស្តរ និងតង់ស្យុងទាំងអស់, ចរន្ត អាចត្រូវបានគណនាដោយមិនប្រើច្បាប់គៀធុប។




២. តើរេស៊ីស្តង់សមមូលនៃសៀគ្វីបង្ហាញដូចរូបក្នុងសំណួរទី១ មានតម្លៃប៉ុន្មាន?

៣. តើចរន្តអគ្គិសនីដែលឆ្លងកាត់រេស៊ីស្តរនីមួយៗនៃសៀគ្វីបង្ហាញដូចរូបក្នុងសំណួរទី១ មានតម្លៃប៉ុន្មាន?

៤. ពិនិត្យសៀគ្វីបង្ហាញដូចខាងក្រោម ។ អនុវត្តច្បាប់គៀធុប ចំពោះសៀគ្វី ចូរសរសេរសមីការទាំងបីក្នុងករណីស្គាល់ធាតុនៃសៀគ្វី និងមិនស្គាល់ចរន្តបង្ហាញដូចរូបខាងក្រោម ៖




៥.តើចរន្តឆ្លងកាត់រេស៊ីស្តរនីមួយៗបង្ហាញដូចរូបទី៤ មានប៉ុន្មាន បើសន្មតថារេស៊ីស្តង់ក្នុងនៃថ្មពិល $r_1$ និង $r_2$ ស្មើសូន្យ?

៦. តើចរន្តឆ្លងកាត់រេស៊ីស្តរនីមួយៗបង្ហាញដូចរូបទី៤ មានប៉ុន្មាន បើសន្មតថារេស៊ីស្តង់ក្នុងនៃថ្មពិល $r_1 = 7.6$ Ω និង $r_2 = 3.8$?

៤. តម្រូវការសម្ភារ (សម្ភារខាងក្រោមនេះគឺសម្រាប់អនុវត្តជាក់ស្តែង)

- វ៉ុលម៉ែត្រចរន្តជាប់ (digital, 0-12 V),
- អំពែម៉ែត្រចរន្តជាប់១(digital, 0-400 mA) (អ្នកអាចប្រើតែម៉ុលទីម៉ែត្រលេខ១ព្រោះវាមានវ៉ុលម៉ែត្រ អំពែម៉ែត្រ និងអូមម៉ែត្រ។ រង្វាស់តង់ស្យុង និងចរន្តមានរហូតដល់ 400 V និង 400 mA រៀងគ្នា)
- ប្រភពកម្លាំងអគ្គិសនីចលករ (emf) ពីរ (ថ្មពិល៦, 1.5 V×4 = 6.0V ជាប្រភពមួយ, និង 1.5V×2 = 3.0 V ជាប្រភពមួយទៀត)
- រេស៊ីស្តរបួន ឬប្រអប់រេស៊ីស្តង់ ($R_1$ = 50.0 Ω, $R_2$ = 75.0Ω, $R_3$ = $R_4$ = 100.0 Ω)
- អូមម៉ែត្រលេខ, ខ្សែចម្លងដែលមានក្រចាប់ ឬដង្កៀប, បន្ទះសៀគ្វី និងប្រអប់ដាក់ថ្មពិល។

៥. ដំណើរការពិសោធន៍

១. ដោយជ្រើសរើសរេស៊ីស្តង់ស្តង់ដា ចូរជ្រើសរើសតម្លៃ $R_1$ = 50.0 Ω, $R_2$ = 75.0 Ω និង $R_3$ = 100 Ω ប្រើអូមម៉ែត្រ ដើម្បីវាស់តម្លៃរេស៊ីស្តរនីមួយៗ ឬអ្នកអាចអានកូដពណ៌របស់វាក៏បាន។ កត់ត្រាតម្លៃទាំងនោះចូលក្នុងតារាងទិន្នន័យទី១។

២. ដោយប្រើប្រភពតង់ស្យុងពីរដែល $_1$ = 6.0 V និង $_2$ = 3.0 V និងរេស៊ីស្តរ $R_1$, $R_2$, និង $R_3$ ដំឡើងសៀគ្វីបង្ហាញ ដូចរូប(ក)ខាងក្រោម។

៣. វាស់ចរន្ត $I_1$, $I_2$, និង $I_3$។ សន្មតថាអំពែម៉ែត្រមានតែមួយ ដូច្នេះយើងត្រូវវាស់ចរន្តម្តងមួយៗដោយដាក់វាត្រង់ទីតាំង បង្ហាញដូចក្នុងរូប។ ដាក់អំពែម៉ែត្រឱ្យត្រូវប៉ូលដូចបង្ហាញក្នុងដ្យាក្រាមនៃសៀគ្វី វានឹងផ្តល់អំណានវិជ្ជមានកាលណាចរន្ត រត់តាមទិសដៅសន្មត។ បើប្រើអំពែម៉ែត្រលេខទំនើបដើម្បីវាស់ចរន្ត នោះអំពែម៉ែត្រនឹងផ្តល់អំណានវិជ្ជមានកាលណាចរន្ត រត់តាមទិសដៅសន្មត និងផ្តល់អំណានអវិជ្ជមានកាលណាចរន្តរត់តាមទិសដៅផ្ទុយ។ បើអំពែម៉ែត្រដែលប្រើងាកតែតាមទិសដៅមួយ អំពែម៉ែត្រនឹងធេះខូចបើចរន្តរត់តាមទិសដៅផ្ទុយពីទិសដៅដែលបានសន្មត។ ក្នុងករណីនេះដំឡើងតង់ស្យុង ប្រភពបន្តិចម្តងៗដើម្បីឃើញថាអំពែម៉ែត្រងាកតាមទិសដៅត្រឹមត្រូវ ឬអ្នកត្រូវគណនាតម្លៃចរន្ត $I_1$, $I_2$, និង $I_3$ តាមទ្រឹស្តី ជាមុនក្នុងគោលបំណងដើម្បី
ដឹងពីទិសដៅពិតនៃចរន្តដែលឆ្លងកាត់ជាតុនៃសៀគ្វី។

៤. វាស់ emf $_1$ និង $_2$ ដោយប្រើវ៉ុលម៉ែត្រ និងកត់ត្រាតម្លៃរបស់វាចូលក្នុងតារាងទិន្នន័យទី១។ តង់ស្យុងគោលនៃប្រភព ត្រូវបានសន្មតថាជា emf ។

៥. ដំឡើងសៀគ្វីដូចបង្ហាញដូច(ខ)ខាងក្រោមដែលមានប្រភពតង់ស្យុងពីរដែរ ប៉ុន្តែមានរេស៊ីស្តរបួន។ ជ្រើសរើសតម្លៃ $\varepsilon_1$ = 3.13V , $\varepsilon_2$ = 6.27V, $R_1$ = 49.2Ω, $R_2$ = 75.3 Ω, $R_3$ = 100.0 Ω, និង
$R_4$= 99.6 Ω, ឬតម្លៃផ្សេងទៀតដែលគៀកទៅ នឹងតម្លៃទាំងនោះ។ កំណត់ និងកត់ត្រាតម្លៃរេស៊ីស្តរ ចរន្តទាំងបួន និង emf ចូលក្នុងតារាងទិន្នន័យទី២។







រូប(ក) សៀគ្វីស្មុគស្មាញដែលមានចរន្តបីជាអញ្ញាត្តិ    រូប(ខ) សៀគ្វីស្មុគស្មាញដែលមានចរន្តបួនជាអញ្ញាត្តិ

➢ ដំបូន្មានក្នុងការគណនា (**ADVICES FOR CALCULATIONS**)

១. អនុវត្តច្បាប់គៀធុបចំពោះសៀគ្វីដូចបង្ហាញក្នុងរូប(ក) សម្រាប់តម្លៃពិតដែលប្រើក្នុងសៀគ្វី។ មានសមីការបីដែលមានចរន្ត $I_1$, $I_2$, និង $I_3$ ។ សមីការមួយគឺជាសមីការ KCR និងសមីការពីរទៀតគឺជា KVR ។ កត់ត្រាសមីការទាំងបីនេះ ចូលក្នុងតារាងគណនាទី១។

២. ដោះស្រាយសមីការទាំងបីនេះដើម្បីទាញរក $I_1$, $I_2$, និង $I_3$ និងកត់ត្រាតម្លៃនេះក្នុងតារាងគណនាទី១។

៣. គណនាកម្រិតល្អៀងរបស់ចរន្តនៃតម្លៃតាមទ្រឹស្តី និងពិសោធន៍ និងកត់ត្រាចូលក្នុងតារាងគណនាទី១

៤. អនុវត្តច្បាប់គៀធុបក្នុងរូប(ខ)ដោយប្រើតម្លៃផ្ទាល់ក្នុងសៀគ្វី។ មានសមីការបួនដែលមានចរន្តបួន $I_1$, $I_2$, $I_3$, និង $I_4$ ។ សមីការមួយគឺជាសមីការ KCR និងសមីការបីទៀតគឺជា KVR ។ កត់ត្រាសមីការទាំងបីនេះ ចូល ក្នុងតារាងគណនាទី២។

៥. ដោះស្រាយសមីការទាំងបួននេះដើម្បីទាញរក $I_1$, $I_2$, $I_3$ និង $I_4$ និងកត់ត្រាតម្លៃនេះក្នុងតារាងគណនាទី២

៦. គណនាកម្រិតល្អៀងរបស់ចរន្តនៃតម្លៃតាមទ្រឹស្តី និងពិសោធន៍ និងកត់ត្រាចូលក្នុងតារាងគណនាទី២

៦. លទ្ធផល

តារាងទិន្នន័យទី១

| តង់ស្យុងប្រភពជា emf<br>$\varepsilon_1$ = ____________V<br><br>$\varepsilon_2$ = ____________V | |
|---|---|
| តម្លៃរេស៊ីស្តង់ (Ω) | តម្លៃចរន្តពិសោធន៍ (mA) |
| $R_1$ = | $I_1$ = |
| $R_2$ = | $I_2$ = |
| $R_3$ = | $I_3$ = |

តារាងគណនាទី១

| ច្បាប់គៀឆុបចំពោះសៀគ្វី<br>**(1) KCL:**<br>**(2) KVL1:**<br>**(3) KVL2:** | |
|---|---|
| តម្លៃចរន្តតាមទ្រឹស្តី (mA) | %Error |
| $I_1$ = | |
| $I_2$ = | |
| $I_3$ = | |

| តារាងទិន្នន័យទី២<br>តង់ស្យុងប្រភពជា emf<br>$\varepsilon_1$ = ____________V<br><br>$\varepsilon_2$ = ____________V | |
|---|---|
| តម្លៃរេស៊ីស្តង់ (Ω) | តម្លៃចរន្តពិសោធន៍ (mA) |
| $R_1$ = | $I_1$ = |
| $R_2$ = | $I_2$ = |
| $R_3$ = | $I_3$ = |
| $R_4$ = | $I_4$ = |

តារាងគណនាទី២

| ច្បាប់គៀឆុបចំពោះសៀគ្វី<br>**(1) KCL:**<br>**(2) KVL1:**<br>**(3) KVL2:**<br>**(4) KVL3:** | |
|---|---|
| តម្លៃចរន្តតាមទ្រឹស្តី (mA) | %Error |
| $I_1$ = | |
| $I_2$ = | |
| $I_3$ = | |
| $I_4$ = | |

➢ ការគណនាគំរូ

- KCR, KVR1, និង KVR2 សរសេរសមីការបីដើម្បីដោះស្រាយរកចរន្ត $I_1$, $I_2$, និង $I_3$។

……………………………………………………………………………………………………………….

………………………………………………………………………………………………………….

- KCL, KVL1, KVL2, និង KVL3 សរសេរសមីការបីដើម្បីដោះស្រាយរកចរន្ត $I_1$, $I_2$, $I_3$, និង $I_4$

……………………………………………………………………………………………………………………

…………………………………………………………………………………………………………………

## ៧. សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ កម្រិតល្អៀងគឺ........, និងកម្រិតល្អៀងនេះតិចជាង 5%។ ដូចនេះដោយប្រើសម្ភារពិសោធន៍ខាងលើ អ្នកអាចសន្និដ្ឋានបានថាតម្លៃចរន្តតាមពិសោធន៍គឺ………។

## ៨. សំណួរពិភាក្សា

១. តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលលើកម្រិតល្អៀងនៃពិសោធន៍?

២. តើកម្រិតល្អៀងរបស់វានឹងទៅជាយ៉ាងណា (កើនឡើង នៅដដែល ឬថយចុះ) បើយើងគិតរេស៊ីស្តង់ក្នុងរបស់បាតឺរី ដោយសន្មតថារេស៊ីស្តង់ក្នុងរបស់បាតឺរីនីមួយៗគឺ $r_1 = r_2 = 2.00\ \Omega$ ។

# វាស់កម្លាំងអគ្គិសនីចលករនៃថ្មពិលដោយប្រើប៉ូតង់ស្យូម៉ែត្រ និងវ៉ុលម៉ែត្រ

## ១. វត្ថុបំណង

- កំណត់គោលការណ៍ដំណើរការនៃប៉ូតង់ស្យូម៉ែត្រ។
- ប្រៀបធៀប emf របស់ថ្មពិលដែលវាស់ដោយប៉ូតង់ស្យូម៉ែត្រ និងវាស់ដោយវ៉ុលម៉ែត្រ។
- កំណត់រេស៊ីស្តង់ក្នុងរបស់ថ្មពិល។

## ២. ទ្រឹស្តី

- ផ្នែកទី១ ៖ លក្ខណៈនៃថ្មពិល

ថ្មពិលថ្មីមានកម្លាំងអគ្គិសនីចលករ (e) រវាងពី 1.50 V ទៅ 1.60 V និងមានរេស៊ីស្តង់ក្នុង( Ri )ប្រហែលពីរ ឬបីអូម។ តង់ស្យុងរវាងគោលនៃថ្មពិលដែលបញ្ចេញចរន្ត $I$ គឺតាងដោយ $V$

$$V = e - IR_i \quad (1)$$




កាលណាមានចរន្តឆ្លងកាត់ខ្សែចម្លង $V < e$ ។ ប៉ុន្តែកាលណាគ្មានចរន្តឆ្លងកាត់ខ្សែចម្លង(សៀគ្វីចំហ), ( $I = 0$ ) នោះ V = e ។ គេតរេស៊ីស្តរ( $R_L$ )មួយរវាងគោលនៃថ្មពិល បង្ហាញដូចរូបខាងស្តាំ ចរន្តដែលបញ្ចេញដោយថ្មពិល៖

$I = e / (R_i + R_L)$ ។

តង់ស្យុងរវាងគោលនៃថ្មពិលគឺ $V = (e R_L)/(R_i + R_L) \quad (2)$

ថ្មពិលចាស់ កម្លាំងអគ្គិសនីចលករ( $e$ )ថយចុះ និងរេស៊ីស្តង់ក្នុង( $R_i$ )របស់វាកើនឡើង។ ឧទាហរណ៍ ថ្មពិលចាស់មួយមាន $e = 1.30$V និងរេស៊ីស្តង់ក្នុង ( $R_i$ ) ≅ 2000Ω ~ 3000Ω ។ កាលណា $R_i$ កាន់តែធំមានន័យថាមានចរន្តបញ្ចេញពីថ្ម បណ្តាលឱ្យមានទន្លាក់តង់ស្យុងកើតឡើងរវាងគោលនៃរេស៊ីស្តង់។ ជាលទ្ធផល តង់ស្យុង ( $V$ ) រវាងគោលនៃថ្មពិលមានតម្លៃយ៉ាងតូច និងថ្មពិលលែងដំណើរការ។

- **ផ្នែកទី២ ៖ វង្វាស់វ៉ុលម៉ែត្រ (Voltmeter Measurement)**

ប្រើវ៉ុលម៉ែត្រដើម្បីវាស់តង់ស្យុងនៃគោលថ្មពិល រេស៊ីស្តង់របស់វ៉ុលម៉ែត្រ( $R_V$ )ជារេស៊ីស្តង់របស់រេស៊ីស្តរបន្ទុក ( $R_L$ )។ តង់ស្យុង( $V$ )ដែលវាស់ដោយវ៉ុលម៉ែត្រគឺដូចគ្នានឹងសមីការ (2) ដែល $R_L$ ត្រូវជំនួសដោយ $R_V$ (រេស៊ីស្តង់របស់វ៉ុលម៉ែត្រ)។

សមីការឱ្យដោយ $V = (e R_V)/(R_i + R_V) \quad (3)$

តម្លៃនៃ $R_V$ អាស្រ័យយ៉ាងខ្លាំងលើគុណភាពនៃវ៉ុលម៉ែត្រ។ វ៉ុលម៉ែត្រដែលសិស្សប្រើក្នុងមន្ទីពិសោធន៍មានតម្លៃប្រហែល 3000 Ω ។ បើវ៉ុលម៉ែត្របែបនេះត្រូវបានប្រើដើម្បីវាស់តង់ស្យុងគោលនៃថ្មពិលថ្មី ដែលមានរេស៊ីស្តង់ក្នុង $R_i$ ស្មើ 1.0 Ω ពេលនោះតង់ស្យុងគោល ( $V$)

$V$ = ( 3000 $e$ /3001 ) = 0.9997 នៃ emf

ម្យ៉ាងវិញទៀត បើវ៉ុលម៉ែត្រដដែលនេះត្រូវបានប្រើដើម្បីវាស់តង់ស្យុងគោលនៃថ្មពិលដែលមានរេស៊ីស្តង់ក្នុង $R_i$ = 5000 Ω នោះតង់ស្យុងគោលគឺ $V'$ = ( 3000 e /8000 ) = 0.375 នៃ emf ។ តម្លៃ $R_V$ នៃវ៉ុលម៉ែត្រទំនើបដែលមានគុណភាពខ្ពស់ស្ថិតក្នុងលំដាប់ពី 10 MΩ ទៅ 20 MΩ ។ បើប្រើវ៉ុលម៉ែត្រប្រភេទនេះវាស់តង់ស្យុងនៃគោលថ្មពិលខាងលើ តម្លៃរបស់វាខិតទៅជិត ឬសឹងតែស្មើនឹងតម្លៃនៃ emf ។

### ❖ ផ្នែកទី៣ ៖ រង្វាស់ដោយប្រើប៉ូតង់ស្យូម៉ែត្រងាយ




ប៉ូតង់ស្យូម៉ែត្រមួយបង្ហាញដូចរូបខាងស្តាំ ជាឧបករណ៍មួយដែលប្រើដើម្បីប្រៀបធៀបតម្លៃនៃប្រភព emf ដែលស្គាល់( $e_K$)ទៅនឹង emf ដែលមិនស្គាល់ ( $e_U$) ។ គេដាក់ ( $e_U$) ក្នុងសៀគ្វីដែលឈមគ្នានឹង ( $e_K$) ហើយ ( $e_U$) នេះមានលំនឹង នឹងផលសងប៉ូតង់ស្យែលដែលស្គាល់ កាលណាគ្មានចរន្តក្នុង emf ដែលមិន ស្គាល់។ emf ពិតត្រូវបានកំណត់ដោយសារគ្មាន ទន្លាក់តង់ស្យុងឆ្លងកាត់រេស៊ីស្តង់ក្នុង។ កុងតាក់ $SW_1$ អាចឱ្យកម្លាំងអគ្គិសនីចលករនៃ ថ្មពិល $e_S$ ឬ $e_U$ តជាខ្សែងជាមួយនឹងប៉ូតង់ស្យូម៉ែត្រ ។ ថ្មពិលដែលមានកម្លាំងអគ្គិសនីចលករ $e_S$ ជាថ្មពិលស្តង់ដា (Standard cell ) ដែល emf របស់វាត្រូវបានគេស្គាល់ច្បាស់ និង $e_U$ តាងឱ្យកម្លាំងអគ្គិសនីចលករមិនស្គាល់ដែលយើង ត្រូវវាស់។ ចរន្តអគ្គិសនីក្នុងប៉ូតង់ស្យូម៉ែត្រត្រូវជ្រើសរើសឱ្យធំគ្រប់គ្រាន់ដើម្បីទទួលបានបម្រែបម្រួលប៉ូតង់ស្យែលពី $A$ ទៅ $B$ ធំជាង $e_U$ ឬ $e_S$ ។ ជាមួយនឹងកុងតាក់ $SW_1$ បិទ ដូចនេះ $e_S$ ស្ថិតនៅក្នុងសៀគ្វី កូនបូតអាចត្រូវបានរំកិលតាមបណ្តោយ ខ្សែរហូត ដល់ចំណុច $C$ ដែលជាទីតាំងដែលទន្លាក់តង់ស្យុងពី $A$ ទៅ $C$ ស្មើគ្នានឹង $e_S$ ។ រេស៊ីស្តង់ដែលត្រូវគ្នាគឺ $R_1$។ រកចំណុចទីតាំង $C$ ដែលគ្មានចរន្តឆ្លងកាត់កាល់វ៉ាណូម៉ែត្រដែលតជាស៊េរីជាមួយនឹង $e_S$។ ដោយដាក់កុងតាក់ $SW_1$មកទីតាំងមួយទៀតដែលមាន $e_U$ នៅក្នុងសៀគ្វី រកចំណុច $D$ មួយថ្មីទៀតដែលទន្លាក់តង់ស្យុងពី $A$ ទៅ $D$ ស្មើនឹង $e_U$ ។ រេស៊ីស្តង់ដែលត្រូវគ្នាគឺ $R_1$។ ចំណុចនេះត្រូវបានរកឃើញតាម

ពិសោធន៍ ហើយក៏ជាចំណុចដែលគ្មានចរន្តឆ្លងកាត់កាល់វ៉ាណូម៉ែត្រដែរ។ ដោយសារទន្លាក់តង់ស្យុងតាមបណ្ដោយខ្សែសមាមាត្រទៅនឹងរេស៊ីស្តង់ ដូចនេះទំនាក់ទំនងរវាងកម្លាំងអគ្គិសនីចលករ និង រេស៊ីស្តង់ គឺ

$$e_U = e_S R'_1 / R_1 \qquad (4)$$

❖ រង្វាស់រេស៊ីស្តង់ក្នុងនៃថ្មពិល

ធ្វើតាមតារាងទិន្នន័យពិសោធន៍ទី៣ ក្នុងរបាយការណ៍ពិសោធន៍នៅចំណុចទី៦។




## ៣. សំណួរមុនពេលធ្វើពិសោធន៍

១. ជាធម្មតាចំពោះថ្មពិលថ្មី តើកម្លាំងអគ្គិសនីចលករ និងរេស៊ីស្តង់ក្នុងរបស់វាមានតម្លៃប្រហែលប៉ុន្មាន? និងចំពោះថ្មពិលចាស់ តើកម្លាំងអគ្គិសនីចលករ និងរេស៊ីស្តង់ក្នុងរបស់វាមានតម្លៃប្រហែលប៉ុនាន?

២. ថ្មពិលមួយមានកម្លាំងអគ្គិសនីចលករ 1.54 V និងរេស៊ីស្តង់ក្នុង 1.90 V។ តើតង់ស្យុងគោលរបស់វាមានតម្លៃប៉ុន្មាន? បើវាត្រូវបានភ្ជាប់ទៅនឹងរេស៊ីស្តង់ 15.3$\Omega$។ បង្ហាញការគណនារបស់អ្នក។

៣. វ៉ុលម៉ែត្រមួយមានរេស៊ីស្តង់ធំ 10 MW ត្រូវបានប្រើដើម្បីវាស់តង់ស្យុងគោលនៃថ្មពិលថ្មីមួយ។ ចូរពន្យល់ថា ហេតុអ្វីបានជារង្វាស់នេះមានតម្លៃសឹងតែស្មើនឹងតម្លៃនៃ emf របស់ថ្មពិល?

៤. ក្នុងរង្វាស់ដោយប្រើប៉ូតង់ស្យូម៉ែត្រ កម្លាំងអគ្គិសនីចលករដែលស្គាល់ និងមិនស្គាល់ត្រូវបានគេប្រៀបធៀបទៅនឹង ទន្លាក់តង់ស្យុង: ក. ឆ្លងកាត់វ៉ុលម៉ែត្រ ខ. ឆ្លងកាត់កាល់វ៉ាណូម៉ែត្រ គ. តាមបណ្ដោយប៉ូតង់ស្យូម៉ែត្រពិត ឃ. ឆ្លងកាត់តង់ស្យុងប្រភពដែលមានតម្លៃថេរ។

៥. ក្នុងរង្វាស់ដោយប្រើប៉ូតង់ស្យូម៉ែត្របង្ហាញដូចរូបខាងលើ ចូរបង្ហាញថា $e_U = e_S R'_1/R_1$ ។

៦. តង់ស្យុងប្រភពដែលផ្តល់ទៅកាន់ប៉ូតង់ស្យូម៉ែត្រមានតម្លៃប្រហែល 4.50 V ។ កម្លាំងអគ្គិសនីចលករដែលស្គាល់ ($e_S$) នៃថ្មពិលពីរដែលតជាស៊េរីគឺ 1.50 V ។ កាលណាកុងតាក់ $S_1$ ត្រូវបានដាក់ទៅទីតាំងនៃ ($e_S$)

និងធ្វើការកែតម្រូវកូនបូតរហូតដល់គ្មានចរន្តឆ្លងកាត់កាល់វ៉ាណូម៉ែត្រ  ពេលនោះរេស៊ីស្តង់ដែលត្រូវគ្នារបស់វាគឺ 330 Ω ។ បន្ទាប់មក កុងតាក់ $SW_1$ ត្រូវបានដាក់ទៅទីតាំងនៃ ($\varepsilon_U$) និងធ្វើការកែតម្រូវកូនបូតរហូតដល់គ្មានចរន្ត ឆ្លងកាត់កាល់វ៉ាណូម៉ែត្រ ពេលនោះ រេស៊ីស្តង់ដែលត្រូវគ្នារបស់វាគឺ 340 Ω ។ តើកម្លាំងអគ្គិសនីចលករដែល(មិនស្គាល់)វាស់ ($\varepsilon_U$) នេះមានតម្លៃប៉ុន្មាន?

## ៤. តម្រូវការសម្ភារ (EQUIPMENT NEEDED)

Software Proteus (ទាញយក Battery Active, cell, SW-SPDT, POT-HG, និងវ៉ុលម៉ែត្រឬអំពែម៉ែត្រ)

## ៥. ដំណើរការពិសោធន៍ (Experiment Procedure)

ដំឡើង Proteus ដូចបង្ហាញក្នុងរូប។ ត្រូវចាំថារេស៊ីស្តង់ដែលត្រូវគ្នានឹង $e_S$ គឺ $R_1$ និង $e_U$ គឺ $R_1'$ដែលវាស់ពី $A$ ទៅ $C$ និង $A$ ទៅ $D$ រៀងគ្នា។ $C$ និង $D$ ស្ថិតនៅចន្លោះ $AB$។




## ៦. របាយការណ៍ពិសោធន៍

ពិសោធន៍ទី១

តារាងទិន្នន័យ និងគណនាទី១

| ($\varepsilon_U$) | $R_1$(Ω) | វាស់លើកទី១(V) | វាស់លើកទី២(V) | វាស់លើកទី៣(V) |
|---|---|---|---|---|
| ថ្មពិលទី 1 | | | | |
| ថ្មពិលទី 2 | | | | |
| ថ្មពិលទី 3 | | | | |
| $\varepsilon_S$ = | | | $R_1$ =…………..Ω | |

| តម្លៃមធ្យម $\overline{emf}$ (V) | $\alpha_{emf}$ (V) |
|---|---|
| | |
| | |
| | |

## ពិសោធន៍ទី២

## តារាងទិន្នន័យ និងគណនាទី២

| តម្លៃមធ្យម $\overline{emf}$(V) | វ៉ុលម៉ែត្ររេស៊ីស្តង់ធំ(V) | វ៉ុលម៉ែត្ររេស៊ីស្តង់តូច (V) |
|---|---|---|
| | | |
| | | |
| | | |

| %Error វ៉ុលម៉ែត្ររេស៊ីស្តង់ធំ | %Error វ៉ុលម៉ែត្ររេស៊ីស្តង់តូច |
|---|---|
| | |
| | |
| | |

## ពិសោធន៍ទី៣(រង្វាស់រេស៊ីស្តង់ក្នុងនៃថ្មពិល)

## តារាងទិន្នន័យ និងគណនាទី៣

| Resistor R (Ω) | Voltage V (V) | Current I (A) |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |




### ការគណនាគំរូ

$$\sigma_{n-1} = \sqrt{\frac{1}{n-1}\sum(emf-\overline{emf})^2} =$$

……………………………………………………………………………………………………………………….

……………………………………………………………………………………………………………………….

……………………………………………………………………………………………………………….

$$\alpha(RU) = \frac{\sigma_{n-1}}{\sqrt{n}} =$$

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

……………………………………………………………………………………………………………

$$\% \text{ Error} = \left|\frac{\text{តម្លៃតាមទ្រឹស្តី} - \text{តម្លៃតាមពិសោធន៍}}{\text{តម្លៃតាមទ្រឹស្តី}}\right| \times 100\% =$$

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

……………………………………………………………………………………………………………

មេគុណប្រាប់ទិសនៃបន្ទាត់ = $R_l$ = $\tan\theta =$

………………………………………………………………………………………………………………………

………………………………………………………………………………………………………………………

……………………………………………………………………………………………………………

## ៧. សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ អ្នករកឃើញថាកម្រិតល្បឿង និងល្បឿងស្តង់ដារបស់កម្លាំងអគ្គិសនីចលករនៃថ្មពិលមាន មានតម្លៃ____________________និង តម្លៃរេស៊ីស្តង់ក្នុងស្មើនឹង____________________។ ដូចនេះ ដោយ ប្រើឧបករណ៍ពិសោធន៍ខាងលើ អ្នកអាចសន្និដ្ឋានបានថា តម្លៃរេស៊ីស្តង់ក្នុង និងកម្លាំងអគ្គិសនីចលកររបស់ថ្មពិល អាច______________________________។

## ៨. ពិភាក្សា (DISCUSSION QUESTIONS)

១. តើកត្តាអ្វីខ្លះដែលធ្វើឱ្យពិសោធន៍នេះមានកម្រិតល្បឿងធំ?

២. ដើម្បីបានលទ្ធផលល្អ តើអ្នកត្រូវធ្វើដូចម្តេច?

# ខ្វាស់ស្ពានកាប៉ាស៊ីតេ និងបន្តុំកុងដង់

១. វត្ថុបំណង

- ➢ កំណត់កាប៉ាស៊ីតេនៃកុងដង់សាទ័រខ្លះៗដោយប្រើស្ពានសៀគ្វីដែលវងលំនឹង។
- ➢ កំណត់កាប៉ាស៊ីតេនៃកុងដង់សាទ័រតាមពិសោធន៍ក្នុងបង្គុំជាស៊េរី និងជាខ្នែង រួចប្រៀបធៀបលទ្ធផលរបស់វាទៅ នឹងតម្លៃតាមទ្រឹស្តី

២. ទ្រឹស្តី

កុងដង់សាទ័រជាបង្គុំនៃបន្ទះអង្គធាតុចម្លងពីរដាក់ស្របគ្នា ឃ្លាតពីគ្នាចម្ងាយ *d* និងខ័ណ្ឌពីគ្នាដោយឌីអេឡិចទ្រិច ឬខ្យល់។ កាលណាមានចរន្តឆ្លាស់ដែលមានប្រេកង់ *f* ឆ្លងកាត់កុងដង់សាទ័រ នោះរង្វាស់ដែលប្រឆាំងទៅនឹងចរន្តត្រូវបានគេហៅថា រ៉េអាក់តង់នៃកុងដង់សាទ័រ (Capacitive Reactance) តាងដោយ $X_c$ ៖

$X_c = 1/C$ (1), $= 2 f$ ដែល $C$ ជាកាប៉ាស៊ីតេនៃកុងដង់សាទ័រ គិតជា ហ្វារ៉ាដ (F) និង ជាប្រេកង់មុំ, ពុលសាស្យុង ឬល្បឿនមុំ គិតជា (rad/s) ។

តង់ស្យុង ឬផលសងប៉ូតង់ស្យែលរវាងគោលនៃកុងដង់សាទ័រ $V = X_c I$។ $X_c$ នៅក្នុងចរន្តឆ្លាស់មាននាទីដូចគ្នានឹង រេស៊ីស្តង់នៅក្នុងចរន្តជាប់ ហើយ $I$ ជាចរន្តនៅក្នុងកុងដង់សាទ័រ។ ក្នុងពិសោធន៍នេះ យើងនឹងបង្កើតសៀគ្វីស្ពានចរន្តឆ្លាស់ ដោយប្រើកុងដង់សាទ័រពីរ និងរេស៊ីស្តរពីរ បង្ហាញដូច រូបទី១ ខាងក្រោម។ កាលណាស្ពានវងលំនឹង នោះប៉ូតង់ស្យែល ត្រង់ $M$ ស្មើនឹងប៉ូតង់ស្យែលត្រង់ $N$ គេសរសេរ ៖

$V_M = V_N$ និង $V_{AM} = V_{AN}$ $X_{CU} I_1 = X_{CK} I_2$ $X_{CU} / X_{CK} = I_2 / I_1$ (2)

លំយោលករ




រូបទី១

ផលសងប៉ូតង់ស្យែល ... $/ R_2 = I_2 / I_1$ (3)

ពីសមីការ (2) និង (3) យើងបាន ៖

$X_{CU} / X_{CK} = R_1 / R_2$

$(1/C_U)/(1/C_K) = R_1 / R_2$ ដូចនេះ យើងបាន $C_U = C_K R_2/R_1$ (4)

ដែល $C_U$ ជាកាប៉ាស៊ីតេនៃកុងដង់សាទ័រដែលត្រូវវាស់ និង $C_K$ ជាកាប៉ា ... ទ័រដែលស្គាល់។




រូបទី២ ក. កុងដង់សាទ័រជាស៊េរី ខ.កុងដង់សាទ័រជាខ្នែង

កាប៉ាស៊ីតេសមមូលក្នុងបង្គុំជាស៊េរីឱ្យដោយ ៖ $1/C_e = 1/C_1 + 1/C_2$ (5)

កាប៉ាស៊ីតេសមមូលក្នុងបង្គុំជាខ្នែងឱ្យដោយ៖ $C_e = C_1 + C_2$ (6)

ក្នុងពិសោធន៍នេះ យើងនឹងកំណត់កាប៉ាស៊ីតេនៃកុងដង់សាទ័រមិនស្គាល់ខ្លះៗដោយដាក់វាក្នុងស្ពាន បង្ហាញដូច រូបទី១ ខាងលើ។ ក្នុងបង្គុំជាស៊េរី និងជាខ្នែង យើងនឹងកំណត់ និងប្រៀបធៀបរវាងតម្លៃកាប៉ាស៊ីតេ តាមទ្រឹស្តី និង តាមពិសោធន៍។

៣. សំណួរមុនពេលធ្វើពិសោធន៍

១. តើកុងដង់សាទ័រជាអ្វី?

២. ចូរសរសេររូបមន្តរេអាក់តង់នៃកុងដង់សាទ័រ។

៣. ចូរពណ៌នាពីតួនាទីនៃរេអាក់តង់របស់កុងដង់សាទ័រ កាលណាមានចរន្តឆ្លាស់ឆ្លងកាត់កុងដង់សាទ័រ។

ចាប់ពីសំណួរទី ៤ ដល់ទី៨ ចូរពិនិត្យសៀគ្វីអគ្គិសនីដូចបង្ហាញក្នុង រូបទី១ ដែលជាស្ពានរងលំនឹង។ ចូរគូសរង្វង់ ឬ □ លើចម្លើយដែលត្រឹមត្រូវ។

៤. $V_{AM} = V_{MB}$ និង $V_{AN} = V_{NB}$ ក. □ ត្រូវ ខ. □ ខុស

៥. $V_{MN} = 0$ ក. □ ត្រូវ ខ. □ ខុស

៦. $V_{AB} = V_{MN}$ ក. □ ត្រូវ ខ. □ ខុស

៧. $V_{AM} = V_{NB}$ និង $V_{AN} = V_{MB}$ ក. □ ត្រូវ ខ. □ ខុស

៨. $V_{AM} = V_{AN}$ និង $V_{MB} = V_{NB}$ ក. □ ត្រូវ ខ. □ ខុស

៩.ស្ពានដែលបង្ហាញដូច រូបទី១ រងលំនឹង។ កុងដង់សាទ័រដែលស្គាល់តម្លៃ $C_K$ មានកាប៉ាស៊ីតេ 1.0 μF ។ តម្លៃរេស៊ីស្តង់ $R_1$ = 10.0k និង តម្លៃរេស៊ីស្តង់ $R_2$ = 1.01k ។

ក. រកតម្លៃកាប៉ាស៊ីតេនៃកុងដង់សាទ័រដែលមិនស្គាល់ $C_U$។

ខ. បើតម្លៃតាមទ្រឹស្តីនៃកុងដង់សាទ័រមិនស្គាល់ស្មើនឹង 0.10□F (តាមការអានតម្លៃកូដរបស់វា) តើកម្រិតល្អៀង របស់វាមានតម្លៃប៉ុន្មាន?

១០. កុងដង់សាទ័រមួយមានកាប៉ាស៊ីតេ 0.10 □F តជាស៊េរីជាមួយនឹងកុងដង់សាទ័រមួយទៀតដែលមានកាប៉ាស៊ីតេ 0.010 μF។ តើកាប៉ាស៊ីតេសមមូល $C_e$ នៃកុងដង់សាទ័រនេះមានតម្លៃប៉ុន្មាន? បង្ហាញការគណនារបស់អ្នក

១១. កុងដង់សាទ័រមួយមានកាប៉ាស៊ីតេ 0.10 μF តជាខ្នែងនឹងកុងដង់សាទ័រមួយទៀតដែលមានកាប៉ាស៊ីតេ 0.010 μF ។ តើកាប៉ាស៊ីតេសមមូល $C_e$ នៃកុងដង់សាទ័រនេះមានតម្លៃប៉ុន្មាន? បង្ហាញការគណនារបស់អ្នក។

**៤. តម្រូវការសម្ភារ**

- កុងដង់សាទ័រមួយដែលស្គាល់កាប៉ាស៊ីតេរបស់វាច្បាស់លាស់( គឺ 1.0 μF )។
- កុងដង់សាទ័រពីរដែលសន្មតថាមិនស្គាល់កាប៉ាស៊ីតេរបស់វា (តាមរយៈកូដលេខ104 = 0.1μF និងកូដលេខ 103 = 0.01μF) ។
- ប្រអប់រេស៊ីស្តង់មានតម្លៃរហូតដល់ 1000□□ និង រេស៊ីស្តង់ 10.0k មួយ។

- ជនិតាស៊ីនុយសូអ៊ីត (Sine wave generator) (ប្រេកង់ប្រែប្រួល, អំព្លីទុតតង់ស្យុងកំពូល-កំពូល 5V) ។
- វ៉ុលម៉ែត្រចរន្តឆ្លាស់ (បើជា Digital ជាការប្រសើរ) ។

## ៥. ដំណើរការពិសោធន៍

១. តាងកុងដង់សាទ័រដែលមិនស្គាល់ (កុងដង់សាទ័រដែលត្រូវវាស់) ដោយ $C_1$ និង $C_2$ ។ កត់ត្រាតម្លៃកាប៉ាស៊ីតេនៃ កុងដង់សាទ័រដែលស្គាល់ $C_K$ ក្នុងតារាងទិន្នន័យខាងក្រោម។

២. បង្កើតសៀគ្វីដូចបង្ហាញក្នុង រូបទី១ ដោយដាក់កុងដង់សាទ័រ $C_1$ ត្រង់ទីតាំងនៃ $C_U$ និងកុងដង់សាទ័រដែលស្គាល់ ត្រង់ទីតាំងនៃ $C_K$។ ដាក់រេស៊ីស្តង់ 10.0k ត្រង់ទីតាំងនៃ $R_1$។ ដាក់ប្រអប់រេស៊ីស្តង់ 1000Ω ត្រង់ទីតាំងនៃ $R_2$ ។ កត់ត្រាតម្លៃ $R_1$ ដាក់ក្នុងតារាងទិន្នន័យ។

៣. ភ្ជាប់ជនិតាស៊ីនុយសូអ៊ីតដោយដាក់ Output របស់វារវាងចំណុច $A$ និង $B$ ។ បើកវាទៅកាន់អំព្លីទុតអតិបរមា និង ដាក់ប្រេកង់ប្រហែលជា 1000 Hz ។

៤. ដាក់វ៉ុលម៉ែត្ររវាងចំណុច $M$ និង $N$ ក្នុងសៀគ្វី។ កែតម្រូវតម្លៃ $R_2$ រហូតដល់តង់ស្យុងអប្បបរមាដែលអានដោយវ៉ុលម៉ែត្រវ៉ុលម៉ែត្ររវាងចំណុច $M$ និង $N$។ កត់ត្រាតម្លៃ $R_2$ ដែលបង្កើតតង់ស្យុងអប្បបរមាក្នុងតារាងទិន្នន័យ។

៥. ធ្វើពីជំហានទី២ដល់ទី៤ឡើងវិញ ចំពោះកុងដង់សាទ័រមិនស្គាល់ $C_2$ ។

៦. ធ្វើពីជំហានទី២ដល់ទី៤ឡើងវិញដោយយក $C_1$ និង $C_2$ ជាខ្នែង និងដាក់វាត្រង់ទីតាំង $C_U$ រូបទី១។

៧. ធ្វើពីជំហានទី២ដល់ទី៤ឡើងវិញដោយយក $C_1$ និង $C_2$ ជាស៊េរី និងដាក់វាត្រង់ទីតាំង $C_U$ រូបទី១។

- **ដំបូន្មានក្នុងការគណនា**

១. ប្រើសមីការ (4) ដើម្បីគណនាកាប៉ាស៊ីតេនៃកុងដង់សាទ័រមិនស្គាល់ និងក្នុងបង្គុំជាស៊េរី និងជាខ្នែងតាមពិសោធន៍។ កត់ត្រាលទ្ធផលជា $C_{exp}$ ក្នុងតារាងគណនា។

២. ប្រើសមីកា (5) និង (6) ដើម្បីគណនាកាប៉ាស៊ីតេសមមូលតាមទ្រឹស្តីក្នុងបង្គុំជាស៊េរី និងខ្នែង។ ប្រើតម្លៃដែលកំណត់ តាមពិសោធន៍ចំពោះកាប៉ាស៊ីតេនៃកុងដង់សាទ័រ $C_1$, $C_2$, និង $C_3$ ក្នុងការគណនា បើកុងដង់សាទ័រគ្មានកូដលេខ។ កត់ត្រាលទ្ធផលទាំងនោះជា $C_{theo}$ ក្នុងតារាងគណនា។

៣. គណនាកម្រិតល្អៀងនៃតម្លៃតាមពិសោធន៍ក្នុងបង្គុំជាស៊េរី និងខ្នែងដោយធៀបទៅនឹងតម្លៃតាមទ្រឹស្តី។ កត់ត្រា លទ្ធផលដាក់ក្នុងតារាងគណនា។

## ៦. លទ្ធផល (របាយការណ៍ពិសោធន៍)

| Capacitors | $R_2$ ( ) | $C_{exp}$ (F) | $C_{theo}$ (F) | %Error |
|---|---|---|---|---|
| $C_1$ (104 = 0.1uF) | | | | |
| $C_2$ (103 = 0.01uF) | | | | |
| $C_1$ & $C_2$ ខ្នែង | | | | |
| $C_1$ & $C_2$ ស៊េរី | | | | |

| | |
|---|---|
| $C_K =$ 1 $\mu$F | $R_1 =$ 10 k Ω |

➢ ការគណនាគំរូ

- $C_{exp} = (C_K R_2)/R_1$
- (ខ្នែង) $C_{theo} = C_1 + C_2 =$
- (ស៊េរី) $C_{theo} = (1)/(1/C_1 + 1/C_2)$
- % error =

## ៧. សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ កម្រិតល្អៀងតូចជាង 5% និងតម្លៃកាប៉ាស៊ីតេនៃកុងដង់សាទ័ររវាងទ្រឹស្តី និងពិសោធន៍________________________________។ ដូចនេះ ដោយប្រើស្ពានកុងដង់សាទ័រ និងរេស៊ីស្តរខាងលើ អ្នកអាចសន្និដ្ឋាន បានថា តម្លៃកាប៉ាស៊ីតេនៃកុងដង់សាទ័រ_____________________ ___________។

## ៨. សំណួរពិភាក្សា

១. តើកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើលទ្ធផលពិសោធន៍?

២. ដើម្បីទទួលបានលទ្ធផលពិសោធន៍ល្អ តើអ្នកត្រូវធ្វើដូចម្តេច?

# សៀគ្វីRC (ថេរពេល)

## ១. វត្ថុបំណង

- កំណត់រយៈពេលចាំបាច់ដើម្បីផ្ទុក និងផ្ទេរបន្ទុកពីកុងដង់សាទ័រក្នុងសៀគ្វី *RC*។
- វាស់តង់ស្យុងឆ្លងកាត់រេស៊ីស្តរជាអនុគមន៍នៃពេលក្នុងសៀគ្វី *RC* ដើម្បីកំណត់ថេរពេល *RC*។
- កំណត់តម្លៃរេស៊ីស្តង់ក្នុង (ឬអាំប៉េដង់)នៃវ៉ុលម៉ែត្រ និងរេស៊ីស្តរពីរង្វាស់។

## ២. ទ្រឹស្តី

ចូរពិនិត្យសៀគ្វីអគ្គិសនីបង្ហាញដូចរូបទី១។ សៀគ្វីនេះរួមមាន កុងដង់សាទ័រមួយដែលមានកាប៉ាស៊ីតេ *C*, រេស៊ីស្តរ *R*, ប្រភពមួយដែលមានកម្លាំងអគ្គិសនីចលករ ε, និងកុងតាក់ *S* មួយ។ បើគេដាក់កុងតាក់ *S* ទៅចំណុច *A* នៅខណៈ $t = 0$ ដែលដំបូងកុងដង់សាទ័រគ្មានបន្ទុក នោះបន្ទុកចាប់ផ្តើមផ្ទុកក្នុងកុងដង់សាទ័ររហូតដល់ពេញទើបឈប់ផ្ទុក។ ចរន្តអគ្គិសនី *I* ដែលមានតម្លៃដើមរបស់វាគឺ $I_0 = \varepsilon/R$ ថយចុះជាអនុគមន៍អិចស្ប៉ូណង់ស្យែលនៃពេល។ បន្ទុក *Q* នៅលើអាម៉ាតួនៃ កុងដង់សាទ័រចាប់ផ្តើពីកើនពីសូន្យ (0)និងកើនឡើងជាអនុគមន៍អិចស្ប៉ូណង់ស្យែលនៃពេល រហូតដល់តម្លៃ $Q_0 = C\varepsilon$ បង្ហាញដោយសមីការខាងក្រោម ។

$$Q = C\varepsilon\,(1 - e^{-t/RC}) \text{ និង } I = (\varepsilon/R)\, e^{-t/RC} \qquad (1)$$

$$\text{ឬ } Q = Q_0\,(1 - e^{-t/RC}) \text{ និង } I = I_0\, e^{-t/RC}, \text{ ដែល } Q_0 = C\varepsilon \text{ និង } I_0 = \varepsilon/R$$

ទំហំ *RC* ត្រូវបានគេហៅថា ថេរពេលនៃសៀគ្វី មានខ្នាតជាវិនាទី (s), *R* គិតជាអូម (Ω), កាប៉ាស៊ីតេ *C* គិតជាផារ៉ាត (F) ។ ក្រោយមួយរយៈពេលវែងសមល្មមធៀបទៅនឹងថេរពេល *RC* ដែលកុងដង់សាទ័រផ្ទុកបន្ទុកពេញ នោះបន្ទុករបស់វា គឺ *Q* ដែលស្មើនឹង $Q_0 = C\varepsilon$ និងគ្មានចរន្តឆ្លងកាត់សៀគ្វី មានន័យថា ចរន្តស្មើសូន្យ ឥឡូវនេះកុងតាក់ *S* ត្រូវបានដាក់ទៅចំណុច ឬទីតាំង *B* ពេលនោះកុងដង់សាទ័រចាប់ផ្តើមផ្ទេរបន្ទុកអគ្គិសនីតាម រយៈរេស៊ីស្តរ។ បន្ទុកលើអាម៉ាតួរបស់កុងដង់សាទ័រ និងចរន្តក្នុងសៀគ្វីថយចុះជាអនុគមន៍នៃពេលក្នុងខណៈដែលកុងដង់សាទ័រផ្ទេរបន្ទុក បង្ហាញដូចសមីការខាងក្រោម ៖

$$Q = C\varepsilon\, e^{-t/RC} \text{ និង } I = (\varepsilon/R)e^{-t/RC} \qquad (2)$$

$$\text{ឬ } Q = Q_0\, e^{-t/RC} \text{ និង } I = -I_0\, e^{-t/RC}, \text{ ដែល } Q_0 = C\varepsilon \text{ និង } I_0 = \varepsilon/R$$

ចរន្តអគ្គិសនីក្នុងករណីកុងដង់សាទ័រផ្ទេរបន្ទុកមានទិសដៅផ្ទុយពីករណីកុងដង់សាទ័រផ្ទុកបន្ទុក ប៉ុន្តែអាំងតង់ស៊ីតេប៉ុនគ្នា។

ចូរពិនិត្យសៀគ្វីអគ្គិសនីបង្ហាញដូចរូបទី២ ដែលរួមមានប្រភពមួយមានកម្លាំងអគ្គិសនីចលករ ε, កុងដង់សាទ័រមានកាប៉ាស៊ីតេ *C*, កុងតាក់ *S* និងវ៉ុលម៉ែត្រដែលមានរេស៊ីស្តង់ *R*។ បើជាដំបូង កុងតាក់ *S* បិទ កុងដង់សាទ័រផ្ទុកបន្ទុក និងតង់ស្យុងរបស់វាកើនឡើងជាអនុគមន៍អិចស្ប៉ូណង់ស្យែលនៃពេលដែល $V = \varepsilon\,(1 - e^{-t/RC})$, និងកើនឡើងយ៉ាងរហ័ស រហូតដល់តម្លៃ ε ដែលជាតង់ស្យុងរបស់ប្រភព, រូបទី២ ក.។ កាលណាកុងតាក់ *S* ត្រូវបានបើកកុងដង់សាទ័របញ្ចេញបន្ទុកតាមរយៈរេស៊ីស្តង់ *R* របស់ឧបករណ៍(វ៉ុលម៉ែត្រ)ដែលមានថេរពេល *RC*។ ជាមួយ

នឹងកុងតាក់បើក ជាតុនៃសៀគ្វីមានតែកុងដង់សាទ័រមួយដែលមានកាប៉ាស៊ីតេ $C$ និងវ៉ុលម៉ែត្រមួយដែលមានរេស៊ីស្តង់ $R$ ដូច្នេះតង់ស្យុងឆ្លងកាត់កុងដង់សាទ័រស្មើនឹងតង់ស្យុងឆ្លងកាត់វ៉ុលម៉ែត្រ (រូបទី២ ខ.) $V = \varepsilon e^{-t/RC}$ (3)

ពីសមីការ (3) យើងទាញបាន ៖ $\ln(\varepsilon/V) = (1/RC)\,t$ (4)




រូបទី១ សៀគ្វីងាយ




រូបទី២ ក. សៀគ្វី $RC$ ដែលប្រើវ៉ុលម៉ែត្រជារេស៊ីស្តង់




រូបទី២ ខ.សៀគ្វី $RC$ ដែលប្រើវ៉ុលម៉ែត្រជារេស៊ីស្តង់




រូបទី៣សៀគ្វី $RC$ ដែលប្រើវ៉ុលម៉ែត្រ និង $R_U$ តជាខ្នែង

បើតង់ស្យុងឆ្លងកាត់កុងដង់សាទ័រត្រូវបានកំណត់ជាអនុគមន៍នៃពេល ក្រាប $\ln(\varepsilon/V)$ ជាអនុគមន៍នៃពេលមានរាងជាបន្ទាត់ត្រង់ដែលមានមេគុណប្រាប់ទិសស្មើនឹង $(1/RC)$ ។ ដូច្នេះ $RC$ អាចត្រូវបានកំណត់ កាលណាគេស្គាល់រេស៊ីស្តង់របស់វ៉ុលម៉ែត្រ $R$ និងបន្ទាប់មកគេអាចទាញកាប៉ាស៊ីតេរបស់កុងដង់សាទ័រ $C$ បាន។ បើគេដាក់រេស៊ីស្តរមិនស្គាល់ជាខ្នែងជាមួយនឹងវ៉ុលម៉ែត្រ នោះយើងបានសៀគ្វីបង្ហាញដូចរូបទី៣។ កុងដង់សាទ័រអាចត្រូវបានផ្ទុក និងផ្ទេរជាថ្មីម្តងទៀត ប៉ុន្តែឥឡូវនេះថេរពេលស្មើនឹង $R_tC$ ដែល $R_t$ ជារេស៊ីស្តង់សមមូលក្នុងបង្គុំ

ជាខ្នែងនៃ $R$ និង $R_U$ ។ ទំនាក់ទំនងរវាង $R_U$, $R$ និង $R_t$ ឱ្យដោយ ៖

$$R_U = (RR_t)/(R - R_t) \qquad (5)$$

ដូចនេះរង្វាស់តង់ស្យុងនៃកុងដង់សាទ័រជាអនុគមន៍នៃពេលនឹងបង្កើតភាពអាស្រ័យគ្នាដូចដែលបានឱ្យដោយសមីការ(4) លើកលែងតែមេគុណប្រាប់ទិសនៃបន្ទាត់ដែលស្មើនឹង $(1/R_tC)$ ។ បើគេស្គាល់ $C$ និង $R_tC$ ត្រូវបានរកឃើញពីមេគុណប្រាប់ទិស ដូចនេះ $R_t$ អាចត្រូវបានកំណត់។ ដោយប្រើសមីការ (5) $R_U$ អាចត្រូវបានកំណត់ពី $R$ និង $R_t$ ។

$$\%\text{កម្រិតល្អៀង} = \left|\frac{\text{តម្លៃតាមទ្រឹស្តី} - \text{តម្លៃតាមពិសោធន៍}}{\text{តម្លៃតាមទ្រឹស្តី}}\right| \times 100\%$$

$$\text{កម្រិតល្អៀងគំរូ}(\alpha) = \frac{\text{លំងាកគំរូ}(\delta_{n-1})}{\sqrt{n}}$$

$$\text{លំងាកគំរូ}(\delta_{n-1}) = \sqrt{\frac{1}{n-1}\sum_i (x_i - \bar{x})^2}$$

## ៣. សំណួរមុនពេលធ្វើពិសោធន៍

១. សៀគ្វីបង្ហាញដូចរូបទី១ ដំបូងកុងដង់សាទ័រគ្មានបន្ទុកអគ្គិសនីទេនៅពេលដែលកុងតាក់ $S$ ត្រូវបានដាក់ទៅទីតាំង $A$ នៅខណៈ $t = 0$ ។ បន្ទុកលើអាម៉ាតួនៃកុងដង់សាទ័រគឺ

ក. ដំបូងមានតម្លៃសូន្យ និងចុងបញ្ចប់មានតម្លៃ $C\varepsilon$

ខ. មានតម្លៃថេរស្មើនឹង $C\varepsilon$

គ. ដំបូងមានតម្លៃ $C\varepsilon$ និងចុងបញ្ចប់មានតម្លៃសូន្យ

ឃ. មានតម្លៃតូចជាង $\varepsilon/R$ ជានិច្ច។

២. សៀគ្វីបង្ហាញដូចរូបទី១ ដំបូងកុងដង់សាទ័រគ្មានបន្ទុកអគ្គិសនីទេនៅពេលដែលកុងតាក់ $S$ ត្រូវបានដាក់ទៅទីតាំង $A$ នៅខណៈ $t = 0$ ។ ចរន្តនៅក្នុងសៀគ្វីគឺ

ក. ដំបូងមានតម្លៃសូន្យ និងចុងបញ្ចប់មានតម្លៃ $\varepsilon / R$

ខ. មានតម្លៃថេរស្មើនឹង $\varepsilon / R$

គ. មានតម្លៃ $C\varepsilon$

ឃ. ដំបូងមានតម្លៃ $\varepsilon / R$ និងចុងបញ្ចប់មានតម្លៃស្មើនឹងសូន្យ។

៣. សៀគ្វីបង្ហាញដូចរូបទី២ ក. កុងតាក់ $S$ ត្រូវបានបិទដើម្បីផ្ទុកបន្ទុកឱ្យកុងដង់។ ក្នុងពេលផ្ទុកបន្ទុក តង់ស្យុងរបស់វាគឺ

ក. $V = \varepsilon e^{-t/RC}$ ខ. $V = \varepsilon(1 - e^{-t/RC})$

គ. $V = C\varepsilon$ ឃ. $V = \varepsilon/R$ ។

៤. សៀគ្វីបង្ហាញដូចរូបទី២ ខ. កុងតាក់ $S$ ត្រូវបានបិទដើម្បីផ្ទុកបន្ទុកឱ្យកុងដង់ និងបន្ទាប់មកបើកនៅខណៈ $t = 0$ ។ ក្នុងពេលបន្ទេរបន្ទុក តង់ស្យុងរបស់វាគឺ

ក. $V = \varepsilon e^{-t/RC}$ ខ. $V = \varepsilon(1 - e^{-t/RC})$

គ. $V = C\varepsilon$ ឃ. $V = \varepsilon/R$ ។

៥. បង្ហាញថា $RC$ មានខ្នាតជាវិនាទី (s) បើ $R$ គិតជា (Ω) និង $C$ គិតជា (F) ។

៦. សន្មតថាសៀគ្វីត្រូវបានបង្កើតដូចរូបទី៣ ។ កាប៉ាស៊ីតេនៃកុងដង់សាទ័រគឺ 47.0 $\mu$F តង់ស្យុងប្រភពគឺ 20.0 V អាំប៉េដង់របស់វ៉ុលម៉ែត្រគឺ 11.8 MΩ និងរេស៊ីស្តង់ $R_U$ = 1.74 MΩ ។ បើដំបូងកុងតាក់ត្រូវបិទ និងបន្ទាប់មកបើក តើអំណានរបស់វ៉ុលម៉ែត្រស្មើនឹងប៉ុន្មាន ក្រោយកុងតាក់បើក 40.0s ? ចូរបង្ហាញការគណនារបស់អ្នក។

$V$ = ____________________.

៧. កុងដង់សាទ័រមួយមានកាប៉ាស៊ីតេ 47.0 $\mu$F និងរេស៊ីស្ទរមួយមានរេស៊ីស្តង់ 11.8 MΩ ។ សៀគ្វីនេះជាសៀគ្វី $RC$ ។ បើកុងដង់សាទ័រផ្ទុកក្រោមតង់ស្យុង 20.0 V តើរយៈពេលប៉ុន្មានដែលតង់ស្យុងរបស់កុងដង់សាទ័រឡើងដល់ 10.0 V? ចូរបង្ហាញការគណនារបស់អ្នក។

## ៤. តម្រូវការសម្ភារ

Software Proteus ដែលដំឡើងរួចក្នុងកំព្យូទ័រ ដោយទាញយកគ្រឿងដូចជា៖

- វ៉ុលម៉ែត្រ១ (រេស៊ីស្តង់ក្នុង 10 MΩ, បើជាវ៉ុលម៉ែត្រឌីជីតាល់ជាការប្រសើរ)
- ក្រូណូម៉ែត្រ១
- ប្រភពចរន្តជាប់ 20V
- រេស៊ីស្តង់មិនស្គាល់ (ប្រហែលជាពី 2 ទៅ 10 MΩ )
- កុងតាក់១(ពីរផ្លូវ) និងកុងតាក់មួយផ្លូវ

## ៥. ដំណើរការ

### រេស៊ីស្តង់ក្រៅដែលមិនស្គាល់សម្រាប់ផ្ទុកបន្ទុកឱ្យកុងដង់សាទ័រ

1. អានតម្លៃកុងដង់សាទ័រតាមរយៈលេខកូដលើតួរបស់វា និងកត់ត្រាតម្លៃដាក់ក្នុងតារាងទិន្នន័យទី១។
2. មួលតម្រូវតង់ស្យុងប្រភពទៅតម្លៃប្រហែល 20.0V ។
3. ដំឡើងសៀគ្វីបង្ហាញដូចរូបទី២ ក. ដោយប្រើកុងដង់សាទ័រ១, វ៉ុលម៉ែត្រ,រេស៊ីស្ទរ និងតង់ស្យុងប្រភព។
4. បិទកុងតាក់ និងចាប់ផ្តើមកត់ត្រាពេលដោយប្រើក្រូណូម៉ែត្រក្នុងពេលជាមួយគ្នា។
5. អំណានវ៉ុលម៉ែត្រនឹងកើនឡើង កាលណាកុងដង់សាទ័រផ្ទុកបន្ទុក។ ឱ្យក្រូណូម៉ែត្រដំណើរការបន្ត និងគ្រប់តម្លៃតង់ស្យុងទាំងអស់ដែលឱ្យក្នុងតារាងទិន្នន័យទី១ កត់ត្រារយៈពេល $t$ ដែលត្រូវគ្នានឹងអំណាន

តង់ស្យុងពីវ៉ុលម៉ែត្រ។ ជម្រើសសមស្របរបស់តង់ស្យុងដើម្បីវាស់រយៈពេល $t$ គួរធ្វើកំណើន 10% ជាដំបូង និងបន្តបន្ទាប់។ ឧទាហរណ៍ បើ $\varepsilon$ = 20.0 V ពេលនោះត្រូវប្រើតង់ស្យុង 2.0 V, 4.0 V, 6.0 V ។ល។ កត់ត្រាតង់ស្យុង $V$ និងរយៈពេល $t$ ដាក់ក្នុង តារាងទិន្នន័យ និងគណនាទី១។

6. ធ្វើជំហានទី៤ និងទី៥ឡើងវិញចំនួនពីរដងទៀត។
7. ទុកឱ្យកុងដង់សាទ័រផ្ទុកបន្ទុករហូតដល់ពេញ។ តង់ស្យុងខ្ពស់បំផុតរបស់កុងដង់សាទ័រដែលផ្ទុកបន្ទុកពេញស្មើនឹងកម្លាំងអគ្គិសនីចលករ $\varepsilon$, ដែល $V = \varepsilon$។ កត់ត្រាតម្លៃនេះដាក់ក្នុងតារាងទិន្នន័យនិងគណនាទី១។
8. វាស់រេស៊ីស្តង់ក្រៅ($R_{th}$)ដោយប្រើអូមម៉ែត្រ។ កត់ត្រាតម្លៃនេះដាក់ក្នុងតារាងទិន្នន័យនិងគណនាទី១។

**រេស៊ីស្តង់ក្នុងរបស់វ៉ុលម៉ែត្រដែលមិនស្គាល់ចំពោះបន្ទេរបន្ទុកពីកុងដង់សាទ័រ**

1. អានតម្លៃកុងដង់សាទ័រតាមរយៈលេខកូដលើតួរបស់វា និងកត់ត្រាតម្លៃដាក់ក្នុងតារាងទិន្នន័យទី២។
2. ដំឡើងសៀគ្វីបង្ហាញដូចរូបទី២ ខ. ដោយប្រើកុងដង់សាទ័រជាប្រភព, វ៉ុលម៉ែត្រ និងតង់ស្យុងប្រភព។
3. បិទកុងតាក់ និងមួលតម្រូវតង់ស្យុងប្រភពដែលមានកម្លាំងអគ្គិសនីចលករ $\varepsilon$ ដែលអានដោយវ៉ុលម៉ែត្រទៅតម្លៃ ប្រហែល 20.0 V ។ កត់ត្រាតម្លៃ $\varepsilon$ ក្នុងតារាងទិន្នន័យ និងគណនាទី២។
4. បើកកុងតាក់ និងចាប់ផ្តើមវាស់ពេលដោយប្រើក្រូណូម៉ែត្រក្នុងពេលជាមួយគ្នា។
5. អំណានវ៉ុលម៉ែត្រនឹងធ្លាក់ចុះកាលណាកុងដង់សាទ័រផ្ទេរបន្ទុក។ ឱ្យក្រូណូម៉ែត្រដំណើរការបន្ត និងគ្រប់តម្លៃតង់ស្យុង ទាំងអស់ដែលឱ្យក្នុងតារាងទិន្នន័យទី២ កត់ត្រារយៈពេល $t$ ដែលត្រូវគ្នានឹងអំណានតង់ស្យុងពីវ៉ុលម៉ែត្រ។ ជម្រើស សមស្របរបស់តង់ស្យុងដើម្បីវាស់រយៈពេល $t$ គួរធ្វើកំណើន 10%។ ឧទាហរណ៍ បើ $\varepsilon$ = 20.0 V ពេលនោះត្រូវ ប្រើតង់ស្យុង 18.0 V, 16.0 V, 14.0 V ។ល។ កត់ត្រាតង់ស្យុង $V$ និងរយៈពេល $t$ ដាក់ក្នុងតារាងទិន្នន័យ និងតារាងគណនាទី២។
6. ធ្វើពីជំហានទី៣ ដល់ទី៥នេះឡើងវិញចំនួនពីរដងទៀត។

**រេស៊ីស្តង់ដែលមិនស្គាល់ចំពោះបន្ទេរបន្ទុកពីកុងដង់សាទ័រ**

1. ដំឡើងសៀគ្វីបង្ហាញដូចរូបទី៣ដោយប្រើកុងដង់សាទ័រដូចគ្នាដែលបានប្រើក្នុងសៀគ្វីមុន និងរេស៊ីស្តង់ដែល ស្គាល់។ បិទកុងតាក់ និងមួលតម្រូវតង់ស្យុងប្រភពទៅកាន់តម្លៃដូចមុន។
2. ធ្វើពីជំហាន២ដល់៥នៃដំណើរការខាងលើឡើងវិញ រួចកត់ត្រាតម្លៃដាក់ក្នុងតារាងទិន្នន័យ និងតារាងគណនាទី៣។

ដំបូន្មានក្នុងការគណនា

**រេស៊ីស្តង់ក្នុង និងរេស៊ីស្តង់ក្រៅនៃវ៉ុលម៉ែត្រដែលមិនស្គាល់**

1. គណនាតម្លៃ $\ln(1 - V/\varepsilon)$, $\ln(\varepsilon/V)$ និងកត់ត្រាវាដាក់ក្នុងតារាងទិន្នន័យ និងតារាងគណនាទី២។
2. គណនាតម្លៃមធ្យម និងល្បឿនស្តង់ដា $\alpha_t$ របស់តង់ស្យុងនីមួយៗ រួចកត់ត្រាវាដាក់ក្នុងដាក់ក្នុងតារាងទិន្នន័យ និងតារាងគណនាទី១ និងទី២រៀងគ្នា។
3. គូរក្រាបដោយប្រើទិន្នន័យ $\ln(1 - V/\varepsilon)$, $\ln(\varepsilon/V)$ ស្ថិតលើអ័ក្សឈរ និងស្ថិតលើអ័ក្សដេក។

4. កត់ត្រាតម្លៃមេគុណប្រាប់ទិសក្នុងតារាងទិន្នន័យ និងតារាងគណនាទី១ និងទី២។
5. គណនា $R_eC$, $RC$ ជាចម្រាស់នៃមេគុណប្រាប់ទិស។ កត់ត្រាតម្លៃ $R_eC$, $RC$ ក្នុងតារាងទិន្នន័យទី១ និងទី២រៀងគ្នា។
6. ប្រើតម្លៃ $R_eC$, $RC$ និង $C$ ដើម្បីគណនាតម្លៃរេស៊ីស្តង់ក្នុង $R_e$, $R$ ដែលមិនស្គាល់ រួចកត់ត្រាវាដាក់ក្នុងតារាងទិន្នន័យ និងតារាងគណនាទី១ និងទី២រៀងគ្នា។

## រេស៊ីស្តង់ដែលមិនស្គាល់

1. គណនាតម្លៃ $\ln(\varepsilon/V)$ រួចកត់ត្រាតម្លៃដាក់ក្នុងតារាងទិន្នន័យ និងតារាងគណនាទី៣។
2. គណនាតម្លៃមធ្យម និងល្បៀងស្តង់ដា $\alpha_t$ របស់ $t$ នៃតង់ស្យុងនីមួយៗ និងកត់ត្រាវាដាក់ក្នុងតារាងទិន្នន័យ និងតារាងគណនាទី៣។
3. គូរក្រាបដោយដោយប្រើ $\ln(\varepsilon/V)$ លើអ័ក្សឈរ និង លើអ័ក្សដេក។
4. កត់ត្រាតម្លៃមេគុណប្រាប់ទិសក្នុងតារាងទិន្នន័យ និងតារាងគណនាទី៣។
5. គណនាតម្លៃ $R_tC$ ជាចម្រាស់នៃមេគុណប្រាប់ទិស។ កត់ត្រាតម្លៃ $R_tC$ ក្នុងតារាងទិន្នន័យ និងតារាងគណនាទី៣។
6. គណនាតម្លៃ $R_t$ ដែលមិនស្គាល់ និងកត់ត្រាវាក្នុងតារាងទិន្នន័យ និងតារាងគណនាទី៣។
7. គណនាតម្លៃ $R_U$ ដែលមិនស្គាល់ពីតម្លៃ$R_t$ និង$R$និងកត់ត្រា$R_U$ ក្នុងតារាងទិន្នន័យនិងតារាងគណនាទី៣។

- **ជំនួយក្នុងការគូរក្រាប**

1. ចំពោះទិន្នន័យពីតារាងទិន្នន័យ និងការគណនាទី១ គូរក្រាបដោយដាក់ $\ln(1-V/\varepsilon)$ និង $\ln(\varepsilon/V)$ លើអ័ក្សឈរ និង លើអ័ក្សដេក។ ក្រាបដែលគូសបានគឺជាបន្ទាត់ត្រង់។
2. ចំពោះទិន្នន័យពីតារាងទិន្នន័យ និងការគណនាទី៣ គូរក្រាបដោយដាក់ $\ln(\varepsilon/V)$ លើអ័ក្សឈរ និងលើអ័ក្សដេក។ ក្រាបដែលគូសបានគឺជាបន្ទាត់ត្រង់។
3. គូរក្រាប $V$- ចំពោះបន្ទុក និងបន្ទេរកុងដង់សាទ័រ។




រូបទី២ ខ.

## ៦. របាយការណ៍ពិសោធន៍

តារាងទិន្នន័យ និងគណនាទី១(កុងដង់សាទ័រផ្ទុកបន្ទុក)

| $V$(V) | $t_1$ (s) | $t_2$ (s) | $t_3$ (s) | ln(1- $V/\varepsilon$) | $\bar{t}$ (s) | $\alpha_t$ (s) |
|---|---|---|---|---|---|---|
| 0 | 0 | 0 | 0 | 0 | 0 | |
| 2.0 | | | | | | |
| 4.0 | | | | | | |
| 6.0 | | | | | | |
| 8.0 | | | | | | |
| 10.0 | | | | | | |
| 11.0 | | | | | | |
| 12.0 | | | | | | |
| 13.0 | | | | | | |
| 14.0 | | | | | | |
| 15.0 | | | | | | |
| 16.0 | | | | | | |
| 17.0 | | | | | | |
| ε =20 V | $R_e$ = kΩ | $R_{th}$ = 100 kΩ | | $r$ = | | |
| Slope = $s^{-1}$ | $R_eC$ = | $C$ = 1000 μF | | % Error $R_e$ = % | | |

- កត់ត្រាតម្លៃតង់ស្យុង និងតម្លៃមធ្យមនៃពេលពីតារាងខាងលើដាក់ក្នុងតារាងខាងក្រោម ៖

| $V$(V) | 0 | 2.0 | 4.0 | 6.0 | 8.0 | 10.0 | 11.0 | 12.0 | 13.0 | 14.0 | 15.0 | 16.0 | | 17.0 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| $\bar{t}$ (s) | 0 | | | | | | | | | | | | | |

- គូរក្រាបរបស់កុងដង់សាទ័រផ្ទុកបន្ទុក






តារាងទិន្នន័យ និងគណនាទី២(កុងដង់សាទ័រផ្ទេរបន្ទុក)

| $V$(V) | $t_1$ (s) | $t_2$ (s) | $t_3$ (s) | (s) | ln($\varepsilon/V$) | $\alpha_t$ (s) |
|---|---|---|---|---|---|---|
| | 0 | 0 | 0 | 0 | 0 | |
| 18.0 | | | | | | |
| 16.0 | | | | | | |
| 14.0 | | | | | | |
| 12.0 | | | | | | |
| 10.0 | | | | | | |
| 8.0 | | | | | | |
| 6.0 | | | | | | |
| 5.0 | | | | | | |
| 4.0 | | | | | | |
| 3.0 | | | | | | |
| 2.0 | | | | | | |
| ε = V | $C$ = μF | | | $r$ = | | |
| Slope = $s^{-1}$ | $RC$ = s | $R$ = MΩ | | | | |

- កត់ត្រាតម្លៃតង់ស្យុង និងតម្លៃមធ្យមនៃពេលពីតារាងខាងលើដាក់ក្នុងតារាងខាងក្រោម ៖

| $V$(V) | | 18.0 | 16.0 | 14.0 | 12.0 | 10.0 | 8.0 | 6.0 | 5.0 | 4.0 | 3.0 | 2.0 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| t(s) | 0 | | | | | | | | | | | |

- គូរក្រាបរបស់កុងដង់សាទ័រផ្ទេរបន្ទុក







តារាងទិន្នន័យ និងគណនាទី៣( កុងដង់សាទ័រផ្ទេរបន្ទុក )

| $V$(V) | $t_1$ (s) | $t_2$ (s) | $t_3$ (s) | ln($\varepsilon/V$) | (s) | $\alpha_t$ (s) |
|---|---|---|---|---|---|---|
| | 0 | 0 | 0 | 0 | 0 | |
| 18.0 | | | | | | |
| 16.0 | | | | | | |
| 14.0 | | | | | | |
| 12.0 | | | | | | |
| 10.0 | | | | | | |
| 8.0 | | | | | | |
| 6.0 | | | | | | |
| 5.0 | | | | | | |
| 4.0 | | | | | | |
| 3.0 | | | | | | |
| 2.0 | | | | | | |

| | | | |
|---|---|---|---|
| ε = V | $R$ = MΩ | $C$ = μF | $r$ = |
| Slope = $s^{-1}$ | $R_tC$ = s | $R_t$ = MΩ | $R_U$ = MΩ |

- កត់ត្រាតម្លៃតង់ស្យុង និងតម្លៃមធ្យមនៃពេលពីតារាងខាងលើដាក់ក្នុងតារាងខាងក្រោម ៖

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| $V$(V) | | 18.0 | 16.0 | 14.0 | 12.0 | 10.0 | 8.0 | 6.0 | 5.0 | 4.0 | 3.0 | 2.0 |
| (s) | 0 | | | | | | | | | | | |

- គូរក្រាបរបស់កុងដង់សាទ័រផ្ទេរបន្ទុក






❖ ការគណនាគម្រូ ( SAMPLE CALCULATIONS )

- $\ln(1 - V/\varepsilon)$ =

- $\ln(\varepsilon/V)$ =

- $RC$ = 1/slope =

- $R = RC/C$=
- $R_t = R_t\, C/C$ =
- $R_U = (R_t\, R)/(R - R_t)$ =
- % Error =
- $\delta_{n-1}$=
- $\alpha_t$ =

## ៧. សន្និដ្ឋាន ( CONCLUSTIONS )

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ កម្រិតល្បឿង និងល្បឿងស្តង់ដាគឺ……………………… , ហើយតម្លៃនៃថេរពេល និងរេស៊ីស្តង់គឺ ………………………..។ ដូចនេះ ដោយប្រើឧបករណ៍ពិសោធន៍ខាងលើអ្នកអាចសន្និដ្ឋានថា រយៈពេល ដែលកុងដង់សាទ័រផ្ទុកបន្ទុក និងផ្ទេរបន្ទុក តង់ស្យុង ថេរពេល និងរេស៊ីស្តង់គឺ…………………………។

## ៨. សំណួរពិភាក្សា ( DISCUSSION QUESTIONS )

- ដើម្បីសម្រួលក្នុងការវាស់តង់ស្យុង តើអ្នកត្រូវធ្វើដូម្តេច ?
- ដើម្បីទទួលបានលទ្ធផលពិសោធន៍ល្អ តើអ្នកត្រូវធ្វើដូចម្តេច ?

# កម្លាំងម៉ាញេទិច(បម្លាស់ទីរបស់កំណាត់របារលោហៈ)

## ១. វត្ថុបំណង

- បង្ហាញថាទិសដៅបម្លាស់ទីរបស់របារអាស្រ័យនឹងទិសដៅនៃចរន្ត និងដែនម៉ាញេទិចតាមរយៈពិសោធន៍

## ២. ចំណេះដឹងមូលដ្ឋាន

ប្រើវិធានដៃស្តាំដើម្បីកំណត់ទិសដៅកម្លាំងអេឡិចត្រូម៉ាញេទិច

- លាម្រាមទាំងបួនតាមទិសដៅចរន្ត
- ក្ដោបម្រាមទាំងបួនតាមទិសដៅដែនម៉ាញេទិច
- កន្ទេកមេដៃឱ្យកែងនឹងម្រាមទាំង៤ មេដៃជាទិសដៅកម្លាំងអេឡិចត្រូម៉ាញេទិច

## ៣. ពិសោធន៍៖

### ៣.១ ការកំណត់បញ្ហា

យើងឱ្យចរន្តឆ្លងកាត់របារដូចរូប ដែលទិសដៅចរន្ត និងដែនម៉ាញេទិចត្រូវបានកំណត់ តើរបារផ្លាស់ទីទៅតាមទិសដៅណា(មើលរូបខាងក្រោម)?




### ៣.២ ការបង្កើតសម្មតិកម្ម

| ទិសដៅ | ១ | ២ | ៣ | ៤ |
|---|---|---|---|---|
| ដែនម៉ាញេទិច | ចុះក្រោម | ឡើងលើ | ចុះក្រោម | ឡើងលើ |

| ចរន្តអគ្គិសនី | ស្តាំទៅឆ្វេង | ស្តាំទៅឆ្វេង | ឆ្វេងទៅស្តាំ | ឆ្វេងទៅស្តាំ |
|---|---|---|---|---|
| របារ | | | | |

**តម្រុយះ**

ទិសដៅបម្លាស់ទីរបស់របារកំណត់នូវទិសដៅនៃ.................................. ហើយទិសដៅនៃ................ នេះអាស្រ័យនឹងទិសដៅនៃ .................និង............................។ ដោយប្រើផលគុណវ៉ិចទ័រ អ្នកអាចកំណត់ទិសដៅនៃកម្លាំងម៉ាញេទិចដោយអនុវត្តតាមវិធានដៃស្តាំលើពិសោធនេះ។

## ៣.៣ តេស្តសម្មតិកម្ម ឬពិសោធន៍

### ក. សម្ភារ

អាគុយ មេដែករាងអ៊ុយ របារអង្គធាតុចម្លងរាងស៊ីឡាំង (របារស្ពាន់) ខ្សែចម្លងជាប់ដង្កៀប និងបន្ទះស្នោរ

### ខ. ដំណើរការពិសោធះ

១. ចោះរន្ធ៤លើបន្ទះស្នោររាងចតុកោណកែងដែលមានទទឹងប្រហែល 3cm និងបណ្ដោយប្រហែល 7cm។



២. យករបារអង្គធាតុចម្លងរាងស៊ីឡាំងមកកាត់ជាពីរកំណាត់ហើយពត់ជារាងអក្សរអ៊ុយដែលមានបាតប្រវែងប្រហែល 30cm និងកម្ពស់ប្រហែល 4cm (ដូចរូប)។

៣. យករបារដែលពត់រួចទាំងពីរទៅដាំនឹងបន្ទះស្នោរដែលចោះរន្ធរួច ដោយធ្វើយ៉ាងណាឱ្យរបារទាំងពីរស្របគ្នា។



៤. ដាក់មេដែករាង ∪ ក្នុងចន្លោះរបារទាំងពីរ

៥. កាត់របារអេង្គធាតុចម្លងរាងស៊ីឡាំងប្រវែងប្រហែល 8cm រួចដាក់ឱ្យកែងលើរបារស្របគ្នាដោយ ធ្វើយ៉ាងណាឱ្យរបារនេះនៅចន្លោះប៉ូលទាំងពីរនៃមេដែករាង ∪ ។

៦. ភ្ជាប់ចរន្តពីអាគុយទៅរបារស្របគ្នាដោយប្រើខ្សែចម្លងជាប់ដង្កៀប




**ចំណាំ៖** ឱ្យចរន្តឆ្លងកាត់ក្នុងរយៈពេលខ្លីពី២ ទៅ៣ វិនាទីប៉ុណ្ណោះ។

## ៣.៤ លទ្ធផល

របារឆ្លងកាត់ដោយចរន្តដាក់ក្នុងដែនម៉ាញេទិច នោះវានឹង.......................។ ទិសដៅបម្លាស់ទីរបស់របារអាស្រ័យនឹង ....................និង...................................។

| **ទិសដៅ** | ១ | ២ | ៣ | ៤ |
|---|---|---|---|---|
| **ដែនម៉ាញេទិច** | ចុះក្រោម | ឡើងលើ | ចុះក្រោម | ឡើងលើ |
| **ចរន្តអគ្គិសនី** | ស្ដាំទៅឆ្វេង | ស្ដាំទៅឆ្វេង | ឆ្វេងទៅស្ដាំ | ឆ្វេងទៅស្ដាំ |
| **របារ** | | | | |

### ៣.៥ វិភាគ និងសន្និដ្ឋាន

ទិសដៅបម្លាស់ទីរបស់របារគឺជាទិសដៅនៃ.....................ដែលអាចរកបានតាមវិធាន..................។ ដូចនេះសម្មតិកម្មរបស់អ្នកគឺ...............ដោយពិសោធមានន័យថាវិធានដៃស្តាំត្រូវបានគាំទ្រដោយពិសោធន៍។

### ៤. ពិភាក្សា

១. យើងមានខ្សែចម្លងត្រង់ពីរដាក់ស្របគ្នាឆ្លងកាត់ដោយចរន្តមានទិសដៅដូចគ្នាដូចរូបខាងក្រោម តើខ្សែចម្លងទាំងពីរទាញគ្នាចូលឬច្រានគ្នាចេញ?



២. យើងមានខ្សែចម្លងត្រង់ពីរដាក់ស្របគ្នាឆ្លងកាត់ដោយចរន្តមានទិសដៅផ្ទុយគ្នាដូចរូបខាងក្រោម

តើខ្សែចម្លងទាំងពីរទាញគ្នាចូលឬច្រានគ្នាចេញ?



# សៀគ្វីចរន្តឆ្លាស់ RL

## ១. វត្ថុបំណង

- កំណត់មុំផាសនៃចរន្តអគ្គិសនីធៀបនិងតង់ស្យុង។
- បង្ហាញថាអាំងឌុចទ័រពិត មានអាំងឌុចតង់សុទ្ធ ហើយនិងរេស៊ីស្តង់សុទ្ធ $r$ តជាស៊េរី។
- កំណត់តម្លៃ $L$ និង $r$ ពីអាំងឌុចទ័រដែលមិនស្គាល់។

## ២. ទ្រឹស្តី

ពិនិត្យសៀគ្វីពីរដូចរូបទី១ ដែលសៀគ្វីនេះមានជនិតារលក *(Wave generator)* ដែលមានប្រេកង់ $f$ និងភ្ជាប់ទៅនឹងរេស៊ីស្តរ $R$ បន្ទាប់មកភ្ជាប់ទៅនិងអាំងឌុចតង់សុទ្ធ $L$ ជាច់ដោយឡែកពីគ្នា។ សន្មតថាជនិតាមានតង់ស្យុងអតិបរមា $V_m$ និងបង្កើតតង់ស្យុងអតិបរមា $V_m$ ឆ្លងកាត់រេស៊ីស្តរក្នុងសៀគ្វីក. វាក៏បង្កើតតង់ស្យុងអតិបរមា $V_m$ ឆ្លងកាត់អាំងឌុចទ័រក្នុងសៀគ្វីខ. ដែរ។ តង់ស្យុងឆ្លងកាត់រេស៊ីស្តរទាក់ទងនឹងចរន្តឲ្យតាមរូបមន្តដូចចរន្តជាប់ដែរគឺ $V_R = IR$ (1)

បើ $L$ ជាអាំងឌុចតង់ដែលមានខ្នាតគិតជាហង់រី ($H$) និង $\omega = 2\pi f$ ជាប្រេកង់មុំឬល្បឿនមុំនៃជនិតាគិតជារ៉ាដ្យង់ក្នុងមួយវិនាទី (rad/s) នោះទំនាក់ទំនងរវាង $V_L$ និងចរន្ត $I$ គឺ $V_L = I\omega L$ (2)

ទំហំ $\omega L = X_L$ ត្រូវបានគេហៅថា អាំប៉េដង់របស់អាំងឌុចទ័រ *(Inductive reactance)* មានខ្នាតជាអូម ($\Omega$)។ កាលណាចរន្តឆ្លាស់ឬតង់ស្យុងឆ្លាស់ត្រូវបានវាស់ដោយប្រើឧបករណ៍ លេខអំណាននៃចរន្តឬតង់ស្យុងត្រូវគិតតម្លៃជាតម្លៃមធ្យមហៅថាតម្លៃប្រសិទ្ធនៃចរន្តឬតង់ស្យុងតាងដោយ($I_{rms}$ ឬ $V_{rms}$)។ ទំនាក់ទំនងរវាង $I_{rms}$ និង $I_m$ (ចរន្តអតិបរមា) ឲ្យតាមរូបមន្ត

$$I_{rms} = \frac{I_m}{\sqrt{2}} \text{ ឬ } I_{rms} = \frac{I_m}{\sqrt{2}} = 0.707\, I_m$$

ដូចគ្នាដែរចំពោះតង់ស្យុង

$$V_{rms} = \frac{V_m}{\sqrt{2}} \text{ ឬ } V_{rms} = \frac{V_m}{\sqrt{2}} = 0.707\, V_m$$

**ក្នុងពិសោធន៍នេះគេវាស់តែតង់ស្យុងប៉ុណ្ណោះ ហើយ តម្លៃរង្វាស់របស់វាជាតម្លៃប្រសិទ្ធ។**




ក.                                    ខ.

រូបទី១ ជនិតានិងរេស៊ីស្តរ និងជនិតានិងអាំងឌុចទ័រ។ ទំនាក់ទំនងរវាងផាសតង់ស្យុងនិងចរន្ត និងសំណង់ប្រេណែលរបស់វា

រូបទី១ ខាងលើបង្ហាញពីសៀគ្វី និងក្រាបចរន្ត និងតង់ស្យុងឆ្លងកាត់ជាតុក្នុងមួយខួបពេញ។ ក្រាបក្នុងករណីរេស៊ីស្តរបង្ហាញថាចរន្តឆ្លងកាត់រេស៊ីស្តរ $I_{Rm}$ និងតង់ស្យុង $V_{Rm}$ មានផាសដូចគ្នា។ សម្រាប់អាំងឌុចទ័រ ក្រាបបង្ហាញថា ចរន្តឆ្លងកាត់អាំងឌុចទ័រ $I_{Lm}$ និងតង់ស្យុងឆ្លងកាត់អាំងឌុចទ័រ $V_{Lm}$ ខុសផាសគ្នា $90^o$ ដែលតង់ស្យុងលឿនផាសជាងចរន្តចំនួន $90^o$ ។

រូបទី១ ខាងក្រោមបំផុតតាងឲ្យសំណង់ប្រេណែលដែលបង្ហាញពីទំនាក់ទំនងផាស។ ក្នុងសំណង់ប្រេណែលវ៉ិចទ័រដែលគូសចេញ ប្រវែងរបស់វាសមាមាត្រទៅនឹងតម្លៃនៃទំហំដែលតាង ហើយប្រេកង់នៃជនិតាត្រូវបានសន្មតថាវិលតាមទិសដៅផ្ទុយពីរង្វិលទ្រនិចនាឡិកា។ នៅខណៈណាមួយ ចំណោលនៃវ៉ិចទ័ររង្វិលមួយលើអ័ក្ស $y$ គឺជាតម្លៃខណៈនៃទំហំនោះ។ ចំពោះអាំងឌុចទ័រ វ៉ិចទ័រតាងតង់ស្យុងអាំងឌុចទ័រលឿនផាសជាងវ៉ិច ទ័រតាងចរន្តចំនួន $90^o$ ។ ឥឡូវនេះចូរពិនិត្យមើលសៀគ្វីដែលមានអាំងឌុចតង់សុទ្ធ $L$ ( គ្មានរេស៊ីស្តង់ $r$) និងរេស៊ីស្តរ $R$ តជាសេរីជាមួយនឹងជនិតាស៊ីនុយសូអ៊ីតដែលមានតង់ស្យុងអតិបរមា $V_m$ បង្ហាញដូចរូបទី២ ។




រូបទី២ សៀគ្វីដែលមានអាំងឌុចទ័រ និងរេស៊ីស្តរតជាស៊េរី និងសំណង់ប្រេណែល

ចំពោះសៀគ្វីនេះ **ចរន្ត $I_m$ មានតម្លៃដូចគ្នាគ្រប់ខណៈពេលទាំងអស់ក្នុងធាតុទាំងបីនៃសៀគ្វី**។ ចំណែកឯសំណង់ប្រេណែលបង្ហាញតែតង់ស្យុងប៉ុណ្ណោះ។ **វ៉ិចទ័រតាងឲ្យចរន្ត(មិនបានបង្ហាញទេ)មានទិសដៅដូចវ៉ិចទ័រ $V_{Rm}$ ព្រោះចរន្តនិងតង់ស្យុងឆ្លងកាត់រេស៊ីស្តរមានផាសដូចគ្នា**។ ចំណាំថាតង់ស្យុងឆ្លងកាត់អាំងឌុចទ័រ $V_{Lm}$ លឿនផាសជាងតង់ស្យុងឆ្លងកាត់រេស៊ីស្តរ $V_{Rm}$ ចំនួន $90°$ និងតង់ស្យុងរបស់ជនិតា $V_m$ លឿនផាសជាង $V_{Rm}$ ចំនួន$\phi$ ។ សំណង់ប្រេណែលនេះបង្ហាញថា តង់ស្យុងនៃជនិតាគឺជាផលបូកវ៉ិចទ័រនៃ $V_{Rm}$ និង $V_{Lm}$ ។

សមីការសរសេរ៖ $\vec{V}_m = \vec{V}_{Rm} + \vec{V}_{Lm}$ និង $V_m = \sqrt{(V_{Rm})^2 + (V_{Lm})^2}$ (3)

សំណង់ប្រេណែលបង្ហាញថាមុំផាស $\phi$ មានទំនាក់ទំនងនឹងតង់ស្យុង $V_{Rm}$ និង $V_{Lm}$ និងក៏មានទំនាក់ទំនងនឹង $R$ និង $\omega L$ តាមសមីការ (1) និង(2)។ ទំនាក់ទំនងឲ្យដោយ៖

$$\tan\phi = \frac{V_{Lm}}{V_{Rm}} = \frac{L\omega}{R} \quad (4)$$

កត់សម្គាល់ថាសមីការ (4) មានតម្លៃតែចំពោះអាំងឌុចទ័រសុទ្ធដែលគ្មានរេស៊ីស្តង់ក្នុង។ អាំងឌុចទ័រពិតមានទាំងអាំងឌុចតង់ $L$ និងរេស៊ីស្តង់ក្នុង $r$ និងអាចត្រូវបានតាងដោយអាំងឌុចទ័រសុទ្ធ $L$ តជាស៊េរីនឹងរេស៊ីស្តង់សុទ្ធ $r$។ រូបទី៣បង្ហាញពីអាំឌុចទ័រពិតតជាស៊េរីនិង រេស៊ីស្តរ $R$ និងតង់ស្យុងជនិតា $V_m$ ។ តង់ស្យុងរវាងចំណុច $A$ និង $B$ គឺជាតង់ស្យុងនៃជនិតា និងតង់ស្យុងរវាងចំណុច $A$ និង $C$ ជាតង់ស្យុងរេស៊ីស្តរ(ឆ្លងកាត់រេស៊ីស្តរ) $V_{Rm}$ ។ រវាងចំណុច $B$ និង $C$ ជាតង់ស្យុងសរុប(ផ្ទួប)រវាងអាំងឌុចតង់ $L$ និងរេស៊ីស្តង់ក្នុង $r$ ។ តង់ស្យុងនេះតាងដោយ $V_{ind}$ ។ មានតង់ស្យុងខ្លះទៀតដូចជា $V_{Lm}$ ឆ្លងកាត់ $L$ និង $V_{rm}$ ឆ្លងកាត់ $r$ ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ យើងមិនអាចវាស់ $V_{Lm}$ និង $V_{rm}$ ដោយផ្ទាល់បានទេ។ ទំហំដែលអាចវាស់បានមានតែ $V_{indm}$ ប៉ុណ្ណោះដែលជាផលបូកវ៉ិចទ័ររវាង $V_{Lm}$ និង $V_{rm}$ ។ សំណង់ប្រេណែលនៃសៀគ្វីបង្ហាញដូចរូបទី៣។

អនុវត្តច្បាប់កូស៊ីនុសចំពោះត្រីកោណដែលបង្កើតដោយ $V$, $V_R$, និង $V_{ind}$ យើងបាន

$$\cos\phi = \frac{{V_m}^2 + {V_{Rm}}^2 - {V_{indm}}^2}{2V_m V_{Rm}} \quad (5)$$

សំណាង់ប្រេណែលក្នុងរូបទី៣ បង្ហាញថា តង់ស្យុង $V_{Lm}$ និង $V_{rm}$ អាចត្រូវបានកំណត់ពី $V_m$, $V_{Rm}$ និង $\phi$ ដោយ

$$V_{Lm} = V_m \sin\phi\text{, និង } V_{rm} = V_m\cos\phi - V_{Rm} \quad (6)$$

ចរន្ត $I_m$ មានតម្លៃដូចគ្នាទាំងអស់នៅក្នុងជាតុនៃសៀគ្វី និងវាទាក់ទងនឹងតង់ស្យុងឆ្លងកាត់ជាតុនីមួយៗតាមសមីការខាងក្រោម

$$V_{Lm} = L\omega I_m, \quad V_{Rm} = RI_m, \quad V_{rm} = rI_m \quad (7)$$

ដែល $\phi, V_{Lm}$ និង $V_{rm}$ ត្រូវបានកំណត់ពីសមីការ(5) និង(6) សមីការ (7) អាចត្រូវបានប្រើដើម្បីទាញរក $\omega L$ និង $r$។ ដោយបំបាត់ $I_m$ យើងបាន

$$X_{Lm} = L\omega = \frac{RV_{Lm}}{V_{Rm}}, \qquad r = \frac{RV_{rm}}{V_{Rm}}$$




រូបទី៣ សៀគ្វីតជាស៊េរីរវាង $L$, $r$, $R$ និង $V_m$ (តង់ស្យុងគោលនៃប្រភព) និងសំណាង់ប្រេណែល

សម្គាល់៖

- សមីការ (5), (6), (7)អាចសរសេរតម្លៃអតិបរមាឬតម្លៃប្រសិទ្ធនិងអាចគូរក្រាបនៃរូបទី៣ក្រោមទម្រង់ជាតង់ស្យុងប្រសិទ្ធឬតង់ស្យុងអតិបរមាណាមួយក៏បានដែរ។

## ៣.សំណួរមុនពេលធ្វើពិសោធន៍

១. ក្នុងសៀគ្វីចរន្តឆ្លាស់មួយដែលមានតែរេស៊ីស្តរមួយ តជាស៊េរីជាមួយនឹងប្រភពចរន្តឆ្លាស់ **គម្លាតផាសរវាងចរន្ត និងតង់ស្យុងឆ្លងកាត់រេស៊ីស្តរ**គឺ ក.ចរន្តលឿនផាសជាងតង់ស្យុង$90^o$ ខ.ចរន្តយឺតផាសជាងតង់ស្យុង $90^o$ គ. ចរន្ត និងតង់ស្យុងមានផាសដូចគ្នា ឃ.ចរន្តយឺតផាសជាងតង់ស្យុង $\phi$ ។

២. ក្នុងសៀគ្វីចរន្តឆ្លាស់មួយដែលមានតែអាំងឌុចទ័រសុទ្ធមួយ តជាស៊េរីជាមួយនឹងប្រភពចរន្តឆ្លាស់ **គម្លាតផាសរវាងចរន្ត និងតង់ស្យុងឆ្លងកាត់អាំងឌុចទ័រ**គឺ ក. ចរន្តលឿនផាសជាងតង់ស្យុង $90^o$ ខ.ចរន្តយឺតផាសជាងតង់ស្យុង $90^o$ គ. ចរន្ត និងតង់ស្យុងមានផាសដូចគ្នា ឃ.ចរន្តយឺតផាសជាងតង់ស្យុង $\phi$ ។

៣. ក្នុងសៀគ្វីចរន្តឆ្លាស់មួយដែលមានរេស៊ីស្តរមួយ តជាស៊េរីជាមួយនឹងអាំងឌុចទ័រសុទ្ធមួយ និងប្រភពចរន្តឆ្លាស់ **គម្លាតផាសរវាងចរន្ត និងតង់ស្យុងឆ្លងកាត់ប្រភព**គឺ ក. ចរន្តលឿនផាសជាងតង់ស្យុង $90^o$ ខ.ចរន្តយឺតផាសជាងតង់ស្យុង $90^o$ គ. ចរន្ត និងតង់ស្យុងមានផាសដូចគ្នា ឃ.ចរន្តយឺតផាសជាងតង់ស្យុង $\phi$ ។

៤. ចូរសរសេររូបមន្តអាំប៉េដង់របស់អាំងឌុចទ័រក្នុងសៀគ្វីចរន្តឆ្លាស់មួយដែលមានតែអាំងឌុចទ័រសុទ្ធមួយ តជាស៊េរីជាមួយនឹងប្រភពចរន្តឆ្លាស់។

៥. ចូរសរសេររូបមន្តអាំប៉េដង់សរុបរបស់សៀគ្វីចរន្តឆ្លាស់មួយដែលមានរេស៊ីស្តរមួយ តជាស៊េរីជាមួយនឹងអាំងឌុចទ័រសុទ្ធមួយ និងប្រភពចរន្តឆ្លាស់។

៦. ចូរសរសេររូបមន្តអាំប៉េដង់សរុបរបស់សៀគ្វីចរន្តឆ្លាស់មួយដែលមានរេស៊ីស្តរមួយ តជាស៊េរីជាមួយនឹងអាំងឌុចទ័រពិតមួយ និងប្រភពចរន្តឆ្លាស់។

៧. ជនិតាចរន្តឆ្លាស់មួយមានតង់ស្យុងអតិបរមា 5.00 V គណនាតង់ស្យុងប្រសិទ្ធរបស់វា។

៨. ជនិតាចរន្តឆ្លាស់មួយមានចរន្តអតិបរមា 3.00 A គណនាចរន្តប្រសិទ្ធរបស់វា។

៩. ជនិតាចរន្តឆ្លាស់មួយមានប្រេកង់ $f = 800$ Hz តជាស៊េរីជាមួយនិងអាំងឌុចទ័រសុទ្ធដែលមានអាំងឌុចតង់ 100 mH និងតង់ស្យុងអតិបរមារវាងគោលរបស់វាគឺ 12.0 V ។ គណនាចរន្តប្រសិទ្ធ។

១០. ជនិតាចរន្តឆ្លាស់មួយមានតង់ស្យុងអតិមរមា $V_m$ តជាស៊េរីនិងអាំងឌុចទ័រសុទ្ធ $L$ និងរេស៊ីស្តរ $R$។ តង់ស្យុងអតិបរមានៃគោលអាំងឌុចទ័រគឺ $V_{Lm} = 6.00\,V$ និងតង់ស្យុងអតិបរមានៃគោលរេស៊ីស្តរគឺ $V_{Rm} = 8.00\,V$ ។ គណនាតង់ស្យុងអតិមរមា $V_m$ ជនិតាចរន្តឆ្លាស់។

១១. រេស៊ីស្ទរមួយមានរេស៊ីស្តង់ 500Ω និងអាំងឌុចទ័រពិតមួយមានអាំងឌុចតង់សុទ្ធ $L$ និងរេស៊ីស្តង់ក្នុង $r$ តជាស៊េរីជាមួយនឹងជនិតាមួយដែលមានតង់ស្យុង $V_m = 10.0$ V និងប្រេកង់មុំ $\omega = 1000$ rad/s ។ តង់ស្យុងឆ្លងកាត់អាំងឌុចទ័រពិតត្រូវបានវាស់ឃើញស្មើនឹង 4.73 V និងតង់ស្យុងឆ្លងកាត់រេស៊ីស្តង់ 500Ω ត្រូវបានវាស់ឃើញស្មើនឹង 6.57 V ។ គណនាតម្លៃ $L$ និង $r$ ។

## ៤. តម្រូវការសម្ភារ

ជនិតាស៊ីនុយសូអ៊ីត( ប្រេកង់ប្រែប្រួល និងអំព្លីទុត 5V ), ប្រអប់រេស៊ីស្តង់, អាំងឌុចទ័រ 100 mH ( រេស៊ីស្តង់ប្រហែល 350 Ω ដើម្បីធ្វើជារេស៊ីស្តង់មិនស្គាល់ ), វ៉ុលមែត្រចរន្តឆ្លាស់( ជាឌីជីថល និងអាចវាស់ប្រេកង់ខ្ពស់បាន ), ដែកឈាន និងម៉ែត្រសំរាប់វាស់មុំ( Protractor )

## ៥. ដំណើរការ

ក. ភ្ជាប់អាំងឌុចទ័រជាស៊េរីជាមួយនិងជនិតាស៊ីនុយសូអ៊ីត និងរេស៊ីស្តង់ដើម្បីបង្កើតជាសៀគ្វីបង្ហាញដូចរូបទី៣។

ខ. ដាក់( មួល )ជនិតាទៅកាន់ប្រេកង់ខ្ពស់ 800 Hz ។

គ. ដាក់( ប្រអប់ )រេស៊ីស្តង់ទៅកាន់តម្លៃ 400 Ω ។ កត់ត្រាតម្លៃរេស៊ីស្តង់ និងប្រេកង់នេះក្នុងតារាងទិន្នន័យខាងក្រោម។

ឃ. ប្រើវ៉ុលម៉ែត្រចរន្តឆ្លាស់ដើម្បីវាស់តង់ស្យុងជនិតា( $V$), តង់ស្យុងអាំងឌុចទ័រ( ពិត )( $V_{ind}$), និងតង់ស្យុងនៃរេស៊ីស្ទរ ( $V_R$) ។ កត់ត្រាតម្លៃរបស់វាក្នុងតារាងទិន្នន័យខាងក្រោម។

ង. ធ្វើឡើងវិញពីជំហានក.ដល់ឃ. ចំពោះតម្លៃរេស៊ីស្តង់ 600 Ω, 800 Ω និង 1000 Ω ។ ទោះបីជាជនិតាបានដាក់ទៅតង់ស្យុងអតិបរមាក៏ដោយ ក៏តង់តង់ស្យុងចេញរបស់វាអាចមានការប្រែប្រួលបន្តិចបន្តួចទៅតាមបម្រែបម្រួលនៃរេស៊ីស្តង់ $R$ ។ **ដូច្នេះត្រូវវាស់តង់ស្យុងទាំងបីចំពោះតម្លៃនៃរេស៊ីស្តង់នីមួយៗ។**

ច. ចូរកត់សម្គាល់ឲ្យបានច្បាស់លាស់ចំពោះអាំងឌុចទ័រដែលបានប្រើ និងតម្លៃ $L$ និង $r$ ដែលបានកំណត់ ព្រោះអ្នកអាចប្រើវាទៀតនៅពេលក្រោយ។

- ដំបូន្មានក្នុងការគណនា

  ក. ដោយស្គាល់តម្លៃប្រេកង់ $f$ ចូរគណនាតម្លៃប្រេកង់មុំ $\omega$ ដែល $\omega = 2\pi f$ រួចកត់ត្រាវាដាក់ក្នុងតារាងគណនាខាងក្រោម។

  ខ. ប្រើសមីការដើម្បីគណនា $\cos\phi,\ \phi, V_L, V_r, X_L = L\omega, L$ និង $r$ រួចកត់ត្រាតម្លៃរបស់វាដាក់ក្នុងតារាងគណនាខាងក្រោម។

គ. គណនាតម្លៃមធ្យម និងកម្រិតល្អៀងស្តង់ដារបស់ $L$ និង $r$ រួចកត់ត្រាចូលក្នុងតារាងគណនាខាងក្រោម។

❖ ដំបូន្មានក្នុងការគូរក្រាប

ក. សង់សំណង់ប្រេណៃលដោយប្រើមាត្រដ្ឋានដូចបង្ហាញក្នុងរូបទី៤ខាងក្រោម។ ប្រើក្រដាសគូរក្រាប និងគូរជ្យាក្រាមបួនផ្សេងគ្នាលើក្រដាសតែមួយ។

ខ. ប្រើមាត្រដ្ឋានសមស្រប( ឧទាហរណ៍ $1.00\ \mathrm{V/cm}$ ) ដូចនេះយើងបានក្រាបធំសមស្រប។

គ. ដំបូងសង់វ៉ិចទ័រមួយតាមបណ្តោយអ័ក្ស $x$ ដែលអាំងតង់ស៊ីតេរបស់វាស្មើនឹងតម្លៃរបស់ $V_R$ ដូចបង្ហាញដូចរូបទី៤ ។

ឃ. ប្រើដែកឈានដើម្បីគូសធ្នូវង់មួយ ដោយគូសចេញពីចុង $V_R$ ដែលមានកាំស្មើនឹងតម្លៃ $V_{ind}$ និងគូសធ្នូវង់មួយទៀតដោយចេញពីគល់ $V_R$ ទៅកាត់នឹងធ្នូវង់មុន។ កាំនៃធ្នូវង់ក្រោយនេះស្មើនឹងតម្លៃនៃ $V$ ។

ម៉្យាងទៀត $\vec{V}_{ind} = \vec{V}_r + \vec{V}_L$ (រូបទី៤ )។




រូបទី៤ សំណង់ប្រេណៃល

សម្គាល់៖ អ្នកអាចគូរក្រាបនេះក្រោមទម្រង់ជាតង់ស្យុងប្រសិទ្ធឬតង់ស្យុងអតិបរមាណាមួយក៏បានដែរ។

## ៦. លទ្ធផល

តារាងទិន្នន័យ

| ប្រេកង់ $f=$ 800 Hz | | | | |
|---|---|---|---|---|
| $R\,(\Omega)$ | 400 | 600 | 800 | 1000 |
| $V$ (V) | | | | |
| $V_R$ (V) | | | | |
| $V_{ind}$ (V) | | | | |

តារាងគណនា

| ល្បឿនមុំ $\omega = 2\pi f = \quad 1600\pi \quad rad/s$ | | | | |
|---|---|---|---|---|
| $\cos\phi$ | | | | |
| $\phi$ ( ដឺក្រេ ) | | | | |
| $V_L$( V ) | | | | |
| $V_r$( V ) | | | | |
| $r$ (Ω) | | | | |
| $L$ ( H ) | | | | |
| $\bar{r} =$ (Ω) | $\alpha_r =$ (Ω) | $\bar{L} =$ (H) | $\alpha_L =$ (H) | |

### ❖ ការគណនាគំរូ

ក. $\omega = 2\pi f =$

ខ. $\cos\phi = \dfrac{V^2 + {V_R}^2 - {V_{ind}}^2}{2VV_R} =$

គ. $\cos\phi =$ $\quad\quad\quad\quad$ $, \phi =$

ឃ. $V_L = V\sin\phi =$

ង. $V_r = V\cos\phi - V_R =$

ច. $L = \dfrac{RV_L}{\omega V_R} =$

ឆ. $r = \dfrac{RV_r}{V_R}$

ជ. $L = \dfrac{X_L}{\omega} =$

## ៧. សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើយើងបាន (មុំផាសនៃចរន្តអគ្គិសនីធៀបនិងតង់ស្យុង)$\phi$, $V_{ind}$ អាចត្រូវបានគណនា ហើយ $\bar{L} =$ …………………., និង $\bar{r} =$ ……………………… និង $V_{ind}$មាន $L$ និង $r$ តជា……………………។ ដូចនេះសម្មតិកម្ម(វត្ថុបំណង)ត្រូវបានគាំដោយពិសោធន៍។

## ៨. ពិភាក្សា

១. ចូររៀបរាប់ពីភាពជាក់លាក់(Precision) នៃរង្វាស់ $L$ និង $r$ ដោយបង្ហាញកស្តុតាងរបស់អ្នក។

២. ពិនិត្យសំណង់ប្រហែលដែលបានសង់រួច។ ដោយប្រើឧបករណ៍វាស់មុំ(Protractor) ចូរវាស់មុំ$\phi$, $\phi =$ ……….. និងប្រៀបធៀបវាទៅនឹងតម្លៃដែលបានគណនា រួចគណនាកកម្រិតល្អៀងរបស់វា។

៣. បើអ្នកតអាំងឌុចទ័រជាស៊េរីជាមួយនិងរេស៊ីស្តង់ $R = 10000\,\Omega = 10\,\text{k}\Omega$ និងប្រើ $\omega = 100\,000\,\text{rad/s}$ មានន័យថាប្រើ ប្រេកង់ប្រហែល $f = 16$ kHz តើតម្លៃ $\phi$ នឹងទៅជាយ៉ាងណា? ករណីនេះ $r << R$។

៤. ប្រើរេស៊ីស្តង់ $R = 600\,\Omega$ និងគណនាចរន្តឆ្លងកាត់សៀគ្វីពីសមីការទី(7)ទាំងបី រួចប្រៀបធៀបគ្នា។

៥. បើអ្នកមានអាំងឌុចតង់តែ 0.100 mH និងចង់ធ្វើពិសោធន៍នេះឲ្យជោគជ័យ តើអ្នកគួរប្រើ រេស៊ីស្តង់ $R$ និងប្រេកង់ប្រហែលប៉ុន្មាន? (**ណែនាំ៖** អ្នកគួរប្រើរេស៊ីស្តង់ឲ្យតូច( $R \sim 15\,\Omega$ ឬតូចជាង)ដើម្បីបាន $V_R$ តូច និងប្រេកង់ឲ្យធំ( $f \sim 10^5$Hz ) ដើម្បីបាន $Vind$ ធំ។ ការធ្វើបែបនេះអ្នកនឹងទទួលបាន $V_R < Vind$ ) បង្ហាញដូចរូបខាងក្រោម។



# សៀគ្វីចរន្តឆ្លាស់RC និង RLC

## ១. វត្ថុបំណង

- កំណត់ទំនាក់ទំនងផាសរវាងតង់ស្យុងឆ្លងកាត់រេស៊ីស្តរ ($V_R$) និងតង់ស្យុងឆ្លងកាត់កុងដង់សាទ័រ ($V_C$) ក្នុងសៀគ្វី *RC*។
- កំណត់តម្លៃកាប៉ាស៊ីតេនៃកុងដង់សាទ័រក្នុងសៀគ្វី *RC*។
- កំណត់ទំនាក់ទំនងផាសរវាងតង់ស្យុងឆ្លងកាត់រេស៊ីស្តរ ($V_R$) តង់ស្យុងឆ្លងកាត់អាំងឌុចទ័រ ($V_L$) និងតង់ស្យុងឆ្លងកាត់កុងដង់សាទ័រ ($V_C$) ក្នុងសៀគ្វី *RLC*។
- កំណត់ទំនាក់ទំនងផាសរវាងតង់ស្យុងនៃគោលជនិតា( $V$) និងចរន្ត( $I$) ឆ្លងកាត់សៀគ្វី *RLC*។

## ២. ទ្រឹស្តី

❖ សៀគ្វីចរន្តឆ្លាស់ *RC*

សៀគ្វីតជាស៊េរីដែលរួមមាន កុងដង់សាទ័រ $C$ រេស៊ីស្តរ $R$ និងជនិតាស៊ីនុយសូអ៊ីតដែលមានប្រេកង់ $f$ បង្ហាញដូចរូបទី១.១។ សំណង់ប្រេណែលបង្ហាញពីជនិតាតង់ស្យុង $V$ តង់ស្យុងឆ្លងកាត់រេស៊ីស្តរ $V_R$ និងតង់ស្យុងឆ្លងកាត់កុងដង់សាទ័រ $V_C$។ **សន្មតថាតង់ស្យុងទាំងអស់ដែលបានពោលមកនេះជាតង់ស្យុងប្រសិទ្ធ**។ តង់ស្យុង $V_R$ និង $V_C$ មានផាសខុសគ្នា $90^o$ និងតង់ស្យុង $V$, $V_R$ និង $V_C$ បង្កើតបានត្រីកោណកែងដូចបង្ហាញក្នុងរូបទី១.១។ សមីការរបស់វាជាអាំងតង់ស៊ីតេក្នុងសៀគ្វី *RC* ឲ្យដោយ

$$V = \sqrt{V_R{}^2 + V_C{}^2} \qquad (1)$$

សមីការ (1) មានតម្លៃចំពោះតែកុងដង់សាទ័រសុទ្ធដែលគ្មានកំប៉ូសង់ទប់(No resistive component) ។ បើរង្វាស់លើកុងដង់សាទ័រពិតបង្ហាញភាពត្រូវគ្នានឹងសមីការ (1) វាបង្ហាញថាកុងដង់សាទ័រគ្មានកំប៉ូសង់ទប់ទេ។




រូបទី១.១ សៀគ្វី *RC* និងសំណង់ប្រណែលនៃតង់ស្យុង

ក្នុងសៀគ្វី *RC* ចរន្ត $I$ មានតម្លៃដូចគ្នាទាំងអស់ក្នុងធាតុនីមួយៗនៃសៀគ្វី ហើយទំនាក់ទំនងរវាងតង់ស្យុងនិងចរន្តចំពោះរេស៊ីស្តរ និងកុងដង់សាទ័រឲ្យដោយ៖

$$V_R = RI \quad \text{និង} \quad V_C = X_C I = \frac{I}{C\omega}, \quad X_C = 1/C\omega \qquad (2)$$

ទំហំ $X_C = 1/C\omega$ ហៅថារេអាក់តង់នៃកុងដង់សាទ័រ ឬអាំប៉េដង់នៃកុងដង់សាទ័រ និងមានខ្នាតជាអូម($\Omega$)។ បើបំបាត់ចរន្តចេញពីសមីការ យើងបាន

$$C = \left(\frac{1}{\omega R}\right)\left(\frac{V_R}{V_C}\right) \quad (3)$$

ដូច្នេះតម្លៃកាប៉ាស៊ីតេនៃកុងដង់សាទ័រដែលមិនស្គាល់អាចត្រូវបានគណនាចេញពីសមីការ (3) បើ$\omega$ និង $R$ ស្គាល់ និង$V_R$និង$V_C$ ត្រូវបានវាស់ឃើញ។

❖ សៀគ្វីចរន្តឆ្លាស់ *RLC*

ពិនិត្យសៀគ្វី *RLC* តជាស៊េរីបង្ហាញដូចរូបទី១.២ ដែលមានជនិតាតង់ស្យុង *V* មួយ រេស៊ីស្តរ *R* មួយ កុងដង់សាទ័រ *C* មួយ និងអាំងឌុចទ័រមួយមានអាំងឌុចតង់ *L* និងរេស៊ីស្តង់ក្នុង *r* ។ សន្មតថាកុងដង់សាទ័រគ្មានរេស៊ីស្តង់។ រូបទី១.២ក. បង្ហាញពីសំណង់ប្រេណែលនៃតង់ស្យុង $V, V_R, V_C, V_L$ និង $V_r$ ។ តាមរូបបង្ហាញថា$V_L$ និង $V_C$ ខុសផាសគ្នា 180° និង $V_R$ និង $V_r$ មានផាសដូចគ្នា។




រូបទី១.២ សៀគ្វី *RLC* ត




រូបទី១.៣ សំណង់ប្រេណែល $V_V$ និង $V_r$

ទំហំ $V_L - V_C, V$ និង $V_R + V_r$បង្កើតជាត្រីកោណកែងឲ្យដោយ

$$V = \sqrt{(V_L - V_C)^2 + (V_R + V_r)^2} \quad (4)$$

គេមិនអាចវាស់ $V_L$ ឬ $V_r$ ដោយផ្ទាល់បានទេ។ ប៉ុន្តែគេអាចវាស់តង់ស្យុងផ្តួប ($V_{ind}$) រវាងគោលអាំងឌុចទ័រដែលមាន *L* និង *r* តជាស៊េរីបាន។

$$V^2{}_{ind} = V_L{}^2 + V_r{}^2 \quad (5)$$

ចរន្ត *I* ក្នុងសៀគ្វីមានតម្លៃដូចគ្នាក្នុងធាតុនីមួយៗនៃសៀគ្វី។ $V_L$ និង $V_r$ អាចសរសេរបានដូចខាងក្រោម៖

$$V_L = X_L I = L\omega\, I, \quad \text{និង} \quad V_r = r\, I \quad (6)$$

ដោយ $I = \frac{\mathrm{V_{ind}}}{\mathrm{Z_{Lr}}} = \frac{\mathrm{V_{ind}}}{\sqrt{(L\omega)^2 + r^2}}$ យើងបាន

$$V_L = V_{ind}\frac{\omega L}{\sqrt{(L\omega)^2 + r^2}} \quad \text{និង } V_r = V_{ind}\frac{r}{\sqrt{(L\omega)^2 + r^2}} \quad (7)$$

សន្មតថា $\omega, L$ និង $r$ ស្គាល់ សមីការ(7)ត្រូវបានប្រើដើម្បីកំណត់ $V_L$ និង $V_r$ បើ $V_{ind}$ ត្រូវបានវាស់។ តម្លៃនៃ $V_L$ និង $V_r$ រួមគ្នានិង $V_R$ និង $V_C$ ដែលបានវាស់អាចឲ្យយើងកំណត់បាននូវតម្លៃ $V$ ក្នុងសមីការ(4)។

## ៣. សំណួរមុនចូលទីពិសោធន៍

១. ក្នុងសៀគ្វី $RC$ តជាស៊េរីបង្ហាញដូចរូបទី១.១ ទំនាក់ទំនងផាសរវាងតង់ស្យុងនៃជនិតា $V$, តង់ស្យុងនៃកុងដង់សាទ័រ $V_C$ និងតង់ស្យុងនៃរេស៊ីស្តរ $V_R$ គឺ

(ក) $V$ និង $V_R$ មានផាសដូចគ្នា, $V_C$ យឺតផាសជាង $V$ ចំនួន $90^\circ$

(ខ) $V_C$ និង $V_R$ មានផាសខុសគ្នាចំនួន$\phi$, $V_C$ យឺតផាសជាង $V$ ចំនួន $90^\circ$

(គ) $V_C$ យឺតផាសជាង $V_R$ ចំនួន $90^\circ$, $V$ យឺតផាសជាង $V_R$ ចំនួន$\phi$

(ឃ) $V_R$ យឺតផាសជាង $V_C$ ចំនួន$\phi$, $V_C$ លឿនផាសជាង $V$ ចំនួន $90^\circ$

២. បើសៀគ្វី $RC$ តជាស៊េរីមាន $V_R = 10.0\text{ V}$, និង$V_C = 6.63\text{ V}$ តង់ស្យុងនៃគោលជនិតាស្មើនឹង

(ក) 12.6 V (ខ) 16.6 V (គ) 3.37 V (ឃ) 12.0 V

៣. សៀគ្វី $RC$ តជាស៊េរីមាន$\omega = 2000\text{ rad/s}$ និង $R = 300\ \Omega$ ។ តង់ស្យុង $V_C$ ត្រូវបានវាស់ឃើញស្មើនឹង 4.76 V និងតង់ស្យុង $V_R$ ត្រូវបានវាស់ឃើញស្មើនឹង 4.78 V។ គណនាកាប៉ាស៊ីតេនៃកុងដង់សាទ័រ។

៤. សៀគ្វី $RC$ តជាស៊េរីមាន$R = 500\ \Omega$ និង $C = 3.00\ \mu\text{F}$ ។ តង់ស្យុងរបស់វាត្រូវបានវាស់ឃើញ$V_R = 8.07\text{V}$ និង$V_C = 6.68\text{V}$ ។ គណនាចរន្ត $I$ និងប្រេកង់មុំ $\omega$ ។

៥. សៀគ្វី $RLC$ តជាស៊េរីមានអាំងឌុចទ័រមួយដែលមានអាំងឌុចតង់$L$ និងរេស៊ីស្តង់ $r$ កុងដង់សាទ័រកាប៉ាស៊ីតេ$C$ រេស៊ីស្តរ $R$ និងជនិតាដែលមានតង់ស្យុង $V$។ ចូរជ្រើសរើសត្រូវឬខុសចំពោះពំនោលខាងក្រោម។

(ក) $V_R$ និង$V_r$ មានផាសដូចគ្នា។

(ខ) $V_L$ លឿនផាសជាង $V_C$ ចំនួន $90^o$។

(គ) $V$ បង្កើតបានមុំផាស $\phi$ធៀបនឹង$V_R$។

(ឃ) $V_L - V_C$ មានផាសដូចគ្នាnនឹង $V_R$។

(ង) $V_C$ យឺតផាសជាង $V_R$ ចំនួន $90^o$។

៦. សៀគ្វី $RLC$ តជាស៊េរីមានអាំងឌុចទ័រមួយដែលមានអាំងឌុចតង់$L$ និងរេស៊ីស្តង់ $r$ កុងដង់សាទ័រកាប៉ាស៊ីតេ$C$ រេស៊ីស្តរ $R$ និងជនិតាដែលមានតង់ស្យុង $V$។ គេឲ្យ $V_L = 10.76\text{ V}$, $V_C = 5.68\text{ V}$, $V_R = 6.32\text{ V}$, និង $V_r = 3.75\text{ V}$ គណនាតង់ស្យុងនៃជនិតា។

៧. អាំងឌុចទ័រមួយមានអាំងឌុចតង់ $L = 150\ \mathrm{mH}$ និង$r = 200\ \Omega$ តជាស៊េរីនឹងកុងដង់សាទ័រមួយ រេស៊ីស្តរមួយនិងជនិតាមួយដែលមានប្រេកង់មុំ$\omega = 1000\ \mathrm{rad/s}$។ តង់ស្យុងឆ្លងកាត់អាំងឌុចទ័រត្រូវបានវាស់ឃើញគឺ $V_{ind} = 10.87\ \mathrm{V}, V_R = 4.65\ \mathrm{V}$ និង$V_C = 5.96\ \mathrm{V}$ ។ ដោយប្រើសមីការត្រឹមត្រូវ កំណត់$V_L, V_r$និង$V$។

## ៤. តម្រូវការសម្ភារ

- ជនិតាស៊ីនុយសូអ៊ីត ( ប្រេកង់ប្រែប្រួល អំព្លីទុតកំពូល-កំពូល 5V )
- ប្រអប់រេស៊ីស្តង់
- អាំងឌុចទ័រដែលស្គាល់អាំងឌុចតង់$L = 100\ \mathrm{mH}$ និង $r$( គប្បីប្រើពីពិសោធន៍មុនព្រោះស្គាល់តម្លៃហើយ )
- កុងដង់សាទ័រមាន $C = 1.00\ \mu\mathrm{F}$
- ដែកឈាន និងបន្ទាត់សម្រាប់គូរមុំ
- វ៉ុលម៉ែត្រចរន្តឆ្លាស់ ( មុលទីម៉ែត្រលេខ អាចវាស់ប្រេកង់ខ្ពស់បាន )

## ៥. ដំណើរការ

- **ចំពោះសៀគ្វី *RC***

ក. ភ្ជាប់កុងដង់សាទ័រជាស៊េរីនឹងជនិតាស៊ីនុយសូអ៊ីត និងប្រអប់រេស៊ីស្តង់ដើម្បីបង្កើតជាសៀគ្វីបង្ហាញដូចរូបទី១.១។ ដាក់ជនិតាចេញ ( Generator output )ទៅតង់ស្យុងអតិបរមា និងប្រើប្រេកង់ 250Hz ។ កត់ត្រាតម្លៃប្រេកង់នេះដាក់ក្នុងតារាងទិន្នន័យទី១។ ប្រើរេស៊ីស្តង់ 300 Ω ( ពីប្រអប់រេស៊ីស្តង់ ) និងកត់ត្រាតម្លៃវាដាក់ក្នុងតារាងទិន្នន័យទី១។

ខ. ប្រើវ៉ុលម៉ែត្រចរន្តឆ្លាស់ដើម្បីវាស់តង់ស្យុង និងកត់ត្រាតម្លៃដាក់ក្នុងតារាងទិន្នន័យត្រង់តង់ស្យុងនៃជនិតា $V$, តង់ស្យុងនៃកុងដង់សាទ័រ$V_C$, និងតង់ស្យុងនៃរេស៊ីស្តរ $V_R$។

គ. ធ្វើចំណុចក. និងខ. ឡើងវិញចំពោះករណី $R = 500\ \Omega, 700\ \Omega$ និង $900\ \Omega$ ។ តង់ស្យុងចេញនៃជនិតាអាចប្រែប្រួលតិចតួចតាមបម្រែបម្រួល$R$។ដូចនេះត្រូវវាស់តង់ស្យុងទាំងអស់ចំពោះតម្លៃនីមួយៗនៃ $R$។

ឃ.យកតម្លៃកាប៉ាស៊ីតេនៃកុងដង់សាទ័រពីលោកគ្រូរបស់អ្នកនិងសរសេរវាជាកុងដង់សាទ័រស្គាល់ ( $C_k$)។

- **ចំពោះសៀគ្វី *RLC***

ក. បង្កើតសៀគ្វី *RLC*តជាស៊េរីដូចបង្ហាញក្នុងរូបទី១២.២ ដោយប្រើកុងដង់សាទ័រ( $C_k$)មុន អាំងឌុចទ័រត្រូវស្គាល់តម្លៃ$L$និង $r$ប្រអប់រេស៊ីស្តង់ និងជនិតាស៊ីនុយសូអ៊ីត។ កត់ត្រាតម្លៃដាក់ក្នុងតារាងទិន្នន័យទី២។

ខ.ដាក់ជនិតាចេញ ( Generator output )ទៅតង់ស្យុងអតិបរមា និងប្រើប្រេកង់ 800Hz។ ប្រើរេស៊ីស្តង់ 200Ω ( ពីប្រអប់រេស៊ីស្តង់ ) និងកត់ត្រាតម្លៃតម្លៃប្រេកង់និងរេស៊ីស្តង់ដាក់ក្នុងតារាងទិន្នន័យទី២។

គ. ប្រើវ៉ុលម៉ែត្រចរន្តឆ្លាស់ដើម្បីវាស់តង់ស្យុងនៃជនិតា *V*, តង់ស្យុងនៃកុងដង់សាទ័រ$V_C$, តង់ស្យុងនៃរេស៊ីស្តរ $V_R$,និងតង់ស្យុងនៃអាំងឌុចទ័រ$V_{ind}$។ កត់ត្រាតម្លៃដាក់ក្នុងតារាងទិន្នន័យទី២។
ឃ. ធ្វើចំណុចក. ខ.និងគ. ឡើងវិញចំពោះ $R = 200\,\Omega$ និង *f*= 600 Hz។
ង. ធ្វើចំណុចក. ខ.និងគ. ឡើងវិញពីរដងទៀត ម្តង $R = 300\,\Omega$ និង *f*= 600 Hz និងម្តងទៀត $R = 300\,\Omega$ និង *f*= 800 Hz ។

## ការគណនា

❖ **ចំពោះសៀគ្វី *RC***

ក. ពីតម្លៃប្រេកង់ *f*ដែលស្គាល់ គណនាប្រេកង់មុំ $\omega = 2\pi f$។ កត់ត្រាតម្លៃ $\omega$ ដាក់ក្នុងតារាងគណនាទី១។
ខ. គណនាទំហំ $\sqrt{V_C^2 + V_R^2}$ ចំពោះករណីនីមួយៗ និងកត់ត្រារបស់វាដាក់ក្នុងតារាងគណនាទី១។ គណនាកម្រិតល្អៀងភាគរយនៃតម្លៃនីមួយៗដោយប្រៀបធៀបនឹងតម្លៃរង្វាស់តង់ស្យុងនៃជនិតា និងកត់ត្រាវាដាក់ក្នុងតារាងគណនាទី១។
គ. គណនាតម្លៃ *C* ពីតម្លៃ$V_R$និង$V_C$ដែលបានវាស់ចំពោះតម្លៃ *R*នីមួយៗ។ កត់ត្រាតម្លៃ *C* នីមួយៗក្នុងតារាងគណនាទី១។ គណនាតម្លៃមធ្យមនៃកាប៉ាស៊ីតេ($\overline{C}$) និងកម្រិតល្អៀងស្តង់ដា($\alpha_C$)ចំពោះតម្លៃបួននៃ *C* និងកត់ត្រាវាដាក់ក្នុងតារាងគណនាទី១។
ឃ. គណនាកម្រិតល្អៀងភាគរយនៃតម្លៃ ($\overline{C}$)ដោយប្រៀបធៀបទៅនឹងតម្លៃ( $C_k$)។

❖ **ចំពោះសៀគ្វី *RLC***

ក. ពីតម្លៃ *f* ដែលស្គាល់ក្នុងករណីនីមួយៗ គណនាប្រេកង់មុំ $\omega = 2\pi f$។ កត់ត្រាតម្លៃ $\omega$ ដាក់ក្នុងតារាងគណនាទី២។
ខ. គណនាតម្លៃទាំងបួននៃ $V_L$និង $V_r$ និងកត់ត្រាតម្លៃវាដាក់ក្នុងតារាងគណនាទី២។
គ.គណនាតម្លៃទាំងបួននៃ $V_L - V_C$និង $V_R + V_r$ និងកត់ត្រាតម្លៃវាដាក់ក្នុងតារាងគណនាទី២។
ឃ. គណនាតម្លៃនៃទំហំ $\sqrt{(V_L - V_C)^2 + (V_R + V_r)^2}$នីមួយៗនៃករណីទាំងបួន និងកត់ត្រាតម្លៃវាដាក់ក្នុងតារាងគណនាទី២។
ង. គណនាកម្រិតល្អៀងភាគរយនៃទំហំ$\sqrt{(V_L - V_C)^2 + (V_R + V_r)^2}$ដោយប្រៀបធៀបទៅនឹងតម្លៃដែលបានវាស់របស់តង់ស្យុងនៃជនិតា *V*។ កត់ត្រាតម្លៃនៃកម្រិតល្អៀងភាគរយដាក់ក្នុងតារាងគណនាទី២។

## ៦. លទ្ធផល

តារាងទិន្នន័យទី១( សៀគ្វីចរន្តឆ្លាស់ *RC* )

| ប្រេកង់ *f* = 250 Hz | $C_k =$ 1.0 $\mu F$ |
|---|---|

| $R$ (Ω) | 300 | 500 | 700 | 900 |
|---|---|---|---|---|
| $V_R$ (V) | | | | |
| $V_C$ (V) | | | | |
| $V$ (V) | | | | |

តារាងគណនាទី១( សៀគ្វីចរន្តឆ្លាស់ $RC$ )

| $\omega = 2\pi f = \quad 500\,\pi \quad$ rad/s | | | | |
|---|---|---|---|---|
| $V = \sqrt{V_R^2 + V_C^2}$ | | | | |
| % Error | | | | |
| $C$ (μF) $=\left(\frac{1}{\omega R}\right)\left(\frac{V_R}{V_C}\right)$ | | | | |
| $\bar{C}$= μF | $\alpha_C =$ μF | % Error $\bar{C}$= % | | |

តារាងទិន្នន័យទី២( សៀគ្វីចរន្តឆ្លាស់ $RLC$ )

| $r$ = 1.74 Ω | $L$ = 0.100 H | $C$ = 1.00 μF | | |
|---|---|---|---|---|
| $f$ (Hz) | 800 | 600 | 600 | 800 |
| $R$ (Ω) | 200 | 200 | 300 | 300 |
| $V$ (V) | | | | |
| $V_{ind}$ (V) | | | | |
| $V_C$ (V) | | | | |
| $V_R$ (V) | | | | |

តារាងគណនាទី២( សៀគ្វីចរន្តឆ្លាស់ $RLC$ )

| ω(Rad/s) | 1600п | 1200п | 1200п | 1600п |
|---|---|---|---|---|
| $V_L(\mathrm{V}) = V_{ind}\dfrac{\omega L}{\sqrt{(L\omega)^2 + r^2}}$ | | | | |
| $V_r(\mathrm{V}) = V_{ind}\dfrac{r}{\sqrt{(L\omega)^2 + r^2}}$ | | | | |
| $(V_L - V_C)(\mathrm{V})$ | | | | |
| $(V_R + V_r)(\mathrm{V})$ | | | | |

| | | | | |
|---|---|---|---|---|
| $\sqrt{(V_L - V_C)^2 + (V_R + V_r)^2}$ (V) | | | | |
| % Error ធៀបទៅ $V$ | | | | |
| $\phi = \tan^{-1}\left(\frac{V_L - V_C}{V_R + V_r}\right)$ (ដឺក្រេ) | | | | |
| អាំប៉េដង់ផ្ទួបនៃសៀគ្វី Z = $\sqrt{(R + r)^2 + \left(L\omega - \frac{1}{C\omega}\right)^2}$ | | | | |

❖ ការគណនាគំរូ

1. $\omega = 2\pi f =$
2. $V = \sqrt{V_C^2 + V_R^2} =$
3. $C = (1/\omega R)(V_R/V_C) =$
4. $V_L = (V_{\text{ind}})\left(\omega L/\sqrt{(\omega L)^2 + r^2}\right) =$
5. $V_r = (V_{\text{ind}})\left(r/\sqrt{(\omega L)^2 + r^2}\right) =$
6. $V = \sqrt{(V_L - V_C)^2 + (V_R + V_r)^2} =$

## ៧. សន្និដ្ឋាន

តាមលទ្ធផលពិសោធន៍ខាងលើ យើងឃើញថា **ក្នុងសៀគ្វី** *RC* ផាសរវាងតង់ស្យុងឆ្លងកាត់រេស៊ីស្តរ ($V_R$) និង តង់ស្យុងឆ្លងកាត់កុងដង់សាទ័រ ($V_C$) ខុសគ្នាចំនួន…………….និង($V_R$) …………………ជាង($V_C$) ចំនួន…………។

កាប៉ាស៊ីតេនៃកុងដង់សាទ័រមានតម្លៃ *C* = ……………… ដូចនេះមានន័យថាវាអាចត្រូវបានគណនា។

ចំណែកឯ**ក្នុងសៀគ្វី** *RLC* ផាសរវាងតង់ស្យុងឆ្លងកាត់រេស៊ីស្តរ ($V_R$) និងតង់ស្យុងឆ្លងកាត់អាំងឌុចទ័រ ($V_L$) ខុសគ្នាចំនួន…………….និង($V_R$) …………………ជាង($V_L$)ចំនួន…………។ ផាសរវាងតង់ស្យុងឆ្លងកាត់រេស៊ីស្តរ ($V_R$)និងតង់ស្យុងឆ្លងកាត់កុងដង់សាទ័រ ($V_C$) ខុសគ្នាចំនួន…………….និង($V_R$) …………………ជាង($V_C$)ចំនួន…………។ ម្យ៉ាងវិញទៀតផាសរវាងតង់ស្យុងនៃគោលជនិតា($V$) និងចរន្ត($I$) ឆ្លងកាត់សៀគ្វីអាចត្រូវបានរកឃើញតាមទំនាក់ទំនង $\phi = \tan^{-1}\left(\frac{V_L - V_C}{V_R + V_r}\right)$។ ដូចនេះមានទំនាក់ទំនងផាសរវាង($V_R$), ($V_L$) និង($V_C$) និង ($V$) និងចរន្ត($I$) អាចត្រូវបានកំណត់ មានន័យថាសម្មតិកម្មត្រូវបានគាំទ្រដោយពិសោធន៍។

## ៨. ពិភាក្សា

ក. ក្នុងសៀគ្វី *RC* ខាងលើ ផាសរវាងតង់ស្យុងនៃជនិតា និងចរន្តរត់ក្នុងសៀគ្វីខុសគ្នាប៉ុន្មានដឺក្រេ និងមួយណាលឿនផាសជាង។ គណនាអាំប៉េដង់នៃកុងដង់សាទ័រ និងអាំប៉េដង់ផ្តួបរបស់សៀគ្វី។

ខ. ក្នុងសៀគ្វី *RLC* ខាងលើដែលអ្នកទើបបានធ្វើពិសោធរួច ចូរគណនាអាំប៉េដង់នៃកុងដង់សាទ័រ, អាំប៉េដង់នៃបូប៊ីន និងអាំប៉េដង់ផ្តួបរបស់សៀគ្វី។

# ដំណើរការសមាសធាតុអេឡិចត្រូនិក

## វត្ថុបំណង:

- គូសនិមិត្តសញ្ញានៃគ្រឿងអេឡិចត្រូនិចផ្សេងៗទៀតបានត្រឹមត្រូវ។
- ពោលនិយមន័យសីមីកុងឌុចទ័របានច្បាស់លាស់។
- ដំឡើង និងពន្យល់ដំណើរការរបស់សៀគ្វីផ្សេងៗបានត្រឹមត្រូវ។

## ១. និមិត្តសញ្ញានៃគ្រឿងអេឡិចត្រូនិក



បន្ទះសៀគ្វី










រូបទី3.46 ( ក )　　　　　　　　　　　　　　　　　( ខ )

យើងនឹងលើកយកធាតុ( គ្រឿង )មួយចំនួនមកបង្ហាញ រួចដំឡើងដើម្បីបង្កើតសៀគ្វី ហើយអ្នកត្រូវពិនិត្យមើលថាតើវាដំណើរការយ៉ាងដូចម្តេច។ ការដំឡើងសៀគ្វីចែកចេញជាពីរ៖ ទី១ ប្រើតាមកម្មវិធី E-Lab ដែលដំណើរការដោយ Software និងទី២ ប្រើបន្ទះសៀគ្វីជាក់ស្តែង។

## ២. ដំណើរការប៉ូតង់ស្យូម៉ែត្រ ឬរ៉ូលូម

រូប និងនិមិត្តសញ្ញា






រូបទី3.47 (ក) ប្រភេទផ្សេងនៃប៉ូតង់ស្យូម៉ែត្រ (ខ)និមិត្តសញ្ញា

តើប៉ូតង់ស្យូម៉ែត្រជាអ្វី និងវាដំណើរការដូចម្តេច?

❖ វិធីទី១៖ ការប្រើ E-Lab ដោយដំណើរការ Software

- **តម្រូវការសម្ភារៈ ៖** (ទាញយកគ្រឿងពីSoftwareដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក) ប៉ូតង់ស្យូម៉ែត្រ(Pot-HG) រេស៊ីស្តង់(Res) LEDពណ៌លឿង (LED-y) និងបាតឺរី(Battery)
- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វីដូចរូបទី3.48 និងពិនិត្យមើលពន្លឺLEDដោយមួលជើងCនៃប៉ូតង់ស្យូម៉ែត្រមកទីតាំង ផ្សេងៗគ្នា




រូបទី3.48 (ក)រេស៊ីស្តង់ប៉ូ. 0% (ខ)រេស៊ីស្តង់ប៉ូ. 1%នៃ100k (គ) រេស៊ីស្តង់ប៉ូ. 2%នៃ100k

- **សង្កេត៖** រូប(ក)អំពូលLEDភ្លឺខ្លាំង (ខ)អំពូលLEDភ្លឺខ្សោយ (គ)អំពូលLEDភ្លឺខ្សោយខ្លាំង ឬរលត់
- **វិភាគ និងសន្និដ្ឋាន៖**

**វិភាគ៖** ទីតាំងជើងC

- ត្រួតគ្នានឹងជើងA ធ្វើឱ្យអំពូលLEDភ្លឺខ្លាំង រេស៊ីស្តង់ប៉ូតង់ស្យូម៉ែត្រតូចបង្ហាញ 0% (0 Ω)។

- ខិតទៅខាងស្តាំជើងA អំពូលLEDភ្លឺខ្សោយ រេស៊ីស្តង់ប៉ូតង់ស្យូម៉ែត្រកើនឡើង1% (1000 Ω)។

- ខិតទៅខាងស្តាំជើងAវែងជាងមុន អំពូលLEDភ្លឺខ្សោយខ្លាំង ឬរលត់ បញ្ជាក់ថារេស៊ីស្តង់ប៉ូតង់ស្យូម៉ែត្រកើនឡើងខ្លាំងជាងមុន 2% (2000 Ω)។

**សន្និដ្ឋាន៖** តាមការពិសោធខាងលើប៉ូតង់ស្យូម៉ែត្រជាគ្រឿងអេឡិចត្រូនិកដែលមាន*រេស៊ីស្តង់ប្រែប្រួល*ហើយត្រូវបានប្រើដើម្បីកម្រិត*ចរន្តវត់ឆ្លងកាត់*សៀគ្វី។

❖ វិធីទី២៖ ការប្រើបន្ទះសៀគ្វី

- **តម្រូវការសម្ភារៈ ៖**
  ប៉ូតង់ស្យូម៉ែត្រ100kΩ រេស៊ីស្តង់220Ω LED ខ្សែភ្លើងសម្រាប់ដោត បន្ទះសៀគ្វី ថ្មពិល9.0 V និងប្រដាប់ដាក់ថ្មពិល

សម្គាល់៖ LED មានជើងពីរ ជើងមួយវែងជាអាណូត(A)(តួជាកងមូល) និងជើងមួយខ្លីជាកាតូត(C) (តួជាផ្ទៃរាប)។ ចរន្តអគ្គិសនីចូលតាមជើង A និងចេញតាមជើង C និងបើប្រាសមកវិញវាមិនដំណើរការទេ។

- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វី និងធ្វើពិសោធដូចរូប3.48ខាងលើ។ អ្នកអាចយកខ្សែដោតមួយសម្រាប់ធ្វើជាកុងតាក់។




**៣. ដំណើរការរេស៊ីស្តង់ដែលអាស្រ័យនឹងពន្លឺ(LDR)**

LDR ជាភាសាអង់គ្លេសគឺ Light Dependent Resistor (LDR) ឬអាចហៅម៉្យាងទៀតថាជាផូតូសែល (Photocell) ។






រូបទី3.49 (ក) (ខ) និមិត្តសញ្ញា

តើ LDR ជាអ្វី និងវាដំណើរការដូចម្តេច? (ដំឡើងសៀគ្វីដូចរូបទី3.50)

❖ វិធីទី១៖ ការប្រើ E-Lab ដោយដំណើការ Software

- **តម្រូវការសម្ភារៈ ៖** (ទាញយកគ្រឿងពីSoftwareដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក) រេស៊ីស្តង់ដែលអាស្រ័យនឹងពន្លឺ(LDR) LEDពណ៌លឿង (LED-y) និងបាតឺរី(Battery)
- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វីដូចរូបទី3.50 និងពិនិត្យពន្លឺLEDដោយដាក់មុខLDR ដូចរូប(ក) (ខ) និង(គ)




រូបទី 3.50 (ក)គ្របមុខ LDR (ខ) )មុខLDR ត្រូវពន្លឺខ្សោយ (គ)មុខLDR ត្រូវពន្លឺខ្លាំង

**សង្កេត៖** រូប(ក)អំពូលLEDមិនភ្លឺទេ (ខ)អំពូលLEDឆេះភ្លឺខ្សោយ និង(គ)អំពូលLEDឆេះភ្លឺខ្លាំង

- **វិភាគ សន្និដ្ឋាន៖**

**វិភាគ៖**

- គ្របមុខLDR ឬLDR នៅទីងងឹត អំពូលLEDមិនភ្លឺទេ បញ្ជាក់ថារេស៊ីស្តង់LDR ធំខ្លាំង។

- មុខLDR ត្រូវពន្លឺខ្សោយ( ពន្លឺក្នុងបន្ទប់ ) អំពូលLEDឆេះភ្លឺខ្សោយ បញ្ជាក់ថារេស៊ីស្តង់LDRថយចុះមកតម្លៃតូចជាងមុន។

- មុខLDR ត្រូវពន្លឺខ្លាំង (ត្រូវពន្លឺថ្ងៃ ឬពន្លឺភ្លើងពិលទូរស័ព្ទ ) អំពូលLEDឆេះភ្លឺខ្លាំង បញ្ជាក់ថារេស៊ីស្តង់LDR ថយចុះខ្លាំង( តម្លៃតូចខ្លាំង )។

**សន្និដ្ឋាន៖** តាមការពិសោធខាងលើLDRជាគ្រឿងអេឡិចត្រូនិកដែលមាន *រេស៊ីស្តង់ប្រែប្រួល* ដោយអាស្រ័យលើអាំងតង់ស៊ីតេពន្លឺដែលចាំងប៉ះលើផ្ទៃមុខរបស់វា។ នៅទីងងឹត LDR *មានរេស៊ីស្តង់ធំណាស់* ( ស្ថិតក្នុងកម្រិត MΩ ) ប៉ុន្តែនៅទីភ្លឺ LDR *មានរេស៊ីស្តង់តូច* ។ LDRត្រូវបានគេប្រើធ្វើជា *សិនស័រពន្លឺ*( Light Sensor )។

❖ វិធីទី២៖ ការប្រើបន្ទះសៀគ្វី

- **តម្រូវការសម្ភារៈ ៖**

LDR LED ខ្សែភ្លើងសម្រាប់ដោត ពន្លឺភ្លើងពិល( ពន្លឺពិលទូរស័ព្ទ ) បន្ទះសៀគ្វី ថ្មពិល9.0 V និងប្រដាប់ដាក់ថ្មពិល

- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វី និងធ្វើពិសោធដូចរូប3.50ខាងលើ។ អ្នកអាចយកខ្សែដោតមួយសម្រាប់ធ្វើជាកុងតាក់។




### ៤ ដំណើរការរបស់កុងដង់សាទ័រ

រូប និងនិមិត្តសញ្ញា







រូបទី3.51 (ក) (ខ) និម្មិតសញ្ញា

តើកុងដង់សាទ័រជាអ្វី និងវាដំណើរការដូចម្តេច? (ដំឡើងសៀគ្វីដូចរូបទី3.52)

❖ វិធីទី១៖ ការប្រើ E-Lab ដោយដំណើរការ Software

- **តម្រូវការសម្ភារៈ ៖** (ទាញយកគ្រឿងពីSoftwareដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក) កុងដង់សាទ័រ(cap) LEDពណ៌លឿង (LED-y) និងបាតឺរី(Battery)
- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វីដូចរូបទី3.52 និងពិនិត្យពន្លឺLEDដោយដាក់មុខLDR ដូចរូប(ក) (ខ) និង(គ)




(ក)




(ខ)




រូបទី3.52 (គ)

**សង្កេត៖**រូបទី3.52 (ក)ខណៈកុងបិទតាក់ LED ឆេះភ្លឺខ្សោយ (ខ)ខណៈបន្ទាប់ LED ឆេះភ្លឺខ្លាំងជាង (គ) ខណៈបើកកុងតាក់ LED ឆេះភ្លឺខ្សោយវិញ និងភ្លឺខ្សោយជាបន្តបន្ទាប់ ចុងបញ្ចប់រលត់។

- **វិភាគ សន្និដ្ឋាន៖**

**វិភាគ៖**

- រូបទី3.52(ក)ខណៈកុងបិទតាក់ LED ឆេះភ្លឺខ្សោយ ដោយសារតែ*ចរន្តអគ្គិសនីចេញពីគោល (+) នៃបាតឺរីឆ្លងកាត់កុងតាក់មកដល់A។ ត្រង់A ចរន្តបែងចែកជាពីរ មួយចូលមកផ្ទុកកុងដង់សាទ័រ$C_1$និងមួយទៀតឆ្លងកាត់ $R_2$LED B និងបន្តទៅដល់គោល(-)នៃបាតឺរី។កុងដង់សាទ័របន្តផ្ទុកនិងLED បន្តភ្លឺខ្លាំងឡើងៗ។* - រូប(ខ)ខណៈបន្ទាប់ LED ឆេះភ្លឺខ្លាំងជាងដោយសារតែ *ពេលកុងដង់ផ្ទុកពេញគ្មានចរន្តឆ្លងកាត់កុងដង់សាទ័រទៀតទេ ចរន្តទាំងអស់ត្រូវឆ្លងកាត់ LED ចំណុចB និងទៅដល់គោល (-) នៃបាតឺរី។*

- រូប(គ) ខណៈបើកកុងតាក់ ភ្លាមនោះLED ឆេះភ្លឺខ្សោយបន្តិចវិញ និងបន្តចុះខ្សោយ ចុងបញ្ចប់ក៏រលត់ដោយសារតែ*កុងដង់សាទ័រផ្ទេរបន្ទុកអគ្គិសនីហើយថាមពលរបស់វាថយចុះជាបន្តបន្ទាប់ ចុងបញ្ចប់ក៏អស់ ហើយអំពូលLEDលែងភ្លឺ។*

**សន្និដ្ឋាន៖** តាមការពិសោធខាងលើបង្ហាញថា កុងដង់សាទ័រជាគ្រឿងអេឡិចត្រូនិកដែលត្រូវបានប្រើដើម្បី*ផ្ទុក-ផ្ទេរបន្ទុកអគ្គិសនី*។ វាមាននាទីជា*ប្រភពអគ្គិសនីបណ្តោះអាសន្ន*។

សម្គាល់៖ កុងដង់សាទ័រអាចត្រូវបានប្រើដើម្បីច្រោះចរន្ត(Filter)ពេលដែលបំប្លែងពីរន្តឆ្លាស់ទៅចរន្តជាប់ និងបម្រែបម្រួលប្រេកង់សម្លេង ឬបង់(ប៉ុស្តិ៍)វិទ្យុ...។

❖ វិធីទី២៖ ការប្រើបន្ទះសៀគ្វី

- **តម្រូវការសម្ភារៈ ៖**

កុងដង់សាទ័រ(1000 $\mu$F,16 V) រេស៊ីស្តង់ពីរ(220Ω និង1kΩ) LED ខ្សែភ្លើងសម្រាប់ដោត បន្ទះសៀគ្វី ថ្មពិល9.0 V និងប្រដាប់ដាក់ថ្មពិល

- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វី និងធ្វើពិសោធដូចរូប3.52ខាងលើ។ អ្នកអាចយកខ្សែដោតមួយសម្រាប់ធ្វើជាកុងតាក់។

## ៥ ដំណើរការរបស់ឌីយ៉ូត




រូប និងនិមិត្តសញ្ញា




រូបទី3.53 (ក)ឌីយ៉ូតស៊ីលីស្យូម (ខ) សែនឺរ(ក្រហម) (គ) សែម៉ាញ៉ូម(បៃតង)(ឃ) និមិត្តសញ្ញា

តើឌីយ៉ូតជាអ្វី វាដំណើរការដូចម្ដេច និងគេប្រើវាសម្រាប់ធ្វើអ្វី?

## ឌីយ៉ូតស៊ីលីស្យូម

(ដំឡើងសៀគ្វី រូបទី3.54, 3.55 និង 3.56 )

❖ វិធីទី១៖ ការប្រើ E-Lab ដោយដំណើការ Software

- **តម្រូវការសម្ភារៈ ៖** (ទាញយកគ្រឿងពីSoftwareដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក)

ឌីយ៉ូត(1N4001) ស្ពានឌីយ៉ូត(Bridge diode) LEDពណ៌លឿង(LED-y) រេស៊ីស្តរ(RES) កុងដង់សាទ័រ(cap) បាតឺរី(Battery)និងប្រភពចរន្តឆ្លាស់(Alternator ឬAlt)

**សម្គាល់៖** ពេលធ្វើពិសោធ អ្នកចង់មើលក្រាបសំទួយកន្លះខួប ត្រូវចុចលើ Virtual instruments mode រួចយក Oscilloscope និងដំឡើងដូចរូបទី3.55 បន្ទាប់មកចុច Run។ តែត្រូវរយៈពេលមក0.24 ms នោះអ្នកនឹងទទួលបានក្រាបដូចរូបទី3.55(ខ)។ស្រដៀងគ្នាដែរចំពោះក្រាបផ្សេងៗទៀត។

- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វីដូចរូបទី3.54, 3.55, 3.56 រៀងគ្នា និងធ្វើពិសោធម្តងមួយៗ និងពិនិត្យពន្លឺLED ឬក្រាបតាមរូបរបស់វាដាក់ស្តែងតាមលំដាប់លំដោយ។

ក. ប្រើជាមួយចរន្តជាប់ រូបទី3.54







(ក) ចរន្តឆ្លងកាត់សៀគ្វីបាន LEDភ្លឺ (ខ) ចរន្តមិនអាចឆ្លងកាត់សៀគ្វីបានទេ LEDរលត់

ខ.ប្រើជាមួយចរន្តឆ្លាស់ រូបទី3.55










(ក)ប្រភពចរន្តឆ្លាស់ (ខ)សំទួយកន្លះខួប

រូបទី3.56







(ក)សំទួយពេញ១ខួប




(ខ) ដាក់កុងដង់សាទ័រ

**សង្កេត៖**

- រូប3.54(ករណីប្រភពចរន្តជាប់) (ក) អាណូតA ភ្ជាប់ទៅគោល (+) និងកាតូតCភ្ជាប់ទៅគោល (-) នៃថ្មពិល LED ឆេះភ្លឺ និង(ខ)ប្រាសមកវិញ LED មិនឆេះភ្លឺទេ។

- រូប3.55(ករណីប្រភពចរន្តឆ្លាស់) (ក)(មិនទាន់ដាក់ឌីយ៉ូត)ភ្ជាប់ជើងអូស៊ីឡូស្កូបរវាងប្រភពចរន្តឆ្លាស់ និងរេស៊ីស្តរ10 kΩ ក្រាបជាចរន្តឆ្លាស់ និង(ខ)(ដាក់ឌីយ៉ូត) ភ្ជាប់ជើងអូស៊ីឡូស្កូបរវាងឌីយ៉ូតនិងរេស៊ីស្តរ ក្រាបជាជីពចរលេក(សំទួយកន្លះខួប)។

- រូប3.56(ករណីចរន្តឆ្លាស់) (ក)ដាក់ស្ពានឌីយ៉ូតសេរីជាមួយនឹងរេស៊ីស្តង់10 kΩ (មិនទាន់ភ្ជាប់កុងដង់សាទ័រ) ភ្ជាប់ជើងអូស៊ីឡូស្កូបរវាងស្ពានឌីយ៉ូត និងរេស៊ីស្តង់ ក្រាបជាចរន្តជាប់(សំទួយពេញមួយខួប) ប៉ុន្តែនៅមានលំយោល (នៅមានតង់ស្យុង ឬចរន្តស្មើសូន្យ)។ រូប(ខ) តកុងដង់សាទ័រ 100 μFជាខ្នែងនឹងរេស៊ីស្តរ (ករណីនេះគេហៅថាច្រោះ) ក្រាបជាចរន្តជាប់រាងអង្កាញ់ៗ ប៉ុន្តែគ្មានតង់ស្យុងឬចរន្តសូន្យទេ។

- **វិភាគ សន្និដ្ឋាន៖**

**វិភាគ៖** រូប3.54 (ក) LED ឆេះភ្លឺ ដោយសារ *ឌីយ៉ូតស្ថិតក្នុងទិសដៅចរន្តឆ្លងកាត់វាឬប៉ូលកម្មស្រប* និង(ខ) LED មិនឆេះភ្លឺទេ ដោយសារ *ឌីយ៉ូតស្ថិតក្នុងទិសដៅផ្ទុយពីចរន្តឆ្លងកាត់វាឬប៉ូលកម្មប្រាស* ។

- រូប3.55 (ក) ក្រាបជាចរន្តឆ្លាស់ ដោយសារ *ចរន្តឆ្លាស់ប្តូរទិសដៅពីរដងក្នុងមួយខួប*និង(ខ) ក្រាបជាជីពចរលេក(សំទួយកន្លះខួប)ដោយសារ *ឌីយ៉ូតក្នុងប៉ូលកម្មប្រាសមិនអនុញ្ញាតិឱ្យចរន្តឆ្លងកាត់*។

- រូប3.56 (ក) ក្រាបជាចរន្តជាប់(សំទួយពេញមួយខួប) ប៉ុន្តែនៅមានលំយោល (នៅមានតង់ស្យុង ឬចរន្តស្មើសូន្យ) ដោយសារ *កន្លះខួបលើ ឌីយ៉ូត$D_1$ ឱ្យចរន្តឆ្លងកាត់ និងកន្លះខួបក្រោម ឌីយ៉ូត$D_2$ ឱ្យចរន្តឆ្លងកាត់ និងខួបបន្តបន្ទាប់គ្រាន់តែធ្វើសារឡើងវិញប៉ុណ្ណោះ*។ រូប(ខ) ក្រាបជាចរន្តជាប់រាងអង្កាញ់ៗ ប៉ុន្តែគ្មានតង់ស្យុងឬចរន្តសូន្យទេ ដោយសារតែ *ពេលកុងដង់សាទ័រផ្ទុកពេញវាចាប់ផ្តើមផ្ទេរ វាផ្ទេរបានត្រឹមតែ 1/3 នៃតង់ស្យុងសរុបរបស់វាប៉ុណ្ណោះ វាក៏ចាប់ផ្តើមផ្ទុកវិញ និងធ្វើឡើងវិញជាបន្តបន្ទាប់*។

**សន្និដ្ឋាន៖** ផ្អែកតាមពិសោធន៍ខាងលើ ឌីយ៉ូត*គឺជាគ្រឿងអេឡិចត្រូនិច និងសឺមីកុងឌុចទ័រដែលមានគោលពីរ មួយជាអាណូត(A)និងមួយទៀតជាកាតូត(C) ហើយវាអាចឱ្យចរន្តឆ្លងកាត់តែតាមទិសដៅពីអាណូត*

*(A)ទៅកាតូត(C)ប៉ុណ្ណោះ។* គេប្រើវាដើម្បីការពារសៀគ្វីពីការឆេះខូចពេលចាប់ប្រភពអគ្គិសនីបញ្ច្រាសគោល(ប៉ូល) និងសំទួយចរន្តពីAC ទៅDC។

សឺមីកុងឌុចទ័រ(semi-conductor)ជារូបធាតុចម្លងអគ្គិសនីដែលស្ថិតរវាងអង្គធាតុចម្លង និងអ៊ីសូឡង់អគ្គិសនី រួមមាន៖ ស៊ីលីស្យូម(Si) ហ្គេម៉ានីញ៉ូម(Ge) សេលេញ៉ូម(Se) កាបូន(C)...។ យើងនឹងសិក្សាពិស្តានៅសាកលវិទ្យាល័យ។

❖ វិធីទី២៖ ការប្រើបន្ទះសៀគ្វី

- **តម្រូវការសម្ភារៈ ៖**

ឌីយ៉ូត៤(1N4001) និង/ឬស្ពានឌីយ៉ូត LED រេស៊ីស្តរ២(220Ω និង5kΩ) កុងដង់សាទ័រ100μF បន្ទះសៀគ្វី ខ្សែភ្លើងសម្រាប់ដោត ថ្មពិល9.0 V ប្រដាប់ដាក់(ថ្មពិល) និងប្រភពចរន្តឆ្លាស់ តង្កៀបមានក្រចាប់។

**សម្គាល់៖** ពេលធ្វើពិសោធ អ្នកចង់មើលក្រាបត្រូវប្រើ Oscilloscope។

- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វីដូចរូបទី3.54, 3.55, 3.56 ខាងលើរៀងគ្នា និងធ្វើពិសោធម្តងមួយៗ និងពិនិត្យពន្លឺLED ឬក្រាបតាមរូបរបស់វាជាក់ស្តែងតាមលំដាប់លំដោយ។




## ៦. ដំណើរការរបស់ត្រង់ស៊ីស្ទរ

រូប និងនិមិត្តសញ្ញា






រូបទី3.57 (ក)ប្រភេទផ្សេងៗនៃត្រង់ស៊ីស្ទរ (ខ) និមិត្តសញ្ញា

តើត្រង់ស៊ីស្ទរជាអ្វី មានប៉ុន្មានប្រភេទ ដំណើរការដូចម្តេច និងគេប្រើវាសម្រាប់ធ្វើអ្វី?

❖ វិធីទី១៖ ការប្រើ E-Lab ដោយដំណើការ Software

- **តម្រូវការសម្ភារៈ ៖** (ទាញយកគ្រឿងពីSoftwareដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក)

ត្រង់ស៊ីស្ទរ២(2N3904, 2N3906) LEDពណ៌លឿង(LED-y) រេស៊ីស្តរ២(RES) កុងតាក់កណ្តឹង កុងតាក់(SW) និងបាតឺរី(Battery)

- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វីដូចរូបទី3.58 រៀងគ្នា និងធ្វើពិសោធម្តងមួយៗ និងពិនិត្យពន្លឺLED




(ក) ប្រើ NPN ជាកុងតាក់បិទ




(ខ) ប្រើ NPN ជាកុងតាក់បើក




រូបទី3.58 (គ) ប្រើ PNP ជាកុងតាក់បិទ




(ឃ) ប្រើ PNP ជាកុងតាក់បើក

**សង្កេត៖**ត្រង់ស៊ីស្ទរមានពីរប្រភេទគឺ NPN និងPNP ហើយវាមានជើង៣ ជើងបាសB(Base) ជើងកូឡិចទ័រ C(Collector) និងជើងអេមីទ័រE(Emitter)។

រូបទី3.58 (ក) បិទកុងតាក់(SW) អំពូលLEDឆេះភ្លឺ (ខ) បើកកុងតាក់(SW) អំពូលLEDរលត់ (គ) បិទកុងតាក់(SW) អំពូលLEDឆេះភ្លឺ (ឃ)បើកកុងតាក់(SW) អំពូលLEDរលត់។

- **វិភាគ សន្និដ្ឋាន៖**

**វិភាគ៖** រូប3.58

-(ក) បិទកុងតាក់ (SW) ចរន្តតូចមួយឆ្លងកាត់ $R_1$ (រេស៊ីស្តង់ធំ) បន្តឆ្លងកាត់ជើង B របស់ត្រង់ស៊ីស្ទ័រ (ជើង B ភ្ជាប) ត្រង់ស៊ីស្ទ័រ NPN ដំណើរការ នោះចរន្តយ៉ាងធំឆ្លងកាត់LED $R_2$ជើងC ចូលត្រង់ស៊ីស្ទ័រចេញតាមជើង E និងទៅដល់គោល (-) នៃថ្មពិល អំពូលLEDឆេះភ្លឺ។ ករណីនេះ គេថា*ត្រង់ស៊ីស្ទ័រNPN មាននាទីជាកុងតាក់បិទ*។ ចរន្តចេញតាមជើងE, $I_E = I_B + I_C$ ដែល $I_B, I_C$ចរន្តចូលតាមជើងB និងCរៀងគ្នា។

-(ខ) បើកកុងតាក់ (SW) គ្មានចរន្តឆ្លងកាត់ជើង B របស់ត្រង់ស៊ីស្ទ័រNPN (ជើងBមិនភ្ជាប) ត្រង់ស៊ីស្ទ័រ មិនដំណើរការ នោះអំពូលLEDរលត់។ ករណីនេះ គេថា*ត្រង់ស៊ីស្ទ័រNPN មាននាទីជាកុងតាក់បើក*។

-(គ) បិទកុងតាក់ (SW) ចរន្តតូចមួយឆ្លងកាត់ជើង B របស់ត្រង់ស៊ីស្ទ័រ (ជើងB ភ្ជាប) ត្រង់ស៊ីស្ទ័រ PNP ដំណើរការ នោះចរន្តយ៉ាងធំចូលតាមជើងEនៃត្រង់ស៊ីស្ទ័រ រួចចេញតាមជើងCឆ្លងកាត់LED ទៅដល់ថ្នាំង និងបន្តទៅគោល (-) នៃថ្មពិល អំពូលLEDឆេះភ្លឺ។ ករណីនេះ គេថា*ត្រង់ស៊ីស្ទ័រPNP មាននាទីជាកុងតាក់បិទ*។ ចរន្តចូលតាមជើងE, $I_E = I_B + I_C$ ដែល $I_B, I_C$ចរន្តចេញតាមជើងB និងCរៀងគ្នា។

-(ខ) បើកកុងតាក់ (SW) គ្មានចរន្តឆ្លងកាត់ជើង B របស់ត្រង់ស៊ីស្ទ័រPNP (ជើងBមិនភ្ជាប) ត្រង់ស៊ីស្ទ័រ មិនដំណើរការ នោះអំពូលLEDរលត់។ ករណីនេះ គេថា*ត្រង់ស៊ីស្ទ័រPNP មាននាទីជាកុងតាក់បើក*។

**សន្និដ្ឋាន៖** ត្រង់ស៊ីស្ទ័រគឺ *ជាគ្រឿងស៊ីមីកុងឌុចទ័រដែលមានជើង៣ ជើងបាស(B) ជើងកូឡិចទ័រ(C) និងជើងអេមីទ័រ(E)។ត្រង់ស៊ីស្ទ័រមានពីរប្រភេទគឺ NPN និងPNP។ វាដំណើរការកាលណាជើង(B)ភ្ជាបចរន្ត គេថាវាជាកុងតាក់បិទ និងវាមិនដំណើរការកាលណាជើង(B)គ្មានចរន្ត គេថាវាជាកុងតាក់បើក។ គេប្រើវាដើម្បីពង្រីកស៊ីញ៉ាល់អគ្គិសនី។*

❖ វិធីទី២៖ ការប្រើបន្ទះសៀគ្វី

- **តម្រូវការសម្ភារៈ ៖**

ត្រង់ស៊ីស្ទរ២( 2N3904, 2N3906 ) LED រេស៊ីស្តរ២( 220Ω, 1kΩ ) កុងតាក់កណ្ដឹង កុងតាក់( ប្រើខ្សែភ្លើង ) ខ្សែភ្លើងដោត បន្ទះសៀគ្វី ថ្មពិល9.0 V និងប្រដាប់ដាក់( ថ្មពិល )។

- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វីដូចរូបទី3.58 ខាងលើរៀងគ្នា និងធ្វើពិសោធម្តងមួយៗ និងពិនិត្យពន្លឺLED ។




NPN




PNP

- ត្រង់ស៊ីស្ទរគូដាលីងតុន ( Darlington pair )







រូបទី3.59 ( ក ) គូដាលីងតុនNPN ( ខ )គូដាលីងតុនPNP

បើកម្រិតពង្រីកចរន្ត NPN1, $h_{FE1} = 220$ និង NPN2, $h_{FE2} = 40$

កម្រិតពង្រីកចរន្តសរុបនៃគូដាលីងតុនគឺ $h_{FE} = h_{FE1} \times h_{FE2} = 220 \times 40 = 8800$ ។

**ការវាស់ជើងរបស់ត្រង់ស៊ីស្ទរដោយប្រើមុលទីម៉ែត្រ៖**

**ចំពោះNPN (ជើង**

- ជ្រើសរើសកាលីបជាឌីយ៉ូតនៃមុលទីម៉ែត្រ។
- តេស្ត(វាស់)គូជើងរបស់ត្រង់ស៊ីស្ទរម្តងពីរៗ(សរុប6ដង) និងចងចាំថាជើងមុលទីម៉ែត្រក្រហម(+) និងខ្មៅ(-)។




- គូជើងបាស-កូឡិចទ័រ (BC) មាននាទីជាឌីយ៉ូត វាដំណើរការតែមួយទិសដៅប៉ុណ្ណោះគឺ (+)ចុចលើB និងខ្មៅ (-)លើC។ ប្រាសមកវិញ វាមិនដំណើរការទេ។
- គូជើងបាស-អេមីទ័រ (BE) មាននាទីជាឌីយ៉ូត វាដំណើរការតែមួយទិសដៅប៉ុណ្ណោះគឺ (+)ចុចលើB ដដែល និងខ្មៅ (-)លើE។ ប្រាសមកវិញ វាមិនដំណើរការទេ។
- គូជើងកូឡិចទ័រ-អេមីទ័រ (CE) វាមិនដំណើរការទាំងពីរផ្លូវ។
- ស្គាល់ជើងB ជើងជាប់គ្នាជាជើងC និងជើងបន្ទាប់ជាជើងE។ បើជើងB នៅកណ្តាល នោះជើងC នៅខាងស្តាំ និងជើងEខាងឆ្វេង (មើល រូបទី3.60)។

**ចំពោះPNP**

- ជ្រើសរើសកាលីបជាឌីយ៉ូតនៃមុលទីម៉ែត្រ។
- គូជើងបាស-កូឡិចទ័រ (BC) មាននាទីជាឌីយ៉ូត វាដំណើរការតែមួយទិសដៅប៉ុណ្ណោះគឺ ខ្មៅ(-)ចុចលើB និងក្រហម(+)លើC។ ប្រាសមកវិញ វាមិនដំណើរការទេ។




- គូជើងបាស-អេមីទ័រ (BE) គឺ ខ្មៅ(-)ចុចលើBដដែល និងក្រហម(+)លើE។ ប្រាសមកវិញ វាមិនដំណើរការទេ។
- គូជើងកូឡិចទ័រ-អេមីទ័រ (CE) វាមិនដំណើរការទាំងពីរផ្លូវ។
- ស្គាល់ជើងB ជើងជាប់គ្នាជាជើងC និងជើងបន្ទាប់ជាជើងE។ បើជើងB នៅកណ្តាល នោះជើងC នៅខាងស្តាំ និងជើងEខាងឆ្វេង (មើល រូបទី3.61)។

**សម្គាល់៖** លេខតួ និងជើងរបស់ ត្រង់ស៊ីស្ទរ NPN មួយចំនួន




រូបទី3.60

លេខតួ និងជើងរបស់ ត្រង់ស៊ីស្ទរ PNP មួយចំនួន

រូបទី3.61




## ៧. ដំណើរការរបស់SCR

SCR ជាភាសាអង់គ្លេសគឺ Silicon Controlled Rectifier ឬត្រូវបានគេហៅថា ធីរីស្ទរ (Thyristor)

រូប និងនិម្មិតសញ្ញា




រូបទី3.62 (ក) (ខ)

តើធីរីស្ទរ ឬSCRជាអ្វី និងដំណើរការដូចម្តេច?

❖ វិធីទី១៖ ការប្រើ E-Lab ដោយដំណើការ Software

- **តម្រូវការសម្ភារៈ ៖** (ទាញយកគ្រឿងពីSoftwareដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក)

ធីរីស្ទរ ឬSCR(C106B) LEDពណ៌លឿង(LED-y) រេស៊ីស្ទរ២(RES) កុងតាក់២(SW) និងបាតឺរី (Battery)

- **ដំណើរការដំឡើង និងពិសោធន៍៖**

ដំឡើងសៀគ្វីដូចរូបទី3.62 រៀងគ្នា និងធ្វើពិសោធម្តងមួយៗ និងពិនិត្យពន្លឺLED




(ក)




(ខ)




រូបទី3.62 (គ)




(ឃ)

**សង្កេត៖** ធីរីស្ទរ ឬSCRមានជើងបី ជើងអាណូតA(Anode) ជើងកាតូតC(Cathode) និងជើងហ្គេតG(Gate)។

រូបទី3.62 (ក) បិទកុងតាក់(SW1) និងបើកកុងតាក់(SW2) LED មិនឆេះភ្លឺទេ (ខ) បិទកុងតាក់(SW1) និងបិទកុងតាក់(SW2) LED ឆេះភ្លឺ (គ)រក្សាកុងតាក់(SW1)បិទ និងបើកកុងតាក់(SW2) LED នៅបន្តឆេះភ្លឺដដែល (ឃ)បើកកុងតាក់(SW1) និងបិទ/បើកកុងតាក់(SW2) LED មិនឆេះភ្លឺទេ (រលត់)។

- **វិភាគ សន្និដ្ឋាន៖**

**វិភាគ៖** រូបទី3.62

-(ក) បិទកុងតាក់(SW1) និងបើកកុងតាក់(SW2) LED មិនឆេះភ្លឺទេ ដោយសារ *ជើងGរបស់SCRមិនភ្ជាប់ចរន្តអគ្គិសនី* និងSCRមិនចម្លងចរន្តអគ្គិសនី។

-(ខ) បិទកុងតាក់(SW1) និងបិទកុងតាក់(SW2) LED ឆេះភ្លឺ ដោយសារ *ជើងGរបស់SCR ភ្ជាប់ចរន្តអគ្គិសនី និងSCRក្លាយជាអង្គធាតុចម្លង។* ចរន្តអគ្គិសនីឆ្លងកាត់ពីអាណូតAទៅកាតូតC។

-(គ)រក្សាកុងតាក់(SW1)បិទ និងបើកកុងតាក់(SW2) LED នៅបន្តឆេះភ្លឺដដែល ដោយសារ *ជើងG របស់SCR ភ្ញោចចរន្តអគ្គិសនីរួចហើយ និងវាក្លាយជាអង្គធាតុចម្លងរួចហើយ* កុងតាក់(SW2)លែងសំខាន់ហើយ។ ចរន្តអគ្គិសនីបន្តឆ្លងកាត់SCRពីអាណូតAទៅកាតូតCតទៅទៀត។

-(ឃ) បើកកុងតាក់(SW1) និងបិទ/បើកកុងតាក់(SW2) LED មិនឆេះភ្លឺទេ (រលត់)ដោយសារ *កុងតាក់(SW1)ជាកុងតាក់មេ គ្មានចរន្តឆ្លងកាត់SCR។*

**សន្និដ្ឋាន៖** ធីរីស្តរឬSCRគឺ *ជាគ្រឿងស៊ីមីកុងឌុចទ័រដែលមានជើង៣ ជើងអាណូតA ជើងកាតូត(C) និងជើងហ្គេតG ។ វាដំណើរការ កាលណាជើងGភ្ញោចចរន្ត បើវាមិនភ្ញោចទេ នោះSCRមិនដំណើរការទេ។*

- លេខតួរបស់SCR




រូបទី3.63

## ៨. អនុវត្តន៍៖

៨.១ ការដំឡើងសៀគ្វី(ឆេះភ្លឺដោយស្វ័យប្រវត្តិនៅពេលយប់) រូបទី3.64៖(សៀគ្វីនេះត្រូវបានគេប្រើជាមូលដ្ឋានគ្រឹះនៃពន្លឺអំពូលភ្លើងប្រើពន្លឺព្រះអាទិត្យដែលឆេះភ្លឺនៅពេលយប់និងរលត់នៅពេលភ្លឺ ក៏ដូចជាអំពូលដែលប្រើនៅលើបង្គោលអង់តែនខ្ពស់ៗ)




(ក)LDRនៅទីងងឹត(យប់) (ខ) LDRនៅទីភ្លឺ (គ)ការដំឡើងជាក់ស្តែង

ការពន្យល់ដំណើរការនៃសៀគ្វី៖

-រូបទី3.64(ក) ពេលយប់ផ្ទៃមុខLDRគ្មានពន្លឺចាំងប៉ះលើផ្ទៃមុខវាទេ នោះរេស៊ីស្តង់របស់វាធំខ្លាំង(មិនអនុញ្ញាតិឱ្យ ចរន្តឆ្លងកាត់វាទេ) ចរន្តចេញពីគោល(+)នៃថ្មពិលឆ្លងកាត់SW1, $R_2$ ប៉ូតង់ស្យូម៉ែត្រ100k ចូលជើងBនៃត្រង់ស៊ីស្ទ័រ$Q_1$ ធ្វើឱ្យវាដំណើរការ។ ត្រង់ស៊ីស្ទ័រមាននាទីជាកុងតាក់បិទ។ ចរន្តយ៉ាងធំចេញពីគោល(+)នៃថ្មពិលឆ្លងកាត់SW1, $R_1$ LED ជើងCនៃ$Q_1$ និងទៅដល់គោល(-)នៃថ្មពិលវិញ ពេលនោះ LEDឆេះភ្លឺ។

-រូបទី3.64(ខ)ពេលភ្លឺ(ថ្ងៃ)ផ្ទៃមុខLDRត្រូវពន្លឺ នោះរេស៊ីស្តង់វាតូចខ្លាំងហើយអនុញ្ញាតិឱ្យចរន្តឆ្លងកាត់វា។ គ្មានចរន្ត ឆ្លងកាត់ជើងBនៃត្រង់ស៊ីស្ទ័រ$Q_1$ទេ នោះត្រង់ស៊ីស្ទ័រមាននាទីជាកុងតាក់បើក។ ពេលនោះLEDរលត់។ ចំណែករូបទី3.64(គ) គឺជាការដំឡើងសៀគ្វីជាក់ស្តែងដោយប្រើបន្ទះសៀគ្វីផ្ទាល់។

៨.២ ការដំឡើងសៀគ្វីលំយោលត្រង់ស៊ីស្ទ័ រូបទី3.65៖ (សៀគ្វីនេះត្រូវបានប្រើសម្រាប់បង្កើតលំយោលករ (Oscillator)សម្លេង)







រូបទី3.65 (ក) (ខ)

ការពន្យល់ដំណើរការនៃសៀគ្វី៖ កាលណាកុងតាក់(S)បិទ ចរន្តអគ្គិសនីចេញពីប៉ូល(+)នៃប្រភពឆ្លងកាត់ S R1 M ប៉ូតង់ស្យូម៉ែត្រ និងN ដើម្បីផ្ទុកកុងដង់សាទ័រC1 ក្នុងពេលជាមួយគ្នានេះត្រង់ស៊ីស្ទ័រទាំងពីរ(Q1 និងQ2) មាននាទីជាកុងតាក់បើក(ចំហ)។ ក្រោយពេលដែលកុងដង់សាទ័រC1ផ្ទុកពេញ វាក៏ផ្ទេរបន្ទុកអគ្គិសនី។ ពេលនោះមានចរន្តអគ្គិសនីឆ្លងកាត់ជើងBនៃត្រង់ស៊ីស្ទ័រQ1(NPN)ដែលធ្វើឱ្យមានចរន្តអគ្គិសនីយ៉ាងធំឆ្លងកាត់ជើងEនៃត្រង់ស៊ីស្ទ័រQ2(PNP)។ ចរន្តអគ្គិសនីនេះចេញតាមជើងB និងជើងCរបស់Q2 ធ្វើឱ្យត្រង់ស៊ីស្ទ័រ ទាំងពីរ(Q1 និងQ2)ដំណើរការ មានន័យថា វាមាននាទីជាកុងតាក់បិទ។ ចរន្តអគ្គិសនីដែលចេញតាមជើង C នៃ Q2 ឆ្លងកាត់ P អូប៉ាល័រ បន្តទៅR2 Q និងទៅដល់ប៉ូល(-)នៃប្រភព និងក្នុងពេលជាមួយគ្នានេះ អូប៉ាល័របន្លឺសម្លេង។

ក្រោយពេលដែលកុងដង់សាទ័រ C1 ផ្ទេរបានបន្តិច វាក៏ចាប់ផ្តើមផ្ទុកបន្ទុកអគ្គិសនីឡើងវិញ រួចក៏ផ្ទេរបន្ទុកដូចបានពោលខាងលើ។ ចលនានៃការផ្ទុកនិងផ្ទេរបន្ទុកអគ្គិសនីក្នុងកុងដង់សាទ័រជាបន្តបន្ទាប់បែបនេះត្រូវបានគេហៅថា ជីពចរលេក(pulses)។ ចំនួនជីពចរលេកក្នុងមួយវិនាទីត្រូវបានគេហៅថា *ប្រេកង់លំយោល*។ ប្រេកង់លំយោលនេះធ្វើឱ្យកោននៃអូប៉ាល័រញ័រនៅប្រេកង់សម្លេង(សូរ)។ ប្រេកង់សម្លេងដែលត្រចៀកមនុស្សយើងស្តាប់ឮស្ថិតក្នុងចន្លោះពី 20 Hz ទៅ 20 kHz។ សូរដែលមានប្រេកង់ទាបជាង 20 Hz ត្រូវបានគេហៅថាសូរអាំងប្រា និងខ្ពស់ជាង 20 kHz ជាសូរអ៊ុលត្រា។ អ្នកអាចមួលបង្វិលជើងកណ្តាលរបស់ប៉ូតង់ស្យូម៉ែត្ររូបទី3.65 ពេលនោះអ្នកបានសម្លេង(សូរ)ប្រែប្រួល ដែលមានន័យថាប្រេកង់សម្លេងប្រែប្រួល (អាចស្តាប់ឮ ឬស្តាប់មិនឮ)។

៨.៣ ការដំឡើងសៀគ្វី(ផ្ទាំងសាក)បញ្ចូលថ្មពិល ឬទូរស័ព្ទ ចរន្តជាប់DC រូបទី3.65៖






## ការពន្យល់ដំណើរការនៃសៀគ្វី៖

កាលណាកុងតាក់(S)បិទ ចរន្តអគ្គិសនីចេញពីប៉ូល(+)នៃប្រភពឆ្លងកាត់កុងតាក់ S និង ប៉ូតង់ស្យូម៉ែត្រ រួចភ្ជាប(ចូល)ជើង B នៃត្រង់ស៊ីស្ទរ។ ពេលនោះចរន្តអគ្គិសនីយ៉ាងធំចេញពីប៉ូល(+)ឆ្លងកាត់កុងតាក់ S ជើងC ជើងE នៃត្រង់ស៊ីស្ទរ LED និងR2 រួចមកដល់ប៉ូល (-)ប្រភព។ ក្នុងពេលជាមួយគ្នានេះ LEDឆេះភ្លឺ។ គេថាត្រង់ស៊ីស្ទរ(NPN)មាននាទីជាកុងតាក់បិទ។

អ្នកអាចមួល(បង្វិល)ជើងកណ្តាលនៃប៉ូតង់ស្យូម៉ែត្រ ដើម្បីបានតង់ស្យុងចេញ(Output) ដែលត្រូវគ្នានឹងឧបករណ៍ដែលអ្នកចង់បញ្ចូល ឬសាក។

សង្ខេបមេរៀន

- សឺមីកុងឌុចទ័រ( semi-conductor )ជារូបជាតុចម្លងអគ្គិសនីដែលស្ថិតរវាងអង្គធាតុចម្លង និងអ៊ីសូឡង់អគ្គិសនី រួមមាន ស៊ីលីស្យូម( Si ) ហ្គេម៉ានីញ៉ូម( Ge ) សេលេញ៉ូម( Se ) កាបូន( C )...។
- ប៉ូតង់ស្យូម៉ែត្រជាគ្រឿងអេឡិចត្រូនិកដែលមាន *រេស៊ីស្តង់ប្រែប្រួល* ហើយត្រូវបានប្រើដើម្បីកម្រិត *ចរន្តរត់ឆ្លងកាត់* សៀគ្វី។
- LDRជាគ្រឿងអេឡិចត្រូនិកដែលមាន *រេស៊ីស្តង់ប្រែប្រួល* ដោយអាស្រ័យលើអាំងតង់ស៊ីតេពន្លឺដែលចាំងប៉ះលើផ្ទៃមុខរបស់វា។ នៅទីងងឹត LDR *មានរេស៊ីស្តង់ធំណាស់* ( ស្ថិតក្នុងកម្រិត MΩ ) ប៉ុន្តែនៅទីភ្លឺ LDR *មានរេស៊ីស្តង់តូច* ។ LDR ត្រូវបានគេប្រើធ្វើជា *សិនស័រពន្លឺ* ( Light Sensor ) ។
- កុងដង់សាទ័រជាគ្រឿងអេឡិចត្រូនិកដែលត្រូវបានប្រើដើម្បី *ផ្ទុក-ផ្ទេរបន្ទុកអគ្គិសនី*។ វាមាននាទីជា *ប្រភពអគ្គិសនីបណ្ដោះអាសន្ន*។ កុងដង់សាទ័រត្រូវបានប្រើដើម្បីច្រោះចរន្ត( Filter )ពេលដែលបំប្លែងពីរន្តឆ្លាស់ទៅចរន្តជាប់ និងបម្រែបម្រួលប្រេកង់សម្លេង ឬបង់(ប៉ុស្ដិ៍)វិទ្យុ...។
- ឌីយ៉ូត *គឺជាគ្រឿងអេឡិចត្រូនិច និង(គ្រឿង)សឺមីកុងឌុចទ័រដែលមានគោលពីរ មួយជាអាណូត(A)និងមួយទៀតជាកាតូត(C) ហើយវាអាចឱ្យចរន្តឆ្លងកាត់តែតាមទិសដៅពីអាណូត(A)ទៅកាតូត(C)ប៉ុណ្ណោះ។* គេប្រើវាដើម្បីការពារសៀគ្វីពីការឆេះខូចពេលចាប់ប្រភពអគ្គិសនីបញ្ច្រាសគោល(ប៉ូល) និងសំទួយចរន្តពីAC ទៅDC។
- ត្រង់ស៊ីស្ទ័រគឺ *ជា(គ្រឿង)ស៊ីមីកុងឌុចទ័រដែលមានជើង៣ ជើងបាស(B) ជើងកូឡិចទ័រ(C) និងជើងអេមីទ័រ(E)។ត្រង់ស៊ីស្ទ័រមានពីរប្រភេទគឺ NPN និងPNP។ វាដំណើរការកាលណាជើង(B)ភ្លោចចរន្ត គេថាវាជាកុងតាក់បិទ និងវាមិនដំណើរការកាលណាជើង(B)គ្មានចរន្ត គេថាវាជាកុងតាក់បើក។ គេប្រើវាដើម្បីពង្រីកស៊ីញ៉ាល់អគ្គិសនី។*
- ធីរីស្ទ័រឬSCRគឺ *ជា(គ្រឿង)ស៊ីមីកុងឌុចទ័រដែលមានជើង៣ ជើងអាណូតA ជើងកាតូត(C) និងជើងហ្គេតG ។ វាដំណើរការ កាលណាជើងGភ្លោចចរន្ត បើវាមិនភ្លាចទេ នោះSCRមិនដំណើរការទេ។*

**សំណួរ និងលំហាត់៖**

១. តើរេស៊ីស្តរ និង ប៉ូតង់ស្យូម៉ែត្រជាអ្វី? ហើយវាខុសគ្នាដូចម្ដេច?

២. ចូររៀបរាប់ឈ្មោះឧបករណ៍ដែលប្រើប៉ូតង់ស្យូម៉ែត្រ ដែលអ្នកបានស្គាល់ឱ្យបានប្រាំ។

៣. តើ LDR ជាអ្វី? និងចូរគូសដ្យាក្រាមនៃសៀគ្វីងាយណាមួយដែលមានគ្រឿងអេឡិចត្រូនិចផ្សេងៗ និងមានLDRជាចាំបាច់ រួចពន្យល់ពីដំណើរការនៃសៀគ្វីនោះ។

៤. តើគេប្រើកុងដង់សាទ័រសម្រាប់ធ្វើអ្វីខ្លះ?

៥. តើឌីយ៉ូតជាអ្វី?

៦. តើត្រង់ស៊ីស្តរជាអ្វី? និងមានប៉ុន្មានប្រភេទ? ចូរពន្យល់ពីគោលការណ៍ដំណើការរបស់វានីមួយៗ។

៧. ចូរពន្យល់ពីការវាស់រកជើងត្រង់ស៊ីស្តរដើម្បីដឹងថាវាជាត្រង់ស៊ីស្តរប្រភេទNPN ឬPNP។

៨. តើSCR ឬធីរីស្តរជាអ្វី? និងចូរពន្យល់ពីគោលការណ៍ដំណើការរបស់វា។

៩. គេដំឡើងសៀគ្វីដូចរូបទី3.32។

(ក) ចូររៀបរាប់ឈ្មោះគ្រឿងអេឡិចត្រូនិកដែលយកមកប្រើក្នុងដ្យាក្រាមនៃសៀគ្វីនេះ។

(ខ) ចូរពន្យល់ពីដំណើរការនៃសៀគ្វីនេះ។

(គ) (បើអាច)ចូរដំឡើងសៀគ្វីនេះលើបន្ទះសៀគ្វីជាក់ស្តែង។




១០. គេដំឡើងសៀគ្វីដូចរូបទី3.56។ (ក) ចូររៀបរាប់ឈ្មោះគ្រឿងអេឡិចត្រូនិកដែលយកមកប្រើក្នុងដ្យាក្រាមនៃសៀគ្វីនេះ។(ខ) ចូរពន្យល់ពីដំណើរការនៃសៀគ្វីនេះ។(គ) (បើអាច)ចូរដំឡើងសៀគ្វីនេះលើបន្ទះសៀគ្វីជាក់ស្តែង។ អ្នកអាចដំឡើងវាដោយប្រើកម្មវិធីE-Lab។



១១. គេដំឡើងសៀគ្វីដូចរូបទី3.64។ (ក) ចូររៀបរាប់ឈ្មោះគ្រឿងអេឡិចត្រូនិកដែលយកមកប្រើក្នុងដ្យាក្រាមនៃសៀគ្វីនេះ។(ខ) ចូរពន្យល់ពីដំណើរការនៃសៀគ្វីនេះ។ (គ) (បើអាច)ចូរដំឡើងសៀគ្វីនេះលើបន្ទះសៀគ្វីជាក់ស្ដែង និងពិនិត្យមើលដំណើរការវាជាក់ស្ដែង។អ្នកអាចដំឡើងវាដោយប្រើកម្មវិធីE-Lab។




១២. គេដំឡើងសៀគ្វីដូចរូបទី3.65។(ក)ចូររៀបរាប់ឈ្មោះគ្រឿងអេឡិចត្រូនិកដែលយកមកប្រើក្នុងដ្យាក្រាមនៃសៀគ្វីនេះ។(ខ) ចូរពន្យល់ពីដំណើរការនៃសៀគ្វីនេះ។(គ) (បើអាច)ចូរដំឡើងសៀគ្វីនេះលើបន្ទះសៀគ្វីជាក់ស្ដែង និងវាស់តង់ស្យុងចេញដើម្បីពិនិត្យដំណើរការរបស់វា។អ្នកអាចដំឡើងវាដោយប្រើកម្មវិធីE-Lab។




១៣. គេដំឡើងសៀគ្វីដូចរូបទី3.66។ (ក) ចូររៀបរាប់ឈ្មោះគ្រឿងអេឡិចត្រូនិកដែលយកមកប្រើក្នុងដ្យាក្រាមនៃសៀគ្វីនេះ។(ខ) ចូរពន្យល់ពីដំណើរការនៃសៀគ្វីនេះ។(គ) (បើអាច)ចូរដំឡើងសៀគ្វីនេះលើបន្ទះ

សៀគ្វីជាក់ស្តែង និងវាស់តង់ស្យុងចេញដើម្បីពិនិត្យដំណើរការរបស់វា។ អ្នកអាចដំឡើងវាដោយប្រើកម្មវិធីE-Lab។ (សៀគ្វីនេះត្រូវបានគេស្គាល់ថាជាទ្វារតក្កៈAND)




រូបទី3.66

១៤. គេដំឡើងសៀគ្វីដូចរូបទី3.67។ (ក) ចូររៀបរាប់ឈ្មោះគ្រឿងអេឡិចត្រូនិកដែលយកមកប្រើក្នុងដ្យាក្រាមនៃសៀគ្វីនេះ។(ខ) ចូរពន្យល់ពីដំណើរការនៃសៀគ្វីនេះ។(គ) (បើអាច)ចូរដំឡើងសៀគ្វីនេះលើបន្ទះសៀគ្វីជាក់ស្តែង និងវាស់តង់ស្យុងចេញដើម្បីពិនិត្យដំណើរការរបស់វា។ អ្នកអាចដំឡើងវាដោយប្រើកម្មវិធីE-Lab។ (សៀគ្វីនេះត្រូវបានគេស្គាល់ថាជាទ្វារតក្កៈOR)




រូបទី3.67

១៥. គេដំឡើងសៀគ្វីដូចរូបទី3.68។ (ក) ចូររៀបរាប់ឈ្មោះគ្រឿងអេឡិចត្រូនិកដែលយកមកប្រើក្នុងដ្យាក្រាមនៃសៀគ្វីនេះ។(ខ) ចូរពន្យល់ពីដំណើរការនៃសៀគ្វីនេះ។(គ) (បើអាច)ចូរដំឡើងសៀគ្វីនេះលើបន្ទះសៀគ្វីជាក់ស្តែង និងវាស់តង់ស្យុងចេញដើម្បីពិនិត្យដំណើរការរបស់វា។ អ្នកអាចដំឡើងវាដោយប្រើកម្មវិធីE-Lab។ (សៀគ្វីនេះត្រូវបានគេស្គាល់ថាជាទ្វារតក្កៈNOT ឬINVERTER)។




រូបទី3.68

# ពិសោធន៍ទ្វារតក្ក

## វត្ថុបំណង៖

- គូរនិមិត្តសញ្ញានិងដ្យាក្រាមនៃទ្វារតក្ក។
- ពន្យល់កន្សោមប៊ូលៀននិងដំណើរការនៃទ្វារតក្ក។
- អនុវត្តក្នុងការរស់នៅប្រចាំថ្ងៃនិងក្នុងបច្ចេកទេស។

| ភាពតក្ក | |
|---|---|
| ពិត | មិនពិត |
| 1 | 0 |
| ខ្ពស់ | ទាប |
| +Vs | 0 V |
| បិទ | បើក |

សៀគ្វីដែលប្រើដើម្បីដំណើរការស៊ីញ៉ាល់ឌីជីថលត្រូវបានហៅថា ទ្វារតក្ក។ វាជាប្រព័ន្ធគោលពីរនៅក្នុងធម្មជាតិ ហើយជាសៀគ្វីឌីជីថលដែលមានច្រកចូលមួយឬច្រើន ប៉ុន្តែមានច្រកចេញតែមួយ។ ច្រកចេញលេចឡើងសម្រាប់តែការ បន្សំជាក់លាក់នៃកម្រិតតក្កច្រកចូលប៉ុណ្ណោះ។ ទ្វារតក្កគឺជាប្លុកជាតុបង្គគ្រឹះដែលភាគច្រើននៃប្រព័ន្ធឌីជីថល។ លេខ 0 និង 1 តាងឱ្យភាពដែលអាចមានពីរនៃសៀគ្វីតក្ក។ ភាពពីរនេះអាចត្រូវបានហៅថា "បិទ" និង "បើក" ឬ "ខ្ពស់" និង "ទាប" ឬ "ពិត" និង "មិនពិត"។

១. ទ្វារតក្កគ្រឹះ

ជាតុគ្រឹះបង្កើតជាប្រព័ន្ធឌីជីថលគឺទ្វារ *OR, AND* និង *NOT*។ ទ្វារទាំងបីនេះហៅថា ទ្វារតក្កគ្រឹះ។ រាល់ច្រកចូលនិងច្រកចេញដែលអាចកើតមាននៃសៀគ្វីតក្កគឺបានតាងនៅក្នុងតារាងហៅថា តារាង ភាពពិត។ មុខងារនៃទ្វារគ្រឹះទាំងនេះគឺបានពន្យល់ខាងក្រោមជាមួយនឹងសៀគ្វីនិងតារាងភាពពិត។

១.១. ទ្វារ *OR*

ទ្វារ *OR* មានច្រកចូលពីរឬច្រើន ប៉ុន្តែមានច្រកចេញតែមួយ ហើយច្រកចេញគឺខ្ពស់ បើច្រកចូលមួយណាឬទាំងអស់ខ្ពស់។ និមិត្តសញ្ញាតក្កនៃទ្វារច្រកចូល *OR* បានបង្ហាញក្នុងរូបទី ៤-៤២(ក)។ កន្សោមប៊ូលៀនតាងទ្វារ *OR* ដោយ $Q = A + B$ (សញ្ញា + អានជា *OR*)។




(ក) និមិត្តតក្ក




(ខ) សៀគ្វីអគ្គិសនី




រូបទី ៤.៤២

តារាងភាពពិតនៃទ្វារ *OR*

| ប្រកចូល | | ប្រកចេញ | ពណ៌នា |
|---|---|---|---|
| $A$ | $B$ | $Q = A + B$ | |
| 0 | 0 | 0 | $A$ ចំហនិង $B$ ចំហ, ចង្កៀងមិនភ្លឺ |
| 0 | 1 | 1 | $A$ ចំហនិង $B$ ភ្ជាប់, ចង្កៀងភ្លឺ |
| 1 | 0 | 1 | $A$ ភ្ជាប់និង $B$ ចំហ, ចង្កៀងភ្លឺ |
| 1 | 1 | 1 | $A$ ភ្ជាប់និង $B$ ភ្ជាប់, ចង្កៀងភ្លឺ |

-

- សៀគ្វី *IC* នៃទ្វារ *OR*

ទ្វារអនុវត្តប្រតិបត្តិការវិធីចែកតក្កដែលស្គាល់ជាទ្វារ *OR*។ សៀគ្វី *IC* ប្រើសម្រាប់ទ្វារ *OR* ហើយឌីដ្យាក្រាមជើង *IC* នៃទ្វារ *OR* គឺ 7432 Quad 2 input OR Gates ៖




ជើង *IC* នៃប្រកចូលគឺ (1,2), (4,5), (9,10), (12,13) និងជើង *IC* នៃប្រកចេញគឺ (3,6,8,11) ហើយ $V_{CC}$ គឺ 14 និង *GND* គឺ 7។

១.២. ទ្វារ *AND*

ទ្វារ *AND* មានប្រកចូលពីរឬច្រើន ប៉ុន្តែប្រកចេញមួយប៉ុណ្ណោះ ហើយប្រកចេញខ្ពស់និងប្រកចូលទាំងពីរគឺខ្ពស់។ និមិត្តសញ្ញាតក្កនៃទ្វារប្រកចូល *AND* បង្ហាញក្នុងរូបទី ៤-៤៣(ក)។ $Q = A \cdot B$ (សញ្ញា "•" អានជា *AND*) ហើយទ្វារ *AND* បង្ហាញជាសៀគ្វីអគ្គិសនីដូចក្នុងរូបទី ៤-៤៣(ខ) ដែលក្នុងនោះកុងតាក់បានតភ្ជាប់ជាស៊េរី។ នៅពេល *A* និង *B* បិទ នោះចង្កៀងភ្លឺ ហើយប្រកចេញគឺខ្ពស់។







តារាងភាពពិតនៃទ្វារ *AND*

| ច្រកចូល | | ច្រកចេញ | ពណ៌នា |
|---|---|---|---|
| $A$ | $B$ | $Q = A \cdot B$ | |
| 0 | 0 | 0 | $A$ ចំហនិង $B$ ចំហ, ចង្កៀងមិនភ្លឺ |
| 0 | 1 | 0 | $A$ ចំហនិង $B$ ភ្ជាប់, ចង្កៀងមិនភ្លឺ |
| 1 | 0 | 0 | $A$ ភ្ជាប់និង $B$ ចំហ, ចង្កៀងមិនភ្លឺ |
| 1 | 1 | 1 | $A$ ភ្ជាប់និង $B$ ភ្ជាប់, ចង្កៀងភ្លឺ |

រូបទី ៤.៤៣

- សៀគ្វី *IC* នៃទ្វារ *AND*

ទ្វារ *AND* អនុវត្តការប្រតិបត្តិវិធីគុណឌីជីថលដែលស្គាល់ជាទូទៅថា មុខងារ *AND*។ សៀគ្វី *IC* ប្រើសម្រាប់ទ្វារ *AND* គឺ *IC* 7408 ហើយឌីដ្យាក្រាមជើង *IC* នៃទ្វារ *AND* គឺ 7408 Quad 2 input AND Gates ៖



ជើង *IC* នៃប្រកចូលគឺ (1,2), (4,5), (9,10), (12,13) និងជើង *IC* នៃប្រកចេញគឺ (3,6,8,11) ហើយ $V_{CC}$ គឺលេខ 14 និង *GND* គឺលេខ 7។

១.៣. ទ្វារ *NOT*

ទ្វារ *NOT* ជាទ្វារដែលមានប្រកចូលតែមួយនិងប្រកចេញមួយ។ វាត្រូវបាន គេហៅថាដូច្នេះ ដោយសារតែ ប្រកចេញរបស់វាគឺបំពេញបន្ថែមទៅនឹងប្រកចូល។ វាត្រូវបានគេស្គាល់ថាជា អាំងវ៉ែទ័រ។ រូបទី ៤-៤៤(ក) បង្ហាញនិមិត្តសញ្ញាតក្កសម្រាប់ ទ្វារ *NOT*។ កន្សោមប៊ូលៀនដែលតាងឱ្យប្រតិបត្តិការ *NOT* គឺ $Q = \bar{A}$។

ទ្វារ *NOT* ដូចជា សៀគ្វីអគ្គិសនីដូចបង្ហាញក្នុងរូបទី ៤-៤៤(ខ)។ នៅពេលដែលកុងតាក់ A បានបិទ ប្រកចូលគឺខ្ពស់ ហើយអំពូលនឹងមិនភ្លឺទេ ប្រកចេញគឺទាបហើយផ្ទុយមកវិញ។

រូបទី ៤-៥៤(គ)ជាត្រង់ស៊ីស្ទ័រនៅក្នុងរបៀបរួមអេមីតទ័រដែលបានប្រើជាទ្វារ *NOT* ។ នៅពេលប្រកចូល *A* គឺខ្ពស់ ត្រង់ស៊ីស្ទ័រស្ថិតក្នុងភាពឆ្អែត ហេតុដូច្នេះហើយ ប្រកចេញ *Q* គឺទាប។ បើ *A* គឺទាប ត្រង់ស៊ីស្ទ័រកាត់ផ្តាច់ ដូច្នេះ ប្រកចេញ *Q* គឺខ្ពស់។ អាស្រ័យហេតុនេះ រាល់ពេលដែលប្រកចូលគឺខ្ពស់ នោះប្រកចេញគឺទាប ហើយផ្ទុយមកវិញ។ ប្រតិបត្តិការនៃទ្វារ *NOT* បង្ហាញក្នុងតារាងភាពពិត *NOT*។




តារាងភាពពិតនៃទ្វារ *NOT*

| ប្រកចូល | ប្រកចេញ |
|---|---|
| $A$ | $Q = \bar{A}$ |
| 1 | 0 |
| 0 | 1 |

រូបទី ៤.៤៤

- **សៀគ្វី *IC* នៃទ្វារ *NOT***

ប្រកទ្វារដែលអនុវត្តការប្រព្រឹត្តទៅបញ្ច្រាសត្រូវបានហៅថា ទ្វារ *NOT*។ សៀគ្វី *IC* ប្រើសម្រាប់ទ្វារ *NOT* ហើយឌីជ្យាក្រាមជើង *IC* នៃទ្វារ *NOT* គឺ *IC* 7404 Hex NOT Gates (Inverters) ៖




ជើង *IC* នៃប្រកចូលគឺ (1,3,5,9,11,13) និងជើង *IC* នៃប្រកចេញគឺ (2,4,6,8,10,12) ហើយ $V_{CC}$ គឺ 14 និង *GND* គឺ 7។

២. ទ្វារតក្កសកល

២.១. ទ្វារ *NAND*

ទ្វារនេះជាទ្វារ *NOT-AND*។ វាបានដោយការភ្ជាប់ទ្វារ *NOT* នៅប្រកចេញនៃទ្វារ *AND* ក្នុងរូបទី ៤-៤៥ (ក)។ និមិត្តសញ្ញាតក្កសម្រាប់ទ្វារ *NAND* បង្ហាញក្នុងរូបទី ៤-៤៥(ខ)។ មុខងារទ្វារ *NAND* គឺប្រាសនៃមុខងារទ្វារ *AND* ។ ទ្វារ *NAND* នឹងមានប្រកចេញ លុះត្រាតែ ប្រកចូលទាំងពីរគឺមិនមែន 1។ម្យ៉ាងវិញទៀត វាផ្តល់ប្រកចេញ 1 បើ *A* ឬ *B* ឬទាំងពីរគឺ 0។ ប្រតិបត្តិការនៃទ្វារ *NAND* បានតាងនៅក្នុងតារាងភាពពិត *NAND*។




(ក) ទ្វារ *AND* បង្កើតដោយទ្វារ *NOT*




(ខ) និមិត្តសញ្ញាតក្ក




កុងតាក់ *A* ចំហ(បើក)គឺ "0" ភ្ជាប់(បិទ)គឺ "1"
កុងតាក់ *B* ចំហ(បើក)គឺ "0" ភ្ជាប់(បិទ)គឺ "1"
(គ) សៀគ្វីអគ្គិសនី




តារាងភាពពិតនៃទ្វារ *NAND*

| ប្រកចូល | | ប្រកចេញ | ពណ៌នា |
|---|---|---|---|
| *A* | *B* | $Q = \overline{A \cdot B}$ | |
| 0 | 0 | 1 | *A* ចំហនិង *B* ចំហ, ចង្កៀងភ្លឺ |
| 0 | 1 | 1 | *A* ចំហនិង *B* ភ្ជាប់, ចង្កៀងភ្លឺ |
| 1 | 0 | 1 | *A* ភ្ជាប់និង *B* ចំហ, ចង្កៀងភ្លឺ |
| 1 | 1 | 0 | *A* ភ្ជាប់និង *B* ភ្ជាប់, ចង្កៀងមិនភ្លឺ |

រូបទី ៤-៤៥

- **សៀគ្វី *IC* នៃទ្វារ *NAND***

ការបន្សំទ្វារ *NOT* និងទ្វារ *AND*។ ម្យ៉ាងទៀត ទ្វារ *NAND* គឺជាការបញ្ច្រាសទ្វារ *AND*។ ឌីយ៉ាក្រាមជើង *IC* នៃទ្វារ *NOR* គឺ *IC* 7400 Quad 2 input NAND៖




ជើង *IC* នៃប្រកចូលគឺ (1,2), (4,5), (9,10), (12,13) និងជើង *IC* នៃប្រកចេញគឺ (3, 6, 8, 11) ហើយ $V_{CC}$ គឺ 14 និង *GND* គឺ 7៖

២.២. ទ្វារ *NOR*

ទ្វារនេះគឺទ្វារ *NOT-OR*។ វាបង្កើតចេញពីទ្វារ *OR* ដោយភ្ជាប់អាំងវែទ័រនៅប្រកចេញរបស់វាក្នុងរូបទី ៤-៤៦(ក)។ និមិត្តសញ្ញាតក្កសម្រាប់ទ្វារ *NOR* បង្ហាញក្នុងរូបទី ៤-៤៦(ខ)។ មុខងារទ្វារ *NOR* គឺចម្រាស់នៃមុខ

ងារទ្វារ *OR*។ ទ្វារ *NOR* នឹងមានប្រកចេញ លុះត្រាតែ ប្រកចូលទាំងពីរគឺ 0។ នៅក្នុងទ្វារ *NOR* ប្រកចេញគឺខ្ពស់ លុះត្រាប្រកចូលគឺទាប។ ប្រតិបត្តិការ *NOR* តាងនៅក្នុងតារាង។




(ក) ទ្វារ *OR* តាម *NOT*　　(ខ) និមិត្តសញ្ញាតក្ក

កុងតាក់ *A* ចំហ(បើក)គឺ "0" ភ្ជាប់(បិទ)គឺ "1"
កុងតាក់ *B* ចំហ(បើក)គឺ "0" ភ្ជាប់(បិទ)គឺ "1"
(គ) សៀគ្វីអគ្គិសនី




តារាងភាពពិតនៃទ្វារ *NOR*

| ប្រកចូល | | ប្រកចេញ | ពណ៌នា |
|---|---|---|---|
| *A* | *B* | $Q = \overline{A+B}$ | |
| 0 | 0 | 1 | *A* ចំហនិង *B* ចំហ, ចង្កៀងភ្លឺ |
| 0 | 1 | 0 | *A* ចំហនិង *B* ភ្ជាប់, ចង្កៀងមិនភ្លឺ |
| 1 | 0 | 0 | *A* ភ្ជាប់និង *B* ចំហ, ចង្កៀងមិនភ្លឺ |
| 1 | 1 | 0 | *A* ភ្ជាប់និង *B* ភ្ជាប់, ចង្កៀងមិនភ្លឺ |
| កន្សោមប៊ូលៀន $(\overline{A}\,\mathrm{OR}\,\overline{B})$ | | | $\overline{A+B}$ |

រូបទី ៤-៤៦

- **សៀគ្វី *IC* នៃទ្វារ *NOR***

ការបញ្ច្រាសនៃទ្វារ *OR*។ ឌីដ្យាក្រាមជើង *IC* នៃទ្វារ *NOR* គឺ *IC* 7402 Quad 2 input NOR Gates ៖




ជើង *IC* នៃប្រកចូលគឺ (2,3), (5,6), (8,9), (11, 12) និងជើង *IC* នៃប្រកចេញគឺ (1, 4, 10, 13) ហើយ $V_{CC}$ គឺ 14 និង *GND* គឺ 7។

៣. ទ្វារតក្កផ្សេងទៀត

៣.១. ទ្វារ *EX-OR*

និមិត្តសញ្ញាតក្កសម្រាប់ទ្វារ *EXOR* បង្ហាញក្នុងកន្សោមប៊ូលៀន ហើយបង្ហាញដំណើរការទ្វារ *EXOR* គឺ

$$Q = A \oplus B$$

ទ្វារ *EXOR* មានច្រកចេញ 1 លុះត្រាតែច្រកចូលបានបំពេញគ្នាទៅវិញទៅមក។ សៀគ្វីកុងតាក់សមមូលបង្ហាញក្នុងរូបទី៤-៤៧(ខ)។ ទីតាំងកុងតាក់ *A* និង *B* ជាលក្ខណៈនីមួយៗធ្វើឱ្យចង្កៀងភ្លឺ។ ប៉ុន្តែ ការបន្សំនៃ *A* និង *B* គឺមិនអាចទៅរួចបានទេ។ ដំណើរការទ្វារ *EX-OR* បានបង្ហាញក្នុងតារាង។




តារាងភាពពិតនៃទ្វារ *EXOR*

| ច្រកចូល | | ច្រកចេញ | ពណ៌នា |
|---|---|---|---|
| *A* | *B* | $Q = A \oplus B$ | |
| 0 | 0 | 0 | *A* ចំហនិង *B* ចំហ, ចង្កៀងមិនភ្លឺ |
| 0 | 1 | 1 | *A* ចំហនិង *B* ភ្ជាប់, ចង្កៀងភ្លឺ |
| 1 | 0 | 1 | *A* ភ្ជាប់និង *B* ចំហ, ចង្កៀងភ្លឺ |
| 1 | 1 | 0 | *A* ភ្ជាប់និង *B* ភ្ជាប់, ចង្កៀងមិនភ្លឺ |

រូបទី ៤-៤៧

- **សៀគ្វី *IC* នៃទ្វារ *EXOR***

ប្រើនៅក្នុងសៀគ្វីរកឃើញកំហុស ឧបករណ៍ប្រៀបធៀបតក្កព័ត៌មាននិងសៀគ្វីតក្កនព្វន្ធ។ឌីដ្យាក្រាមជើង *IC* នៃទ្វារ *X-OR* គឺ *IC* 7486 Quad 2 input XOR Gates ៖



ជើង *IC* នៃច្រកចូលគឺ (1,2), (4,5), (9,10), (12,13) និងជើង *IC* នៃច្រកចេញគឺ (3, 6, 8, 11) ហើយ $V_{CC}$ គឺ 14 និង *GND* គឺ 7។

### ៣.២. ទ្វារ *EX-NOR*

ទ្វារ *EX-NOR* គឺជាការបំពេញបន្ថែមនៃទ្វារ *EX-OR*។ ច្រកចេញនៃទ្វារ *EX-NOR* គឺខ្ពស់នៅពេលគ្រប់ច្រកចូលគឺដូចគ្នា ឯច្រកចេញគឺទាប(រូបទី ៤-៤៨)។




តារាងភាពពិតនៃទ្វារ *EXNOR*

| ច្រកចូល | | ច្រកចេញ | ពណ៌នា |
|---|---|---|---|
| *A* | *B* | $Q=\overline{A\oplus B}$ | |
| 0 | 0 | 1 | *A* ចំហនិង *B* ចំហ, ចង្កៀងភ្លឺ |
| 0 | 1 | 0 | *A* ចំហនិង *B* ភ្ជាប់, ចង្កៀងមិនភ្លឺ |
| 1 | 0 | 0 | *A* ភ្ជាប់និង *B* ចំហ, ចង្កៀងមិនភ្លឺ |
| 1 | 1 | 1 | *A* ភ្ជាប់និង *B* ភ្ជាប់, ចង្កៀងភ្លឺ |

រូបទី ៤.៤៨

- **សៀគ្វី *IC* នៃទ្វារ *EXNOR***

ជាទ្វារ *XOR* ដែលច្រកចេញដាក់បញ្ច្រាស។ ឌីយ៉ាក្រាមជើង *IC* នៃទ្វារ *XNOR* គឺ *IC* 47266 Quad 2 input XNOR Gates ៖



ជើង *IC* នៃច្រកចូលគឺ (1, 2), (5, 6), (8, 9), (12, 13) និងច្រកចេញគឺ (3, 4, 10, 11) ហើយ $V_{CC}$ គឺ 14 និង *GND* គឺ 7។

៤. សង្ខេបតារាងភាពពិត

តារាងភាពពិតសង្ខេបខាងក្រោមបង្ហាញភាពច្រកចេញសម្រាប់ប្រភេទ 2-ទ្វារច្រកចូលនិង3-ទ្វារច្រកចូល។

| 2-ទ្វារច្រកចូល | | | | | | | |
|---|---|---|---|---|---|---|---|
| ច្រកចូល | | ច្រកចេញនៃទ្វារ | | | | | |
| *A* | *B* | *OR* | *AND* | *NAND* | *NOR* | *EX-OR* | *EX-NOR* |
| 0 | 0 | 0 | 0 | 1 | 1 | 0 | 1 |
| 0 | 1 | 1 | 0 | 1 | 0 | 1 | 0 |
| 1 | 0 | 1 | 0 | 1 | 0 | 1 | 0 |
| 1 | 1 | 1 | 1 | 0 | 0 | 0 | 1 |

| 3-ទ្វារច្រកចូល | | | | | | |
|---|---|---|---|---|---|---|
| ច្រកចូល | | | ច្រកចេញនៃទ្វារ | | | |
| *A* | *B* | *C* | *OR* | *AND* | *NAND* | *NOR* |
| 0 | 0 | 0 | 0 | 0 | 1 | 1 |
| 0 | 0 | 1 | 1 | 0 | 1 | 0 |
| 0 | 1 | 0 | 1 | 0 | 1 | 0 |

| | | | | | | |
|---|---|---|---|---|---|---|
| 0 | 1 | 1 | 1 | 0 | 1 | 0 |
| 1 | 0 | 0 | 1 | 0 | 1 | 0 |
| 1 | 0 | 1 | 1 | 0 | 1 | 0 |
| 1 | 1 | 0 | 1 | 0 | 1 | 0 |
| 1 | 1 | 1 | 1 | 1 | 0 | 0 |

៥. ការបន្សំនៃទ្វារតក្ក

របៀបដែលទ្វារ *NAND* ( *NOT-AND*) ប្រើដើម្បីទទួលបានមុខងារស្តង់ដាណាមួយដោយប្រើតែប្រភេទទ្វារតែមួយនេះ។

- *NOT*: ការភ្ជាប់ច្រកចូលទាំងពីរនៃទ្វារ *NAND* រួមគ្នាបង្កើតមុខងារ *NOT* ។
-




| A | B | Y |
|---|---|---|
| 0 | 0 | 1 |
| 1 | 1 | 0 |

- *AND*: ការបន្ថែមមុខងារ *NOT* (អាំងវែទ័រ) ទៅច្រកចេញនៃទ្វារ *NAND* បង្កើតមុខងារ *AND* ។




| A | B | C | Q |
|---|---|---|---|
| 0 | 0 | 1 | 0 |
| 0 | 1 | 1 | 0 |
| 1 | 0 | 1 | 0 |
| 1 | 1 | 0 | 1 |

- *OR:* ការបញ្ច្រាសច្រកចូលទាំងពីរទៅទ្វារ *NAND* បង្កើតមុខងារ *OR*។
-




| *A* | *B* | *C* | *D* | *Q* |
|---|---|---|---|---|
| 0 | 0 | 1 | 1 | 0 |
| 0 | 1 | 1 | 0 | 1 |
| 1 | 0 | 0 | 1 | 1 |
| 1 | 1 | 0 | 0 | 1 |

- *NOR:* ការប្រើមុខងារ *NOT* ដើម្បីបញ្ច្រាសច្រកចេញនៃមុខងារ *OR* មុខងារ *NOR*។
-




| *A* | *B* | *C* | *D* | *E* | *Q* |
|---|---|---|---|---|---|
| 0 | 0 | 1 | 1 | 0 | 1 |
| 0 | 1 | 1 | 0 | 1 | 0 |
| 1 | 0 | 0 | 1 | 1 | 0 |
| 1 | 1 | 0 | 0 | 1 | 0 |

- *XOR:* ទ្វារ *NAND* បួន (សៀគ្វី *IC* ទោល) ដែលភ្ជាប់ដូចបានបង្ហាញបង្កើតមុខងារ *XOR* (ហើយសៀគ្វី Quad *NAND IC* គឺប្រហែល 15% ថោកជាង Quad *XOR IC*)។




| *A* | *B* | *C* | *D* | *E* | *Q* |
|---|---|---|---|---|---|
| 0 | 0 | 1 | 1 | 1 | 0 |
| 0 | 1 | 1 | 1 | 0 | 1 |
| 1 | 0 | 1 | 0 | 1 | 1 |
| 1 | 1 | 0 | 1 | 1 | 0 |

- *XNOR:* ការបញ្ច្រាសច្រកចេញនៃមុខងារ *XOR* បង្កើតមុខងារ *XNOR*។




| A | B | C | D | E | F | Q |
|---|---|---|---|---|---|---|
| 0 | 0 | 1 | 1 | 1 | 0 | 1 |
| 0 | 1 | 1 | 1 | 0 | 1 | 0 |
| 1 | 0 | 1 | 0 | 1 | 1 | 0 |
| 1 | 1 | 0 | 1 | 1 | 0 | 1 |

## ៦. ការអនុវត្តទ្រឹស្តីទ្វារ *NAND*

យើងប្រើទ្វារ *NAND* ជាឧទាហរណ៍មួយដើម្បីបញ្ជាក់មុខងាររបស់វានៅក្នុងសៀគ្វី *IC*។ សមាសធាតុបន្សំរួមមានៈ

១. ជនិតា(ថ្មពិល) 3V                    ២. បន្ទះសៀគ្វី(បន្ទះគម្រោង)

៣. រេស៊ីស្ទ័រ 10 kΩ ចំនួន ២ និង 100 Ω ចំនួន ៣

៤. ឌីយ៉ូដ 1N4148 ចំនួន ៣                    ៥. *IC* 7400 ចំនួន ១

៦. ថ្មពិល 1 V ចំនួន ១                    ៧. កុងតាក់ចំនួន ២




ដំណើរការនៃប្រព័ន្ធត្រូវបានបង្ហាញនៅក្នុងផ្នែក ២.១. ក្នុងទ្វារ *NAND*។

## មេរៀនសង្ខេប

. ទ្វារតក្កគ្រឹះគឺ *OR, AND* និង *NOT* បង្កើតជាប្រព័ន្ធឌីជីថល ហើយវាមានកន្សោមប៊ូលៀន សម្រាប់ទ្វារ *OR* គឺ $Q = A + B$ , ទ្វារ *AND* គឺ $Q = A \cdot B$ និងទ្វារ *NOT* គឺ $Q = \bar{A}$។

. ទ្វារតក្កសកលគឺ *NAND* និង *NOR* ។ ទ្វារ *NAND* ផ្សំពី *NOT-AND* ហើយទ្វារ *NOR* ផ្សំពី *NOT-OR* ។ ប្រកចេញភ្ជាប់អាំងវែទ័រនិងមានកន្សោមប៊ូលៀនគឺ $Q = \overline{A \cdot B}$ សម្រប់ទ្វារ *NAND* និងកន្សោមប៊ូលៀនសម្រាប់ទ្វារ *NOR* គឺ $Q = \overline{A + B}$ ។

. ទ្វារ *EXOR* មានកន្សោមប៊ូលៀន $Q = A \oplus B$និងទ្វារ *EXNOR* មានកន្សោមប៊ូលៀន $Q = \overline{A \oplus B}$។

. សៀគ្វី *IC* នៃទ្វារ

- *OR* គឺ 7432 Quad 2 input *OR* Gates
- AND គឺ 7408 Quad 2 input *AND* Gates
- *NOT* គឺ 7404 Hex *NOT* Gates (Inverters)
- NAND គឺ 7400 Quad 2 input *NAND* Gates
- NOR គឺ 7402 Quad 2 input *NOR* Gates
- *EXOR* គឺ 7486 Quad 2 input *XOR* Gates
- *EXNOR* គឺ 47266 Quad 2 input *XNOR* Gates

. បន្សំទ្វារតក្ក *NAND* តែមួយប្រភេទដើម្បីបង្កើតទ្វារ *NOT*, *AND*, *OR*, *NOR*, *XOR* និង *XNOR*។

. អនុវត្តទ្រឹស្តីទ្វារ *NAND*។

## លំហាត់

១. សរសេរកន្សោមប៊ូលៀនសម្រាប់ទ្វារ *AND*។

២. ចូរកំណត់ទ្វារតក្ក។

៣. តើទ្វារសកលគឺជាអ្វី? ចូរឱ្យឧទាហរណ៍។

៤. បើប្រកចូល 0 បានអនុវត្តនៅលើទ្វារ *NOT* តើប្រកចេញនឹងទៅជាយ៉ាងណា?

៥. សរសេរកន្សោមប៊ូលៀនសម្រាប់ទ្វារ *OR*?

៦. តើទ្វារតក្កមួយណាបានគេស្គាល់ថាជា អាំងវែទ័រ?

# ពិសោធន៍ចំណាំងផ្លាត និងចំណាំងបែរនៃពន្លឺ

## ❖ ចំណាំងបែរនៃពន្លឺ

១. វត្ថុបំណង

វិជ្ជាសម្បទា៖ រៀបរាប់ការដំឡើងឧបករណ៍ពិសោធន៍បានត្រឹមត្រូវដោយប្រើ E-Lab។

បំណិនសម្បទា៖ កំណត់សំទុះចំណាំងបែរនៃទឹកបានត្រឹមត្រូវតាមពិសោធន៍E-Lab។

ចរិយាសម្បទា៖ ចូលរួមចំណែកក្នុងការទុកដាក់ និងប្រើប្រាស់ឧករណ៍ចំណាំងបែរនៃពន្លឺក្នុងការរស់នៅរាល់ថ្ងៃ និងក្នុងបច្ចេកទេសបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

២. ចំណេះដឹងមូលដ្ឋាន (ទ្រឹស្តីសំខាន់ៗ)

- ច្បាប់ចំណាំងបែរ (ច្បាប់ដេកាត)ទី២នៃពន្លឺ ឬច្បាប់ Snell៖ $n_1 \sin i = n_2 \sin r$
- ទំនាក់ទំនងមាត្រក្នុងត្រីកោណកែង $\tan\theta = \frac{\text{ជ្រុងឈម}}{\text{អ៊ីប៉ូតេនុស}}$
- សមីការបន្ទាត់ និងមេគុណប្រាប់ទិសនៃបន្ទាត់

៣. ពិសោធន៍

លំនាំបញ្ហា ឬការបង្ហាញបាតុភូត




៣.១ សំណួរគន្លឹះ

ប្រសិនបើគេឱ្យពន្លឺដាលពីខ្យល់ទៅប៉ះផ្ទៃញែកនៃទឹក-ខ្យល់ ពេលនោះពន្លឺមួយភាគធំដាលចូលទៅក្នុងទឹក តើអ្នកអាចកំណត់សន្ទស្សន៍ទឹកបានយ៉ាងដូចម្តេច?

៣.២ សម្មតិកម្ម

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

**តម្រុយ៖**ត្រូវគិតពីច្បាប់ដេកាតទី២ (ច្បាប់Snell) ច្បាប់ចំណាំងបែរទី២។ បន្ទាប់មកត្រូវគូសក្រាប រួចកំណត់មេគុណប្រាប់ទិសតាមក្រាប។ តើមេគុណប្រាប់ទិសនោះជាអ្វី?

៣.៣ តេស្តសម្មតិកម្ម(ដំណើរការ)

(ក) តម្រូវការសម្ភារៈ (តាមE-Lab)

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

(ខ) ប្លង់ពិសោធន៍




.............................................................................................................................................

៣.៤ លទ្ធផល

តារាងទិន្នន័យ និងពិសោធន៍

| i (Degree) | r (Degree) | Sin r | Sin i |
|---|---|---|---|
| 0 | 0 | 0 | 0 |
| 10 | 7.0 | 0.122 | 0.174 |
| 20 | 15 | 0.259 | 0.342 |
| 30 | 22 | 0.375 | 0.500 |
| 40 | 28 | 0.469 | 0.643 |
| 50 | 34 | 0.559 | 0.766 |
| 60 | 40 | 0.643 | 0.866 |
| 70 | 44 | 0.695 | 0.940 |




%កម្រិតល្អៀង = $\left|\frac{1.33-1.36}{1.33}\right| \times 100\%$ = 2.26%

៣.៥ សន្និដ្ឋាន

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.................................................................................................................................... ។

៤. ពិភាក្សា៖

តើចំណាំបែរនៃពន្លឺត្រូវបានអនុវត្តក្នុងការរស់នៅរាល់ថ្ងៃនៅកន្លែងណាខ្លះ?














តើអ្នកត្រូវទុកដាក់ឧករណ៍អុបទិចខាងលើយ៉ាងដូចម្តេចដើម្បីចៀសវាងពីការធាប់ខូច?

# ពិសោធន៍ចម្ងាយកំណុំរបស់ឡង់ទី

## ១. វត្ថុបំណង

- សង់រូបភាពនៃវត្ថុដែលឲ្យដោយឡង់ទីបង្រួមដោយប្រើកាំពិសេស ។
- កំណត់ចម្ងាយកំណុំនៃឡង់ទីបង្រួមតាមរូបភាពពិតនៃវត្ថុដែលនៅឆ្ងាយ និងតាមវត្ថុ និងរូបភាពដែលមានចម្ងាយកំណត់ ។
- កំណត់ផលសងភាគរយនៃចម្ងាយកំណុំ( %Diff. ) និងកម្រិតល្អៀងស្តង់ដារបស់វា( $\alpha_f$ )។

## ១. ទ្រឹស្តី

- **ចំណុចកំណុំ និងចម្ងាយកំណុំឡង់ទីបង្រួម ( $f$)**

កាលណាបាច់ពន្លឺចាំងប៉ះលើឡង់ទីបង្រួមស្របនឹងអ័ក្សមេ ពេលចេញពីឡង់ទី បាច់ពន្លឺនេះត្រូវរួមគ្នាត្រង់ចំណុចមួយលើអ័ក្សមេ ចំណុចនេះហៅថាចំណុចកំណុំនៃឡង់ទី។ ចម្ងាយគិតពីចំណុចកណ្តាល នៃឡង់ទីទៅចំណុចកំណុំត្រូវបានគេហៅថាចម្ងាយកំណុំ តាងដោយ ( $f$)។ ចំពោះឡង់ទីបង្រួម $f > 0$ (រូបទី១)។

- **ចំណុចកំណុំ និងចម្ងាយកំណុំឡង់ទីពង្រីក ( $f$)**

កាលណាបាច់ពន្លឺចាំងប៉ះលើឡង់ទីពង្រីកស្របនឹងអ័ក្សមេ ពេលចេញពីឡង់ទីបាច់ពន្លឺនេះត្រូវបានពង្រីក និងបន្លាយនៃបាច់ពន្លឺនេះជួបគ្នាត្រង់ចំណុចមួយលើអ័ក្សមេ ចំណុចនេះហៅថាចំណុចកំណុំនៃឡង់ទី។ ចម្ងាយគិតពីចំណុចកណ្តាលនៃឡង់ទីទៅចំណុចកំណុំត្រូវបានគេហៅថាចម្ងាយកំណុំ តាងដោយ ( $f$)។ ចំពោះឡង់ទីពង្រីក $f < 0$ (រូបទី២)។

ឡង់ទីបង្រួម






រូបទី១

ឡង់ទីពង្រីក






រូបទី២

➢ **រូបមន្តឡង់ទី**

**ទំនាក់ទំនងរវាង ចម្ងាយកំណុំ( $f$) សន្ទស្សន៍( $n$) និងកាំកំណោង( $R$)**

$$\frac{1}{f} = (n-1)\left(\frac{1}{R_1} - \frac{1}{R_2}\right)$$

$n$ សន្ទស្សន៍របស់ឡង់ទី

$f$ ចម្ងាយកំណុំ, $f > 0$ ចំពោះឡង់ទីបង្រួម និង $f < 0$ ចំពោះឡង់ទីពង្រីក

$R_1$ និង $R_2$ កាំកំណោងរបស់ឡង់ទីបង្រួម ( $R_1 > 0$ និង $R_2 < 0$ )

$R_1$ និង $R_2$ កាំកំណោងរបស់ឡង់ទីពង្រីក ( $R_1 < 0$ និង $R_2 > 0$ )

**ទំនាក់ទំនងរវាង ចម្ងាយកំណុំ( $f$) ចម្ងាយវត្ថុ( $d$) និងចម្ងាយរូបភាព( $d'$)**

$$\frac{1}{f} = \frac{1}{d} + \frac{1}{d'}$$

$f$ ចម្ងាយកំណុំ, $f > 0$ ចំពោះឡង់ទីបង្រួម និង $f < 0$ ចំពោះឡង់ទីពង្រីក

$d$ ចម្ងាយវត្ថុ, បើ $d > 0$ វត្ថុពិត និង $d < 0$ វត្ថុមិនពិត

$d'$ ចម្ងាយរូបភាព, បើ $d' > 0$ រូបភាពពិត និង $d' < 0$ រូបភាពមិនពិត

**កម្រិតពង្រីកទំហំរូបភាព( $M$)**

$$M = \frac{A'B'}{AB} = -\frac{d'}{d}$$

បើ M > 0 រូបភាព និងវត្ថុមានទិសដៅដូចគ្នា

បើ M < 0 រូបភាព និងវត្ថុមានទិសដៅផ្ទុយគ្នា

- **សំណង់រូបភាពរបស់វត្ថុឲ្យដោយឡង់ទី**

ដើម្បីសង់រូបភាពនៃវត្ថុដែលឲ្យដោយឡង់ទី គេត្រូវប្រើកាំពិសេសពីរឬបីក្នុងបណ្តាកាំពិសេសបី៖

**ក. កាំពិសេសទី១**

កាំចាំងប៉ះលើឡង់ទីស្របនឹងអ័ក្សមេ ពេលចេញពីឡង់ទីកាត់តាមចំណុចកំណុំ $F_2$ ដែលនៅពីក្រោយឡង់ទី។

**ខ. កាំពិសេសទី២**

កាំចាំងប៉ះលើឡង់ទីកាត់តាមកំពូល( $O$)នៃឡង់ទី ដាលត្រង់គ្មានវងលំងាក។

**គ. កាំពិសេសទី៣**

កាំចាំងប៉ះលើឡង់ទីកាត់តាមចំណុចកំណុំ$F_1$ ដែលនៅពីខាងមុខឡង់ទី ពេលចេញពីឡង់ទី ស្របនឹងអ័ក្សមេ។




+ បើវត្ថុនៅឯអនន្ត យើងបាន $d = \infty$ នោះ $\frac{1}{f} = \frac{1}{\infty} + \frac{1}{d'}$ ដូចនេះ $d' = f$ មានន័យថាចម្ងាយរូបភាពស្មើនឹងចម្ងាយកំណុំ ដែលបញ្ជាក់ថារូបភាពស្ថិតត្រង់ចំណុចកំណុំ(រូបទី១ និងទី២ខាងលើ)។

+ បើវត្ថុស្ថិតនៅចម្ងាយ $d = 2f$ ពីមុខឡង់ទី នោះ $\frac{1}{f} = \frac{1}{2f} + \frac{1}{d'}$ យើងបានរូបភាពដែលស្ថិតនៅខាងក្រោយឡង់ទីក៏ស្ថិតនៅចម្ងាយ $d' = 2f$ ដែរ និងកម្ពស់រូបភាពស្មើនឹងកម្ពស់វត្ថុ(រូបទី៣)។



រូបទី៣

+ បើវត្ថុស្ថិតនៅចម្ងាយ $d = f$ ពីមុខឡង់ទី នោះ $\frac{1}{f} = \frac{1}{f} + \frac{1}{d'}$ យើងបាន $d'$
$= \infty$ រូបភាពនៅអនន្ត(រូបទី៤)។



រូបទី៤

- ករណីឡង់ទីពីរដាក់ប៉ះគ្នា(បិទភ្ជាប់គ្នា) ឡង់ទីមួយមានចម្ងាយកំណុំ $f_1$ និងឡង់ទីមួយទៀតមានចម្ងាយកំណុំ $f_2$ នោះចម្ងាយកំណុំសមមូល $f$ នៃឡង់ទីថ្មីដែលផ្សំពីឡង់ទីទាំងពីរបិទភ្ជាប់គ្នាឲ្យដោយៈ

$$\frac{1}{f} = \frac{1}{f_1} + \frac{1}{f_2}$$

- ផលសងភាគរយ(%$Diff$)នៃចម្ងាយកំណុំ

$$\%Diff = \left|\frac{f_{theo} - f_{exp}}{\frac{f_{theo} + f_{exp}}{2}}\right| \times 100\%$$

- លំងាកស្តង់ដានៃចម្ងាយកំណុំ

$$\delta_{n-1} = \sqrt{\frac{1}{n-1}\sum_i (f_i - \bar{f})^2}$$

- កម្រិតល្អៀងស្តង់ដានៃចម្ងាយកំណុំ

$$\alpha_f = \frac{\delta_{n-1}}{\sqrt{n}}$$

**ក្នុងការធ្វើពិសោធន៍ខាងក្រោម យើងលើកយកតែឡង់ទីបង្រួមមួយប៉ុណ្ណោះមកសិក្សា។**

## ៣. សំណួរមុនចូលទីពិសោធន៍

១. តើឡង់ទីជាអ្វី?

២. តើគេចែកឡង់ទីជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

៣. តើឡង់ទីបង្រួមជាអ្វី? និងឡង់ទីពង្រីកជាអ្វី?

៤. ចូរពោលពីវិធីដើម្បីសង់រូបភាពឲ្យដោយឡង់ទីបង្រួម និងឡង់ទីពង្រីក ព្រមទាំងគូររូបបញ្ជាក់។
៥. ចូរសង់រូបភាពនៃវត្ថុមួយដែលស្ថិតនៅឯអនន្តឲ្យដោយឡង់ទីបង្រួម និងឡង់ទីពង្រីក។
៦. សរសេររូបមន្តឡង់ទីដែលបង្ហាញពីទំនាក់ទំនងរវាងចម្ងាយកំណុំ សន្ទស្សន៍របស់ឡង់ទី និងកាំកំណោងរបស់វា។
៧. សរសេររូបមន្តឡង់ទីដែលបង្ហាញពីទំនាក់ទំនងរវាងចម្ងាយកំណុំ ចម្ងាយវត្ថុ និងចម្ងាយរូបភាព។
៨. សរសេររូបមន្តឡង់ទីដែលបង្ហាញពីទំនាក់ទំនងរវាងចម្ងាយកំណុំសមមូល ចម្ងាយកំណុំនៃឡង់ទីទី១ និងចម្ងាយកំណុំនៃឡង់ទីទី២ កាលណាគេបិទឡង់ទីពីរភ្ជាប់គ្នា។
៩. សង់រូបភាពនៃវត្ថុពិត *AB* ឈរត្រង់ដែល *A* ស្ថិតនៅលើអ័ក្សមេ និងស្ថិតពីមុខឡង់ទីបង្រួមមួយ បន្ទាប់មកស្រាយបញ្ជាក់ដើម្បីទាញរូបមន្តឡង់ទីដែលបង្ហាញពីទំនាក់ទំនងរវាងចម្ងាយកំណុំ សន្ទស្សន៍របស់ឡង់ទី និងកាំកំណោងរបស់វា$\left(\frac{1}{f}=(n-1)\left(\frac{1}{R_1}-\frac{1}{R_2}\right)\right)$។
១០. សង់រូបភាពនៃវត្ថុពិត *AB* ឈរត្រង់ដែល *A* ស្ថិតនៅលើអ័ក្សមេ និងស្ថិតពីមុខឡង់ទីបង្រួមមួយ បន្ទាប់មកស្រាយបញ្ជាក់ដើម្បីទាញរូបមន្តឡង់ទីដែលបង្ហាញពីទំនាក់ទំនងរវាងចម្ងាយកំណុំ ចម្ងាយវត្ថុ និងចម្ងាយរូបភាព $\left(\frac{1}{f}=\frac{1}{d}+\frac{1}{d\prime}\right)$។
១១. ចូរបង្ហាញថា កាលណាគេបិទឡង់ទីពីរភ្ជាប់គ្នា នោះចម្ងាយកំណុំសមមូល( *f*) ឲ្យដោយរូបមន្ត៖
$\frac{1}{f}=\frac{1}{f_1}+\frac{1}{f_2}$ ដែល $f_1$ ជាចម្ងាយកំណុំនៃឡង់ទីទី១ និង $f_2$ជាចម្ងាយកំណុំនៃឡង់ទីទី២។
១២. វត្ថុពិត *(AB*) មួយមានមានកម្ពស់ 15.0 cm ឈរត្រង់ដែល *A* ស្ថិតលើអ័ក្សមេនៅខាងមុខឡង់ទីចម្ងាយ 30.0 cm។ ចម្ងាយកំណុំរបស់ឡង់ទីស្មើនឹង10.0 cm( សិក្សាទាំងឡង់ទីបង្រួម និងឡង់ទីពង្រីក )។ កំណត់៖

ក. ទីតាំងរូបភាព ខ. ប្រភេទរូបភាព គ. កម្រិតពង្រីកទំហំរូបភាព ឃ. កម្ពស់រូបភាព

១៣. វត្ថុពិត *(AB*) មួយមានមានកម្ពស់ 15.0 cm ឈរត្រង់ដែល*A* ស្ថិតលើអ័ក្សមេនៅពីមុខឡង់ទីបង្រួម ចម្ងាយ 2.58 m ។ ចម្ងាយកំណុំរបស់ឡង់ទីបង្រួម ស្មើនឹង 58.0 cm ។ កំណត់៖

ក. ទីតាំងរូបភាព ខ. ប្រភេទរូបភាព គ. កម្រិតពង្រីកទំហំរូបភាព ឃ. កម្ពស់រូបភាព

ង. កម្រិតល្មៀងរបស់ទីតាំងរូបភាព បើទីតាំងរូបភាពត្រូវបានគេវាស់ឃើញស្មើនឹង 0.75 m ពីក្រោយឡង់ទីបង្រួម។

១៤. វត្ថុពិត *(AB*) មួយមានមានកម្ពស់ 20 cm ឈរត្រង់ដែល*A* ស្ថិតលើអ័ក្សមេនៅពីមុខឡង់ទីបង្រួម ចម្ងាយ 2.04 m ។ ចម្ងាយកំណុំរបស់ឡង់ទីបង្រួម ស្មើនឹង 100 cm ។ កំណត់៖

ក. ទីតាំងរូបភាព ខ. ប្រភេទរូបភាព គ. កម្រិតពង្រីកទំហំរូបភាព ឃ. កម្ពស់រូបភាព

ង. %Diff.នៃចម្ងាយកំណុំ បើកំណុំរូបភាពត្រូវបានគេវាស់ឃើញស្មើនឹង2.00 m ពីក្រោយឡង់ទីបង្រួម។

១៥.គេធ្វើពិសោធន៍ដើម្បីវាស់ចម្ងាយកំណុំនៃឡង់ទីបង្រួមមួយនិងទទួលបានលទ្ធផលដូចក្នុងតារាងខាងក្រោម៖

| ចម្ងាយវត្ថុ<br>$d$ (m) | ចម្ងាយរូបភាព<br>$d'$(m) | ចម្ងាយកំណុំ<br>$f_{theo}$(m) | $\bar{f}_{theo}$(m) | %Diff |
|---|---|---|---|---|
| 0.50 | 0.73 | | | |
| 0.80 | 0.46 | | | |
| 1.1 | 0.40 | | | |
| 1.4 | 0.37 | | | |
| $d = \infty$ (ឆ្ងាយ) | $d' = f_{exp} = $ 30 cm | | $\alpha_f =$ | |

គណនា៖ ក. ចម្ងាយកំណុំរបស់ឡង់ទី ($\bar{f}_{theo}$)

ខ. ផលសងភាគរយនៃចម្ងាយកំណុំ

គ. កម្រិតល្អៀងស្តង់ដានៃចម្ងាយកំណុំ

## ៤. តម្រូវការសម្ភារឧបទេស

Software PHET Simulation ដែលដំឡើងរួចលើកំព្យូទ័ររបស់អ្នក

## ៥. ដំណើរការ

(ក) ចុចពីរដងជាប់គ្នាលើ PHET Simulations លើអេក្រង់នៃកំព្យូទ័ររបស់អ្នក ពេលនោះវានឹងលេចចេញផ្ទាំងអក្សរធំមួយនៅខាងឆ្វេងដែលសរសេរថា Play with Simulations ។ ចុចលើ Play with Simulations វានឹងលេចចេញបញ្ជីឈ្មោះពិសោធន៍ដែលរៀបតាមអក្ខរក្រម(Alphabet)ពីA ទៅ Z ។ នៅជួរខាងឆ្វេងមានពាក្យថា Simulations និងខាងក្រោមវាមានពាក្យថា Physics, Chemistry, Biology, Earth Science, Math, ... ដែលបញ្ជាក់ថាអ្នកអាចធ្វើពិសោធន៍បានជាមួយ Physics, Chemistry, Biology, Earth Science, Math ។

(ខ) ចុចលើពាក្យថា Physics (រូបវិទ្យា) វានឹងបង្ហាញបញ្ជីពិសោធន៍យ៉ាងច្រើនដែលអ្នកអាចធ្វើពិសោធន៍បានក្រោមទម្រង់ជារូបភាព។ សូមចងចាំថាពិសោធន៍របស់អ្នកគឺអុបទិចធរណីមាត្រ(ឡង់ទី)។ ដូចនេះត្រូវយក Geometric Optics ដែលមានរូបពិសោធន៍ឡង់ទី ។ ចុចលើពាក្យ Geometric Optics ពេលនោះវានឹងលេចចេញជា File VIDEO ។

(គ) ចុចលើ VIDEO នេះ វានឹងចេញរូបខាងក្រោម។




❖ នៅផ្នែកខាងលើរូបពិសោធន៍ឡង់ទី មានប្រអប់ធំមួយពណ៌លឿងដែលក្នុងប្រអប់ធំនោះមានប្រអប់ តូចៗជាច្រើនដូចជា៖

- No ray: គ្មានកាំពន្លឺចាំងប៉ះទេ
- Marginal rays: កាំពន្លឺចាំងប៉ះលើឡង់ទី(តែមិនមែនជាកាំពិសេស)
- Principal rays: កាំពន្លឺចាំងប៉ះមេដែលជាកាំពិសេស(**យើងត្រូវប្រើកាំពន្លឺនេះដើម្បីសង់រូបភាព**)
- Many rays: កាំពន្លឺចាំងប៉ះច្រើន
- 2nd Point: ចំណុចទីពីរ(ជាចំណុចវត្ថុដែរដែលមានកាំពន្លឺចេញពីវា)
    - Curvature radius (m): កាំកំណោងគិតជា(m)
    - Refractive index: សន្ទស្សន៍ចំណាំងបែរជា**សន្ទស្សន៍របស់ឡង់ទី**
    - Diameter (m): អង្កត់ផ្ចិតឡង់ទីគិតជា(m)
- Change objects: ប្តូរវត្ថុ អ្នកអាចប្តូរពីខ្មៅដៃទៅវត្ថុផ្សេងៗទៀតដូចជា ផ្កាយ មុខព្រះចន្ទ ព្រួញឈរ។
- Show guides បង្ហាញការណែនាំ
- Virtual image: រូបភាពមិនពិត
- Screen: អេក្រង់
- Ruler: បន្ទាត់

❖ នៅផ្នែកខាងក្រោមរូបពិសោធន៍ឡង់ទីមាន៖

- Show help: បង្ហាញជំនួយ

(ឃ) ចុចលើប្រអប់ដែលមានពាក្យ Principal rays ដើម្បីប្រើកាំពិសេសសង់រូបភាពឲ្យដោយឡង់ទី។ ទាញគន្លឹះរបស់ Curvature radius (m) មកឆ្វេងបំផុតដើម្បីបានកាំ 0.3 m និងចុចលើប្រអប់ Ruler ដើម្បីយកបន្ទាត់ទុកសម្រាប់វាស់ប្រវែង(ចម្ងាយ)។

(ង) ចុចលើរូបឡង់ទីបង្រួមដើម្បីធ្វើបម្រែបម្រួលទីតាំងឡង់ទីដោយដាក់វានៅខាងស្តាំ និងចុចទាញស៊ុមខ្មៅដៃ(វត្ថុ)ទៅផ្នែកខាងស្តាំបង្ហាញដូចរូបខាងក្រោម។ នេះបង្ហាញថាវត្ថុនៅឯអនន្ត យើងបានរូបភាពផ្តុំគ្នានៅត្រង់ចំណុចកំណុំ។




(ច) វាស់ចម្ងាយពីពាក់កណ្តាលឡង់ទីទៅរូបភាពដែលកុំលើចំណុចកំណុំ។ ករណីនេះចម្ងាយរូបភាពស្មើនឹងចម្ងាយកំណុំ ($d' = f_{exp}$) ។ កត់ត្រាតម្លៃនេះដាក់ក្នុងតារាងទិន្នន័យនិងគណនាខាងក្រោម។ តម្លៃនេះជាតម្លៃតាមពិសោធន៍ ( $f_{exp}$)

(ឆ) ចុចទាញឡង់ទី និងស៊ុមខ្មៅដៃម្តងមួយៗ មកជិតផ្នែកកណ្តាលនៃអេក្រង់កំព្យូទ័រ រួចដាក់វត្ថុនៅចម្ងាយ 0.50 m, 0.80 m, 1.1 m, 1.4 m និង 1.7 m រៀងគ្នាពីឡង់ទីបង្រួម និង វាស់ចម្ងាយរូបភាពនីមួយដែលត្រូវគ្នានឹងចម្ងាយរបស់វា រួចកត់ត្រាតម្លៃទាំងនេះដាក់ក្នុងតារាងទិន្នន័យខាងក្រោម។

## ៦. លទ្ធផលពិសោធន៍

តារាងទិន្នន័យ និងគណនា

| ចម្ងាយវត្ថុ $d$ (m) | ចម្ងាយរូបភាព $d'$ (m) | ចម្ងាយកំណុំ $f_{theo}$ (m) | $\bar{f}_{theo}$ (m) | %Diff |
|---|---|---|---|---|
| 0.50 | | | | |
| 0.80 | | | | |
| 1.1 | | | | |
| 1.4 | | | | |
| $d = \infty$ (ឆ្ងាយ) | $d' = f_{exp} =$ 30 cm | | $\alpha_f =$ | |

ការគណនាគម្រូ

$$f = \frac{dd'}{d+d'} =$$

$$\bar{f}_{theo} =$$

$$\%Diff = \left|\frac{f_{theo} - f_{exp}}{\frac{f_{theo} + f_{exp}}{2}}\right| \times 100\% =$$

$$\delta_{n-1} = \sqrt{\frac{1}{n-1}\sum_i \left(f_i - \bar{f}\right)^2}$$

$$\alpha_f = \frac{\delta_{n-1}}{\sqrt{n}} =$$

## ៧. សន្និដ្ឋាន

ដោយផ្អែកលើលទ្ធផលពិសោធន៍ខាងលើ៖

- ដើម្បីសង់រូបភាពនៃវត្ថុដែលឲ្យដោយឡង់ទីបង្រួម គេប្រើកាំពិសេសចំនួន……………….ក្នុងចំណោមកាំពិសេសទាំងបី ។
- គេអាចកំណត់ចម្ងាយកំណុំនៃឡង់ទីបង្រួមបានតាមរយៈ៖

  ក. ដាក់វត្ថុពិតឲ្យនៅឆ្ងាយអនន្ត ពេលនោះបាច់ពន្លឺដែលចេញពីវត្ថុជាបាច់ស្របៗគ្នា ចាំងប៉ះលើឡង់ទីបង្រួម ពេលចេញពីឡង់ទី………………………………….។ ចម្ងាយរូបភាព …………និងចម្ងាយកំណុំ។

  ខ. ដោយវាស់ចម្ងាយវត្ថុ និងចម្ងាយរូបភាព យើងអាចគណនាចម្ងាយកំណុំតាមរូបមន្ត………………។
- ផលសងភាគរយនៃចម្ងាយកំណុំ( %Diff. )ឲ្យតាមរូបមន្ត……………………….=……………….%

  និងកម្រិតល្អៀងស្តង់ដា( $\alpha_f$ )…………………………….=…………………. ។

ដូចនេះវត្ថុបំណងត្រូវសម្រេចដោយជោគជ័យ។

## ៨. ពិភាក្សា

១. តើអ្វីដែលជាការលំបាកដែលអ្នកជួបប្រទះក្នុងពិសោធន៍នេះ?

២. ដើម្បីដោះស្រាយការលំបាកដែលបានលើកឡើងខាងលើ តើអ្នកមានគំនិតច្នៃប្រឌិតដូចម្តេច?

## កិច្ចការស្រាវជ្រាវរបស់គរុនិស្សិត

ពិសោធន៍ច្បាប់រក្សាថាមពល

ពិសោធន៍រង្វាស់មេគុណទង្គិច

ពិសោធន៍រវេសូណាង់សូរ

ពិសោធន៍រលកជញ្ជ្រំ

# ផ្នែកទីបី

# មេរៀនទី១៖ រូបវិទ្យាធៀប

## 1.1 គោលការណ៍ធៀបហ្គាលីលេ

### ចលនាធៀប៖

អ្នករត់ម្នាក់(B) ក្នុងរូប១.១ កំពុងរត់ដោយមានវ៉ិចទ័រល្បឿន $5\ m/s$ ។ សំណួរអាចសួរថាតើវ៉ិចទ័រល្បឿនរបស់អ្នករត់នេះស្មើប៉ុន្មាន? សំនួរនេះមិនមានចម្លើយតែមួយទេ។ ចំពោះ C ដែលឈរស្ងៀមថា វ៉ិចទ័រល្បឿនរបស់អ្នករត់គឺ $v_x = 5\ \text{m/s}$ ។ តែចំពោះ A ដែលកំពុងជិះកង់ទន្ទឹមនឹងអ្នករត់មើលឃើញថា វ៉ិចទ័រល្បឿនរបស់អ្នករត់នោះគឺ $v_x = 0\ \text{m/s}$ ។ ចំពោះ D កំពុងបើកឡានដោយមានវ៉ិចទ័រល្បឿន $15\ \text{m/s}$ បានឃើញអ្នករត់ B ឃ្លាតឆ្ងាយពីគាត់ $10\ \text{m}$ រាល់វិនាទីក្នុងទិសដៅផ្ទុយពីគាត់ តាមរយៈកញ្ចក់ចំហៀងរបស់រថយន្ត។ គាត់ថា វ៉ិចទ័រល្បឿនរបស់អ្នករត់គឺ $v_x = -10\ \text{m/s}$ ។ តើមួយណាជាវ៉ិចទ័រល្បឿនពិតប្រាកដរបស់អ្នករត់?

វ៉ិចទ័រល្បឿនគឺមិនមែនជាបញ្ញាតិដែលអាចថាពិត ឬមិនពិតបានទេ។ វ៉ិចទ័រល្បឿនរបស់អ្នករត់ B ធៀបនឹង C គឺ $5\ \text{m/s}$ ។ គឺថា វ៉ិចទ័រល្បឿនរបស់អ្នករត់គឺ $5\ \text{m/s}$ ក្នុងប្រព័ន្ធកូអរដោនេដែលនៅជាប់នឹង C ដែលនៅនឹង។ វ៉ិចទ័រល្បឿនរបស់អ្នករត់ B ធៀបទៅនឹង A គឺសូន្យ ។ វ៉ិចទ័រល្បឿនរបស់អ្នករត់ B ធៀបនឹង D គឺ $-10\ \text{m/s}$ ។ ទាំងអស់នេះគឺសុទ្ធតែត្រឹមត្រូវចំពោះការពណ៌នាពីវ៉ិចទ័រល្បឿនរបស់អ្នករត់។




រូបទី១.១៖ A, C និង D ម្នាក់ៗវាស់វ៉ិចទ័រល្បឿនរបស់អ្នករត់ម្នាក់ B។
វ៉ិចទ័រល្បឿនដែលបានបង្ហាញក្នុងរូបនេះគឺនៅក្នុងប្រព័ន្ធយោង C ។

### ទីតាំងធៀប៖

សន្មតថា C និង A ត្រូវបានប្រពន្ធ័កូអរដោនេនៅជាប់នឹងខ្លួនរបស់ពួកគេ។ នៅពេល A ជិះកង់ឆ្លងកាត់ C គាត់បាននាំប្រពន្ធ័កូអរដោនេរបស់គាត់ទៅជាមួយ។ ឧបមាថា C និង A មានអ្នកជួយដែលប្រដាប់ដោយម៉ែត និង ក្រូណូម៉ែត(stopwatch) នៅក្នុងប្រពន្ធ័កូអរដោនេរបស់ពួកគេ។ ជាមួយនឹងអ្នកជួយរបស់ពួកគេ គឺអាចវាស់ ទីតាំងដែលបាតុភូតរូប ឬព្រឹត្តិការណ៍ដែលកើតឡើង និងរយៈពេលដែលវាកើតឡើង។ ប្រពន្ធ័កូអរដោនេដែលអ្នកពិសោធន៍អាចធ្វើការវាស់នូវទីតាំង និងរយៈពេលនៃបាតុភូត ឬព្រឹត្តិការណ៍ ហៅថាប្រពន្ធ័យោង។

ក្នុងរូបទី១.២ ប្រពន្ធ័កូអរដោនេ $xy$ ជាប្រពន្ធ័យោង S និងប្រពន្ធ័កូអរដោនេ $x'y'$ ជាប្រពន្ធ័យោង S′ ។ S′ កំពុងផ្លាស់ទីដោយវ៉ិចទ័រល្បឿន $\vec{V}$ ធៀបនឹង S។ បើអ្នកពិសោធន៍នៅជាប់នឹងប្រពន្ធ័យោង S ពិនិត្យចលនារបស់ S′ ដែលបានឆ្លងកាត់ ឃើញថា S′ មានវ៉ិចទ័រល្បឿន $\vec{V}$ ។ ចំពោះអ្នកពិសោធន៍ដែលនៅជាប់នឹងប្រពន្ធ័យោង S′ វិញពិនិត្យឃើញថា S មានវ៉ិចទ័រល្បឿន $-\vec{V}$ ។ ប្រពន្ធ័យោងដែលផ្លាស់ទីដោយល្បឿនថេរ ហៅថាប្រពន្ធ័យោងនិចល(inertial reference frames) ឬអាចនិយាយថាជាប្រពន្ធ័យោងដែលអនុវត្តត្រឹមត្រូវជាមួយច្បាប់ទីមួយញូតុន។




រូបទី១.២៖ ប្រពន្ធ័យោង S′ ផ្លាស់ទីដោយវ៉ិចទ័រ ល្បឿន $\vec{v}$ ធៀបនឹងប្រពន្ធ័យោង S។

សន្មតថាមានអំពូលភ្លើងមួយបញ្ចេញពន្លឺនៅខណៈ $t$ ។ អ្នកសង្កេតនៅក្នុងប្រពន្ធ័យោងទាំងពីរឃើញ និងកំណត់ទីតាំងរបស់វាថា វ៉ិចទ័រទីតាំងរបស់អំពូលភ្លើងធៀបនឹងប្រពន្ធ័យោង S គឺ $\vec{r}$ ហើយធៀបនឹង S′ គឺ $\vec{r}'$ ។ ទំនាក់ទំនងរវាង $\vec{r}$ និង $\vec{r}'$ តាមរូបទី១.៣អាចសរសេរ

$$\vec{r} = \vec{r}' + \vec{R}$$

ដែល $\vec{R}$ ជាវ៉ិចទ័រទីតាំងរបស់ S′ ធៀបនឹង S ។

ប្រពន្ធ័យោង S′ កំពុងផ្លាស់ទីដោយវ៉ិចទ័រល្បឿន $\vec{V}$ ធៀបនឹង S ដែលនៅខណៈដើមពេល $t = 0$ S និង S′ ត្រួតស៊ីគ្នា។ នៅខណៈពេល $t$ ប្រពន្ធ័យោង S′ ផ្លាស់ទីទៅដល់ទីតាំង

មួយដែលមានវ៉ិចទ័រតាំង $\vec{R} = t\vec{V}$ ដូច្នេះគេបាន

$$\vec{r} = \vec{r}' + t\vec{V} \text{ ឬ } \vec{r}' = \vec{r} - t\vec{V} \qquad (១.១)$$

សរសេរជាកំប៉ូសង់នៃទីតាំង

$$x = x' + V_x t \qquad \text{or} \qquad x' = x - V_x t \qquad (១.២)$$
$$y = y' + V_y t \qquad\qquad\quad y' = y - V_y t$$




រូបទី១.៣៖ វង្វាស់បានធ្វើឡើងក្នុងប្រពន្ធ័យោង S និង S′ ។

បើគេដឹងពីទីតាំង និងពេលវេលាដែលព្រឹត្តិការណ៍មួយបានកើតឡើងក្នុងប្រពន្ធ័យោងមួយ គេអាចបំលែងទីតាំងនោះទៅក្នុងប្រពន្ធ័យោងដ៏ទៃទៀត ដែលផ្លាស់ទីធៀបនឹងប្រពន្ធ័យោងទីមួយដោយវ៉ិចទ័រល្បឿនថេរ $\vec{V}$ ។

## ល្បឿនធៀប៖

ឧបមាថានៅខណៈ $t = 0$ ជាខណៈដែលគល់នៃប្រពន្ធ័យោងទាំងពីរត្រួតស៊ីគ្នា។ ដូច្នេះនៅយណៈពេល $t$ គល់នៃប្រពន្ធ័យោងទាំងពីរឃ្លាតពីគ្នាកំណត់ដោយវ៉ិចទ័រទីតាំង $\vec{R} = \vec{V}t$ ។ ទីតាំងចំនុច P របស់ភាគល្អិតធៀបនឹងអ្នកសង្កេត A កំណត់ដោយវ៉ិចទ័រទីតាំង $\vec{r}$ ហើយធៀបនឹង B កំណត់ដោយ $\vec{r}'$ ។ តាមរូបទី ១.៤ ឃើញថា $\vec{r}$ និង $\vec{r}'$ មានទំនាក់ទំនងគ្នាតាម

$$\vec{r} = \vec{r}' + \vec{V}t \qquad (១.៣)$$

ធ្វើដេរីវេសមីការ ១.៣ ធៀបនឹងពេល $t$ គេបាន

$$\frac{d\vec{r}}{dt} = \frac{d\vec{r}'}{dt} + \vec{V} \quad (\vec{V}\ \text{ថេរ})$$

$$\vec{v} = \vec{v}' + \vec{V} \qquad (១.៤)$$

ដែល $\vec{v}$ ជាវ៉ិចទ័រល្បឿនរបស់ភាគល្អិតវាស់ដោយអ្នកសង្កេត A ហើយ $\vec{v}'$ ជាវ៉ិចទ័រល្បឿនវាស់ដោយអ្នកសង្កេត B និង $\vec{V}$ ជាវ៉ិចទ័រល្បឿនរបស់ B ធៀបនឹង A ។




រូបទី ១.៤៖ ភាគល្អិត P ត្រូវបានពណ៌នាដោយអ្នកសង្កេតពីរ មួយនៅប្រពន្ធ័យោង S (នៅនឹង) និងមួយទៀតនៅក្នុងប្រពន្ធ័យោង S′ ផ្លាស់ទីទៅស្តាំដោយវ៉ិចទ័រល្បឿនថេរ $\vec{V}$ ។

## បំលែងហ្គាលីលេ៖

ប្រពន្ធ័យោងពីរ S និង S′ ដែល S′ ផ្លាស់ទីដោយវ៉ិចទ័រល្បឿនថេរ $\vec{V}$ រូបទី ១.៥ ។ ដើម្បីឱ្យងាយស្រួល គេមិនគិតពីអក្ស័ z ទេ។ ប្រពន្ធ័ទាំងពីរមានអក្ស័ $x$ ស្ថិតនៅបន្ទាត់តែមួយ។




គល់តំរុយ O និង O’ ត្រួតស៊ីគ្នានៅខណៈ: $t = 0$

រូបទី ១.៥៖ ទីតាំងភាគល្អិតបង្ហាញដោយកូអរដោនេ $xy$ ក្នុងប្រពន្ធ័យោង S និងកូអរដោនេ $x'y'$ ក្នុងប្រពន្ធ័យោង S′ ។

ទីតាំងភាគល្អិត P ធៀបនឹង S កំណត់ដោយ $x$ ហើយធៀបនឹង S′ គឺ $x'$ ។ តាមរូប១.៥ ទំនាក់ទំនងរវាង $x$ និង $x'$ សរសេរ

$$x = x' + Vt\,,\qquad y = y', z = z' \qquad (១.៥)$$

សមីការ ១.៥ ហៅថាបំលែងទីតាំងរបស់ហ្គាលីលេ។

បើ P ផ្លាស់ទីតាមទិសដៅ $x$ វ៉ិចទ័រល្បឿនខណៈ $v_x$ វាស់ដោយអ្នកសង្កេតនៅនឹងក្នុង S គឺ $v_x = dx/dt$ ។ វ៉ិចទ័រល្បឿន $v_x'$ វាស់ដោយអ្នកសង្កេតក្នុង S′ គឺ $v_x' = dx'/dt$ ។ធ្វើដេរីវេសមីការ ១.៥ ធៀបនឹងរយៈពេលគេបាន

$$\frac{dx}{dt} = \frac{dx'}{dt} + V$$

$$v_x = v_x' + V \tag{១.៦}$$

សមីការ ១.៦ ហៅថាបំលែងវ៉ិចទ័រល្បឿនរបស់ហ្គាលីឡេ ។

## គោលការណ៍ធៀបរបស់ហ្គាលីឡេ៖

អ្នកធ្វើពិសោធន៍ក្នុងប្រពន្ធ័យោង S និង S′ វាស់តម្លៃនៃវ៉ិចទ័រទីតាំង និងតម្លៃវ៉ិចទ័រល្បឿន ទទួលបានខុសគ្នា។ តើការវាស់កម្លាំង និងសំទុះរបស់ភាគល្អិតវិញ ក្នុងរូបទី ១.៦ ដូចម្តេចដែរ?

អ្នកធ្វើពិសោធន៍ក្នុងប្រពន្ធ័យោងទាំងពីរ វាស់កម្លាំងដូចគ្នា




អ្នកធ្វើពិសោធន៍ក្នុងប្រពន្ធ័យោងទាំងពីរ វាស់សំទុះដូចគ្នា

រូបទី ១.៦៖ អ្នកធ្វើពិសោធន៍ក្នុងប្រពន្ធ័យោងទាំងពីរ ធ្វើតេស្តច្បាប់ទីពីរញូតុន ដោយវាស់កម្លាំងដែលមានអំពើលើភាគល្អិត និងសំទុះរបស់វា។

កម្លាំងអាចវាស់បានដោយប្រើឌីណាម៉ូម៉ែត។ អ្នកធ្វើពិសោធន៍ក្នុងប្រពន្ធ័យោងទាំងពីរពិនិត្យ ថាឌីណាម៉ូម៉ែតចង្អុលតម្លៃដូចគ្នា ដូច្នេះពួកគេសន្និដ្ឋានថាកម្លាំងគឺដូចគ្នា។ មានន័យថា $F' = F$ ។ គេអាចបប្រៀបធៀបសំទុះដែលបានវាស់ក្នុងប្រពន្ធ័យោងទាំងពីរដោយធ្វើដេរីវេនៃសមីការបំលែងល្បឿន( សមីការ ១.៦ ) ។ ដោយវ៉ិចទ័រល្បឿនរបស់ប្រពន្ធ័យោងថេរគេបាន $dV/dt = 0$ ដូច្នេះសំទុះរបស់ភាគល្អិតគឺ

$$a' = \frac{dv'}{dt} = \frac{dv}{dt} = a \tag{១.៧}$$

អ្នកធ្វើពិសោធន៍ក្នុងប្រពន្ធ័យោង S និង S′ ទទួលបានតម្លៃនៃវ៉ិចទ័រល្បឿន និងវ៉ិចទ័រទីតាំងខុសគ្នា ប៉ុន្តែពួកគេទទួលស្គាល់ថាសំទុះដូចគ្នា។

បើ $F = ma$ ក្នុងប្រពន្ធ័យោង S ហើយ $F' = ma'$ ក្នុងប្រពន្ធ័យោង S′ ។ គេអាចនិយាយថា បើច្បាប់ទីពីរញូតុនអនុវត្តបានត្រឹមត្រូវក្នុងប្រពន្ធ័យោងនិចលមួយ នោះវាអាចអនុវត្តបានត្រឹមត្រូវក្នុងគ្រប់ប្រពន្ធ័យោងនិចលទាំងអស់។ ពីព្រោះច្បាប់របស់មេកនិច ដូចជា ច្បាប់រក្សាជាដើម គឺចេញពីពីច្បាប់ទីពីរញូតុន។ ការសន្និដ្ឋាននេះថា ជាគោលការធៀបរបស់ហ្គាលីឡេ។

គោលការណ៍ធៀបរបស់ហ្គាលីឡេពោលថា៖ ច្បាប់មេកានិចទាំងឡាយគឺដូចគ្នានៅក្នុងប្រពន្ធ័យោងនិចលទាំងអស់។

ពិនិត្យលើការសង្កេតមួយដែលពន្យល់ពីភាពសមមូលនៃច្បាប់ចលនាមេកានិចក្នុងប្រពន្ធ័យោងនិចលពីរ។ រថយន្តក្នុងរូបទី ១.៧ ផ្លាស់ទីដោយវ៉ិចទ័រល្បឿនថេរធៀបនឹងដី។ បើអ្នកដំណើរលើរថយន្តបោះបាល់មួយឡើងលើត្រង់ ហើយមិនគិតពីអំពើនៃកំលាំងខ្យល់ អ្នកដំណើរនឹងសង្កេតឃើញថា បាល់ផ្លាស់ទីតាមគន្លងឈរ។ ចលនារបស់បាល់បង្ហាញយ៉ាងច្បាស់ថាដូចគ្នានឹងបាល់ដែលត្រូវបានចោលដោយមនុស្សឈរស្ងៀមលើដីដែរ។




រូបទី ១.៧៖ អ្នកសង្កេតពីរនាក់មើលឃើញគន្លងរបស់បាល់ដែលត្រូវបានចោល ខុសគ្នា។

ច្បាប់ទំនាញសាកល និងសមីការចលនាក្រោមសំទុះថេរត្រូវបានគោរពតាម មិនថារថយន្តនៅស្ងៀម ឬមានចលនាស្មើទេ។ អ្នកសង្កេតទាំងពីរទទួលស្គាល់នូវច្បាប់រូបវិទ្យា៖ អ្នកសង្កេតនៅលើឡានចោលបាល់ឡើងលើ ហើយបាល់ក៏ធ្លាក់មកក្នុងដៃគាត់វិញ ដោយយោងទៅតាមចលនារបស់ភាគល្អិតក្រោមសំទុះថេរ។ អ្នកសង្កេតនៅលើដីឃើញគន្លងរបស់បាល់រាងជាប៉ារាបូលដូចរូប ១.៧ខ។ តាមអ្នកសង្កេតនៅលើដី បាល់មានអាប់ស៊ីសវ៉ិចទ័រល្បឿនស្មើនឹងវ៉ិចទ័រល្បឿនរបស់រថយន្ត ហើយចលនាតាមអ័ក្សដេករបស់បាល់

ត្រូវបានពណ៌នាដោយគំរូនៃចលនារបស់ភាគល្អិតដោយល្បឿនថេរ។ ទោះជាអ្នកសង្កេតទាំងពីរមិនយល់ស្របគ្នាលើទិដ្ឋភាព ឬស្ថានភាពដែលបានឃើញ ប៉ុន្តែពួកគេយល់ស្របទៅលើសុពលភាពរបស់ច្បាប់ញូតុន។ ការយល់ព្រមនេះបញ្ជាក់ថា គ្មានពិសោធន៍មេកានិចណាអាចរកឃើញនូវភាពខុសគ្នារវាងប្រពន្ធ័យោងនិចលពីរទេ។ រឿងតែមួយគត់ដែលអាចរកឃើញគឺ ចលនាធៀបរបស់ប្រពន្ធ័យោងមួយធៀបនឹងមយយទៀត។

## 1.2 ពិសោធន៍ Michelson-Morley

ការពិសោធន៍ដ៏ល្បីមួយបានរៀបចំឡើងដើម្បីរកឱ្យឃើញ បម្រែបម្រួលយ៉ាងតូចរបស់ល្បឿនពន្លឺត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ ១៨៨១ ដោយ A. A. Michelson ហើយក្រោយមកទៀតត្រូវបានធ្វើឡើងវិញក្រោមលក្ខខណ្ឌផ្សេងៗដោយ Michelson និង Edward W. Morley នៅឆ្នាំ (១៨៣៨ - ១៩២៣)។

ពិសោធន៍ត្រូវបានរៀបចំឡើងដើម្បីកំណត់វ៉ិចទ័រល្បឿនរបស់ផែនដីធៀបនឹងអាកាស(ether) ។ ពិសោធន៍នេះផ្អែកលើគោលការណ៍ដូចបង្ហាញក្នុងរូបទី ១.៨ ។ ក. គឺជាដ្យាក្រាមនៃ




រូបទី ១.៨៖ ពិសោធន៍ Michelson – Morley ។ ក. Michelson interferometer ។
ខ. ប្រដូចពិសោធន៍ទៅនឹងទូក៖ ទូកទី១ ឆ្លងកាត់ទទឹងទន្លេរួចត្រឡប់មកវិញ
ទូកទី២ចុះតាមបណ្ដោយទឹងហូរ រួចត្រឡប់មកវិញ(ទូកមានល្បឿន $c$ ធៀបនឹងទឹក)។
គ. ការគណនាវ៉ិចទ័រល្បឿនរបស់ទូក(បាច់ពន្លឺ) ក្នុងដំណើរកែងនឹងចរន្តទឹក(ខ្យល់អាកាស ឬether wind)។

ឧបករណ៍ឈ្មោះ Michelson interferometer ហើយសន្មតថាខ្យល់អាកាស(ether wind) កំពុងផ្លាស់ទីទៅស្ដាំដោយល្បឿន $v$ (ផ្លាស់គ្នាជាមួយផែនដីដែលត្រូវបានសន្មតថាផ្លាស់ទីទៅឆ្វេងធៀបនឹងអាកាសដោយល្បឿន $v$ )។ បាច់ពន្លឺចេញពីប្រភពពន្លឺត្រូវបានបែកចេញជាពីរដោយសារ កញ្ចក់ប្លង់ពាក់កណ្ដាលផ្លាត $M_S$ ។ បាច់ពន្លឺមួយដាលឆ្ពោះទៅកញ្ចក់ $M_1$ ហើយបាច់ពន្លឺមួយទៀតដាលឆ្ពោះទៅកញ្ចក់ $M_2$ ។ បាច់

ពន្លឺដែលផ្លាតពីកញ្ចក់ $M_1$ និង $M_2$ ត្រូវបានរួមគ្នាឡើងវិញបន្ទាប់ពីឆ្លងកាត់ $M_S$ ។ តម្រួតនៃបាច់ពន្លឺបង្កើតបានអាំងទែផេរ៉ង់ ហើយជាលទ្ធផលត្រូវបានមើលឃើញដោយភ្នែកអ្នកសង្កេតនូវគំរូអាំងទែផេរ៉ង់។

ទោះជាអាំងទែផេរ៉ង់បែបក៏សាង ឬបំផ្លាញក៏ដោយ កើតមាននៅត្រង់ចំនុចកណ្តាលនៃគំរូអាំងទែផេរ៉ង់ អាស្រ័យនឹងទំនាក់ទំនងផាសរបស់បាច់ពន្លឺទាំងពីរ បន្ទាប់ពីពួកវាបានដាលតាមគន្លងរៀងខ្លួន។ សូមពិនិត្យមើលការប្រដូចនៃដំណើររបស់ទូកឡើង និងចុះព្រមទាំងឆ្លងកាត់ទទឹង ទន្លេមួយដែលចរន្តទឹកហូរមានល្បឿន $v$ ដូចបង្ហាញក្នុងរូប ១.៨ ខ។ ទឹកទន្លេស្ងប់ ទូកផ្លាស់ទីដោយល្បឿន $c$ (មិនមែនជាល្បឿនពន្លឺទេ ករណីនេះ)។

ដំបូងពិនិត្យបាច់ពន្លឺទី២ ក្នុងរូប ១.៨ ក ដែលដាលឆ្ពោះទៅខ្យល់អាកាស(ether wind)។ ក្នុងដំនើររបស់វាពី $M_S$ ទៅ $M_2$ ពន្លឺត្រូវដាលដោយមានល្បឿន $c+v$ ។ តាមរូបវិទ្យាបូរាណ វាដូចជាដំណើររបស់ទូកស្របនឹងចរន្តទឹក(រូប ១.៨ ខ) គេត្រូវបូកល្បឿនរបស់ទឹកទន្លេជាមួយល្បឿនរស់ទូក(ធៀបនឹងទឹក) ដើម្បីទទួលបានល្បឿនទូកធៀបនឹងច្រាំងទន្លេ។ ដោយបាច់ពន្លឺដាលបានចម្ងាយ $l_2$ រយៈពេលដែលត្រូវការដើម្បីចេញពី $M_S$ ទៅ $M_2$ គឺ $t=l_2/(c+v)$ ។ ដើម្បីត្រឡប់មកពី $M_2$ ទៅ $M_S$ វិញ។ ពន្លឺត្រូវដាលប្រឆាំងនឹងខ្យល់អាកាស(ដូចដំណើររបស់ទូកបញ្ច្រាសចរន្តទឹក) ដូច្នេះល្បឿនធៀបរបស់វាគឺ $c-v$ ។ រយៈពេលដែលត្រូវការក្នុងដំនើរត្រឡប់គឺ $l_2/(c-v)$។ រយៈពេលសរុបសម្រាប់បាច់ពន្លឺទី២ ដាលពី $M_S$ ទៅ $M_2$ និងត្រឡប់មកដល់ $M_S$ វិញគឺ។

$$t_2=\frac{l_2}{c+v}+\frac{l_2}{c-v}=\frac{2l_2}{c(1-v^2/c^2)}$$

ឥឡូវពិនិត្យបាច់ពន្លឺទី១ ដែលសដាលកាត់ទទឹងខ្យល់អាកាស។ ដូចគ្នានឹងទូកក្នុងរូប១.៨ ខ។ ទូកចេញពីកំពង់ A ទៅកំពង់ B ដោយកាត់ទទឹងចរន្តទឹក។ បើវាទៅមុខដោយកាត់ទទឹងផ្ទាស់តែម្តង ចរន្តទឹកនឹងនាំទូកចុះតាមបណ្តោយទឹក។ ដើម្បីទៅដល់ B ទូកត្រូវតែតម្រង់ក្បាលយ៉ាងណាឱ្យបង្កើតបានមុំមួយជាមួយនឹងលំហូរទឹក។ តម្លៃជាក់លាក់នៃមុំអាស្រ័យនឹងទំហំរបស់ $c$ និង $v$ ។ រូប១.៨គ បង្ហាញពីការគណនាវ៉ិចទ័រល្បឿន $v'$ របស់ទូកធៀបនឹងផែនដីពេលវាឆ្លងកាត់ទទឹងទន្លេ។ ដោយ $c,v$ និង $v'$ បង្កើតបានជាត្រីកោណកែង គេបានល្បឿន $v'=\sqrt{c^2-v^2}$ ។ ពេលត្រឡប់មកវិញទូកមានល្បឿនដូចពេលទៅ។ បើគេអនុវត្តគោលការណ៍នេះជាមួយជាមួយបាច់ពន្លឺទី១ ក្នុងរូប ១.៨ ក គេរំពឹងទុកថាបាច់ពន្លឺដាលដោយល្បឿន $\sqrt{c^2-v^2}$ ក្នុងដំណើរពី $M_S$ ទៅ $M_1$ និងត្រឡប់មកវិញ។ ចម្ងាយសរុបគឺ $2l_1$ ដូច្នេះរយៈពេលត្រូវការសម្រាប់បាច់ពន្លឺក្នុងចម្ងាយសរុបគឺ $2l_1/\sqrt{c^2-v^2}$ ឬ

$$t_1 = \frac{2l_1}{c\sqrt{1 - v^2/c^2}}$$

បើ $l_1 = l_2 = l$ នោះបាច់ពន្លឺ ២ នឹងយឺតជាងបាច់ពន្លឺ ១ ដោយចំនួន

$$\Delta t = t_2 - t_1 = \frac{2l}{c}\left(\frac{1}{1 - v^2/c^2} - \frac{1}{\sqrt{1 - v^2/c^2}}\right)$$

ដោយ $v/c \ll 1$ គេអាចប្រើការបង្រីកពហុធា(binomial expansion)

$$(1 - x)^n \approx 1 - nx \text{ (ចំពោះ } x \ll 1\text{ )}$$

ក្នុងករណីនេះ $x = v^2/c^2$ គេបាន

$$\frac{1}{1 - v^2/c^2} \approx 1 + \frac{v^2}{c^2} \quad \text{និង} \quad \frac{1}{\sqrt{1 - v^2/c^2}} \approx 1 + \frac{1}{2}\frac{v^2}{c^2}$$

គេបាន

$$\Delta t = t_2 - t_1 \approx \frac{lv^2}{c^3} \qquad (១.៨)$$

ផលសងរយៈពេលរវាងខណៈពីរដែលបាច់ពន្លឺចាំងផ្លាត ដាលមកដល់តេលេទស្សន៍ (telescope) បណ្តាលឱ្យមានផលសងផាសរវាងបាច់ពន្លឺទាំងពីរ ហើយក៏បង្កើតបានអាំងទែផេរ៉ង់ពេលពួកវាជួបគ្នាត្រង់ទីតាំងនៃតេលេទស្សន៍។ បម្រែបម្រួលនៃអាំងទែផេរ៉ង់នឹងត្រូវបានឃើញពេលដែលឧបករណ៍ interferometer (រូប១.៨ ក) ត្រូវបានបង្វិលឱ្យបានមុំ 90° ក្នុងប្លង់ដេក ដូច្នេះបាច់ពន្លឺទាំងពីរផ្លាស់ប្តូរមុខងារ។ លទ្ធផលនៃការបង្វិលនេះធ្វើឱ្យផលសងរយៈពេលក្នុងសមីការ ១.៨ កើនទ្វេរដង។ ដូចនេះផលសងដំណើរដែលត្រូវនឹងផលសងរយៈពេលក្នុងករណីនេះគឺ

$$\Delta d = c(2\Delta t) = \frac{2lv^2}{c^2}$$

ដោយសារតែបម្រែបម្រួលក្នុងប្រវែងគន្លងនៃជំហានរលកមួយត្រូវនឹងបម្រែបម្រួលនៃប្រង់មួយ ហើយបម្រែបម្រួលប្រង់នេះគឺស្មើនឹង ផលសងដំណើរខាងលើចែកឱ្យជំហានរលករបស់ពន្លឺ

$$\text{បម្រែបម្រួលប្រង់} = \frac{2lv^2}{\lambda c^2} \qquad (១.៩)$$

ក្នុងពិសោធន៍ដែលធ្វើដោយ Michelson និង Morley រាល់បាច់ពន្លឺត្រូវបានបំផ្លាតដោយកញ្ចក់ជាច្រើនដងដើម្បីផ្តល់នូវប្រវែងគន្លងច្បាស់លាស់ស្មើនឹង $11\ \mathrm{m}$ ។ ប្រើតម្លៃនេះ ហើយល្បឿន $v = 3.0 \times 10^4\ \mathrm{m/s}$ (ល្បឿនរបស់ផែនដីវិលជុំវិញព្រះអាទិត្យ) និងប្រើពន្លឺមានជំហានរលក $500\ \mathrm{nm}$ គេទទួលបានបម្រែបម្រួលប្រង់គឺ

$$\text{បម្រែបម្រួលប្រង់} = \frac{2(11\,m)(3.0 \times 10^4\,m/s)^2}{(5.0 \times 10^{-7}\,m)(3.0 \times 10^8\,m/s)^2} = 0.44$$

ឧបករណ៍នេះបានប្រើដោយ Michelson និង Morley អាចចាប់បាននូវបម្រែបម្រួល 0.01 ប៉ុន្តែវាបានរកឃើញនូវភាពមិនប្រែប្រួលអ្វីទាំងអស់ក្នុងគំរូប្រង់!(This instrument used by Michelson and Morley could detect shift as small as 0.01 fringe, but it detected no shift whatsoever in fringe pattern!)។ ពិសោធន៍ត្រូវបានធ្វើឡើងវិញជាច្រើនដង ដោយអ្នកវិទ្យាសាស្ត្រជាច្រើនអ្នក ក្រោមលក្ខខណ្ឌផ្សេងៗ ហើយនៅតែគ្មានបម្រែបម្រួលប្រង់ត្រូវបានរកឃើញ។ ដូច្នេះវាត្រូវបានគេសន្និដ្ឋានថាចលនារបស់ផែនដីធៀបនឹងអាកាស(ether) មិនអាចរកឃើញទេ។

ការខំព្រឹងជាច្រើនត្រូវបានធ្វើឡើងដើម្បីពន្យល់លើលទ្ធផលសូន្យនៃពិសោធន៍របស់ Michelson, Morley និងដើម្បីរក្សាគំនិតប្រព័ន្ធយោងអាកាស ព្រមទាំងសមីការបំលែងល្បឿនរបស់ហ្គាលីលេចំពោះពន្លឺ។ លទ្ធផលដែលចេញពីការខំប្រឹងប្រែងទាំងអស់នេះបានបង្ហាញថាខុស។ ក្នុងប្រវត្តិសាស្ត្ររូបវិទ្យា គ្មានពិសោធន៍ណាបានទទួលនូវការខំប្រឹងពន្យល់ពីលទ្ធផលរំពឹងទុកដែលមិនមាន ដូចធ្វើពិសោធន៍របស់ Michelson, Morley ។ សកម្មភាពបន្ទាប់គឺរៀបចំសម្រាប់អាញស្តាញ (Einstein) អ្នកដោះស្រាយបញ្ហាក្នុងឆ្នាំ ១៩០៥ ជាមួយទ្រឹស្តីធៀបពិសេសរបស់គាត់(special theory of relativity)។

## 1.3 គោលការណ៍ធៀបរបស់អាញស្តាញ(Einstein’s Principle of Relativity)

បញ្ហាទាំងឡាយដែលមាននៅដើមសតវត្សទី២០ជាមួយនឹងទ្រឹស្តីអេឡិចត្រូម៉ាញេទិច និងមេកានិចរបស់ញូតុន ត្រូវបានដោះស្រាយដោយទ្រឹស្តីធៀបរបស់អាញស្តាញ(Einstein)ក្នុងឆ្នាំ១៩០៥។ ក្នុងអត្ថបទដ៏ល្បីរបស់គាត់ឆ្នាំ១៩០៥ អាញស្តាញបានស្នើនូវឧបធាពីរ។ ទីមួយគឺពង្រីកនូវគោលការណ៍ធៀបរបស់ហ្គាលីលេដោយរួមបញ្ចូល មិនត្រឹមតែច្បាប់មេកានិចប៉ុណ្ណោះទេ ប៉ុន្តែបានថែមនូវច្បាប់រូបវិទ្យាទាំងឡាយរួមមាន អគ្គិសនី និងម៉ាញេទិច៖

ឧបធាទី១(គោលការណ៍ធៀប)៖ ច្បាប់រូបវិទ្យាទាំងឡាយមានទម្រង់ដូចគ្នាក្នុងប្រព័ន្ធយោងនិចលទាំងអស់។

ឧបធាទីមួយអាចពោលបានម្យ៉ាងទៀតថា៖ គ្មានពិសោធន៍ណាដែលអ្នកអាចធ្វើក្នុងប្រពន្ធ័យោងនិចល មួយដែលប្រាប់អ្នកថាតើអ្នកនៅស្ងៀម ឬកំពុងមានចលនាឯកសណ្ឋានដោយវ៉ិចទ័រល្បឿនថេរទេ។

ពិនិត្យមើលឧទាហរណ៍មួយស្តីអំពីកំលាំងអគ្គិសនីចលករកើតឡើងនៅក្នុងបូប៊ីនមួយនៅជិត មេដែកអចិន្ត្រៃផ្លាស់ទីមួយ។ ក្នុងប្រពន្ធ័យោងជាបូប៊ីនដែលនៅនឹងរូប១.៩ក បំលាស់ទីរបស់មេដែកបណ្តា លឱ្យមានបម្រែបម្រួលភ្លុចឆ្លងកាត់បូប៊ីន ហើយបានបង្កើតនូវកំលាំងអគ្គិសនីចលនា។ ក្នុងប្រពន្ធ័យោង មួយផ្សេងទៀតដែលជាមេដែកនៅនឹង រូប១.៩ខ ចលនារបស់បូប៊ីនឆ្លងកាត់ដែនម៉ាញេទិចបង្កើតបាននូវកំ លាំងអគ្គិសនីចលករ។ ដូចនេះកំលាំងអគ្គិសនីចលករដូចគ្នាត្រូវតែបានបង្កើតឡើងក្នុងករណីទាំងពីរដូច បង្ហាញក្នុងរូប ១.៩ ដែលត្រូវនឹងគោលការណ៍ធៀបក្នុងឧបធាទី១របស់អាញស្តាញ។ ដូច្នេះច្បាប់ផារ៉ាដេគឺ ត្រូវនឹងគោលការណ៍ធៀបរបស់អាញស្តាញ។ តាមពិត គ្រប់ច្បាប់ទាំងអស់នៃអេឡិចត្រូម៉ាញេទិចគឺដូចគ្នា នៅក្នុងរាល់ប្រពន្ធ័យោងនិចលទាំងអស់។




រូបទី១.៩៖ កំលាំងអគ្គិសនីចលករដូចគ្នាត្រូវបានបង្កើតឡើងមិនថា
(ក) មេដែកផ្លាស់ទីធៀបនឹងបូប៊ីន ឬ (ខ) បូប៊ីនផ្លាស់ទីធៀបនឹងមេដែក។

ឧបធាទី២(ភាពថេរនៃល្បឿនពន្លឺ)៖ ពន្លឺដាលឆ្លងកាត់លំហទទេ(សុញ្ញកាស) ដោយល្បឿន កំណត់មួយ $c$ មិនអាស្រ័យនឹងល្បឿនរបស់ប្រភពពន្លឺ ឬអ្នកសង្កេតឡើយ។

ឧបធាទាំងពីរនេះបង្កើតនូវគ្រឹះយ៉ាងរឹងមាំនៃទ្រឹស្តីធៀបពិសេសរបស់អាញស្តាញ។ វាប្រើពាក្យ "ពិសេស" ដើម្បីញែកកុំឱ្យច្រឡំជាមួយទ្រឹស្តីធៀបទូទៅ។

ឧបធាទី២ហាក់ដូចជាពិបាកក្នុងការទទួលយក ព្រោះវាហាក់ដូចជាប្រឆាំងទៅនឹងអ្វីដែលជួប ប្រទះក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្ស។ ល្បឿនពន្លឺដាលក្នុងសុញ្ញកាសគឺដូចគ្នា $3.00 \times 10^8\ m/s$ មិនថា ប្រភពពន្លឺ ឬអ្នកសង្កេតមានល្បឿនក៏ដោយ។ ដូច្នេះ ចំពោះដំណើររបស់មនុស្សម្នាក់ឆ្ពោះទៅ ឬចេញពី

ប្រភពពន្លឺ នឹងវាស់បានល្បឿនពន្លឺដូចគ្នា ហើយក៏ដូចនឹងការវាស់របស់អ្នកនៅនឹងដែលធៀបនឹងប្រភពពន្លឺដែរ។ ទាំងនេះគឺមិនស្របនឹងបទពិសោធន៍ដែលជួបក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្ស ដែលបានរំពឹងទុកថាគួរតែបូកបន្ថែមវ៉ិចទ័រល្បឿនរបស់អ្នកសង្កេត ឬរបស់ប្រភពពន្លឺទៀត។

សន្មតថាអ្នកសង្កេតពីរនាក់វាស់ល្បឿនរបស់ពន្លឺក្នុងសុញ្ញាកាស។ ម្នាក់គឺនៅនឹងធៀបនឹងប្រភពពន្លឺ ហើយម្នាក់ទៀតកំពុងផ្លាស់ទីចេញពីប្រភពពន្លឺ។ ទាំងពីនាក់គឺស្ថិតក្នុងប្រពន្ធ័យោងនិចល។ បើតាមគោលការណ៍ធៀប អ្នកសង្កេតទាំងពីរត្រូវតែទទួលបានលទ្ធផលដូចគ្នា ទោះបីម្នាក់កំពុងផ្លាស់ទីធៀបនឹងម្នាក់ទៀតក៏ដោយ។




រូបទី១.១០៖ (a) មេកានិចរបស់ញូតុន ធ្វើការទស្សទាយបានត្រឹមត្រូវចំពោះចលនាធៀបរបស់វត្ថុមានល្បឿនយឺត។ (b) វាធ្វើការទស្សទាយខុសអំពីការប្រព្រឹត្តនៃពន្លឺ។

ដំណើររបស់យានអវកាសមួយឆ្លងកាត់ផែនដីដោយល្បឿន 1000 m/s បាញ់គ្រាប់មីស៊ីលមួយផ្ដោះទៅមុខត្រង់ដោយល្បឿន 2000 m/s (ធៀបនឹងយានអវកាស) (រូបទី១.១០)។ តើល្បឿនរបស់គ្រប់មីស៊ីលស្មើប៉ុន្មានធៀបនឹងផែនដី? ចម្លើយដែលត្រឹមត្រូវគឺយោងទៅតាមគោលការណ៍ធៀបរបស់ហ្គាលីលេគឺ 3000 m/s ។

ប៉ុន្តែឥឡូវសន្មតថាយានអវកាសបើកភ្លើង ពន្លឺដាលក្នុងទិសដៅដូចទិសដៅរបស់គ្រាប់មីស៊ីលដែលបានបាញ់។ អ្នកសង្កេតនៅលើយានវាស់ល្បឿនរបស់ពន្លឺដែលបានបន្សាយនោះគឺ $c$ ។ តាមឧបធាទី២របស់អាញស្តាញ ចលនារបស់ពន្លឺបន្ទាប់ពីចាកចេញពីប្រភពពន្លឺ មិនអាចអាស្រ័យនឹងចលនារបស់ប្រភពពន្លឺទេ។ ដូច្នេះអ្នកសង្កេតនៅលើផែនដីវាស់ល្បឿនរបស់ពន្លឺនេះទទួលបានតម្លៃដូចគ្នាគឺ $c$ មិនមែន $c +$ 1000 m/s ទេ។

## 1.4 វិបាកនៃទ្រឹស្តីធៀប

### 1.4.1 ភាពដំណាលគ្នា និងធៀបភាពនៃរយៈពេល

វិបាកសំខាន់មួយនៃទ្រឹស្តីធៀបគឺ គេមិនអាចចាត់ទុកពេលវេលាជាទំហំដាច់ខាតទេ។ គ្មានអ្នកម្នាក់សង្ស័យថាពេលវេលាទៅមុខរហូតហើយមិនដែលត្រឡប់ក្រោយ។ ប៉ុន្តែរយៈពេលចន្លោះរវាងព្រឹត្តិការណ៍ពីរ មិនថាព្រឹត្តិការណ៍ទាំងពីរនោះកើតឡើងដំណាលគ្នាឬអត់ គឺអាស្រ័យនឹងប្រព័ន្ធយោងនៃអ្នកសង្កេត។

ព្រឹត្តិការណ៍ពីរកើតឡើងដំណាលគ្នា បើពួកវាកើតឡើងក្នុងពេលជាមួយគ្នាយ៉ាងជាក់លាក់។ ប៉ុន្តែគេអាចដឹងបានយ៉ាងដូចម្តេចថាតើ ព្រឹត្តិការណ៍ពីរកើតឡើងនៅពេលជាមួយគ្នាយ៉ាងត្រឹមត្រូវ? ប្រសិនបើពួកវាកើតឡើងនៅទីតាំងដូចគ្នាក្នុងលំហ ដូចជាផ្លែប៉ោមពីរធ្លាក់ត្រូវក្បាលអ្នកក្នុងពេលតែមួយជាដើម បែបនេះគឺវាងាយស្រួលកំណត់ថាកើតឡើងដំណាលគ្នា។ ប៉ុន្តែបើព្រឹត្តិការណ៍ទាំងពីរស្ថិតនៅយ៉ាងឆ្ងាយពីគ្នាវិញ វាមានភាពលំបាកក្នុងការដឹងថាតើ ពួកវាកើតដំណាលគ្នាឬអត់ ព្រោះគេត្រូវគិតពីរយៈពេលដែលពន្លឺដាលពីកន្លែងដែលព្រឹត្តិការណ៍បានកើតឆ្ពោះមកអ្នក។ ឧទាហរណ៍ ព្រឹត្តិការណ៍ពីរត្រូវបានសង្កេតឃើញថាកើតឡើងក្នុងពេលដូចគ្នា ប៉ុន្តែបើព្រឹត្តិការណ៍មួយពិតជាបានកើតឡើងនៅឆ្ងាយពីអ្នកសង្កេតជាងមួយទៀត នោះព្រឹត្តិការណ៍ដែលមានចម្ងាយឆ្ងាយជាងត្រូវតែបានកើតមុន ហើយព្រឹត្តិការណ៍ទាំងពីរគឺមិនកើតដំណាលគ្នាទេ។

ពិនិត្យពិសោធន៍ងាយមួយ។ ដោយសន្មតយកអ្នកសង្កេតម្នាក់ O ស្ថិតនៅចំកណ្តាលរវាងចំនុច A និង B ជាកន្លែងដែលព្រឹត្តិការណ៍បានកើតឡើង រូប ១.១១ ។ សន្មតថាព្រឹត្តិការណ៍ទាំងពីរជាផ្លេកបន្ទោដែលបាញ់នៅត្រង់ចំនុច A និង B ដូចរូប។ ដោយកំណត់ផ្លេកបន្ទោជារលកនៃពន្លឺ នឹងដាលចេញពី A និង B ឆ្ពោះទៅដល់ O ។ អ្នកសង្កេត O ឃើញព្រឹត្តិការណ៍ទាំងពីរពេលរលកនៃពន្លឺដាលមកដល់ចំនុច O ។ បើរលកនៃពន្លឺទាំងពីរមកដល់ O ក្នុងពេលដូចគ្នា នោះព្រឹត្តិការណ៍ទាំងពីរកើតដំណាលគ្នា។ នេះដោយសាររលកពន្លឺទាំងពីរដាលដោយល្បឿនដូចគ្នា(ឧបធាទី២) និងដោយសារចម្ងាយ OA ស្មើនឹង OB នោះរយៈពេលសម្រាប់ពន្លឺដាលពី A ទៅ O និងពី B ទៅ O ត្រូវតែស្មើគ្នា។ អ្នកសង្កេត O អាចថ្លែងយ៉ាងច្បាស់ថា ព្រឹត្តិការណ៍ទាំងពីរបានកើតឡើងដំណាលគ្នា។ ផ្ទុយទៅវិញ បើអ្នកសង្កេត O ឃើញពន្លឺចេញពីព្រឹត្តិការណ៍ណាមួយមុនព្រឹត្តិការណ៍ផ្សេងទៀត មានន័យថាព្រឹត្តិការណ៍នោះបានកើតមុន។




រូបទី១.១១៖ ខណៈមួយបន្ទាប់ពីផ្លេកបន្ទោបានបាញ់នៅចំនុច A និង B ហើយពន្លឺកំពុងដាល ឆ្ពោះទៅអ្នកសង្កេត O ប៉ុន្តែអ្នកសង្កេត O ឃើញផ្លេកបន្ទោតែពេលណាពន្លឺមកដល់ O ។

បញ្ហាដែលគេពិតជាចង់ពិនិត្យនោះគឺ បើសិនជាព្រឹត្តិការណ៍ទាំងពីរកើតដំណាលគ្នាចំពោះអ្នកសង្កេតក្នុងប្រពន្ធ័យោងមួយ តើពួកវាកើតដំណាលគ្នាចំពោះអ្នកសង្កេតក្នុងប្រព័ន្ធយោងមួយផ្សេងទៀតដែលផ្លាស់ទីធៀបនឹងប្រព័ន្ធយោងមុន? ឧបមាថាអ្នកសង្កេត $O_1$ និង $O_2$ ស្ថិតនៅនឹងក្នុងប្រពន្ធ័យោង ១ និង ២ ដែលផ្លាស់ទីដោយល្បឿន $v$ ធៀបនឹងគ្នា។ សន្មតថាប្រពន្ធ័យោងទាំងពីរជាទូរថភ្លើង (រូប១.១២) ។ $O_2$ ថា $O_1$ កំពុងផ្លាស់ទីទៅស្តាំដោយល្បឿន $v$ រូប១.១២ក ហើយ $O_1$ ថា $O_2$ កំពុងផ្លាស់ទីទៅឆ្វេងដោយល្បឿន $v$ រូប១.១២ខ ។

ឥឡូវសន្មតថា អ្នកសង្កេត $O_1$ និង $O_2$ សង្កេត និងវាស់ផ្លេកបន្ទោទាំងពីរ។ ផ្លេកបន្ទោបានបាញ់ ហើយធ្វើឱ្យមានស្នាមនៅលើទូរថភ្លើងត្រង់ $A_1$ និង $B_1$ លើរថភ្លើង $O_1$ និងនៅត្រង់ $A_2$ និង $B_2$ លើរថភ្លើង $O_2$ រូប១.១៣ក។




រូបទី ១.១២៖ អ្នកសង្កេត $O_1$ និង $O_2$ នៅលើរថភ្លើងពីរផ្សេងគ្នា(ប្រព័ន្ធយោងផ្សេងគ្នា) កំពុងផ្លាស់ទីដោយល្បឿន $v$ ធៀបនឹងគ្នា។ (ក) $O_2$ ថា $O_1$ កំពុងផ្លាស់ទីទៅស្តាំ (ខ) $O_1$ ថា $O_2$ កំពុងផ្លាស់ទីទៅឆ្វេង។ ទស្សនទាំងពីរគឺសុទ្ធតែត្រឹមត្រូវ វាអាស្រ័យនឹងប្រពន្ធ័យោងដែកអ្នកតាំងនៅ។

ដើម្បីងាយស្រួលគេសន្មតថា $O_1$ ស្ថិតនៅចំកណ្តាលរវាង $A_1$ និង $B_1$ និង $O_2$ ស្ថិតនៅចំកណ្តាលរវាង $A_2$ និង $B_2$ ។




រូបទី ១.១៣៖ ពិសោធន៍លើភាពដំណាលគ្នា។ ចំពោះអ្នកសង្កេត $O_2$ ប្រពន្ធ័យោងនៃ $O_1$ កំពុងផ្លាស់ទីទៅស្តាំ។ ក្នុង (ក) ផ្លេកបន្ទោរមួយបានបាញ់ទៅលើប្រព័ន្ធយោងពីរត្រង់ $A_1$ និង $A_2$ ។ ហើយផ្លេកបន្ទោរទីពីរបានបាញ់ត្រង់ $B_1$ និង $B_2$ ។ (ខ) ខណៈក្រោយមក ពន្លឺចេញពីព្រឹត្តិការណ៍ទាំងពីរមកដល់ $O_2$ នៅខណៈពេលដូចគ្នា ដូច្នេះយោងតាមអ្នកសង្កេត $O_2$ ផ្លេកបន្ទោរទាំងពីរកើតដំណាលគ្នា។ ប៉ុន្តែក្នុងប្រព័ន្ធយោង $O_1$ ដោយហេតុថា ពន្លឺពី $A_1$ មិនទាន់បានមកដល់ $O_1$ ។ ដូច្នេះក្នុងប្រព័ន្ធយោង $O_1$ ព្រឹត្តិការណ៍ត្រង់ $B_1$ ត្រូវតែមានមុនព្រឹត្តិការណ៍ត្រង់ $A_1$ ។ ភាពដំណាលគ្នានៃរយៈពេលគឺមិនដាច់ខាតទេ។

ដំបូងសន្មតថាយើងស្ថិតនៅក្នុងប្រពន្ធ័យោង $O_2$ ដូច្នេះយោងសង្កេតឃើញ $O_1$ ផ្លាស់ទីទៅស្តាំដោយល្បឿន $v$ ។ សន្មតផងដែរថាព្រឹត្តិការណ៍ទាំងពីរកើតឡើងដំណាលគ្នាក្នុងប្រព័ន្ធយោង $O_2$ ហើយចំខណៈពេលដែល $O_1$ និង $O_2$ ចាប់ផ្តើមផ្ទុយគ្នា(រូប ១.១៣ក)។ នៅខណៈពេលយ៉ាងខ្លីក្រោយមក(រូប ១.១៣ខ) ពន្លឺពី $A_2$ និង $B_2$ មកដល់ $O_2$ ក្នុងពេលដូចគ្នា។ ព្រោះ $O_2$ ដឹងថាចំងាយរវាង $O_2A_2$ និង $O_2B_2$ គឺស្មើគ្នា ដូច្នេះព្រឹត្តិការណ៍ទាំងពីរកើតដំណាលគ្នាក្នុងប្រព័ន្ធយោង $O_2$ ។

ប៉ុន្តែតើអ្នកសង្កេត $O_1$ វាស់ និងសង្កេតឃើញដូចម្តេច? ពីប្រពន្ធ័យោង $O_2$ យើងអាចទាយនូវអ្វីដែល $O_1$ នឹងសង្កេតឃើញ។ យើងឃើញថា $O_1$ ផ្លាស់ទីទៅស្តាំក្នុងកំឡុងពេលដែលពន្លឺដាលទៅ $O_1$ ពី $A_1$ និង $B_1$ ។ ដូចបង្ហាញក្នុងរូប ១.១៣ខ ពីប្រពន្ធ័យោង $O_2$ យើងអាចឃើញថាពន្លឺពី $B_1$ បានឆ្លងកាត់ $O_1$ រួចទៅហើយ ចំណែកពន្លឺពី $A_1$ មិនទាន់មកដល់ $O_1$ នៅឡើយ។ ដូចនេះ $O_1$ សង្កេតឃើញពន្លឺមកពី $B_1$ មុនពេលសង្កេតឃើញពន្លឺមកពី $A_1$ ។ តាមពិសោធន៍នេះដោយឱ្យ (១) ពន្លឺនោះដាលដោយល្បឿនដូចគ្នា $c$ ក្នុងទិសដៅណាមួយ និងក្នុងប្រព័ន្ធយោងណាមួយ (២) ចម្ងាយ $O_1A_1$ ស្មើ $O_1B_1$ បន្ទាប់មកអ្នកសង្កេត $O_1$ គ្រាន់តែអាចសន្និដ្ឋានបានថា ព្រឹត្តិការណ៍នៅត្រង់ $B_1$ កើតមុនព្រឹត្តិការណ៍ត្រង់ $A_1$ ។ ព្រឹត្តិការណ៍ទាំងពីរគឺមិនដំណាលគ្នាទេចំពោះ $O_1$ ទោះជាពួកវាកើតដំណាលគ្នាសម្រាប់ $O_2$ ក៏ដោយ។

ដូចនេះយើងរកឃើញថាព្រឹត្តិការណ៍ពីរដែលកើតនៅទីតាំងខុសគ្នា ហើយមានភាពដំណាលគ្នាចំពោះអ្នកសង្កេតម្នាក់ គឺពិតជាមិនមានភាពដំណាលគ្នាចំពោះអ្នកសង្កេតទីពីរដែលផ្លាស់ទីធៀបនឹងទីមួយ។

អាចមានសំណួរសួរថា៖ "តើអ្នកសង្កេតមួយណាត្រឹមត្រូវ $O_1$ ឬ $O_2$ ?" ចម្លើយ យោងទៅតាមធៀបភាព គឺថាពួកគេទាំងពីរសុទ្ធតែត្រូវ។ មិនមានប្រពន្ធ័យោងល្អឥតខ្ចោះណាដែលយើងអាចជ្រើសរើសយកមកកំណត់ថាអ្នកសង្កេតមួយណាត្រូវទេ។ ប្រព័ន្ធយោងទាំងពីរគឺល្អដូចគ្នា។ យើងគ្រាន់តែអាចសន្និដ្ឋានថា ភាពដំណាលគ្នាគឺមិនមែនជាគោលការណ៍ដាច់ខាតទេ ប៉ុន្តែគឺធៀបភាព។

### 1.4.2 ការរីកនៃពេល៖

ដើម្បីបង្ហាញឱ្យកាន់តែច្បាស់ថា អ្នកសង្កេតក្នុងប្រពន្ធ័យោងនិចលខុសគ្នាអាចវាស់រយៈពេលរវាងព្រឹត្តិការណ៍ពីខុសគ្នាដែរ ពិនិត្យការផ្លាស់ទីរបស់យានជំនិះមួយទៅស្តាំដោយល្បឿន $v$ ដូចបង្ហាញក្នុងរូប ១.១៤ក ។ កញ្ចក់ប្លង់មួយបានបិទភ្ជាប់នឹងពិដាន(ដំបូល)របស់យានជំនិះនោះ ហើយអ្នកសង្កេត O′ នៅនឹងក្នុងប្រពន្ធ័យោងជាប់នឹងយានជំនិះកាន់ពិល(ប្រភពពន្លឺ)មួយនៅចម្ងាយ $d$ ខាងក្រោមកញ្ចក់។ នៅខណៈយ៉ាងខ្លី ពិលបានបន្សាយនូវកំពូលរលកមួយរបស់ពន្លឺឆ្ពោះទៅកញ្ចក់ប្លង់(ព្រឹត្តិការណ៍១) ហើយខណៈពេលក្រោយមកបន្ទាប់ពីផ្លាតពីកញ្ចក់ កំពូលរលកនៃពន្លឺនោះបានត្រឡប់មកដល់ពិលវិញ (ព្រឹត្តិការណ៍២) ។ អ្នកសង្កេត O′ កាន់នាឡិកាមួយ ហើយប្រើវាសម្រាប់វាស់ចន្លោះពេល $\Delta t_p$ រវាងព្រឹត្តិការណ៍ទាំងពីរ។ ($p$ តាងឱ្យ proper=ពិត) ។ គេចាត់ទុកកំពូលរលកនៃពន្លឺជាចំនុចរូបធាតុមានល្បឿនថេរ។ ព្រោះកំពូលរលកនៃពន្លឺមានល្បឿន $c$ ។ រយៈពេលដែលត្រូវការសម្រាប់កំពូលរលកនៃពន្លឺដាលពី O′ ទៅកញ្ចក់ និងត្រឡប់មកវិញគឺ

$$\Delta t_p = \frac{\text{ចម្ងាយចរ}}{\text{ល្បឿន}} = \frac{2d}{c} \qquad (១.១០)$$




រូបទី១.១៤៖ (ក) កញ្ចក់ប្លង់ត្រូវបានភ្ជាប់ទៅនឹងដំបូលយានជំនិះ ហើយរលកពន្លឺបានបញ្ជូនចេញពីអ្នកសង្កេត O′ ដែលនៅសៀមលើយាន។ (ខ) ធៀបនឹងអ្នកសង្កេតដែលឈរសៀម O ក្រៅយាន កញ្ចក់ និង O′ ផ្លាស់ទីដោយល្បឿន $v$ ។ (គ) ត្រីកោណកែងសម្រាប់គណនាទំនាក់ទំនង $\Delta t$ និង $\Delta t_p$ ។

តាមអ្នកសង្កេត O កញ្ចក់ និងប្រភពពន្លឺ(ពិល)កំពុងផ្លាស់ទីទៅស្តាំដោយល្បឿន $v$ ។ ជាលទ្ធផលគាត់សង្កេតឃើញថា នៅរយៈពេលយ៉ាងខ្លីដែលពន្លឺដាលពីប្រភពទៅប៉ះនឹងកញ្ចក់ កញ្ចក់បានផ្លាស់ទីទៅស្តាំបានចម្ងាយ $v\Delta t/2$ ។ ដែល $\Delta t$ ជារយៈពេលដែលពន្លឺត្រូវការដើម្បីដាលពី O′ ទៅកញ្ចក់ និងត្រឡប់មក O′ វិញ វាស់ដោយ O ។ អ្នកសង្កេត O សន្និដ្ឋានថា ដោយសារចលនានៃយាន បើពន្លឺទៅប៉ះកញ្ចក់ វាត្រូវតែចេញពីប្រភពពន្លឺទៅដោយបង្កើតបានមុំមួយជាមួយនឹងទិសឈរ។ ប្រៀបធៀបរូប១.១៤ក និង១.១៤ខ យើងឃើញថាពន្លឺត្រូវដាលកក្នុងផ្នែក(ខ)ឆ្ងាយជាងក្នុងផ្នែក(ក) ។

យោងតាមឧបធាទី២នៃទ្រឹស្តីធៀប អ្នកសង្កេតទាំងអស់ត្រូវតែវាស់បានល្បឿនរបស់ពន្លឺគឺ $c$ ។ ដោយពន្លឺដាលឆ្ងាយជាងយោងតាមអ្នកសង្កេត O រយៈពេល $\Delta t$ វាស់ដោយ O គឺវែងជាងរយៈពេល $\Delta t_p$ វាស់ដោយ O′ ។ ដើម្បីទទួលបានទំនាក់ទំនងរវាងរយៈពេលទាំងពីរនេះ គេត្រូវប្រើត្រីកោណកែងដូចបង្ហាញក្នុងរូប ១.១៤គ។ តាមទ្រឹស្តីពីតាគ័រ

$$\left(\frac{c\Delta t}{2}\right)^2 = \left(\frac{v\Delta t}{2}\right)^2 + d^2$$

នាំឱ្យ

$$\Delta t = \frac{2d}{\sqrt{c^2 - v^2}} = \frac{2d}{c\sqrt{1 - \frac{v^2}{c^2}}} \qquad (១.១១)$$

ដោយ $\Delta t_p = 2d/c$ គេអាចសរសេរ

$$\Delta t = \frac{\Delta t_p}{\sqrt{1 - \frac{v^2}{c^2}}} = \gamma \Delta t_p \qquad (១.១២)$$

ដែល

$$\gamma = \frac{1}{\sqrt{1 - \frac{v^2}{c^2}}} \qquad (១.១៣)$$

ព្រោះ $\gamma$ តែងតែធំជាងមួយ នោះសមីការ ១.១៣ បង្ហាញថា រយៈពេល $\Delta t$ វាស់ដោយអ្នកសង្កេតផ្លាស់ទីធៀបនឹងនាឡិកាមួយ គឺយូជាងរយៈពេល $\Delta t_p$ វាស់ដោយអ្នកសង្កេតនៅស្ងៀមធៀបនឹងនាឡិកា។ ឥទ្ធិពលនេះហៅថា ការរីកនៃពេល។ (នាឡិកាដែលកំពុងផ្លាស់ទីដើរយឺតជាងនាឡិកាដែលគេដាក់នៅនឹងដោយកត្តា $\gamma$ )។

ឧទាហរណ៍៖ ខួបរបស់ប៉ោលទោលមួយត្រូវបានវាស់ក្នុងប្រព័ន្ធយោងនៃប៉ោលទោលគឺ 3.00 s ។ តើខួបរបស់ប៉ោលទោលនេះវាស់ដោយអ្នកសង្កេតកំពុងផ្លាស់ទីដោយល្បឿន $0.960\,c$ ធៀបនឹងប៉ោលទោលមានតម្លៃប៉ុន្មាន?

ដំណោះស្រាយ៖

ជំនួសពីការដែលអ្នកសង្កេតផ្លាស់ទី ដោយឱ្យប៉ោលទោលផ្លាស់ទីវិញ។ អាចនិយាយម្យ៉ាងទៀតថា ប៉ោលទោលកំពុងផ្លាស់ទីដោយល្បឿន $0.96\,c$ ឆ្លងកាត់អ្នកសង្កេតដែលនៅស្ងៀម។ ដូច្នេះប៉ោលគឺជាឧទាហរណ៍មួយរបស់នាឡិកាកំពុងផ្លាស់ទីដោយល្បឿនយ៉ាងធំធៀបនឹងអ្នកសង្កេត។

រយៈពេលពិត វាស់ក្នុងប្រព័ន្ធយោងនៅនឹងនៃប៉ោលទោលគឺ $\Delta t_p = 3.00$ s ។

ប្រើសមីការ ១.១២ ដើម្បីរកការរីកនៃរយៈពេល

$$\Delta t = \gamma \Delta t_p = \frac{1}{\sqrt{1-\frac{(0.960\,c)^2}{c^2}}}\Delta t_p = \frac{1}{\sqrt{1-0.9216}}\Delta t_p = 3.57(3.00) = 10.7\text{ s}$$

### 1.4.3 ភាពរួញនៃប្រវែង៖

ការវាស់ចំងាយរវាងចំនុចពីរក្នុងលំហក៏ផ្អែកលើប្រព័ន្ធយោងនៃអ្នកសង្កេតដែរ។ ប្រវែងពិត $L_p$ នៃវត្ថុមួយគឺជាប្រវែងវាស់ដោយអ្នកសង្កេតម្នាក់នៅនឹងធៀបនឹងវត្ថុ។ ប្រវែងរបស់វត្ថុមួយវាស់ដោយអ្នកណាម្នាក់ក្នុងប្រព័ន្ធយោងមួយដែលកំពុងផ្លាស់ទីធៀបនឹងវត្ថុ គឺតែងតែខ្លីជាងប្រវែងពិត។

ដើម្បីយល់នូវភាពរួញនៃប្រវែង សូមពិនិត្យការធ្វើដំណើររបស់យានអវកាសមួយមានល្បឿន $v$ ពីផ្កាយមួយទៅផ្កាយមួយទៀត។ អ្នកសង្កេតនៅស្ងៀមលើផែនដីវាស់ចម្ងាយរវាងផ្កាយទាំងពីរ គឺជាចម្ងាយពិត $L_p$ ។ បើតាមអ្នកសង្កេតនេះ រយៈពេលដែលត្រូវការសម្រាប់យានអវកាសដើម្បីបញ្ចប់ការធ្វើដំណើររបស់វាគឺ $\Delta t = L_p/v$ ។ ហើយរយៈពេលដែលអ្នកសង្កេតនៅក្នុងយានវាស់គឺជារយៈពេលពិត $\Delta t_p$ ។ ដោយសារមានការរីកនៃពេល រយៈពេលពិតមានទំនាក់ទំនងជាមួយនឹងរយៈពេលដែលវាស់ដោយអ្នកសង្កេតលើផែនដីតាម $\Delta t_p = \Delta t/\gamma$ ។ ព្រោះអ្នកដំណើរក្នុងយានទៅដល់ផ្កាយទីពីរក្នុងរយៈពេល $\Delta t_p$ នោះអ្នកដំណើរសន្និដ្ឋានថា ចម្ងាយរវាងផ្កាយទាំងពីរគឺ

$$L = v\Delta t_p = v\frac{\Delta t}{\gamma}$$

ដោយប្រវែងពិតគឺ $L_p = v\Delta t$ គេបាន

$$L = \frac{L_p}{\gamma} = L_p\sqrt{1-\frac{v^2}{c^2}} \qquad (១.១៤)$$

ដែល $\sqrt{1-v^2/c^2}$ គឺជាកត្តាដែលមានតម្លៃតូចជា *1* ។ វត្ថុមួយមានប្រវែងពិត $L_p$ ពេលវាត្រូវបានវាស់ដោយអ្នកសង្កេតនៅនឹងធៀបជាមួយវត្ថុនោះ ហើយប្រវែងរបស់វា $L$ ពេលវាផ្លាស់ទីដោយល្បឿន $v$ ក្នុងទិសដៅស្របនឹងប្រវែងរបស់វា ត្រូវបានវាស់ឃើញថាខ្លីជាង តាមសមីការ ១.១៤ ។

ឧទាហរណ៍៖ តើបន្ទាត់មួយដែលមានប្រវែង *1 m* ត្រូវផ្លាស់ទីដោយល្បឿនប៉ុន្មានដើម្បីឱ្យអ្នកសង្កេតមើលឃើញប្រវែងរបស់វាខ្លីជាងមុន *10% (90 cm)* ?

ដំណោះស្រាយ៖ តាមសមីការ ១.១៤

$$L = \frac{L_p}{\gamma} = L_p\sqrt{1-\frac{v^2}{c^2}}$$

$$1-\frac{v^2}{c^2} = \left(\frac{L}{L_p}\right)^2$$

$$\frac{v^2}{c^2} = 1-\left(\frac{L}{L_p}\right)^2 = 1-\left(\frac{0.9\ \mathrm{m}}{1\ \mathrm{m}}\right)^2 = 0.19$$

$$v = 0.43\ c$$

## 1.5 បំលែងរបស់ឡូរ៉ង់ ( The Lorentz Transformations )

### 1.5.1 បំលែងកូអរដោនេរបស់ឡូរ៉ង់៖

ដើម្បីបកស្រាយការបំលែងកូអរដោនេ ពិនិត្យមើលរូបទី ១.១៥។ ដំបូងសន្មតថាគល់នៃប្រព័ន្ធកូអរដោនេត្រួតស៊ីគ្នានៅខណៈដើមពេល $t = 0 = t'$ ។ នៅខណៈពេល $t \neq 0$បន្ទាប់មកចម្ងាយពី *O*ទៅ *O′* គឺ $vt$ ។ អាប់ស៊ីស $x'$ គឺជាប្រវែងពិតក្នុង *S′* ។ ដូច្នេះក្នុង *S*វាត្រូវបានបង្រួមដោយ $1/\gamma = \sqrt{1-v^2/c^2}$ ដូចក្នុងសមីការ ១.១៤ (ព្រោះ *S′* ផ្លាស់ទីធៀបនឹង *S*)។ ដូច្នេះចម្ងាយ $x$ គឺពី *O* ទៅ *P* ដូចឃើញក្នុង *S* គឺមិនងាយស្រួលដូច $x = vt + x'$ ក្នុងបំលែងកូអរដោនេរបស់ហ្គាលីលេឡើយ ប៉ុន្តែគឺ

$$x = vt + x'\sqrt{1 - \frac{v^2}{c^2}} \qquad (១.១៥)$$

ដោះស្រាយសមីការនេះគេបាន $x'$ គឺ

$$x' = \frac{x - vt}{\sqrt{1 - \frac{v^2}{c^2}}} \qquad (១.១៦)$$

សមីការ ១.១៦ គឺជាផ្នែកមួយនៃបំលែងកូអរដោនេរបស់ឡូរ៉ង់។ ផ្នែកផ្សេងទៀតគឺជាសមីការដែលឱ្យដោយរយៈពេល $t'$ ជាអនុគមន៍នៃ $x$ និង $t$ ។ ដើម្បីទទួលបានបែបនេះ គេគត់សម្គាល់

ថាគោលការណ៍ធៀបតម្រូវឱ្យទម្រង់នៃបំលែងពី S ទៅ S′ គឺដូចគ្នានឹងពី S′ ទៅ S។ ការខុសគ្នាតែមួយគត់គឺ ការផ្លាស់ប្តូរសញ្ញារបស់កូអរដោនេវិចទ័រល្បឿនធៀប $v$ ។ ដូច្នេះពីសមីការ ១.១៥ វាត្រូវតែពិតចំពោះថា




រូបទី ១.១៥៖ វាស់ក្នុងប្រព័ន្ធយោង S ចម្ងាយ $x'$ ត្រូវបង្រួមនៅត្រឹម $x'/\gamma$
ដូចនេះ៖ $x = vt + x'/\gamma$ និង $x' = \gamma(x - vt)$ ។

$$x' = -vt' + x\sqrt{1 - \frac{v^2}{c^2}} \qquad (១.១៧)$$

តាមសមីការ ១.១៦ និង ១.១៧ គេអាចបំបាត់ $x'$ ។ ពីនេះគេនឹងទទួលបានសមីការសម្រាប់ $t'$ ជាអនុគមន៍នៃ $x$ និង $t$ ។ ដំណោះស្រាយដូចខាងក្រោម

$$\frac{x - vt}{\sqrt{1 - \frac{v^2}{c^2}}} = -vt' + x\sqrt{1 - \frac{v^2}{c^2}}$$

$$vt' = x\sqrt{1 - \frac{v^2}{c^2}} - \frac{x - vt}{\sqrt{1 - \frac{v^2}{c^2}}}$$

គុណអង្គទាំងសងខាងជាមួយ $\sqrt{1 - v^2/c^2}$ គេបាន

$$vt'\sqrt{1 - \frac{v^2}{c^2}} = x - \frac{v^2 x}{c^2} - x + vt$$

$$t'\sqrt{1 - \frac{v^2}{c^2}} = t - \frac{vx}{c^2}$$

$$t' = \frac{t - vx/c^2}{\sqrt{1 - v^2/c^2}} \qquad (១.១៨)$$

ប្រវែងដែលកែងនឹងទិសដៅនៃចលនាធៀបគឺមិនរងនូវឥទ្ធិពលអ្វីទេ ដូច្នេះ $y' = y$ និង $z' = z$ ។ ប្រមូលយកសមីការបំលែងទាំងអស់មកដោះស្រាយគេបាន

$$x' = \frac{x - vt}{\sqrt{1 - v^2/c^2}} = \gamma(x - vt)$$

$$y' = y$$

$$z' = z \qquad (១.១៩)$$

$$t' = \frac{t - vx/c^2}{\sqrt{1 - v^2/c^2}} = \gamma(t - vx/c^2)$$

សមីការ ១.១៩ ខាងលើហៅ បំលែងកូអរដោនេរបស់ឡូរ៉ង់ពី $S$ ទៅ $S'$ ។ ធៀបភាពទូទៅនៃបំលែងកូអរដោនេរបស់ហ្គាលីលេ។ បើសិនជាគេចង់បំលែងពី $S'$ ទៅ $S$ វិញ វាជាការងាយដោយគ្រាន់តែជំនួស $v$

ដោយ $-v$ ហើយផ្លាស់ប្ដូរសញ្ញាព្រីម( ′) ក្នុងសមីការ ១.១៩ (ពោលគឺកន្លែង $x'$ ជំនួសដោយ $x$ ហើយកន្លែង $x$ ជំនួសដោយ $x'$ វិញ។ រយៈពេលក៏ដូចគ្នា)។

$$x = \gamma(x' + vt')$$

$$y = y'$$

$$z = z' \qquad (១.១៩ក)$$

$$t = \gamma(t' + vx'/c^2)$$

### 1.5.2 បំលែងនៃវិចទ័រល្បឿនរបស់ឡូរ៉ង់៖

សន្មតថាអ្នកសង្កេតពីរនាក់ស្ថិតក្នុងចលនាធៀបដែលធៀបគ្នាទៅវិញទៅមក ហើយពួកគេសង្កេតចលនារបស់វត្ថុមួយ។ កន្លងមកបំលែងល្បឿនរបស់ហ្គាលីលេអនុវត្តបានតែក្នុងករណីដែលលចនារបស់វត្ថុមានវិចទ័រល្បឿនតូច។ បើសិនជាល្បឿនរបស់វត្ថុមួយ ឬល្បឿនធៀបនៃអ្នកសង្កេតមានតម្លៃខិតទៅរកល្បឿនពន្លឺ តើការវាស់វិចទ័រល្បឿននៃវត្ថុនោះរបស់អ្នកសង្កេតទាំងពីរយ៉ាងដូចម្ដេច? ជាថ្មីម្ដងទៀត ប្រពន្ធ័យោង $S'$ ផ្លាស់ទីដោយល្បឿន $v$ ធៀបនឹង $S$។ សន្មតថាវត្ថុមានកូអរដោនេនៃវិចទ័រល្បឿនតាមអក្ស័ $x$ គឺ $u'_x$ វាស់ក្នុង $S'$។ តាមនិយមន័យនសវិចទ័រល្បឿនគឺ

$$u'_x = \frac{dx'}{dt} \qquad (១.២០)$$

តាមសមីការ ១.១៩ គេបាន

$$dx' = \gamma(dx - vdt)$$

$$dt' = \gamma\left(dt - \frac{v}{c^2}dx\right)$$

ជំនួសតម្លៃនេះក្នុងសមីការ ១.២០ គេបាន

$$u'_x = \frac{dx - vdt}{dt - \frac{v}{c^2}dx} = \frac{\frac{dx}{dt} - v}{1 - \frac{v}{c^2}\frac{dx}{dt}}$$

$$u'_x = \frac{u_x - v}{1 - \frac{u_x v}{c^2}} \qquad (១.២១)$$

បើសិនជាវត្ថុមានកូអរដោនេនៃវិចទ័រល្បឿតាម $y$ និង $z$ វិចទ័រល្បឿនទាំងនេះវាស់ដោយអ្នកសង្កេតក្នុង $S'$ គឺ

$$u'_y = \frac{u_y}{\gamma\left(1 - \frac{u_x v}{c^2}\right)} \quad \text{និង} \quad u'_z = \frac{u_z}{\gamma\left(1 - \frac{u_x v}{c^2}\right)} \tag{១.២២}$$

សម្គាល់ $u'_y$ និង $u'_z$ មិនមាន $v$ នៅក្នុងភាគយកទេ ព្រោះវ៉ិចទ័រល្បឿនធៀបគឺតាមអក្ស័ $x$ ។

ពេល $v$ មានតម្លៃតូចខ្លាំងធៀបនឹង $c$ (nonrelativistic case) ភាគបែងនៃសមីការ ១.២១ ខិតទៅរក $1$ ដូច្នេះ $u'_x \approx u_x - v$ ដែលជាបំលែងនៃវ៉ិចទ័រល្បឿនរបស់ហ្គាលីលេ។ ប៉ុន្តែបើ $u_x = c$ សមីការ ១.២១ ក្លាយជា

$$u'_x = \frac{c - v}{1 - \frac{cv}{c^2}} = \frac{c\left(1 - \frac{v}{c}\right)}{1 - \frac{v}{c}} = c$$

លទ្ធផលនេះបង្ហាញថា ល្បឿនបានវាស់ស្មើនឹង $c$ ដោយអ្នកសង្កេតម្នាក់ក្នុងប្រពន្ធ័យោង $S$ គឺដូចគ្នានឹងល្បឿនដែលបានវាស់ដោយអ្នកសង្កេតក្នុងប្រព័ន្ធយោង $S'$ ដែរ។ សេចក្តីសន្និដ្ឋាននេះគឺស្របនឹងឧបធាទី ២ របស់អាញស្តាញដែលពោលថា៖ ល្បឿនរបស់ពន្លឺត្រូវតែដូចគ្នា $c$ ធៀបនឹងប្រព័ន្ធយោងនិចលទាំងអស់។ ម្យ៉ាងទៀតគេរកឃើញថាល្បឿនរបស់វត្ថុមួយមិនដែលត្រូវបានវាស់ឃើញថាធំជាងល្បឿនពន្លឺ $c$ ទេ។

ដើម្បីទទួលបាន $u_x$ ជាអនុគមន៍នៃ $u'_x$ គឺ (តាមនិយមន័យល្បឿន)

$$u_x = \frac{dx}{dt}$$

ដោយប្រើសមីការ ១.១៩ក គេអាចទទួលបានតម្លៃ $dx$ និង $dt$ បន្ទាប់មកគេបាន $u_x$ ដូចសមីការខាងក្រោម

$$u_x = \frac{u'_x + v}{1 + \frac{u'_x v}{c^2}} \tag{១.២៣}$$

ឧទាហរណ៍៖ យានអវកាសពីរ $A$ និង $B$ កំពុងផ្លាស់ទីក្នុងទិសដៅផ្ទុយគ្នាដូចបង្ហាញក្នុងរូប១.១៦ ។ យាន $A$ មានល្បឿន $0.750c$ និងយាន $B$ មានល្បឿន $0.850c$ ធៀបនឹងអ្នកសង្កេតម្នាក់នៅលើផែនដី។ រកវ៉ិចទ័រល្បឿនរបស់យាន $B$ សង្កេតដោយអវកាសយានិកក្នុង $A$ ។




រូបទី ១.១៦៖ យានអវកាសពីរ A និង B ផ្លាស់ទីក្នុងទិសដៅផ្ទុយគ្នា។

ដំណោះស្រាយ៖ មានអ្នកសង្កេតពីរ ម្នាក់នៅ($O$)លើផែនដីហើយម្នាក់ទៀត($O'$)នៅក្នុងយាន $A$ ។ ព្រឹត្តិការណ៍គឺជាចចលនារបស់យាន $B$។

ប្រព័ន្ធយោង $S'$ដែលនៅជាប់នឹងយាន $A$ ផ្លាស់ទីដោយល្បឿន $v = 0.750c$ ធៀបនឹងអ្នកសង្កេតនៅនឹងលើផែនដី(ប្រព័ន្ធយោង $S$)។ យាន $B$មានល្បឿនធៀបនឹងអ្នកសង្កេតនៅនឹងលើផែនដី(ប្រព័ន្ធយោង $S$) គឺ $u_x = -0.850c$ (ល្បឿនមានទិសដៅតាម $x$ អវិជ្ជមាន)។ ល្បឿនរបស់យាន $B$ធៀបនឹង $A$ គឺ $u'_x$ ដែលត្រូវរក។ តាមគោលការណ៍បំលែងល្បឿនរបស់ឡូរ៉ង់

$$u'_x = \frac{u_x - v}{1 - \frac{u_x v}{c^2}} = \frac{-0.850c - 0.750c}{1 - \frac{(-0.850c)(0.750c)}{c^2}} = -0.977c$$

## 1.6 បរិមាណចលនាធៀបៈ

ច្បាប់ចលនារបស់ញូតុនគឺមានទម្រង់ដូចគ្នាក្នុងប្រព័ន្ធយោងនិចលទាំងអស់។ នៅពេលគេធ្វើការបំលែងដើម្បីប្តូរពីប្រព័ន្ធយោងនិចលមួយទៅមួយផ្សេងទៀត ច្បាប់ទាំងនោះគួរតែមិនត្រូវបានប្រែប្រួលទេ។ ប៉ុន្តែក្នុងសៀវភៅនេះទើបតែបានបង្ហាញថា គោលការណ៍ធៀបបង្ខំឱ្យយើងជំនួសនូវ ការបំលែងរបស់ហ្គាលីលេដោយការបំលែងរបស់ឡូរ៉ង់ដែលមានភាពទូទៅជាង។

គោលការណ៍រក្សាបរិមាណចលនាពោលថា ពេលអង្គធាតុពីរមានអំពើលើគ្នា បរិមាណចលនាសសរុបមានតម្លៃថេរ វាបានបង្ហាញថា កំលាំងក្នុងសរុបដែលមានអំពើលើអង្គធាតុក្នុងប្រព័ន្ធយោងនិចលមួយគឺស្មើសូន្យ(ក្នុងប្រព័ន្ធត្រមោច)។ បើសិនគោលការណ៍រក្សាបរិមាណចលនាគឺជាច្បាប់ដែលមានភាពត្រឹមត្រូវយកជាការបាន វាត្រូវតែជាច្បាប់ដែលយកជាការបានក្នុងប្រពន្ធ័យោងនិចលទាំងអស់។

ប្រសិនបើគេនៅតែបន្តកំណត់ន័យរបស់បរិមាណចលនា $\vec{P}$ នៃរូបធាតុមួយគឺ $m\vec{v}$ ផលគុណរវាងម៉ាស និងវ៉ិចទ័រល្បឿន នោះបរិមាណចលនាសរុបមិនត្រូវបានរក្សាទេចំពោះអ្នកសង្កេតក្នុងប្រព័ន្ធយោងខុសគ្នា។ គេមានជំរើសពីរ៖ (១) បោះបង់ចោលនូវច្បាប់រក្សាបរិមាណចលនា (២) ធ្វើឱ្យប្រសើឡើងនូវនិយមន័យរបស់បរិមាណចលនាតាមវិធីថ្មីទៀត ដែលច្បាប់រក្សាបរិមាណចលនានៅតែអនុវត្តបានត្រឹមត្រូវ។ ចំរើសដែលត្រឹមត្រូវគឺជំរើសទីពីរ។

ពិនិត្យចលនាភាគល្អិតមួយមានល្បឿនថេរ $v$ ក្នុងទិសដៅ $x$ វិជ្ជមាន។ តាមទ្រឹស្តីបុរាណ បរិមាណចលនារបស់វាគឺ

$$P = mv = m\frac{\Delta x}{\Delta t} \qquad (១.២៤)$$

ដែល $\Delta x$ គឺជាចម្ងាយដែលវាធ្វើបានក្នុងរយៈពេល $\Delta t$ ។ ដើម្បីរកកន្សោមបរិមាណចលនាធៀប គេចាប់ផ្តើមពី

$$P = m\frac{\Delta x}{\Delta t_0}$$

ដូចខាងលើដែរ $\Delta x$ គឺជាចម្ងាយចររបស់ភាគល្អិតដែលឃើញដោយអ្នកសង្កេតម្នាក់កំពុងមើលភាគល្អិតនោះ។ $\Delta t_0$ គឺជារយៈពេលដែលត្រូវការដើម្បីចរបានចំងាយខាងលើ ដែលមិនមែនវាស់ដោយអ្នកសង្កេតដែលកំពុងមើលភាគល្អិតទេ តែជារយៈពេលវាស់ដោយអ្នកសង្កេតដែលកំបុងផ្លាស់ជាមួយភាគល្អិត។ ភាគល្អិតនៅនឹងធៀបជាមួយអ្នកសង្កេតទីពីរនេះ ដូច្នេះវាជារយៈពេលពិត(*proper time*) ហើយម៉ាសរបស់ភាគល្អិតក៏សន្មតថាជាម៉ាសនៅនឹងដែរ។ ដោយប្រើសមីការរបស់ភាពរីកនៃពេល $\Delta t = \gamma \Delta t_p$ ($\Delta t_p = \Delta t_0$) (សមីការ ១.១២)

$$P = m\frac{\Delta x}{\Delta t_0} = m\frac{\Delta x}{\Delta t}\frac{\Delta t}{\Delta t_0} = m\frac{\Delta x}{\Delta t}\gamma$$

ដោយផលធៀប $\Delta x/\Delta t$ គឺជាវ៉ិចទ័រល្បឿន $v$ គេបាន

$$P = \gamma m v$$

$$P = \frac{mv}{\sqrt{1-\frac{v^2}{c^2}}} \qquad (១.២៥)$$

$$\vec{P} = \frac{m\vec{v}}{\sqrt{1 - \frac{v^2}{c^2}}} \tag{១.២៦}$$

ពេលល្បឿនរបស់ភាគល្អិត $v$ តូចខ្លាំងធៀបនឹងល្បឿនពន្លឺ $c$ គេបានបរិមាណចលនាដូចគ្នានឹងបរិមាណចលនាក្នុងមេកានិចរបស់ញូតុនដែរ $\vec{P} = m\vec{v}$ ។ វាខុសពីនិយមន័យក្នុងទ្រឹស្តីបុរាណដោយកត្តាឡូរ៉ង់ $\gamma$ ហើយម្យ៉ាងទៀតកាលណាល្បឿនរបស់ភាគល្អិតខិតទៅរកល្បឿនពន្លឺ $c$ បរិមាណចលនាខិតទៅរកអនន្ត។

### 1.6.1 ធៀបភាព ច្បាប់ទី២ញូតុន៖

ក្នុងមេការនិចញូតុន កន្សោមទូទៅនៃច្បាប់ទី២ញូតុនគឺ

$$\vec{F} = \frac{d\vec{P}}{dt} \tag{១.២៧}$$

កំលាំងសរុប $\vec{F}$ ដែលមានអំពើលើភាគល្អិតស្មើនឹងបម្រែបម្រួលបរិមាណចលនាធៀបនឹងរយៈពេល។ តាមពិសោធន៍បានបង្ហាញថាលទ្ធផលនេះគឺនៅតែត្រឹមត្រូវក្នុងមេកានិចធៀប ហើយប្រើបរិមាណចលនាធៀបក្នុងសមីការ ១.២៦ ដើម្បីធ្វើឱ្យច្បាប់ទី២ញូតុនកាន់តែមានភាពទូទៅ

$$\vec{F} = \frac{d}{dt}\frac{m\vec{v}}{\sqrt{1 - v^2/c^2}} \tag{១.២៨}$$

ព្រោះបរិមាណចលនាមិនសមាមាត្រនឹងវ៉ិចទ័រល្បឿនដោយផ្ទាល់ នោះបម្រែបម្រួលបរិមាណចលនាក៏មិនសមាមាត្រនឹងសំទុះដោយផ្ទាល់ទៀតដែរ។ ជាលទ្ធផល កម្លាំងថេរមិនបង្កើតឱ្យមានសំទុះថេរទេ។ ឧទាហរណ៍ ពេលកំលាំងសរុប និងវ៉ិចទ័រល្បឿនមានទិសដៅតាមអ័ក្ស $x$ តាមសមីការ ១.២៨ គេបាន

$$F = \frac{m}{(1 - v^2/c^2)^{3/2}}a \tag{១.២៩}$$

ដែល $a$ ជាសំទុះមានទិសដៅតាមអ័ក្ស $x$ ដោះស្រាយសមីការ ១.២៩ គេទទួលបានសំទុះ

$$a = \frac{F}{m}\left(1 - \frac{v^2}{c^2}\right)^{3/2}$$

គេសង្កេតឃើញថាល្បឿបរបស់ភាគល្អិតកើន សំទុះដែលកើតពីកំលាំងបន្តថយចុះ។ កាលណាល្បឿនកើនដល់ $c$ សំទុះថយដល់សូន្យ មិនថាមានកំលាំងមានអំពើលើភាគល្អិតខ្លាំងប៉ុណ្ណាក៏ដោយ។ ដូច្នេះវាគឺមិនអាចកើតឡើងបានទេដែលថាល្បឿនរបស់ភាគល្អិតមួយអាចបង្កើនរហូតដល់ស្មើ ឬធំជាងល្បឿនពន្លឺនោះ។ ល្បឿនរបស់ពន្លឺជាល្បឿនដែលលឿនបំផុត។

### 1.6.2 ថាមពលស៊ីនេទិចធៀបៈ

គេប្រើទ្រឹស្តីកម្មន្តថាមពល ចាប់ផ្តើមពីនិយមន័យរបស់កម្មន្ត។ ពេលកំលាំងសរុប និងបំលាស់ទីមានទិសដៅដូចគ្នា កម្មន្តដែលធ្វើដោយកំលាំងនោះគឺ $W = \int F dx$ ។ គេជំនួសតម្លៃរបស់ $F$ តាមសមីការ ១.២៩ ។ កម្មន្តដែលបានបំពេញពីទីតាំង $x_1$ ទៅទីតាំង $x_2$ គឺ

$$W = \int_{x_1}^{x_2} F dx = \int_{x_1}^{x_2} \frac{madx}{(1 - v^2/c^2)^{3/2}} \qquad (១.៣០)$$

ដើម្បីរកកន្សោមថាមពលស៊ីនេទិច $K$ ជាអនុគមន៍នៃល្បឿន គេគួរតែបំលែងកន្សោមនេះទៅជាអាំងតេក្រាលនៃល្បឿន។ ដើម្បីធ្វើបាន ដំបូងត្រូវចងចាំថា ថាមពលស៊ីនេទិចនៃភាគល្អិតមួយគឺស្មើនឹងកម្មន្តដែលបានបំពេញក្នុងចលនារបស់វាពីភាពនៅនឹងទៅរហូតដល់ល្បឿន $v$ $(K = W)$។ មានន័យថាល្បឿនស្មើសូន្យត្រង់ទីតាំង $x_1$ និង $v$ ត្រង់ទីតាំង $x_2$ ។ ដោយចលនាតាមអក្ស $x$ ល្បឿន $v$ ជំនួសដោយ $v_x$ ដែលជាវ៉ិចទ័រល្បឿនចុងរបស់ភាគល្អិត កាលណាកំលាំងធ្វើឱ្យវាមានចលនាស្ទុះពីភាពនៅនឹងទៅ។ នៅក្នុងខណៈដ៏ខ្លី $dt$ ភាគល្អិតធ្វើបានចំងាយយ៉ាងខ្លី $dx$ និងល្បឿន $dv_x$ ។ ដោយ $v_x = dx/dt$ និង $a = dv_x/dt$ ដូច្នេះគេអាចសរសេរ $adx$ ដូចខាងក្រោម

$$adx = \frac{dv_x}{dt} dx = dx \frac{dv_x}{dt} = \frac{dx}{dt} dv_x = v_x dv_x$$

ជំនួសតម្លៃនេះក្នុងសមីការ ១.៣០ គេបាន

$$K = W = \int_0^v \frac{mv_x dv_x}{(1 - v_x^2/c^2)^{3/2}} \qquad (១.៣១)$$

ដោះស្រាយអាំងតេក្រាល

$$K = W = \int_0^v m(1 - v_x^2/c^2)^{-3/2}\, v_x dv_x$$

តាង $y = 1 - v_x^2/c^2$ បើ $v_x = 0, y = 1$ ហើយបើ $v_x = v,\ y = 1 - v^2/c^2$ ។ នាំឱ្យ

$$dy = -\frac{2}{c^2} v_x dv_x$$

$$K = W = -\frac{mc^2}{2} \int_1^{1-v^2/c^2} y^{-\frac{3}{2}} dy$$

$$K = W = -\frac{mc^2}{2}\left(\frac{y^{-1/2}}{-\frac{1}{2}}\right)_1^{1-v^2/c^2}$$

$$K = W = mc^2\left(\left(1-\frac{v^2}{c^2}\right)^{-1/2} - 1\right)$$

$$K = \frac{mc^2}{\sqrt{1-v^2/c^2}} - mc^2 = (\gamma - 1)mc^2 \qquad (១.៣២)$$

សមីការ ១.៣២ ជាថាមពលស៊ីនេទិចធៀប។ កាលណា $v$ ខិតទៅរក $c$ ថាមពលស៊ីនេទិចខិតទៅរកអនន្ត។ បើសមីការ ១.៣២ ត្រឹមត្រូវ វាត្រូវតែខិតទៅរកកន្សោមថាមពលស៊ីនេទិចរបស់ញូតុន $K = mv^2/2$ កាលណា $v$ មានតម្លៃតូចណាស់ធៀបនឹង $c$ ។ បើ $v \ll c$ នោះ $v^2/c^2 \ll 1$ តាមទំនាក់ទំនងតម្លៃប្រហែលក្នុងគណិតវិទ្យា $(1-x)^n \approx 1 - nx$ ដែលត្រឹមត្រូវចំពោះ $|x| \ll 1$ គេបាន

$$\left(1-\frac{v^2}{c^2}\right)^{-\frac{1}{2}} \approx 1 + \frac{1}{2}\frac{v^2}{c^2}$$

តាមសមីការ ១.៣២ គេបាន

$$K = W = mc^2\left(1 + \frac{1}{2}\frac{v^2}{c^2}\right) - mc^2 = \frac{1}{2}mv^2$$

សមីការ ១.៣២ អាចសរសេរក្រោមទម្រង់

$$E = K + mc^2 = \frac{mc^2}{\sqrt{1-\frac{v^2}{c^2}}} = \gamma mc^2 \qquad (១.៣៣)$$

សមីការ ១.៣៣ ជាថាមពលសរុបរបស់ភាគល្អិត។ ចំពោះភាគល្អិតនៅនឹង $(K = 0)$ គេឃើញថាថាមពល $E = mc^2$ ។ ថាមពល $mc^2$ នេះហៅថា ថាមពលនៅនឹង( *rest energy*) តាងដោយ $E_0$ ។ សមីការ ១.៣៣ អាចសរសេរ

$$E = K + E_0 \qquad (១.៣៤)$$

ដែល

$$E = \frac{mc^2}{\sqrt{1-\frac{v^2}{c^2}}} = \gamma mc^2 \qquad (១.៣៥)$$

$$E_0 = mc^2 \quad (១.៣៦)$$

គេអាចសរសេរទំនាក់ទំនងរវាងថាមពលសរុប និងបរិមាណចលនាធៀបបានតាមរយៈសមីការ ១.២៥ និងសមីការ ១.៣៥។ ពីសមីការ១.២៥ គេបាន

$$P = \frac{mc\frac{v}{c}}{\sqrt{1-\frac{v^2}{c^2}}}$$

$$\left(\frac{P}{mc}\right)^2 = \frac{v^2/c^2}{1-v^2/c^2}$$

ពីសមីការ ១.៣៥ គេអាចសរសេរ

$$\left(\frac{E}{mc^2}\right)^2 = \frac{1}{1-v^2/c^2}$$

យក

$$\left(\frac{E}{mc^2}\right)^2 - \left(\frac{P}{mc}\right)^2 = \frac{1}{1-v^2/c^2} - \frac{v^2/c^2}{1-v^2/c^2}$$

$$\left(\frac{E}{mc^2}\right)^2 - \left(\frac{P}{mc}\right)^2 = 1$$

$$E^2 = (mc^2)^2 + (pc)^2 \quad (១.៣៧)$$

សមីការ ១.៣៧ គឺជាទំនាក់ទំនងរវាង ថាមពលសរុប ថាមពលនៅស្ងៀម និងបរិមាណចលនា។ ជាថ្មីម្តងទៀត គេសង្កេតឃើញថា ចំពោះភាគល្អិតនៅស្ងៀម ($P = 0$) នោះ $E = mc^2$ ។

សមីការ ១.៣៧ ក៏បានបង្ហាញដែរថា ភាគល្អិតអាចមានថាមពល និងបរិមាណចលនាដែរ ទោះជាពេលវាមិនមានម៉ាសនៅស្ងៀម។ ក្នុងករណី $m = 0$ គេបាន

$$E = Pc \quad (១.៣៨)$$

តាមពិតភាគល្អិតគ្មានម៉ាសពិតជាមាន។ ដូចជាភាគល្អិតដែលមានចលនាដោយល្បឿនស្មើល្បឿនពន្លឺដាលក្នុងសុញ្ញកាស។ ឧទាហរណ៍ ផូតុង ការបញ្ចេញរស្មីអេឡិចត្រូម៉ាញេទិចនៃកង់ទិច។ ផូតុងត្រូវបានបន្សាយ ឬស្រូបក្នុងពេលបម្រែបម្រួលភាពនៃអាតូម ឬប្រព័ន្ធនុយក្លេអ៊ែ ពេលដែលថាមពល និងបរិមាណចលនានៃប្រព័ន្ធផ្លាស់ប្តូរ។

### 1.6.3 អេឡិចត្រុងវ៉ុល(eV)៖

ក្នុងរូបវិទ្យាអាតូម ជាធម្មតាខ្នាតរបស់ថាមពលគិតជា អេឡិចត្រុងវ៉ុល(eV) ដែល 1eV គឺជាថាមពលដែលអេឡិចត្រុងមួយមានចលនាស្ទុះដោយតង់ស្យុង *1* វ៉ុល។

$$1\text{ eV} = (1.602 \times 10^{-19}\text{C})(1.000\ V) = 1.602 \times 10^{-19}\text{J}$$

មានទំហំពីរដែលជាធម្មតាគិតជាអេឡិចត្រុងវ៉ុលគឺ ថាមពលអ៊ីយ៉ុងនៃអាតូមមួយ(កម្មន្តដែលត្រូវការដើម្បីទាញយកអេឡិចត្រុងមួយក្នុងចំនោមអេឡិចត្រុងទាំងអស់) និងថាមពលសម្ពន្ធ័នៃម៉ូលេគុល (ថាមពលដែលត្រូវកាដើម្បីផ្តាច់អាតូមចេញពីគ្នា)។ ថាមពលអ៊ីយ៉ុងរបស់នីត្រូសែនគឺ 14.5 eV ។

$$1\text{ keV} = 10^3\text{ eV}, \qquad 1\text{ MeV} = 10^6\text{ eV}, \qquad 1\text{ GeV} = 10^9\ eV$$

ថាមពលនៅស្ទៀមរបស់ភាគល្អិតដំបូងជាញឹកញាប់គិតជា MeV និង GeV ហើយដែលត្រូវនឹងម៉ាសនៅស្ទៀមត្រូវគិតជា

$$\text{MeV}/c^2 \quad \text{និង} \quad \text{GeV}/c^2$$

ឧទាហរណ៍៖ អេឡិចត្រុងមួយ($m = 0.511\text{ MeV}/c^2$) និងផូតុង($m = 0$) ទាំងពីរមានបរិមាណចលនា $2.000\ MeV/c$ ។ រកថាមពលសរុបរបស់ភាគល្អិតនីមួយៗ?

ដំនោះស្រាយ៖ ថាមពលសរុបរបស់អេឡិចត្រុងគឺ

$$E = \sqrt{m^2c^4 + P^2c^2} = \sqrt{(0.511\text{ MeV}/c^2)^2c^4 + (2.000\text{ MeV}/c)^2c^2}$$

$$E = \sqrt{(0.511\text{ MeV})^2 + (2.000\text{ MeV})^2} = 2.064\text{ MeV}$$

ថាមពលសរុបរបស់ផូតុងគឺ តាមសមីការ ១.៣៨

$$E = Pc = (2.000\text{ MeV}/c)c = 2.000\text{ MeV}$$

លំហាត់

១. រថយន្តពីរកំពុងមានចលនាដោយល្បឿនថេរលើផ្លូវក្នុងទិសដៅស្របគ្នា។ រថយន្តទីមួយមានល្បឿន 60 km/h ហើយរថយន្តទីពីរមានល្បឿន 40 km/h ។ល្បឿនរបស់រថយន្តទាំងពីរវាស់ធៀបនឹងអ្នកសង្កេតនៅស្ទៀមលើដី។ រកល្បឿនរបស់រថយន្តទីមួយធៀបនឹងទីពីរ?(20km/h)

២. យានអវកាសមួយហោះដោយល្បឿន $0.850c$ អ្នកសង្កេតឃើញថាប្រវែងរបស់យាននោះស្មើនឹង $38.2\ m$ ។ បើយាននោះនៅនឹងវិញ តើវាមានប្រវែងប៉ុន្មាន ? ចំលើយ៖ *72.5 m* ។( *Gian* )

៣. តើនៅល្បឿនប៉ុន្មានដែលរូបមន្តក្នុងធៀបភាពចំពោះ (ក)ប្រវែង (ខ)រយៈពេល ខុសពីតម្លៃក្នុងទ្រឹស្តីបុរាណចំនួន *1%* ។ ចំលើយ៖ *0.141c* ។( *Gian* )

## ឯកសារយោង


1. Hugh D. Young & Roger A. Freedman, University Physics with Modern Physics, 13ed.
2. Raymond A. Serway & John W. Jewett, Physics for Scientists and Engineers with Modern Physics, 9ed.
3. Randall D. Knight, Physics for Scientists and Engineers, 2ed.
4. Halliday & Resnick, Fundamentals of Physics, 9ed.
5. Douglas C. Giancoli, Physics for Scientists and Engineers with Modern Physics, 4ed

# មេរៀនទី២៖ សេចក្តីផ្តើមនៃរូបវិទ្យាកង់ទិច

នៅសតវត្សរ៍ទី២០ ពិសោធន៍ជាច្រើន និងទ្រឹស្តី បញ្ហាជាច្រើនត្រូវបានដោះស្រាយដោយទ្រឹស្តីធៀបពិសេស។ តែចំពោះបញ្ហាជាច្រើនផ្សេងទៀត ទ្រឹស្តីធៀប ឬរូបវិទ្យាបុរាណគឺមិនអាចផ្តល់ចម្លើយបានទេ។ ការព្យាយាមអនុវត្តច្បាប់ក្នុងរូបវិទ្យាបុរាណដើម្បីពន្យល់ពីការប្រព្រឹត្តទៅនៃរូបធាតុក្នុងកម្រិតអាតូមគឺមិនទទួលបានជោគជ័យទេ។ ឧទាហរណ៍ ការបន្សាយនៃជំហានរលកក្នុងទម្រង់ដាច់ ឬដាកញ្ចប់របស់ពន្លឺពីអាតូមក្នុងឧស្ម័នដែលមានសីតុណ្ហភាពខ្ពស់ មិនអាចត្រូវបានពន្យល់ដោយប្រើហេតុផលរបស់រូបវិទ្យាបុរាណឡើយ។

អ្នករូបវិទ្យាបានរកឃើញវិធីថ្មីដើម្បីដោះស្រាយបញ្ហាទាំងនេះ បដិវត្តន៍មួយផ្សេងទៀតបានកើតឡើងក្នុងរូបវិទ្យានៅចន្លោះពីឆ្នាំ ១៩០០ ទៅឆ្នាំ ១៩៣០។ ទ្រឹស្តីថ្មីមួយហៅថា មេកានិចកង់ទិច គឺទទួលបានជោគជ័យខ្ពស់ក្នុងការពន្យល់ពីការប្រព្រឹត្តទៅនៃភាគល្អិតក្នុងទំហំមីក្រូ(microscopic size)។

ការពន្យល់បាតុភូតដំបូងបង្អស់ដោយប្រើទ្រឹស្តីកង់ទិចគឺលោក Max Planck ។ ហើយការអភិវឌ្ឍន៍ក្នុងវិបាកគណិតវិទ្យាជាច្រើន និងការបកស្រាយបញ្ជាក់ជាច្រើន ត្រូវបានធ្វើឡើងដោយអ្នករូបវិទ្យាផ្សេងៗជាច្រើនរួមមាន លោក អាញស្តាញ លោក បរ (Bohr) លោក de Broglie លោក Schrodinger និងលោក Heisenberg។ ដោយសារសៀវភៅនេះមិនមែនជាសៀវភៅមេកានិចកង់ទិច ដូច្នេះមិនមានការបកស្រាយ ឬពន្យល់ស៊ីជម្រៅទេ គឺគ្រាន់តែបង្ហាញពីសេចក្តីផ្តើម និងគោលការណ៍មួយចំនួន។

## 2.1 បន្សាយរស្មីនៃអង្គធាតុខ្មៅ និងសម្មតិកម្មប្លង់៖

### 2.1.1 បន្សាយរស្មីនៃអង្គធាតុខ្មៅ៖

អង្គធាតុមួយនៅសីតុណ្ហភាពណាមួយបន្សាយរលកអេឡិចត្រូម៉ាញេទិចក្នុងទម្រង់នៃការបញ្ចេញរស្មីពីផ្ទៃរបស់វា។ លក្ខណៈនៃការបញ្ចេញរស្មីនេះផ្អែកលើសីតុណ្ហភាព និងលក្ខណៈនៃផ្ទៃរបស់អង្គធាតុ។ បើអង្គធាតុមួយស្ថិតនៅសីតុណ្ហភាពបន្ទប់ ជំហានរលកនៃការបញ្ចេញរស្មីគឺស្ថិតនៅក្នុងតំបន់ពន្លឺអាំងប្រា ដែលមិនត្រូវបានមើលឃើញដោយភ្នែករបស់មនុស្សទេ។ កាលណាសីតុណ្ហភាពលើផ្ទៃរបស់អង្គធាតុកើនឡើង អង្គធាតុចាប់ផ្តើមបញ្ចេញបន្តិចៗម្តងនូវពន្លឺមើលឃើញពណ៌ក្រហម ដូចជាបូប៊ីននៅក្នុងឧបករណ៍សម្រាប់អាំង ឬ

ឧបករណ៍កម្តៅ។ នៅសីតុណ្ហភាពខ្ពស់គ្រប់គ្រាន់ ពន្លឺចេញពីអង្គធាតុឡើងទៅជាស ដូចជាសសៃតង់ស្តែននៅក្នុងអំពូលវង្គុំ(អំពូលពងមាន់)។

ពីទស្សនបុរាណ ការបញ្ចេញរស្មីគឺចេញពីការពន្លឿនរបស់ភាគល្អិតមានបន្ទុកអគ្គិសនីក្នុងអាតូមក្បែរផ្ទៃនៃអង្គធាតុ។ រញ្ជួយរបស់ភាគល្អិតដោយកម្តៅអាចមានរបាយនៃថាមពលមួយ ដែលពន្យល់ពីភាពជាប់នៃស្ប៉ិចរបស់រស្មីបានបន្សាយដោយអង្គធាតុនោះ។ នៅចុងសតវត្សរ៍ទី១៩ វាត្រូវបានគេមើលឃើញថា ទ្រឹស្តីបុរាណនៃការបញ្ចេញរស្មីគឺមិនគ្រប់គ្រាន់។ បញ្ហាចំបងគឺ ស្ថិតក្នុងភាពមិនយល់ពីការសង្កេតរបាយជំហានរលកក្នុងរស្មីបានបន្សាយដោយអង្គធាតុខ្មៅ។ អង្គធាតុខ្មៅគឺសំដៅទៅលើអង្គធាតុណាដែលស្រូបនូវរស្មីចាំងប៉ះលើវាទាំងអស់។ ដោយហេតុថាគ្មានពន្លឺណាមួយត្រូវបានផ្លាត ឬបញ្ជូន វត្ថុប្រែជាខ្មៅពេលវាចុះត្រជាក់។ ការបញ្ចេញរស្មីអេឡិចត្រូម៉ាញេទិចបានបន្សាយដោយអង្គធាតុខ្មៅពេលវាឡើងកម្តៅហៅថា ការបញ្ចេញរស្មីនៃអង្គធាតុខ្មៅ។

ការប្រដូចនឹងអង្គធាតុខ្មៅដ៏ល្អមួយគឺជាវត្ថុមានរន្ធតូចមួយដែលអាចនាំទៅដល់ប្រហោងផ្នែកខាងក្នុងរបស់វត្ថុនោះដូចបង្ហាញក្នុងរូប ២.១។ រស្មីពន្លឺពីខាងក្រៅចាំងប៉ះលើរន្ធបានចូលទៅក្នុងអង្គធាតុទាំងអស់ និងផ្លាតជាច្រើនដងលើជញ្ជាំងផ្នែកខាងក្នុងនៃប្រហោង ហើយរន្ធមាននាទីជាអ្នកស្រូបយកឥតខ្ចោះ។




រូបទី២.១៖ ការធ្វើគំរូតាងឱ្យអង្គធាតុខ្មៅ។

ធម្មជាតិនៃការបញ្ចេញរស្មីពីប្រហោងនៃវត្ថុតាមរន្ធ គឺផ្អែកលើតែសីតុណ្ហភាពនៃជញ្ជាំងរបស់ប្រហោង ហើយមិនអាស្រ័យនឹងរូបធាតុដែលយកមកបង្កើតជាជញ្ជាំងទេ។

របាយជំហានរលកនៃការបញ្ចេញរស្មីពីប្រហោងត្រូវបានសិក្សានៅចុងសតវត្សទី១៩។ រូបទី២.២ បង្ហាញពីអាំតង់ស៊ីតេនៃការបញ្ចេញរស្មីរបស់អង្គធាតុខ្មៅប្រែប្រួលជាមួយសីតុណ្ហភាព និងជំហានរលក។ ការពិសោធន៍រកឃើញស្របគ្នាពីរមានលក្ខណពិសេសគួរឱ្យគត់សម្គាល់ដូចខាងក្រោម៖

១. អានុភាពសរុបនៃការបញ្ចេញរស្មីកើនឡើងជាមួយសីតុណ្ហភាព។ កំណត់ដោយច្បាប់ Stefan ( ស្តេហ្វេន )

$$P = \sigma A e T^4 \qquad (២.១)$$

ដែល $P$ ជាអានុភាពគិតជាវ៉ាត់បន្សាយដោយមានគ្រប់ជំហានរលកពីផ្ទៃនៃអង្គធាតុ។ $\sigma = 5.670 \times 10^{-8}\ Wm^{-2}K^4$ គឺជាថេរ ស្តេហ្វេន ប៊ុលហ្សាមេន ( Stefan-Boltzmann )។ $A$ ជាក្រលាផ្ទៃរបស់វត្ថុ។ $e$ តាងអេមីសស៊ីវីធី ( emissivity )របស់ផ្ទៃ ចំពោះអង្គធាតុខ្មៅវាមានតម្លៃស្មើ 1 ។ $T$ ជាសីតុណ្ហភាពគិតជាកែលវិន $K$ ។




រូបទី២.២៖ អាំងតង់ស៊ីតេនៃការបញ្ចេញរស្មីរបស់អង្គធាតុខ្មៅ និងជំហានរលកនៅសីតុណ្ហភាពបីផ្សេងគ្នា។ ជំហាននៃពន្លឺមើលឃើញនៅចន្លោះ 0.4 μm និង 0.7 μm ។

ម្យ៉ាងទៀតច្បាប់ស្តេហ្វេនអាចសរសេរក្រោមទម្រង់អាំងតង់ស៊ីតេនៃការបញ្ចេញរស្មីក៏បានគឺ អាំងតង់ស៊ីតេសរុប (ថាមពលនៃការបញ្ចេញរស្មីក្នុងមួយខ្នាតផ្ទៃ ឬអនុភាពក្នុងមួយខ្នាតផ្ទៃ) បានបន្សាយពីផ្ទៃរបស់អង្គធាតុខ្មៅគឺសមាមាត្រនឹងសីតុណ្ហភាពស្វ័យគុណ៤។

$$I = \sigma T^4$$

២. កំពូលនៃរបាយជំហានរលកប្រែប្រួលខិតទៅខាងជំហានរលកខ្លីជាង ពេលសីតុណ្ហភាពកើនឡើង។ កំណត់ដោយច្បាប់បំលាស់ទីវៀន (Wien's displacement law)

$$\lambda_{max} T = 2.898 \times 10^{-3}\ \mathrm{mK} \qquad (២.២)$$

ដែល $\lambda_{max}$ ជាជំហានរលកនៅត្រង់កំពូលខ្សែកោង។ $T$ ជាសីតុណ្ហភាពដាច់ខាតរបស់ផ្ទៃនៃវត្ថុដែលបន្សាយរស្មី។ ជំហានរលកនៅត្រង់កំពូលខ្សែកោងគឺប្រាសសមាមាត្រនឹងសីតុណ្ហភាពដាច់ខាត។ កាលណាសីតុណ្ហភាពកើន កំពូលខ្សែកោងផ្លាស់ទៅរកទីតាំងមានជំហានរលកខ្លីជាង។

ឧទាហរណ៍៖ សីតុណ្ហភាពលើផ្ទៃព្រះអាទិត្យ។ ការប៉ាន់ស្មានសីតុណ្ហភាពរបស់ផ្ទៃនៃព្រះអាទិត្យ ដោយដឹងថាព្រះអាទិត្យបញ្ចេញពន្លឺដែលមានកំពូលរបស់អាំងតង់ស៊ីតេក្នុងតំបន់ពន្លឺមើលឃើញដែលមានជំហានរលកប្រហែល 500 nm ។

ដំណោះស្រាយ៖ សម្មតថាព្រះអាទិត្យជាអង្គធាតុខ្មៅមួយ ហើយកំពូលនៃជំហានរលកនៅក្នុងច្បាប់វៀនគឺ $\lambda = 500\ \mathrm{nm}$ ។ តាមច្បាប់វៀន

$$\lambda T = 2.898 \times 10^{-3}\ \mathrm{mK}$$

$$T = \frac{2.898 \times 10^{-3}\ \mathrm{mK}}{\lambda} = \frac{2.898 \times 10^{-3}\ \mathrm{mK}}{500 \times 10^{-9}\mathrm{m}} = 5.796 \times 10^{3}\mathrm{K}$$

ទ្រឹស្តីដែលជោគជ័យចំពោះការបញ្ចេញរស្មីនៃអង្គធាតុខ្មៅគឺត្រូវតែព្យាករថាទម្រង់នៃខ្សែកោងគឺដូចក្នុងរូបទី ២.២ ហើយភាពអាស្រ័យនឹងសីតុណ្ហភាពគឺបានបញ្ជាក់ដោយច្បាប់ស្តេហ្វេន និងបម្រែបម្រួលកំពូលនៃជំហានរលកជាមួយនឹងសីតុណ្ហភាពត្រូវបានព៌ណនាដោយច្បាប់បំលាស់ទីវៀន។ មានការព្យាយាមពន្យល់ជាច្រើនពីទម្រង់នៃខ្សែកោងដូចក្នុងរូប២.២ដោយប្រើទ្រឹស្តីបុរាណតែបរាជ័យ។ ឥឡូវពិនិត្យការពន្យល់មួយ

ដោយប្រើទ្រឹស្តីបុរាណ ដើម្បីព៌ណនាពីរបាយថាមពលចេញពីអង្គធាតុខ្មៅ។ លទ្ធផលនៃការគណនាគឺផ្អែកលើ ច្បាប់ *Rayleigh-Jeans*

$$I(\lambda,T)=\frac{2\pi c k_B T}{\lambda^4} \qquad (២.៣)$$

ដែល $k_B$ ជាថេរប៊ុលស្មាន់( *Boltzmann*) ។ អង្គធាតុខ្មៅត្រូវបានប្រដូចទៅនឹងរន្ធមួយដែលអាចនាំទៅដល់ប្រហោងខាងក្នុងដូចរូប២.១ ហើយលទ្ធផលនៃលំយោលរបស់ដែនអេឡិចត្រូម៉ាញេទិចបណ្តាលឱ្យមានសំទុះនៃបន្ទុកអគ្គិសនីក្នុងជញ្ជាំងរបស់ប្រហោង និងបន្សាយរលកអេឡិចត្រូម៉ាញេទិចគ្រប់ជំហានរលក។

ក្រាបនៃពិសោធន៍មួយនៃការបញ្ចេញរស្មីរបស់អង្គធាតុខ្មៅ និងការព្យាកររបស់ Rayleigh-Jean គឺត្រូវបានបង្ហាញក្នុងរូប ២.៣។




រូបទី ២.៣៖ ការប្រៀបធៀបលទ្ធផលពិសោធន៍ និងខ្សែកោងដែលបានគិតទុកដោយច្បាប់ Rayleigh-Jean ចំពោះរបាយនៃការបញ្ចេញរស្មីរបស់អង្គធាតុខ្មៅ។

ករណីជំហានរលកវែង ច្បាប់ Rayleigh-Jean គឺត្រូវជាមួយនឹងពិសោធន៍ តែករណីជំហានរលកខ្លីច្បាប់នេះគឺមិនគាំទ្រដោយពិសោធន៍ទេ។ កាលណាជំហានរលកខិតទៅរកសូន្យ អាំងតង់ស៊ីតេក្នុងសមីការ ២.៣ ខិតទៅរកតម្លៃមិនកំណត់។ ដូច្នេះបើតាមទ្រឹស្តីបុរាណ ជំហានរលកខ្លីដែលមានក្នុងការបញ្ចេញរស្មីនៃអង្គធាតុខ្មៅខិត

ទៅរកសូន្យ នោះថាមពលដែលបានបន្សាយដោយអង្គធាតុខ្មៅនឹងខិតទៅរកតម្លៃមិនកណត់។ ប៉ុន្តែផ្ទុយទៅវិញ ក្រាបដែលបានមកពីទិន្នន័យពិសោធន៍គឺមានទម្រង់ដូចរូប២.៣ (ខ្សែកោងព៍ណខៀវ) បង្ហាញថា ខណៈដែលជំហានរលកខិតទៅរកសូន្យ អាំងតង់ស៊ីតេក៏ខិតទៅរកសូន្យដែរ។ ភាពមិនស្របគ្នារវាងទ្រឹស្ដី និងពិសោធន៍បានក្លាយជាកង្វល់ដែលអ្នកវិទ្យាសាស្ត្រហៅថា Ultraviolet catastrophe មហន្តរាយនៃកាំរស្មី UV (មហន្តរាយ គឺថាមពលមានតម្លៃអនន្ត ដែលកើតឡើងពេលជំហានរលកខិតទៅរកសូន្យ ពាក្យ Ultraviolet គឺកាំរស្មីមានជំហានរលកខ្លី)។

### 2.1.2 សម្មតិកម្មប្លង់៖

ក្នុងឆ្នាំ ១៩០០ លោក Max Planck បានអភិវឌ្ឍន៍ទ្រឹស្ដីមួយនៃការបញ្ចេញរស្មីរបស់អង្គធាតុខ្មៅដែលនាំទៅដល់សមីការមួយចំពោះ $I(\lambda,T)$ ដែលគាំទ្រទាំងស្រុងដោយលទ្ធផលពិសោធន៍ចំពោះគ្រប់ជំហានរលក។ ហើយដែលមកទល់ពេលនេះគេនិយមហៅរូបមន្តនោះថា រូបមន្តនៃការបញ្ចេញរស្មីរបស់អង្គធាតុខ្មៅ របស់ Max Planck ។

$$I(\lambda,T)=\frac{2\pi hc^2}{\lambda^5(e^{hc/\lambda k_BT}-1)} \qquad (២.៤)$$

ដែល $h$ ជាប៉ារ៉ាម៉ែតមួយដែលប្លង់ប្រើដើម្បីកែសម្រួលខ្សែកោងឱ្យត្រូវជាមួយនឹងទិន្នន័យពិសោធន៍ចំពោះគ្រប់ជំហានរលក ក្រោយមកត្រូវគេហៅថាជាថេរប្លង់ $h=6.626\times10^{-34}$ js។ ដោយប្រើរូបមន្ត Power series: $e^x=1+x+\frac{x^2}{2!}+\frac{x^3}{3!}+\cdots$ ចំពោះ $x$ មានតម្លៃតូចគេបាន

$e^x\approx1+x$ កាលណាជំហានរលកវែងនោះ $hc/\lambda k_BT$ មានតម្លៃតូចគេបាន

$e^{hc/\lambda k_BT}\approx1+\frac{hc}{\lambda k_BT}$ សមីការ ២.៤ក្លាយជា $I(\lambda,T)=\frac{2\pi ck_BT}{\lambda^4}$ រូបមន្តរបស់ Rayleigh-Jean ។ ហើយចំពោះជំហានរលកខ្លី $I(\lambda,T)$ ថយចុះដែលស៊ីគ្នាជាមួយនឹងលទ្ធផលពិសោធន៍។

លោក ប្លង់ បានសន្និដ្ឋានថា ការបញ្ចេញរស្មីនៃប្រហោងក្នុងរូប២.១ គឺមកពីលំយោលនៃអាតូមនៅក្នុងជញ្ជាំងរបស់ប្រហោងនៃអង្គធាតុនោះ។

ក. ថាមពលនៃលំយោលករអាចមានតែក្នុងកញ្ចប់ដាច់នៃតម្លៃពិតប្រាកដណាមួយ $E_n$

$$E_n=nhf \qquad (២.៥)$$

ដែល $n$ ជាចំនួនថេរវិជ្ជមានហៅថា ចំនួនកង់ទិច ហើយ $f$ ជាប្រេកង់នៃលំយោលករ និង $h$ គឺជាប៉ារ៉ាម៉ែតមួយដែលលោកប្លង់បានលើកឡើង ឥឡូវត្រូវបានគេហៅថា ថេរប្លង់។ ដោយសារតែថាមពលនៃលំយោលករនីមួយៗអាចមានតែតាមតម្លៃដាច់ៗតាមសមីការ២.៥ គេអាចនិយាយថាថាមពលគឺមានតម្លៃដាកញ្ចប់ដាច់ៗ (The energy is quantized)។ តម្លៃដាច់ៗនៃថាមពលនីមួយៗគឺត្រូវជាមួយនឹងតម្លៃកង់ទិចខុសៗគ្នា។ ពេលលំយោលករស្ថិតក្នុងភាពកង់ទិច $n = 1$ ថាមពលរបស់វាគឺ $hf$ នៅពេលវាស្ថិតក្នុងភាពកង់ទិច $n = 2$ ថាមពលរបស់វាគឺ $2hf$ ហើយនិងបន្តបន្ទាប់ទៀត។

ខ. លំយោលករបញ្ចេញ ឬស្រូបថាមពលពេលមានការផ្លាស់ប្តូរភាពកង់ទិចមួយទៅភាពកង់ទិចមួយផ្សេងទៀត។ ក្នុងពេលមានការផ្លាស់ប្តូររវាងភាពដើមនិងភាពស្រេច ឬផ្ទុយមកវិញ ថាមពលត្រូវបានបន្សាយ ឬស្រូបស្មើកង់ទិចទោលមួយ។ បើឆ្លងពីភាពមួយទៅភាពមួយទៀតដែលទាបជាងនៅជាប់គ្នា ឧទាហរណ៍ពីភាព $n = 3$ ទៅ $n = 2$ សមីការ ២.៥ បង្ហាញថាចំនួនថាមពលបានបន្សាយដោយលំយោលករ និងដោយការបញ្ចេញស្មើកង់ទិចគឺ

$$E = hf \qquad (២.៦)$$

សរុបក្នុងចំនុច(ខ)គឺថា លំយោលករមួយបន្សាយ ឬស្រូបថាមពលតែក្នុងពេលវាផ្លាស់ភាពកង់ទិច។ បើវាស្ថិតនៅតែក្នុងភាពកង់ទិចមួយ នោះមិនមានថាមពលត្រូវបានស្រូប ឬបញ្ចេញឡើយ។ ក្នុងរូប ២.៤ គឺជាដ្យាក្រាមនៃនីវ៉ូថាមពលបង្ហាញពីភាពដាច់នៃនីវ៉ូថាមពល និងការឆ្លងទៅមករវាងនីវ៉ូដែលអាចកើតមាន ដែលបានស្នើឡើងដោយលោក ប្លង់។ ការបង្ហាញក្រាហ្វិចសំខាន់នេះគឺត្រូវបានជាញឹកញាប់ក្នុងរូបវិទ្យាកង់ទិច។



រូបទី២.៨៖ នីវ៉ូថាមពលចំពោះលំយោលករមួយមានប្រេកង់ $f$ ។

ចំនុចគន្លឹះនៃទ្រឹស្តីរបស់ប្លង់គឺ ការសន្មតយ៉ាងសំខាន់នៃថាមពលក្នុងភាពកង់ទិច។

ឧទាហរណ៍៖ ដុំមួយមានម៉ាស 2.00 kg ត្រូវបានភ្ជាប់ទៅនឹងរ៉ឺស័រមួយមិនគិតម៉ាសហើយមានថេរកំរាញ $k$ = 25.0 N/m ។ គេធ្វើឱ្យរ៉ឺស័រយឺតបានប្រវែង 0.400 $m$ ពីទីតាំងលំនឹងរួចលែងវិញដោយគ្មានល្បឿនដើម។

ក. រកថាមពលសរុបនៃប្រព័ន្ធ និងប្រេកង់នៃលំយោល តាមទ្រឹស្តីបុរាណ?

ខ. សម្មតថា ថាមពលនៃលំយោលគឺជាថាមពលកង់ទិច( ទម្រង់ដាច់ ) ចូររកចំនួនកង់ទិច $n$ ចំពោះប្រព័ន្ធយោលជាមួយអំព្លីទុតនេះ?

ដំណោះស្រាយ៖ ក. ថាមពលសរុបនៃប្រព័ន្ធ

តាមរូបមន្ត៖ $E = \frac{1}{2}kA^2 = \frac{1}{2}(25.0\ N/m)(0.400\ m)^2 = 2.00\ \text{J}$

ប្រេកង់នៃលំយោលគឺ $f = \frac{1}{2\pi}\sqrt{\frac{k}{m}} = \frac{1}{2\pi}\sqrt{\frac{25.0 N/m}{2.00\ \text{kg}}} = 0.563\ \text{Hz}$

ខ. ចំនួនកង់ទិច : តាមរូបមន្ត

$$E_n = nhf \quad \text{ឬ} \quad n = \frac{E_n}{hf} = \frac{2.00\ \text{J}}{(6.626\times10^{-34}\text{Js})(0.563\ \text{Hz})} = 5.36\times10^{33}$$

ចំនួនកង់ទិចស្មើនឹង $5.36\times10^{33}$ គឺមានតម្លៃធំណាស់ដែលត្រូវនឹងប្រព័ន្ធម៉ាក្រូ។

សន្មតថា លំយោលករផ្លាស់ប្តូរភាពកង់ទិចពី $n = 5.36\times10^{33}$ ទៅភាពកង់ទិច $n = 5.36\times10^{33} - 1$ ។ តើថាមពលមានតម្លៃប៉ុន្មានក្នុងបម្រែបម្រួលភាពមួយកង់ទិចនេះ។ ពីសមីការ២.៦ ថាមពលនៃលំយោលករក្នុងបម្រែបម្រួលភាពមួយកង់ទិចគឺ

$$E = hf = (6.626\times10^{-34}\ \text{Js})(0.563\ \text{Hz}) = 3.73\times10^{-34}\ J$$

ដែលមានតម្លៃយ៉ាងតូចក្រៃលែង ដូច្នេះបើទោះជាប្រព័ន្ធម៉ាក្រូនៃលំយោលគឺមានលក្ខណៈកង់ទិច( ទម្រង់ដាច់នៃថាមពល ) ហើយថយចុះនូវតម្លៃយ៉ាងតូចនៃនីវ៉ូថាមពលកង់ទិចពិតមែន តែការដឹងដោយវិញ្ញាណរបស់

យើងគិតថាវាមានលក្ខណៈជាប់។ ដូចនេះផលកង់ទិចក្លាយទៅជាសំខាន់តែសម្រាប់ប្រព័ន្ធមីក្រូក្នុងកម្រិតអាតូម ឬម៉ូលេគុលទេ។

## 2.2 ផលផូតូអគ្គិសនី៖

ក្នុងឆ្នាំ ១៩០៥ ដដែលទន្ទឹមនឹងការបង្ហាញពីទ្រឹស្តីធៀបពិសេស លោកអាញស្តាញបានពង្រីកនូវគំនិតស្តីពីកង់ទិចដោយស្នើឡើងនូវទ្រឹស្តីថ្មីមួយអំពីពន្លឺ។ កិច្ចការរបស់លោកប្លង់បានស្នើឡើងថា ថាមពលនៃលំយោលរបស់ម៉ូលេគុលក្នុងអង្គធាតុបញ្ចេញរស្មីគឺមានលក្ខណៈកង់ទិច( លក្ខណៈជាកញ្ចប់ដាច់ៗនៃថាមពល )ជាមួយថាមពល $E_n = nhf$ ដែល $n$ ជាចំនួនថេរហើយ $f$ ជាប្រេកង់នៃលមយោលរបស់ម៉ូលេគុល។ លោកអាញស្តាញបានអះអាងពីទ្រឹស្តីរបស់គាត់ថា ពេលពន្លឺត្រូវបានបន្សាយដោយលំយោលករម៉ូលេគុល ថាមពលរបស់ម៉ូលេគុលមានលំយោលដែលស្មើ $nhf$ ត្រូវថយអស់ចំនួន $hf$ (ឬ $2hf$ ។ល។) ទៅជាតម្លៃថាមពលមួយផ្សេងទៀតដែលស្មើនឹងចំនួនថេរគុណនឹង $hf$ ដូចជា $(n-1)hf$ ។ ដើម្បីរក្សាថាមពលពន្លឺគួរតែត្រូវបានបន្សាយក្នុងទម្រង់ជាកញ្ចប់ ឬកង់ទិច ឬហៅថាផូតុង ដែលមានថាមពល

$$E = hf \qquad (២.៧)$$

ដែល $f$ ជាប្រេកង់របស់ពន្លឺដែលបានបន្សាយ។ ហើយ $h$ ជាថេរប្លង់។

ពេលពន្លឺចាំងទៅលើផ្ទៃរបស់លោហៈមួយ អេឡិចត្រុងត្រូវបានខ្ទាតចេញពីផ្ទៃលោហៈនោះ។ បាតុភូតនេះហៅថា ផលផូតូអគ្គិសនី ហើយអេឡិចត្រុងដែលខ្ទាតចេញហៅថា ផូតូអេឡិចត្រុង វាកើតឡើងកចំពោះអង្គធាតុជាច្រើន ប៉ុន្តែងាយស្រួលសង្កេតជាងគេគឺចំពោះលោហៈ។ រូប ២.៥(ខ) ជាឧបករណ៍សម្រាប់សង្កេតពីផលផូតូអគ្គសនី។ បន្ទះលោហៈមួយ P និងអេឡិចត្រូតផ្ទាមួយ C ត្រូវបានដាក់ក្នុងបំពង់កែងសុញ្ញកាសមួយហៅថាកោសិការផូតូ( Photocell ) ។ មានអេឡិចត្រូតពីរភ្ជាប់ទៅអំពែម៉ែត និងជនិតា។ ពេលកោសិការផូតូស្ថិតក្នុងទីងងឹត អំពែម៉ែតចង្អុលសូន្យ។ ប៉ុន្តែពេលពន្លឺមានប្រេកង់ខ្ពស់គ្រប់គ្រាន់ចាំងទៅលើបន្ទះលោហៈ អំពែម៉ែតបង្ហាញថាមានចរន្តតក្នុងសៀគ្វី។ នេះគឺព្រោះតែអេឡិចត្រុងដែលខ្ទាតចេញមកដោយសាការទង្គិចរបស់ពន្លឺ ហោះឆ្លងកាត់បំពង់ពីបន្ទះ P ទៅអេឡិចត្រូត( collector ) C ដូចក្នុងរូប ២.៥(ខ)។




រូបទី ២.៥៖ ផលផូតូអគ្គិសនី។

ដើម្បីវាស់ថាមពលស៊ីនេទិចរបស់អេឡិចត្រុង គេត្រូវត្រឡប់ប៉ូលរបស់ជនិតាមានន័យថាអេឡិចត្រូត C គឺអវិជ្ជមាន និងអេឡិចត្រូត P គឺវិជ្ជមាន រូប២.៥(ក)។ អេឡិចត្រុងដែលបន្សាយចេញពី P នឹងត្រូវរុញច្រានដោយអេឡិចត្រូតអវិជ្ជមាន ប៉ុន្តែបើតង់ស្យុងនេះមានតម្លៃតូចល្មម អេឡិចត្រុងដែលមានល្បឿនលឿន ឬថាមពលស៊ីនេតិចខ្លាំង នឹងទៅដល់ C ដែលធ្វើឱ្យមានចរន្តក្នុងសៀគ្វី។ គេអាចកំណត់ថាមពលស៊ីនេទិចអតិបរមារបស់អេឡិចត្រុងបាន ដោយបង្កើនតង់ស្យុង VCP រហូតដល់តម្លៃណាមួយដែលធ្វើឱ្យចរន្តក្នុងសៀគ្វីស្មើសូន្យ មានន័យថាអេឡិចត្រុងមិនមានថាមពលស៊ីនេទិចគ្រប់គ្រាន់ដើម្បីហោះទៅដល់ C ទេ។ តម្លៃតង់ស្យុងនោះហៅថាតង់ស្យុងបញ្ឈប់(Stopping potential or stopping voltage) តាងដោយ $V_0$ ។ ដោយ VCP អវិជ្ជមានគេបាន VCP = $-V_0$។ ពេលអេឡិចត្រុងមួយផ្លាស់ទីពី P ទៅ C កម្មន្តនៃដែនអគ្គិសនីធ្វើទៅលើអេឡិចត្រុងមានតម្លៃ $W = \vec{F}.\vec{d} = |q|E.d.\cos 180° = -|q|V_{PC} = -eV_0$ ព្រោះ $q = -e$(បន្ទុកអេឡិចត្រុង) $|q| = e$ ហើយ $V_{PC} = -V_{CP}$ ។ អេឡិចត្រុងផ្លាស់ទីចេញពី P មានថាមពលស៊ីនេទិច $K_{max} = \frac{1}{2}mv_{max}^2$ ហើយថាមពលនេះស្មើសូន្យពេលទៅជិតដល់ C ។ ដោយប្រើទ្រឹស្តីថាមពលនិងកម្មន្ត គេបាន

$$W = \Delta K = 0 - K_{max}$$

$$-eV_0 = -K_{max}$$

$$K_{max} = \frac{1}{2}mv_{max}^2 = eV_0 \qquad (២.៨)$$

ដែល $e = 1.60 \times 10^{-19} C$ ។

ឥឡូវពិនិត្យនូវផលផូតូអគ្គិសនីដែលបកស្រាយតាមទស្សនៈនៃទ្រឹស្តីរលកទល់នឹងទ្រឹស្តីភាគល្អិតរបស់អាញស្តាញ។ ដំបូងទ្រឹស្តីរលក ដោយសន្មតថាពន្លឺជាពន្លឺម៉ូណូក្រូម៉ាទិច។ លក្ខណៈសំខាន់របស់ពន្លឺគឺ អាំតង់ស៊ីតេ និងប្រេកង់ ឬជំហានរលករបស់វា។ ពេលទំហំទាំងពីរនេះប្រែប្រួល ទ្រឹស្តីនៃរលកធ្វើការព្យាករដូចខាងក្រោម៖

១. បើអាំងតង់ស៊ីតេនៃពន្លឺកើនឡើង ចំនួនអេឡិចត្រុងដែលបានខ្ចាតចេញ និងថាមពលស៊ីនេទិចអតិបរិមារបស់ពួកវាគួរតែកើនឡើង ព្រោះការកើននៃអាំងតង់ស៊ីតេមានន័យថាអំព្លីទុតនៃដែនអគ្គិសនីកាន់តែធំ ហើយបើដែនអគ្គិសនីកាន់តែធំវាគួរតែផ្តាច់អេឡិចត្រុងចេញដោយមានល្បឿនកាន់តែធំ។

២. ប្រេកង់នៃពន្លឺមិនគួមានឥទ្ធិពលលើថាមពលស៊ីនេទិចអតិបរិមារបស់ផូតូអេឡិចត្រុងទេ។ មានតែអាំងតង់ស៊ីតេទេទើបមានឥទ្ធិពលលើថាមពលស៊ីនេទិចអតិបរិមា។

ទ្រឹស្តីផូតុងគឺខុសគ្នាទាំងស្រុងពីការព្យាករខាងលើ។ ទីមួយ គេគត់សម្គាល់ថាក្នុងបាច់នឺម៉ូណូក្រូម៉ាទិចគ្រប់ផូតុងមានថាមពលដូចគ្នា($hf$)។ ការបង្កើនអាំងតង់ស៊ីតេនៃបាច់ពន្លឺមានន័យថាបង្កើនចំនួនផូតុងក្នុងបាច់ពន្លឺ ប៉ុន្តែមិនមានឥទ្ធិពលអ្វីលើថាមពលរបស់ផូតុងនីមួយៗទេ បើប្រេកង់មិនប្រែប្រួល។ តាមទ្រឹស្តីរបស់អាញស្តាញ អេឡិចត្រុងមួយត្រូវបានផ្តាច់ចេញពីផ្ទៃលោហៈ គឺដោយសាការទង្គិចជាមួយផូតុងទោលមួយ។ ក្នុងដំណើរការនេះ ថាមពលនៃផូតុងទាំងអស់ត្រូវបានផ្ទេរទៅឱ្យអេឡិចត្រុង ហើយផូតុងក៏បាត់លែងមាន។ អេឡិចត្រុងនីមួយៗដែលនៅក្នុងផ្ទៃលោហៈគឺដោយសាកំលាំងទំនាញ ដើម្បីផ្តាច់អេឡិចត្រុងចេញពីផ្ទៃលោហៈគឺត្រូវការថាមពលអប្បរមា $W_0$ ហៅថាកម្មន្តទំនាញយក ដែលមានតម្លៃប្រហែលពីរឬបីអេឡិចត្រុងវ៉ុលចំពោះលោហៈភាគច្រើន។ បើប្រេកង់នៃពន្លឺចាំងប៉ះ មានតម្លៃតូច គឺថា $hf$ តូចជាង $W_0$ នោះផូតុងនឹងមិនមានថាមពលគ្រប់គ្រាន់ដើម្បីផ្តាច់អេឡិចត្រុងបានទេ។ បើសិនជា $hf > W_0$ នោះអេឡិចត្រុងត្រូវបានផ្តាច់ចេញ ហើយថាមពលត្រូវបានរក្សាក្នុងប្រត្តិបតិការនេះ។ គឺថា ថាមពលដែលបានផ្តល់ឱ្យ $hf$ នឹងស្មើថាមពលស៊ីនេទិចអតិបរមារបស់អេឡិចត្រុងបូកថាមពលដែលត្រូវការសម្រាប់ផ្តាច់អេឡិចត្រុងចេញពីផ្ទៃលោហៈ $W_0$ ។

$$hf = K_{max} + W_0 \quad (២.៩)$$

ចេញពីការពិនិត្យខាងលើ ទ្រឹស្តីផូតុងធ្វើការព្យាករដូចខាងក្រោម

១. ការកើនឡើងនៃអាំងតង់ស៊ីតេរបស់បាច់ពន្លឺមានន័យថាមានផូតុងកាន់តែច្រើនប៉ះនឹងបន្ទះលោហៈ ដូច្នេះអេឡិចត្រុងកាន់តែច្រើនត្រូវបានផ្តាច់ចេញ ប៉ុន្តែដោយសាថាមពលរបស់ផូតុងនីមួយៗមិនបានប្រែប្រួល ថាមពលស៊ីនេទិចអតិបរមារបស់អេឡិចត្រុងក៏មិនប្រែប្រួលដោយសាការកើនឡើងនៃអាំងតង់ស៊ីតដែរ។

២. បើសិនជាប្រេកង់នៃពន្លឺកើនឡើង ថាមពលស៊ីនេទិចអតិបរមារបស់អេឡិចត្រុងកើនឡើងជាលីនេអ៊ែរ តាមសមីការ ២.១០ ដែលពីសមីការ ២.៩ គេបាន

$$K_{max} = hf - W_0 \quad (២.១០)$$

ទំនាក់ទំនងក្នុងសមីការ ២.១០ គឺត្រូវបានបង្ហាញដោយក្រាបក្នុងរូបទី ២.៦

៣. ប្រេកង់មានតម្លៃតូចជាងតម្លៃក្រិត (cutoff frequency) $f_0$ ដែល $hf_0 = W_0$ គឺមិនមានអេឡិចត្រុងត្រូវបានផ្តាច់ចេញទេ មិនថាអាំងតង់ស៊ីតេពន្លឺធំយ៉ាងណាក៏ដោយ។

ការព្យាកររបស់ទ្រឹស្តីផូតុង គឺខុសគ្នាពីការព្យាកររបស់ទ្រឹស្តីរលក។




រូបទី ២.៦៖ ផលផូតូអគ្គិសនី: ថាមពលស៊ីនេទិចអតិបរមារបស់អេឡិចត្រុងកើនឡើងជាលីនេអ៊ែរជាមួយប្រេកង់នៃពន្លឺចាំងប៉ះ។ មិនមានអេឡិចត្រុងខ្ទាតចេញទេបើ $f < f_0$ ។

ឧទាហរណ៍៖ គណនាថាមពលរបស់ផូតុងនៃពន្លឺព័ណខៀវ មានជំហានរលក $\lambda = 450$ nm ក្នុងខ្យល់។

ដំណោះស្រាយ៖ ថាមពលរបស់ពន្លឺព៌ណខៀវគឺ

$$E = hf \quad \text{តែ} \quad f = c/\lambda$$

$$E = hf = \frac{hc}{\lambda} = \frac{(6.63 \times 10^{-34}\ \text{Js})(3.0 \times 10^{8}\ \text{m/s})}{(4.5 \times 10^{7}\ \text{m})} = 4.4 \times 10^{-19}\ \text{J}$$

$$E = \frac{4.4 \times 10^{-19}\ \text{J}}{1.6 \times 10^{-19}\ \text{J}/eV} = 2.8\ \text{eV}$$

ឧទាហរណ៍៖ ផ្ទៃរបស់សូដ្យូមមួយត្រូវបានបញ្ចាំងពន្លឺដែលមានជំហានរលក 300 nm ។ កម្មន្តទំនាញយករបស់សូដ្យូមគឺ 2.46 eV ។

ក. គណនាថាមពលស៊ីនេទិចអតិបរមារបស់ផូតូអេឡិចត្រុង ?

ខ. រកតម្លៃកម្រិតនៃជំហានរលក ( cutoff wavelength ) $\lambda_0$ ?

ដំណោះស្រាយ៖ ក. ថាមពលស៊ីនេទិចអតិបរមា

ថាមពលរបស់ផូតុងនីមួយៗគឺ $E = hf = hc/\lambda$

ថាមពលស៊ីនេទិចអតិបរមាគឺ

$$K_{max} = \frac{hc}{\lambda} - W_0 = \frac{6.626 \times 10^{-34}\ \text{Js} \times 3 \times 10^{8}\text{ms}^{-1}}{300\ \text{nm}} - 2.46\ \text{eV}$$

$$K_{max} = 6.626 \times 10^{-19} J - 2.46\ \text{eV} = 4.14\ \text{eV} - 2.46\ \text{eV} = 1.68\ \text{eV}$$

ខ. តម្លៃកម្រិតនៃជំហានរលក

$$hf_0 = W_0 \quad \text{ឬ} \quad \frac{hc}{\lambda_0} = W_0$$

$$\lambda_0 = \frac{hc}{W_0} = \frac{6.626 \times 10^{-34}\ \text{Js} \times 3 \times 10^{8}\ \text{ms}^{-1}}{2.46\ \text{eV}} = \frac{12.4237 \times 10^{-7}\ \text{eVm}}{2.46\ \text{eV}} = 5.05 \times 10^{-7}\ \text{m}$$

## 2.3 ផលកំតុង ( Compton Effect )៖

ឆ្នាំ១៩១៩ លោកអាញស្តាញបានសន្និដ្ឋានថា ផូតុងមានថាមពល $E$ ផ្លាស់ទីក្នុងទិសដៅតែមួយ ហើយមានបរិមាណចលនាស្មើនឹង $P = E/c$ ។ មុនឆ្នាំ១៩២២ លោកកំតុង និងសហការីរបស់គាត់បាន

ប្រមូលភស្តុតាងជាច្រើនមកបង្ហាញថា ទ្រឹស្តីរលកនៃពន្លឺគឺមិនអាចពន្យល់ពីការទង្គិចខ្ចាយរបស់កាំរស្មី X ពីអេឡិចត្រុង( scattering X rays from electron )។

ពេលកាំរស្មី X ទៅទង្គិចជាមួយនឹងរូបធាតុ កាំរស្មីខ្លះត្រូវខ្ចាតខ្ចាយ( scattered )។ លោកកំតុងបានរកឃើញថាកាំរស្មីដែលបានខ្ចាតខ្ចាយមានប្រេកង់តូចជាង( ជំហានរលកធំ ) កាំរស្មីចាំងប៉ះ ហើយបម្រែបម្រួលជំហានរលកគឺអាស្រ័យនឹងមុំដែលកាំរស្មីបានខ្ចាតចេញ។ ជាពិសេស បើកាំរស្មីដែលខ្ចាតចេញបង្កើតបានមុំ $\emptyset$ ធៀបនឹងទិសដៅនៃកាំរស្មីចាំងប៉ះ(រូប២.៧) ហើយបើ $\lambda$ និង $\lambda'$ គឺជាជំហានរលករបស់កាំរស្មីចាំងប៉ះ និងកាំរស្មីខ្ចាត គេបាន




រូបទី ២.៧៖ ការពិសោធន៍ពីផលកំតុង។

$$\lambda' - \lambda = \frac{h}{mc}(1 - \cos\emptyset) \qquad (២.១១)$$

ដែល $m$ ជាម៉ាសរបស់អេឡិចត្រុងនៅនឹង។ ទំហំ $h/mc$ ដែលមាននៅក្នុងសមីការ ២.១១ មានខ្នាតជាខ្នាតប្រវែង ហៅថាជំហានរលកកំតុង $\lambda_C$ (C=Compton) ហើយតម្លៃរបស់វាគឺ

$$\frac{h}{mc} = \frac{6.626 \times 10^{-34}\ \mathrm{J.s}}{(9.109 \times 10^{-31}\ \mathrm{kg})(2.998 \times 10^{8}\ \mathrm{m/s})} = 2.426 \times 10^{-12}\ \mathrm{m}$$

គេមិនអាចពន្យល់ភាពរាយប៉ាយ ឬការទង្គិចខ្ចាយរបស់កំតុង( ផលកំតុង )ដោយប្រើទ្រឹស្តីបុរាណនៃរលកអេឡិចត្រូម៉ាញេទិចបានទេ ដែលទ្រឹស្តីនេះបានគិតថាចំហានរលករបស់កាំរស្មីចាំងប៉ះ និងជំហានរលករបស់កាំរស្មីខ្ចាតចេញក្រោយទង្គិចស្មើគ្នា។ ម្យ៉ាងទៀត ទ្រឹស្តីកង់ទិចបានផ្តល់នូវការពន្យល់យ៉ាងច្បាស់មួយ។ គេសន្មត

ថាដំណើការនៃទង្គិចខ្ចាយ( scattering process )ខាងលើគឺត្រូវប្រដូចទៅនឹងទង្គិចរវាងភាគល្អិតពីរ គឺផូតុងផ្លាស់ទី និងអេឡិចត្រុងនៅស្ងៀម រូប២.៨ ក។ ផូតុងដែលផ្លាស់ទីទៅទង្គិចនឹងអេឡិចត្រុង បានផ្តល់ថាមពល និងបរិមាណចលនារបស់វាមួយចំនួនទៅឱ្យអេឡិចត្រុង ជាលទ្ធផលនៃទង្គិច ថាមពល និងបរិមាណចលនារបស់ផូតុងថយចុះ។ ដូច្នេះបើថាមពលថយចុះ នោះប្រេកង់ក៏ថយចុះ ហើយជំហានរលកកើនឡើងធំជាងផូតុងមុនទង្គិច រូប ២.៨ ខ។




រូបទី ២.៨៖ ដ្យាក្រាមផលកំតុង (ក)មុនទង្គិច (ខ) ក្រោយទង្គិចផូតុងផ្លាស់ទីក្នុងទិសដៅបង្វើតបាន មុំ $\emptyset$ ធៀបនឹងទិសដៅដើម (គ) ដ្យាក្រាមបង្ហាញពីការរក្សាបរិមាណចលនាក្នុងទង្គិច។

គេអាចបកស្រាយសមីការ២.១១ ចេញពីគោលការណ៍រក្សាថាមពល និងបរិមាណចលនា។ ថាមពលទង្គិចរបស់អេឡិចត្រុងអាចស្ថិតក្នុងចង្កោមនៃទ្រឹស្តីធៀប ដូច្នេះគេប្រើទំនាក់ទំនងថាមពល បរិមាណចលនាក្នុងទ្រឹស្តីធៀប។ ផូតុងចាំងប៉ះមានបរិមាណចលនា $P$ និងថាមពល $E = Pc$ ។ ក្រោយទង្គិចផូតុងមានបរិមាណចលនា $P'$ និងថាមពល $E' = P'c$ ។អេឡិចត្រុងមុនទង្គិចនៅនឹងមានថាមពល $mc^2$ ។ ក្រោយទង្គិចអេឡិចត្រុងមានថាមពល

$$E_e^2 = (mc^2)^2 + (P_e c)^2$$

ច្បាប់រក្សាថាមពល

$$Pc + mc^2 = P'c + E_e$$

$$Pc - P'c + mc^2 = E_e$$

$$(Pc - P'c + mc^2)^2 = E_e^2 = (mc^2)^2 + (P_e c)^2 \qquad (២.១២)$$

តាមច្បាប់រក្សាបរិមាណចលនា រូប ២.៨ គ

$$\vec{P} = \vec{P'} + \vec{P_e}$$

(២.១៣)

$$\vec{P_e} = \vec{P} - \vec{P'}$$

ធ្វើផលគុណស្កាលែនៃវ៉ិចទ័រទៅលើអង្គទាំងសងខាងនៃសមីការ ២.១៣ គេបាន

$$\vec{P_e}.\vec{P_e} = (\vec{P} - \vec{P'}).\vec{P_e} = (\vec{P} - \vec{P'}).(\vec{P} - \vec{P'})$$

$$\vec{P_e}.\vec{P_e} = \vec{P}.\vec{P} - \vec{P'}.\vec{P} - \vec{P'}.\vec{P} + \vec{P'}.\vec{P'}$$

$$P_e^2 \cos 0° = P^2 \cos 0° - P'P \cos \emptyset - P'P \cos \emptyset + {P'}^2 \cos 0°$$

$$P_e^2 = P^2 + {P'}^2 - 2P'P \cos \emptyset \qquad (២.១៤)$$

ជំនួសសមីការ ២.១៤ចូលក្នុងសមីការ ២.១២

$$(Pc - P'c + mc^2)^2 = (mc^2)^2 + c^2\left(P^2 + {P'}^2 - 2P'P \cos \emptyset\right)$$

$$(Pc - P'c + mc^2)(Pc - P'c + mc^2) = m^2c^4 + c^2P^2 + c^2{P'}^2 - 2c^2P'P \cos \emptyset$$

$$c^2P^2 - PP'c^2 + Pmc^3 - PP'c^2 + c^2{P'}^2 - P'mc^3 + Pmc^3 - P'mc^3 + m^2c^4$$
$$= m^2c^4 + c^2P^2 + c^2{P'}^2 - 2c^2P'P \cos \emptyset$$

$$-2PP'c^2 + 2Pmc^3 - 2P'mc^3 = -2c^2P'P \cos \emptyset$$

$$-PP' + Pmc - P'mc = -P'P \cos \emptyset$$

ចែកអង្គទាំងសងខាងនឹង $PP'$

$$-1 + \frac{mc}{P'} - \frac{mc}{P} = -\cos \emptyset \qquad (២.១៥)$$

ដោយ $E = hf = hc/\lambda$ និង $P = E/c$ គេបាន $P = h/\lambda$ តាមសមីការ ២.១៥ គេអាចសរសេរ

$$\frac{mc\lambda'}{h} - \frac{mc\lambda}{h} = 1 - \cos\emptyset$$

$$\lambda' - \lambda = \frac{h}{mc}(1 - \cos\emptyset) \qquad (២.១៦)$$

ដោយ $E = hf = hc/\lambda$ សមីការ ២.១៦ អាចសរសេរ

$$\frac{1}{E'} - \frac{1}{E} = \frac{1}{mc^2}(1 - \cos\emptyset) \qquad (២.១៧)$$

ដែល $\lambda$ ជាជំហានរលករបស់ផូតុងមុនទង្គិច $\lambda'$ ជាជំហានរលករបស់ផូតុងក្រោយទង្គិច។ សមីការ ២.១៦ និង ២.១៧ បង្ហាញពីបម្រែបម្រួលជំហានរលក និងបម្រែបម្រួលថាមពលរបស់ផូតុងជាអនុគមន៍នៃមុំខ្ចាត $\emptyset$ (Scattering angle)។ ដោយសារតែផ្នែកខាងស្ដាំនៃសមីការមិនអាចអវិជ្ជមាននោះ $E'$ តែងតែតូចជាង $E$ ឬក៏ $\lambda'$ តែងតែធំជាង $\lambda$ ដូច្នេះផូតុងក្រោយទង្គិចមានថាមពលតូចជាងមុនទង្គិច។ ផលសងថាមពល $E - E'$ គឺជាថាមពលស៊ីនេទិចដែលផ្តល់ឱ្យអេឡិចត្រុង។ ដូចគ្នាដែរ $\lambda'$ តែងតែធំជាង $\lambda$ មានន័យថាផូតុងខ្ចាតចេញក្រោយទង្គិចវែងជាងជំហានរលករបស់ផូតុងមុនទង្គិច។ បម្រែបម្រួលជំហានរលកគឺស្ថិតក្នុងចន្លោះពី សូន្យកាលណាមុំ $\emptyset = 0°$ ទៅពីរកាលណាមុំ $\emptyset = 180°$ ។

លទ្ធផលនៃពិសោធន៍របស់លោក កំតុង បានបង្ហាញដូចរូបទី ២.៩ ។ នៅតម្លៃរបស់មុំនីមួយៗ កំពូលនៃខ្សែកោងពីរបានលេចឡើង ដែលឆ្លើយតបនឹងការខ្ចាតចេញរបស់ផូតុងនៃកាំរស្មី X ត្រូវនឹងភាពខុសគ្នាពីរនៃថាមពល ឬជំហានរលក។ ខ្សែកោងនៃជំហានរលកមានកំពូលមិនប្រែប្រួលទេនៅខណៈដែលមុំប្រែប្រួល កំពូលនេះត្រូវនឹងការខ្ចាតដែលទាក់ទងនឹងអេឡិចត្រុងស្ថិតនៅស្រទាប់ក្នុងនៃអាតូម ដែលចងសម្ព័ន្ធយ៉ាងរឹងមាំក្នុងអាតូម ដូច្នេះផូតុងអាចខ្ចាតដោយគ្មានបាត់បង់ថាមពល។ កំពូលខ្សែងកោងនៃជំហានរលកផ្សេងទៀត ប្រែប្រួលខ្លាំងជាមួយមុំ។




រូបទី ២.៩៖ ក្រាបនៃអាំងតង់ស៊ីតេ និងជំហានរលក ចំពោះផលកំតុងត្រូវនឹងតម្លៃមុំមួយចំនួន។ កំពូលខាងឆ្វេងក្នុងករណីនីមួយៗ គឺជាលទ្ធផលនៃផូតុងដែលខ្ចាតដោយសារអេឡិចត្រុងមានសម្ព័នយ៉ាងរឹងមាំក្នុងអាតូម។

ដោយប្រើថាមពលសរុបរបស់អេឡិចត្រុងតាមរូបមន្តក្នុងទ្រឹស្តីធៀប $E_e = K + mc^2$ ដែល $K$ ជាថាមពលស៊ីនេទិចរបស់អេឡិចត្រុង។ ច្បាប់រក្សាថាមពលគេបាន ថាមពលសរុបមុនទង្គិច $(E + mc^2)$និងថាមពលសរុបក្រោយទង្គិច$(E' + E_e)$ស្មើគ្នា គេបាន

$$E + mc^2 = E' + E_e$$

$$E + mc^2 = E' + K + mc^2$$

$$K = E - E' \qquad (២.១៨)$$

សមីការ ២.១៨ ជាថាមពលស៊ីនេទិចដែលអេឡិចត្រុងទទួលបាន។

ទិសដៅដែលអេឡិចត្រុងបានចេញខ្ចាតដូចរូប ២.១០ គេបាន

តាមច្បាប់រក្សាបរិមាណចលនា

ចំពោះអ័ក្សដេក៖ $P = P' \cos\emptyset + P_e \cos\theta$ នាំឱ្យ $P_e \cos\theta = P - P' \cos\emptyset$

ចំពោះអ័ក្សឈរ៖ $0 = P' \sin\emptyset - P_e \sin\theta$ ឬ $P_e \sin\theta = P' \sin\emptyset$

ទិសដៅដែលអេឡិចត្រុងខ្ទាតគឺ

$$\tan\theta = \frac{P_e \sin\theta}{P_e \cos\theta} = \frac{P' \sin\emptyset}{P - P' \cos\emptyset} = \frac{E' \sin\emptyset}{E - E' \cos\emptyset} \qquad (២.១៩)$$

ព្រោះ $E = Pc, E' = P'c$




រូបទី ២.១០៖ ដ្យាក្រាមតាងឱ្យកូអរដោនេនៃវ៉ិចទ័របរិមាណចលនារបស់ផូតុង និងអេឡិចត្រុង។

ឧទាហរណ៍៖ កាំរស្មី X មានជំហានរលក 0.2400 nm រងនូវផលកំតុង ហើយកាំរស្មីដែលខ្ទាតចេញបង្កើតបានមុំ 60.0° ជាមួយទិសដៅរបស់កាំរស្មីចាំងប៉ះ។ ក. រកជំហានរលកកាំរស្មីដែលបានខ្ទាតចេញ? ខ. រកថាមពលរបស់ផូតុងនៃកាំរស្មី X ដែលខ្ទាតនោះ? គ. រកថាមពលស៊ីនេទិចរបស់អេឡិចត្រុងដែលបានខ្ទាតចេញ? ឃ. រកទិសដៅដែលអេឡិចត្រុងបានខ្ទាតទៅ?

ដំណោះស្រាយ៖ ក. ជំហានរលកនៃកាំរស្មីដែលបានខ្ទាតនោះ

តាមរូបមន្តផលកំតុង

$$\lambda' - \lambda = \frac{h}{mc}(1 - \cos\emptyset)$$

$$\lambda' = \lambda + \frac{h}{mc}(1 - \cos\emptyset) = 0.2400\ \text{nm} + 0.00243\ \text{nm}(1 - \cos 60.0°) = 0.2412\ \text{nm}$$

ខ. ថាមពលផូតុងដែលខ្ចាតនោះ $E'$

តាមរូបមន្ត

$$E' = \frac{hc}{\lambda'} = \frac{6.626\ \times 10^{-34}\ \text{Js} \times 3 \times 10^{8}\ \text{m/s}}{0.2412\ \text{nm}}$$

$$E' = \frac{(6.626 \times 10^{-34}/1.6 \times 10^{-19})eV \times 3 \times 10^{17}\ \text{nm}}{0.2412\ \text{nm}} = \frac{12.423 \times 10^{2}\ \text{eV.nm}}{0.2412\ \text{nm}} = 5150\ \text{eV}$$

គ. ថាមពលស៊ីនេទិចរបស់អេឡិចត្រុង $K$

ថាមពលកាំរស្មីជាំងប៉ះ $E = hc/\lambda = (6.626\ \times 10^{-34}\ \text{Js} \times 3 \times 10^{8}\ \text{m/s})/0.2400\ \text{nm}$

$$E = 5176\ \text{eV}$$

ថាមពលស៊ីនេទិចរបស់អេឡិចត្រុងគឺ $K = E - E' = 5176\ \text{eV} - 5150\ \text{eV} = 26\ \text{eV}$

ឃ. ទិសដៅដែលអេឡិចត្រុងខ្ចាតចេញទៅ

តាមរូបមន្ត៖

$$\tan\theta = \frac{E'\sin\emptyset}{E - E'\cos\emptyset} = \frac{(5150\ \text{eV})\sin 60°}{5176\ \text{eV} - (5150\ \text{eV})\cos 60°} = 1.714$$

$$\theta = \tan^{-1} 1.714 = 59.7°$$

## 2.4 ធម្មជាតិនៃរលកអេឡិចត្រូម៉ាញេទិច៖

បាតុភូតផលផូតូអគ្គិសនី និងផលកំតុងបានផ្តល់ភស្តុតាងយ៉ាងច្បាស់លាស់ថា ពេលពន្លឺ(ឬទំរង់ផ្សេងៗនៃការបញ្ចេញរស្មីលកអេឡិចត្រូម៉ាញេទិច) និងរូបធាតុមានអន្តរកម្មជាមួយគ្នា ពន្លឺដែលដាលទៅគឺជាលំហូរនៃភាគល្អិតមានថាមពល $hf$ និងបរិមាណចលនា $h/\lambda$ ។ ដូចនេះពន្លឺជាភាគល្អិត ឬហៅថាផូតុង តែពេលខ្លះពន្លឺមានអាំងទែផេរ៉ង់ និងឌីប្រាក់ស្យុង ដែលបាតុភូតទាំងនេះកើតឡើងចំពោះតែរលក។ ដូចនេះពេលនេះពន្លឺគឺជារលក។ តើមួយណាត្រឹមត្រូវ? តើពន្លឺជារលក ឬជាភាគល្អិត? ចម្លើយគឺថា វាអាស្រ័យនឹងបាតុភូតដែលត្រូវសង្កេត។ ពិសោធន៍ខ្លះត្រូវបានពន្យល់ដោយលក្ខណៈជាភាគល្អិត ឬផូតុង ហើយខ្លះទៀតត្រូវបានពន្យល់ដោយលក្ខណៈជារលក។ គេត្រូវតែទទួលយកលក្ខណៈទាំងពីររបស់ពន្លឺ ហើយព្រមទទួលថាការពិតនៃធម្មជាតិរបស់ពន្លឺគឺមិនអាចព៌ណនាក្នុងទំរង់(ភាគល្អិត ឬរលក)តែមួយបានទេ។ បាច់ពន្លឺដូចគ្នាតែមួយ ដែល

អាចផ្តាច់ផូតូអេឡិចត្រុងពីផ្ទៃលោហៈ (មានន័យថាបាច់ពន្លឺមានផូតុង) ហើយក៏អាចមានឌីប្រាក់ស្យុងបានដែរ(មានន័យថាបាច់ពន្លឺជារលក)។

## 2.5 លក្ខណៈរលករបស់ភាគល្អិតៈ

ក្នុងមជ្ឈដ្ឋានជុំវិញយើង ដែលជួបប្រទះរាល់ថ្ងៃ គឺបានចាត់ទុក និងទទួលស្គាល់ថាបឃ្លីគឺជាភាគល្អិតយ៉ាងពិតប្រាកដ ហើយរលកសូរគឺជាទំរង់នៃចលនារលកយ៉ាងច្បាស់លាស់។ ចំពោះការសង្កេតវត្ថុមានទំហំធំគឺអាចត្រូវបានបកស្រាយដោយការប្រើលក្ខណៈជារលកមកពន្យល់ ឬលក្ខណៈជាភាគល្អិតមកពន្យល់ ប៉ុន្តែក្នុងពិភពផូតុង និងអេឡិចត្រុង គឺមិនអាចញែកឱ្យដាច់ពីគ្នាច្បាស់លាស់ទេ។

កាន់តែរំជើបរំជួលថែមទៀតនោះគឺថា ក្នុងលក្ខខណ្ឌជាក់លាក់ណាមួយ វត្ថុដែលយើងបានកំណត់ន័យយ៉ាងច្បាស់លាស់ថាភាគល្អិត បានបង្ហាញឱ្យឃើញនូវលក្ខណៈរលក។ ក្នុងឆ្នាំ ១៩២៣ និក្ខេបទបញ្ចប់ថ្នាក់បណ្ឌិត លោក Louis de Broglie បានដាក់នូវសម្មតិកម្មថា ព្រោះផូតុងមានទាំងពីរលក្ខណៈ ជារលកនិងភាគល្អិត ដូច្នេះប្រហែលជាគ្រប់ទម្រង់នៃរូបធាតុមានលក្ខណៈទាំងពីរនេះ។ នេះគឺជាការបដិវត្តគំនិតយ៉ាងខ្ពស់មួយដែលមិនទាន់មានពិសោធន៍ដើម្បីបញ្ជាក់នៅក្នុងពេលនោះ។

ផូតុងមានថាមពលកំណត់តាមរូបមន្តអាញស្តាញគឺ $E = Pc$ និង $E = hf$ ហើយប្រេកង់ $f = c/\lambda$ គេបានបរិមាណចលនាគឺ

$$P = \frac{h}{\lambda}$$

សមីការនេះបង្ហាញថាជំហានរលករបស់ផូតុងអាចត្រូវបានបង្ហាញយ៉ាងច្បាស់ដោយបរិមាណចលនា $\lambda = h/P$ ។ Louis de Broglie បានស្នើឡើងថា បរិមាណចលនា $P$ របស់ភាគល្អិតនៃសារធាតុ មានលក្ខណៈនៃជំហានរលកដែលឱ្យដោយកន្សោមដូចគ្នា។ ដោយសារម៉ូឌុលនៃបរិមាណចលនារបស់ភាគល្អិតមានម៉ាស $m$ និងល្បឿន $u$ គឺ $P = mu$ គេបានជំហានរលក Louis de Broglie របស់ភាគល្អិតគឺ

$$\lambda = \frac{h}{P} = \frac{h}{mu} \qquad (២.២០)$$

ម្យ៉ាងវិញទៀត ស្រដៀងនឹងផូតុង លោក Louis de Broglie បានដាក់សម្មតិកម្មថា ភាគល្អិតទាំងឡាយគោរពតាមទំនាក់ទំនងរបស់អាញស្តាញ $E = hf$ ដែល $E$ ជាថាមពលសរុបរបស់ភាគល្អិត។ ប្រេកង់របស់ភាគល្អិតគឺ

$$f = \frac{E}{h} \qquad (២.២១)$$

លក្ខណៈទ្វេរភាពនៃរូបធាតុគឺបានបង្ហាញក្នុងសមីការ ២.២០ និង ២.២១ ព្រោះសមីការទាំងពីរមានទំហំដែលសម្គាល់ថាជាភាគល្អិត( $P$ និង $E$ ) និងទំហំដែលសម្គាល់ថាជារលក( $\lambda$ និង $f$ )។

## 2.6 ភាគល្អិតកង់ទិច

ក្នុងចំនុចមុន គេបានពិនិត្យឃើញថាមានភាពខុសគ្នារវាងគំរូភាគល្អិត និងគំរូរលក ហើយការវែកញែកបានក្លាយជាកង្វល់មួយ។ ទស្សនៈដែលថាទាំងពន្លឺទាំងភាគល្អិតនៃរូបធាតុមានលក្ខណៈជាភាគល្អិតផង និងលក្ខណៈជារលកផងគឺមិនសមស្របជាមួយនឹងភាពខុសគ្នានេះទេ។ ការព្រមទទួលយកនៃលក្ខណៈទ្វេរភាពរបស់ធម្មជាតិ( លក្ខណៈជារលកផង និងជាភាគល្អិតផង ) នាំទៅដល់គំរូថ្មីមួយ ហៅថា ភាគល្អិតកង់ទិច ដែលជាបន្សំរវាងគំរូភាគល្អិត និងគំរូរលក។

ក្នុងចំនុចនេះ គេនឹងរកឱ្យឃើញថាគំរូថ្មីនេះអាចធ្វើឱ្យអ្នកកាន់តែមានភាពងាយស្រួលយល់ពីទស្សនៈដែលថាទាំងពន្លឺទាំងភាគល្អិតនៃរូបធាតុមានលក្ខណៈជាភាគល្អិតផង និងលក្ខណៈជារលកផង ដោយការបកស្រាយដោយឡែកមួយពីលក្ខណៈរបស់ភាគល្អិតមួយអាចត្រូវបានផ្សំពីរលកជាច្រើន។

ដំបូងសូមចាំពីលក្ខណៈនៃរលក និងភាគល្អិត។ លក្ខណៈពិសេសរបស់ភាគល្អិតគឺថា វាស្ថិតក្នុងទីតាំងឬតំបន់មួយច្បាស់លាស់ ក្នុងលំហ( it is localized in space ) ។ ហើយរលកមានប្រេកង់ និងមានប្រវែងមិនអាចកំណត់បានដូចក្នុងរូបទី ២.១១ ក។ ដូច្នេះរលកគឺមិនអាចមានទីតាំង ឬកំណត់កន្លែងច្បាស់លាស់ទេក្នុងលំហ( it is unlocalized in space )។ ការកំណត់កន្លែង ឬទីតាំងដោយឡែកមួយអាចត្រូវបានបង្កើតឡើងពីរលកយ៉ាងវែងមិនកំណត់ដូចខាងក្រោម។ ឧបមាថា គេគូបានទម្រង់នៃរលកមួយតាមអក្ស $x$ ដោយខ្នងនៃរលកត្រង់ទីតាំង $x = 0$ ដូចបង្ហាញក្នុងរូបទី២.១១ខ ផ្នែកខាងលើ។ បន្ទាប់មកគូសរលកទីពីរ មានអំព្លីទុតដូចគ្នា និងខ្នងរលកលត្រង់ទីតាំង $x = 0$ តែប្រេកង់ខុសគ្នា។ ជាលទ្ធផលនៃតម្រួតរលក គឺមានប៊ីត( beat ) កើតឡើងខណៈដែលរលកទាំងពីរឆ្លាស់គ្នារវាងស្របផាស និងផ្ទុយផាស។




រូបទី ២.១១៖ ក. រលកមួយមានប្រេកង់ទោល គឺដូចគ្នាក្នុងលំហាទាំងមូល និងគ្រប់ពេល។ ខ. បើរលកពីរមានប្រេកង់ខុសគ្នាបន្តិចបន្តួច ត្រូវបានបញ្ចូលគ្នា នោះលទ្ធផលគឺមានប៊ីត(beat)កើតឡើង។

រូបខាងក្រោមនៃរូបទី២.១១ ខ គឺជាលទ្ធផលនៃតម្រួតរលក។

គត់សម្គាល់ឃើញថារូបទី២.១១ខ បានបង្ហាញនូវការកំណត់តំបន់ខ្លះដោយតម្រួតនៃរលកពីរ។ រលកទោលអំព្លីទុតដូចគ្នាគ្រប់កន្លែងក្នុងលំហ គឺមិនមានជាចំនុចក្នុងលំហទេ។ ដោយបន្ថែមនូវរលកទីពីរ ឃើញថាមានភាពខុសគ្នាអំពីចំនុចដែលរលកទាំងពីរស្រផាស និងចំនុចដែលរលកទាំងពីផ្ទុយផាសគ្នា។

ឥឡូវឧបមាថា បន្ថែមរលកកាន់តែច្រើនទៅលើរលកទាំងពីរខាងដើម ដែលរលកថ្មីនីមួយៗមានប្រេកង់ថ្មីមួយ។ រលកថ្មីនីមួយៗដែលត្រូវបានបន្ថែមមានខ្នងរលកត្រង់ $x = 0$ ជាលទ្ធផលគឺមានអាំងទែផេរ៉ង់អតិបរមាត្រង់ $x = 0$ ។ ពេលគេបន្ថែមរលកយ៉ាងច្រើន ប្រូបាប៊ីលីតេនៃតម្លៃវិជ្ជមានរបស់អនុគមន៍រលកនៅទីតាំងណាមួយ $x \neq 0$ គឺស្មើនឹងប្រូបាប៊ីលីតេនៃតម្លៃអវិជ្ជមានរបស់អនុគមន៍រលក ហើយមានអាំងទែផេរ៉ង់បំផ្លាញ (destructive interference)គ្រប់កន្លែងលើកលែងត្រង់ $x = 0$ ដែលខ្នងរលកទាំងអស់ត្រូវបានតម្រួតគ្នា។ លទ្ធផលត្រូវបានបង្ហាញក្នុងរូប ២.១២។ អាំងទែផេរ៉ង់សង់(constructive interference)ក្នុងតំបន់តូចមួយហៅថា កញ្ចប់រលក(wave packet)។ នេះជាតំបន់បានកំណត់ក្នុងលំហ ដែលខុសពីតំបន់ផ្សេងៗទៀតទាំងអស់។ គេអាចបញ្ជាក់បានថាកញ្ចប់រលកគឺដូចនឹងភាគល្អិត ព្រោះវាមានទីតាំង ឬការកំណត់តំបន់ដែលវាតាំង

នៅ(ឬ localize)ដែលជាលក្ខណៈធម្មជាតិនៃភាគល្អិត។ តំបន់នៃកញ្ចប់រលកគឺត្រូវនឹងទីតាំងរបស់ភាគល្អិត។




រូបទី២.១២៖ បើរលកមានចំនួនយ៉ាងច្រើន ត្រូវបានបញ្ចូលគ្នា លទ្ធផលគេទទួលបានកញ្ចប់រលក ដែលបង្ហាញថាជាភាគល្អិតមួយ។

គេអាចបកស្រាយពីតម្រួតនៃរលកតាមគណិតវិទ្យា ដោយពិនិត្យរលកពីរមានអំព្លីទុតស្មើគ្នាប៉ុន្តែប្រេកង់ខុសគ្នា។

$$y_1 = A\cos(k_1x - \omega_1 t)\ \ ;\ \ y_2 = A\cos(k_2x - \omega_2 t)$$

ដែល $k = 2\pi/\lambda$ និង $\omega = 2\pi f$ ដោយប្រើគោលការន៍តម្រួត

$$y = y_1 + y_2 = A\cos(k_1x - \omega_1 t) + A\cos(k_2x - \omega_2 t)$$

តាមរូបមន្តត្រីកោណមាត្រ

$$\cos a + \cos b = 2\cos\left(\frac{a-b}{2}\right)\cos\left(\frac{a+b}{2}\right)$$

ដោយតាង $a = k_1x - \omega_1 t\ ;\ b = k_2x - \omega_2 t$ គេបាន

$$y = 2a\cos\left[\frac{(k_1x - \omega_1 t) - (k_2x - \omega_2 t)}{2}\right]\cos\left[\frac{(k_1x - \omega_1 t) + (k_2x - \omega_2 t)}{2}\right]$$

$$y = \left[2A\cos\left(\frac{\Delta k}{2}x - \frac{\Delta\omega}{2}t\right)\right]\cos\left(\frac{k_1 + k_2}{2}x - \frac{\omega_1 + \omega_2}{2}t\right) \qquad (២.២២)$$

ដែល $\Delta k = k_1 - k_2\ ;\ \omega = \omega_1 - \omega_2$ ។ អនុគមន៍កូស៊ីនុសទី២នៃសមីការ ២.២២ បង្ហាញពីតម្លៃមធ្យមនៃចំនួនរលក និងប្រេកង់ របស់រលក ។

សមីការ ២.២២ កត្តាដែលនៅក្នុងឃ្នាបបង្ហាញពីស្រោមនៃរលក(envelope of the wave) ដូចបង្ហាញក្នុងរូប ២.១៣។ កត្តានោះក៏មានទម្រង់គណិតវិទ្យានៃរលកផងដែរ។ envelope(ស្រោមនៃរលក) នេះអាចដាលឆ្លងកាត់លំហដោយល្បឿនខុសពីល្បឿននៃរលកផ្គុំនីមួយៗ។ ឧទាហរណ៍ថា មានរលកផ្គុំពីរដូចគ្នាដាលក្នុងទិសដៅផ្ទុយគ្នា។ រលកផ្គុំទាំងពីរមានល្បឿនដូចគ្នា តែ envelope មានល្បឿនសូន្យព្រោះជារលកជញ្ជាំ។




រូបទី២.១៣៖ គំរូប៊ីត(beat)នៃរូប២.១១ខ ជាមួយ envelope (បន្ទាត់ដាច់ៗ)។

ចំពោះរលកផ្គុំនីមួយៗ ល្បឿនកំណត់ដោយ

$$v_{phase} = \frac{\omega}{k} \quad (២.២៣)$$

ល្បឿននេះហៅថាល្បឿនផាសព្រោះវាគឺជាអត្រានៃបម្លាស់ទីទៅមុខរបស់ខ្នងរលកនៃរលកទោលមួយ ដែលជាចំនុចមិនប្រែប្រួលផាស។

ដូចដែលបានពិភាក្សាពីខាងដើមថា ភាគល្អិតអាចត្រូវបានពន្យល់ថា ជាការផ្សំនៃរលកជាច្រើន ហៅថាកញ្ចប់រលក។ ហើយរលកផ្គុំនីមួយៗមានប្រេកង់ខុសគ្នាតិចតួច។ ដោយភាពស្រដៀងគ្នានេះ គេបានល្បឿននៃភាគល្អិតត្រូវបានហៅថា ល្បឿនក្រុម តាងដោយ $v_g$ ឬហៅល្បឿននៃកញ្ចប់រលក។

$$v_g = \frac{d\omega}{dk} \quad (២.២៤)$$

គុណភាគយក និងភាគបែង នឹង $\hbar$ ដែល $\hbar = h/2\pi$

$$v_g = \frac{\hbar d\omega}{\hbar dk} = \frac{d(\hbar\omega)}{d(\hbar k)} \quad (២.២៥)$$

$$\text{តែ}\quad \hbar\omega = \frac{h}{2\pi}(2\pi f) = hf = E$$

$$\text{ហើយ}\quad \hbar k = \frac{h}{2\pi}\left(\frac{2\pi}{\lambda}\right) = \frac{h}{\lambda} = P$$

សមីការ ២.២៥ អាចសរសេរ

$$v_g = \frac{d(\hbar\omega)}{d(\hbar k)} = \frac{dE}{dP} \qquad (២.២៦)$$

ដោយសាគេចង់រកឱ្យឃើញនូវលទ្ធភាពដែលថា envelope នៃតម្រួតរលកជាភាគល្អិត ដូច្នេះពិនិត្យភាគល្អិតសិរីមួយមានចលនាដោយល្បឿន $u$ ដែលមានតម្លៃតូចធៀបនឹងល្បឿនពន្លឺ។ ថាមពលរបស់ភាគល្អិតគឺជាថាមពលស៊ីនេទិចរបស់វា(ព្រោះភាគល្អិតសិរី)

$$E = \frac{1}{2}mu^2 = \frac{P^2}{2m}$$

ធ្វើដេរីវេសមីការនេះធៀបនឹង $P$ គេបាន $v_g$

$$v_g = \frac{dE}{dP} = \frac{d}{dP}\left(\frac{P^2}{2m}\right) = \frac{1}{2m}2P = u \qquad (២.២៧)$$

ដូចនេះ ល្បឿនក្រុមនៃកញ្ចប់រលកគឺដូចគ្នានឹងល្បឿនរបស់ភាគល្អិតដែរ ដែលផ្តល់នូវទំនុកចិត្តបន្ថែមទៀតថាកញ្ចប់រលកគឺជាមធ្យោបាយសមហេតុផលមួយសម្រាប់បង្កើតភាគល្អិតមួយ។

### ប៊ីត(Beat)

រលកផ្គួបក្នុងរូប២.១៤ ខ លើមទៅដូចជារលកស៊ីនុយសូអ៊ីតទោលមានអំព្លីទុតប្រែប្រួលពីអតិបរមាទៅសូន្យ និងពិសូន្យទៅអតិបរមា។ ក្នុងឧទាហរណ៍នេះ អំព្លីទុតប្រែប្រួលដោយមានចំនុចអតិបរមាពីរ និងអប្បរមាពីរក្នុងមួយវិនាទី ដូច្នេះប្រេកង់នៃបម្រែបម្រួលអំព្លីទុតគឺស្មើ 2 Hz ។ បម្រែបម្រួលអំព្លីទុតបណ្តាលឱ្យប្រែប្រួលអាំងតង់ស៊ីតេសូរ(Loudness) ហៅថា ប៊ីត ហើយប្រេកង់ដែលត្រូវនឹងអាំងតង់ស៊ីតេសូរប្រែប្រួលហៅថា ប្រេកង់ប៊ីត។ ក្នុងឧទាហរណ៍នេះប្រេកង់ប៊ីតគឺជាផលសងរវាងប្រេកង់នៃរលកផ្តុំ។

គេអាចបង្ហាញបានថាប្រេកង់ប៊ីតគឺតែងតែស្មើផលសងរវាងប្រេកង់នៃរលកផ្តុំទាំងពីរ $f_1$ និង $f_2$ ។ សន្មតថា $f_1$ ធំជាង $f_2$ ហើយខួបនៃរលកផ្តុំទាំងពីរគឺ $T_1$ និង $T_2$ ដែល $T_1 < T_2$ ។ បើរលកទាំងពីរចាប់ផ្តើម

ដោយស្របផាសគ្នានៅ $t = 0$ ពួកវានឹងស្របផាសម្តងទៀតនៅពេលរលកទីមួយជាលបានទៅច្រើនជាងរលកទីពីរមួយខួប( cycle )។ ទាំងនេះវាកើតឡើងនៅរយៈពេល $t$ ស្មើនឹង $T_{beat}$ ជាខួបរបស់ប៊ីត។ តាង $n$ ជាចំនួនខួប( Number of cycle )នៃរលកទីមួយក្នុងតយៈពេល $T_{beat}$ នោះចំនួនខួបនៃរលកទីពីរគឺ $(n-1)$ គេបានទំនាក់ទំនង




រូបទី២.១៩៖ ប៊ីតជាបម្រែបម្រួលអំព្លីទុតដែលបង្កើតដោយរលកសូរពីរមានប្រេកង់ខុសគ្នាបន្តិចបន្តួច(16 Hz, 18 Hz) ។ (ក). រលកផ្គុំ។ (ខ). រលកផ្គួបដែលកើតចេញពីតម្រួតនៃរលកផ្គុំទាំងពីរ។ ប្រេកង់ប៊ីតគឺ 18 Hz – 16 Hz = 2 Hz ។

$$T_{beat} = nT_1 \;;\quad T_{beat} = (n-1)T_2$$

បំបាត់ $n$ ចោលដោយប្រើទំនាក់ទំនងទាំងពីរ៖

$$n = \frac{T_{beat}}{T_1}$$

$$T_{beat} = \left(\frac{T_{beat}}{T_1} - 1\right) T_2$$

$$T_{beat} = \frac{T_{beat}T_2 - T_1T_2}{T_1}$$

$$T_{beat}T_1 = T_{beat}T_2 - T_1T_2$$

$$T_1T_2 = T_{beat}(T_2 - T_1)$$

$$T_{beat} = \frac{T_1T_2}{T_2 - T_1}$$

ដោយប្រេកង់ $f_{beat} = 1/T_{beat}$ គេបាន

$$f_{beat} = \frac{1}{\frac{T_1T_2}{T_2 - T_1}} = \frac{T_2 - T_1}{T_1T_2} = \frac{1}{T_1} - \frac{1}{T_2}$$

$$f_{beat} = f_1 - f_2 \qquad (២.២៨)$$

## 2.7 ពិនិត្យពិសោធន៍រន្ធពីរ

ឥឡូវលក្ខណៈទ្វិកភាពនៃ រលក-ភាគល្អិត ត្រូវបានទទួលស្គាល់យ៉ាងពេញលេញដោយលទ្ធផលពិសោធន៍។ មធ្យោបាយមួយដែលធ្វើឱ្យទស្សនៈស្ដីពីលក្ខណៈទ្វិកភាពនៃរលក-ភាគល្អិតកាន់តែច្បាស់គឺពិសោធន៍មួយដែលអេឡិចត្រុងត្រូវបានបាញ់ឆ្ពោះទៅរករង្វះពីរដូចក្នុងរូបទី ២.១៥ ។ អេក្រង់សម្រាប់ទទួលអេឡិចត្រុងត្រូវបានដាក់ត្រង់ទីតាំងមួយដែលមានចម្ងាយធំជាងចម្ងាយរវាងរង្វះទាំងពីរ $d$ ។ បើនៅរយៈពេលគ្រប់គ្រាន់មួយ គេរកឃើញថាមានគំរូអាំងទែផេរ៉ង់នៃរលកនៅលើអេក្រង់ ដែលជាចំនួនអេឡិចត្រុងក្នុងមួយនាទី ឬប្រូបាប៊ីលីតេនៃការមកដល់របស់អេឡិចត្រុង។

បើគេវាស់មុំ $\theta$ ដែលត្រូវនឹងអាំងតង់ស៊ីតេនៃអេឡិចត្រុងមកដល់អេក្រង់(រូប២.១៣) គេនឹងរកឃើញថាពួកវាត្រូវបានបង្ហាញដោយសមីការដែលពិតជាដូចគ្នានឹងសមីការក្នុងអាំងទែផេរ៉ង់នៃពន្លឺ $d\sin\theta = m\lambda$ ដែល $m$ ជាចំនួនប្រង់ហើយ $\lambda$ ជាជំហានរលករបស់អេឡិចត្រុង។ ដូច្នេះលក្ខណៈទ្វិកភាពធម្មជាតិរបស់អេឡិចត្រុងគឺត្រូវបានបង្ហាញយ៉ាងច្បាស់ក្នុងពិសោធន៍នេះ។




រូបទី២.១៥៖ អាំងទែផេរ៉ង់នៃអេឡិចត្រុង។ ចម្ងាយរវាងរង្វះ $d$ ធំជាងទំហំនៃរង្វះខ្លាំង ហើយតូចជាងចម្ងាយពីរង្វះទៅអេក្រង់។

## 2.8 គោលការណ៍នៃភាពមិនជាក់លាក់៖

ក្នុងរូបទី២.១៤ ខ ជាកញ្ចប់រលក ឬប៊ីត មានប្រេកង់ដូចក្នុងសមីការ ២.២៨ ដែលជាផលសងរវាងប្រេកង់នៃរលកផ្គុំ។ គេអាចតាងផលសងនៃប្រេកង់នេះដោយ $\Delta f$ ដូច្នេះសមីការ ២.២៨ អាចសរសេរ $f_{beat} = f_1 - f_2 = \Delta f$ បន្ទាប់មកគេបានខួបរបស់ប៊ីតគឺ $T_{beat} = 1/f_{beat} = 1/\Delta f = \Delta t$ គេបានទំនាក់ទំនងរវាងប្រេកង់នឹងខួបគឺ

$$\Delta f \Delta t = 1 \quad (២.២៩)$$




រូបទី២.១៦៖ កញ្ចប់រលក(ភាគល្អិតកង់ទិច) ឬប៊ីតដែលមានខួប $\Delta t$។

ដូចបានបង្ហាញក្នុងចំនុច២.៦ បើគេតម្រួតរលកពីរ គេនឹងសង្កេតឃើញមានកញ្ចប់រលកច្រើនកើតបន្តបន្ទាប់គ្នា។ ប៉ុន្តែបើគេតម្រួតរលកច្រើន គេទទួលបានតែកញ្ចប់រលកទោលមួយគត់។ សន្មតថាកញ្ចប់រលកទោលនោះមានខួប(រយៈពេលវាស់ពីផ្នែកខាងក្រោយទៅផ្នែកខាងមុខនៃកញ្ចប់រលក) $\Delta t$ និងប្រេកង់ $\Delta f$ ។ ក្នុងសៀវភៅនេះមិនបានបកស្រាយទេ តែតាមការវិភាគរបស់ Fourier បានបង្ហាញថា

$$\Delta f \Delta t \approx 1 \qquad (២.៣០)$$

ឧបមាថាគេចង់កំណត់ថាពេលណាកញ្ចប់រលកមកដល់ចំនុចជាក់លាក់ណាមួយក្នុងលំហ ដូចជាមកដល់ឧបករណ៍ចាប់សញ្ញា(detector) ។ តើនៅខណៈពេលណាដែលគេអាចនិយាយថាកញ្ចប់រលកត្រូវបានចាប់ដោយឧបករណ៍ចាប់សញ្ញា? ពេលណាផ្នែកខាងមុខនៃកញ្ចប់រលកមកដល់? ពេលណាចំនុចមានអំព្លីទុតអតិបរមានៃកញ្ចប់រលកមកដល់? ពេលណាផ្នែកខាងក្រោយនៃកញ្ចប់រលកមកដល់? ដោយសាកញ្ចប់រលកសន្ធឹងក្នុងរយៈពេល(spread out in time) វាមិនមានការកំណត់ខណៈពេល $t$ ច្បាស់លាស់ ដែលកញ្ចប់រលកមកដល់បានទេ។ ដូច្នេះគេអាចនិយាយថា វាមកដល់ក្នុងចន្លោះពេល $\Delta t$ ។ ដូចនេះរយៈពេលនៃការមកដល់គឺមិនជាក់លាក់។

រូប២.១៧បង្ហាញពីភាពខុសគ្នានៃកញ្ចប់រលកពីរ។ កញ្ចប់រលកក្នុងរូប ២.១៧ក គឺតូចចង្អៀត និងមានលក្ខណៈ localize ខ្លាំង។ វានឹងទៅដល់នៅខណៈពេលជាក់លាក់មួយ។ ប៉ុន្តែប្រេកង់ $\Delta f$ មានលំដាប់ប្រេកង់យ៉ាងច្រើន(ចំនួនរលកផ្គុំច្រើន)ដើម្បីបង្កើតកញ្ចប់រលកមាន $\Delta t$ យ៉ាងតូច។ ដូចនេះបើទទួលបានភាពជាក់លាក់នៃខួប(រយៈពេល) នោះភាពមិនជាក់លាក់នៃប្រេកង់$\Delta f$ មានកម្រិតខ្ពស់។




រូបទី២.១៧៖ កញ្ចប់រលកពីរដែលមាន $\Delta t$ ខុសគ្នា។

ក្នុងរូបទី២.១៧ខ បង្ហាញនូវស្ថានភាពផ្ទុយ។ កញ្ចប់រលកមានលំយោលច្រើន ហើយប្រេកង់នៃលំយោលទាំងនេះអាចកំណត់បានយ៉ាងច្បាស់លាស់ជាក់លាក់។ ប៉ុន្តែរយៈពេលនៃការទៅដល់មានភាពមិនជាក់លាក់ខ្លាំង។

គ្រប់ពេលដែលធ្វើការវាស់វែងមួយ ភាពមិនជាក់លាក់គឺតែងតែកើតមានជានិច្ច។ ឧទាហរណ៍ គេមិនអាចវាស់ប្រវែងតុមួយដែលទទួលបាននូវលទ្ធផលជាក់លាក់ល្អឥតខ្ចោះឡើយ។ បើទោះជាការវាស់នោះប្រើម៉ែតដែលមានកម្រិតល្អៀងត្រឹម 1mm ក៏ដោយ ក៏នៅមានល្អៀងយ៉ាងហោចណាស់ប្រហែល $\frac{1}{2}$ mm ។ បើប្រើឧបករណ៍កាន់តែមានភាពសុក្រិត លទ្ធផលនៃរង្វាស់ក៏កាន់តែមានភាពជាក់លាក់។ ប៉ុន្តែនៅតែមានល្អៀងកើតឡើង មិនថាឧបករណ៍រង្វាស់នោះល្អយ៉ាងណាក៏ដោយ។

ប៉ុន្តែក្នុងមេកានិចកង់ទិច ពិតជាមានសុក្រិតភាពខ្ពស់បំផុតនៃរង្វាស់។ ភាពសុក្រិតនេះគឺមិនមែនកំណត់ទៅលើឧបករណ៍ដែលល្អ ឬមានកម្រិតល្អៀងតិចតួចឡើយ តែវាមាននៅក្នុងធម្មជាតិ។ វាគឺជាលទ្ធផលនៃកត្តាពីរ៖ លក្ខណៈទ្វិកភាពនៃរលក-ភាគល្អិត និងអន្តរកម្មរវាងវត្ថុត្រូវសង្កេត និងឧបករណ៍សង្កេត។ ពិនិត្យការបកស្រាយខាងក្រោម

ធ្វើការវាស់វែងលើវត្ថុមួយដោយមិនមានការរំខានវា គឺមិនអាចទៅរួចទេ។ ពិនិត្យការព្យាយាមកំណត់ទីតាំងរបស់គ្រាប់ប៉េងប៉ុង ឬកូនបាល់មួយក្នុងបន្ទប់ងងឹតមួយ។ អ្នកកំពុងរាវរកដើម្បីកំណត់ទីតាំងរបស់វា បន្ទាប់មកអ្នកក៏បានប៉ះវាដោយដៃរបស់អ្នក ហើយវាក៏រមៀលចេញទៅ។ គ្រប់ពេលដែលយើងធ្វើការវាស់រកទីតាំងនៃវត្ថុមួយ មិនថាវាជាបាល់ ឬជាអេឡិចត្រុងទេ គឺយើងតែងតែប៉ះវាដោយវត្ថុអ្វីមួយផ្សេងទៀតដែលអាចផ្តល់ព័ត៌មានឱ្យយើងដឹងពីទីតាំងរបស់វា។ ដើម្បីកំណត់ទីតាំងរបស់ប៉េងប៉ុងដែលបានរមៀលទៅនោះ អ្នកអាចស្វែងរកវាដោយប្រើដៃ ឬបន្ទាត់ឈើមួយ ឬអ្នកអាចបញ្ចាំងពន្លឺលើវា ហើយទទួលពន្លឺដែលផ្លាតពីបាល់មកវិញ ពេលនោះគេអាចកំណត់ទីតាំងរបស់វា។ ពេលអ្នកប្រើដៃ ឬបន្ទាត់ឈើដើម្បីរាវរក គេនឹងរកឃើញទីតាំងរបស់បាល់នៅពេលគេប៉ះវា។ ប៉ុន្តែពេលអ្នកប៉ះវាគឺគេចមិនផុតពីទង្គិចវា និងផ្តល់បរិមាណចលនាខ្លះឱ្យវា។ ដូច្នេះអ្នកនឹងមិនដឹងពីទីតាំងរបស់វាក្រោយពេលប៉ះ។ ដូចគ្នាដែរ បើសិនអ្នកសង្កេតទីតាំងរបស់ប៉េងប៉ុងដោយប្រើពន្លឺ។ ដើម្បីឃើញប៉េងប៉ុង យ៉ាងហោចណាស់មានផូតុងមួយត្រូវតែខ្ទាតចេញពីវា ហើយផូតុងដែលបានខ្ទាតចេញត្រូវតែចូលក្នុងភ្នែករបស់អ្នក ឬចូលក្នុងឧបករណ៍សម្រាប់ចាប់យកពន្លឺផ្សេងទៀត(detector)។ ពេលផូតុងមួយទៅប៉ះ ឬទង្គិចនឹងវត្ថុធម្មតាមួយ(ទំហំធំដូចជាឃ្លី) វាមិនបានធ្វើឱ្យវត្ថុនោះផ្លាស់ប្តូរចលនា ឬទីតាំងឡើ

យ។ ប៉ុន្តែពេលផ្ទុតុងទៅទង្គិចនឹងវត្ថុមានទំហំយ៉ាងតូចដូចជាអេឡិចត្រុងមួយ វាអាចបញ្ជូនបរិមាណចលនាទៅឱ្យវត្ថុនោះ ហើយក៏អាចផ្លាស់ប្តូរនូវចលនា និងទីតាំងដែលមិនអាចធ្វើការប៉ាន់ស្មានបាន។

## ឯកសារយោង


1. Hugh D. Young & Roger A. Freedman, University Physics with Modern Physics, 13ed.
2. Raymond A. Serway & John W. Jewett, Physics for Scientists and Engineers with Modern Physics, 9ed.
3. Randall D. Knight, Physics for Scientists and Engineers, 2ed.
4. Halliday & Resnick, Fundamentals of Physics, 9ed.
5. Douglas C. Giancoli, Physics for Scientists and Engineers with Modern Physics, 4ed